# សៀវភៅបណ្ដុះបណ្ដាល ផ្នែកសុខភាពសត្វ








# សៀវភៅបណ្តុះបណ្តាល ផ្នែកសុខភាពសត្វ

បោះពុម្ពលើកទី១

ខែមេសា ២០១៣

# សេចក្តីថ្លែងអំណរគុណ

ការសរសេរសៀវភៅមួយដែលពោរពេញដោយអត្ថន័យ និងអត្ថប្រយោជន៍គឺជាលទ្ធផលដែលចេញពីការចូលរួមពិភាក្សា ត្រួតពិនិត្យ និងកែសម្រួលជាច្រើនលើកច្រើនសារ។ ក្នុងន័យនេះ **ឯកឧត្តម កៅ ផល** ប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាលសូមសំដែងនូវការថ្លែងអំណរគុណចំពោះលោក លោកស្រីដែលមានរាយនាមខាងក្រោមដែលបានចូលរួមយ៉ាងសកម្មក្នុងការតាក់តែងបញ្ចប់នូវសៀវភៅសម្រាប់បណ្តុះបណ្តាលសុខភាពសត្វ ៖

- **លោកបណ្ឌិត សិន សាន** នាយកគម្រោងត្រៀមរៀបចំ និងទប់ស្កាត់បន្ទាន់ជំងឺផ្តាសាយបក្សី-មនុស្ស (AHICPEP) **លោក ថន សូរីរ៉ា** ប្រធានគម្រោង AHICPEP **លោក លឹម ប៉ាក់ លោក អុល ទេវិន្ទ លោក ខិត ស៊ីដេត និងលោកស្រី កាន ដាហ្សី** ទីប្រឹក្សាថ្នាក់ជាតិនៃគម្រោង AHICPEP ។
- សូមថ្លែងអំណរគុណជាពិសេសចំពោះ **លោក ឡុតហ្វី អាឡាល់** ប្រធានក្រុម FAO- ECTAD ដែលបានផ្តល់យោបល់និងភាពអត់ធ្មត់ក្នុងកំឡុងពេលផលិតសៀវភៅ។

  លោក **អឺរ ហ្វ្រូលិច** ទីប្រឹក្សាផ្នែកបសុព្យាបាលដែលបានផ្តល់ដំបូន្មាននិងសំណេរពង្រាង **លោក ហាក់ មករា** ដែលជាអ្នកបច្ចេកទេសបសុព្យាបាលរបស់ ECTAD-FAO សម្រាប់ការចូលរួមមតិ និងគំនិតនូវគ្រប់ដំណាក់កាលនៃការសរសេរសៀវភៅមួយនេះ និងក៏សូមថ្លែងអំណរគុណលោកទាំងពីរដែលបានផ្តល់នូវរូបភាពល្អៗ ដែលមានគុណភាពសម្រាប់ដាក់ក្នុងសៀវភៅ។
- សូមថ្លែងអំណរគុណចំពោះ **មន្ត្រីបសុព្យាបាលទាំង២៤ខេត្តរាជធានី** ដែលបានចូលរួមពិភាក្សា កែរសម្រួលសៀវភៅនេះពីថ្ងៃទី៩ និងទី១០ ខែកក្កដា ឆ្នាំ២០១២នៅខេត្តសៀមរាប។
- យើងក៏មិនអាចបំភ្លេចនូវរាល់**កសិករ**ទាំងឡាយ ដែលបានថ្លែងពីបញ្ហាដែលទាក់ទងនឹងសុខភាពសត្វ និងអនុញ្ញាតឲ្យយើងបានថតរូប ក៏ដូចជាសត្វរបស់ពួកគាត់ផងដែរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ សម្រាប់ការធ្វើឲ្យលេចជារូបរាងឡើងនូវសៀវភៅបណ្តុះបណ្តាលសុខភាពសត្វលើកដំបូងបំផុតនៅកម្ពុជា។

# អារម្ភកថា

យើងមានសេចក្តីរីករាយជាអនេកដែលបានបង្ហាញជូនជាលើកដំបូងនូវសៀវភៅបណ្តុះបណ្តាលស្តីអំពី "សុខភាពសត្វនៅប្រទេសកម្ពុជា" ក៏ឆ្លៀតក្នុងឱកាសនេះយើងសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកដែលបានចូលរួមចំណែកក្នុងការសរសេរសៀវភៅនេះឲ្យលេចចេញជារូបរាងឡើង។

សៀវភៅនេះត្រូវបានតាក់តែងឡើងសម្រាប់អ្នកពាក់ព័ន្ធលើវិស័យនេះគ្រប់កម្រិតដែលរាប់បញ្ចូលទាំងមន្ត្រីបសុពេទ្យ សាកលវិទ្យាល័យ កសិករ វិស័យឯកជននិងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការទាក់ទងនឹងបញ្ហាសុខភាពសត្វក្នុងប្រទេសកម្ពុជា។

គោលបំណងនៃការតាក់តែងសៀវភៅនេះគឺដើម្បីផ្តល់ឲ្យអ្នកអានទាំងអស់នូវពាក្យពេចន៍សាមញ្ញៗអាចអនុវត្តបានព្រមទាំងងាយស្រួលក្នុងការអានដែលអាចយល់បានយ៉ាងងាយស្រួលសម្រាប់អ្នកប្រើប្រាស់គ្រប់ៗគ្នា។ ដើម្បីជៀសវាងនូវការជាន់គ្នានឹងសៀវភៅបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិដែលមានស្រាប់ យើងបានឯកភាពគ្នាក្នុងការចងក្រងសៀវភៅមួយនេះដែលប្រមូលផ្តុំរាល់ជំងឺសំខាន់ៗដែលកើតមានក្នុងប្រទេស ដោយមិនសំដៅតែការបណ្តុះបណ្តាល កសិករ ប៉ុន្តែវាក៏មិនព្យាយាមក្លាយជាវចនានុក្រមសម្រាប់ជំងឺសត្វទាំងអស់នោះទេ។ម្យ៉ាងវិញទៀតដើម្បីធ្វើឲ្យសៀវភៅនេះកាន់តែខិតចូលជិតបានយ៉ាងទូលាយតាមដែលអាចធ្វើទៅបាន យើងព្យាយាមជៀសវាងនូវការប្រើប្រាស់ឃ្លាឃ្លោងបច្ចេកទេសកម្រិតខ្ពស់ទាំងក្នុងភាសាខ្មែរក៏ដូចជាភាសាអង់គ្លេស។ ដូចគ្នានេះផងដែរសៀវភៅនេះអាចជាឯកសារយោងសម្រាប់ផ្នែកសុខភាពសត្វដែលត្រូវធ្វើបច្ចុប្បន្នភាពស្របតាមពេលវេលាណាមួយដោយដាក់បញ្ចូលនូវជំងឺដែលលេចឡើងថ្មីៗ។ យើងសង្ឃឹមថាការងារទាំងនេះនិងចូលរួមចំណែកដល់ការយល់ដឹងឲ្យកាន់តែប្រសើរឡើងព្រមទាំងជួយដោះស្រាយបញ្ហាជំងឺសត្វជាទូទៅក្នុងប្រទេសកម្ពុជាដែលនឹងនាំឲ្យបញ្ហាសន្តិសុខស្បៀង និងកម្រិតជីវភាពប្រជាជនកាន់តែប្រសើរឡើង។

# មាតិកា


ជំពូកទី១៖ កាយវិភាគវិទ្យាសត្វ

ក-បក្សី.....៣

១-ការពណ៌នាផ្នែកខាងក្រៅ:.....៣

២-ការពិពណ៌នាផ្នែកខាងក្នុង.....៤

ខ- ជ្រូក.....១០

១-ការពិពណ៌នាផ្នែកខាងក្រៅ.....១០

២-ការពិពណ៌នាផ្នែកខាងក្នុង.....១១

គ-គោ ក្របី.....១៦

១-ការពិពណ៌នាផ្នែកខាងក្រៅ.....១៦

២-ការពិពណ៌នាផ្នែកខាងក្នុង.....១៧

ជំពូកទី២៖ សរីរវិទ្យាសត្វ

ក-បក្សី.....២៥

១- ការរំលាយអាហារ.....២៥

២- ការដកដង្ហើម.....២៨

៣- ការបង្កកំណើត.....២៩

គ-សត្វគោ ក្របី.....៤១

១-ប្រព័ន្ធរំលាយអាហារ.....៤១

២-ប្រព័ន្ធដកដង្ហើម.....៤៤

៣-ការបន្តពូជ.....៤៥

ជំពូកទី៣៖ ការស្វែងយល់ អំពីជំងឺសត្វ និងសកម្មភាពរបស់ ភ្នាក់ងារសុខភាពសត្វភូមិ

ក. មូលហេតុនៃការឆ្លងជំងឺ:.....៥៣

១. ភ្នាក់ងារចម្លងជំងឺ.....៥៣

២. បរាសិត.....៥៨

៣. កង្វះអាហារូបត្ថម្ភ.....៦១

៤- សុខុមាលភាពសត្វ.....៦៣

ខ. ការរាតត្បាតនៃជំងឺ.....៦៦

១. តើភ្នាក់ងារចម្លងជំងឺរាតត្បាតយ៉ាងដូចម្ដេច?.....៦៦

២. មូលដ្ឋានគ្រឹះនៃជីវសុវត្ថិភាព.....៦៨

៣. ការរំងាប់មេរោគ.....៧១

ជំពូកទី៤៖ ការគ្រប់គ្រងសុខភាព និងសុខុមាលភាពសត្វ

ក. ការធ្វើទ្រុងសត្វ.....៨១

១.មាន់.....៨១

២. ជ្រូក.....៨៣

៣. គោ.....៨៨

ខ. ការផ្ដល់ចំណី.....៨៨

១.មាន់-ទា.....៨៨

២. ជ្រូក.....៩១

៣. គោ ក្របី.....៩៨

ជំពូកទី៥៖ ការចាប់ និងការពិនិត្យសត្វ
ក-បក្សី..........១០៩
ខ-ជ្រូក..........១១១
គ-គោ..........១១៦
ជំពូកទី ៦៖ នីតិវិធីនៃការអនុវត្តការជួយសង្គ្រោះ និងការគ្រៀវ
ក. មាន់..........១២៥
ខ. ជ្រូក..........១៣០
គ. គោ ក្របី..........១៤២
ជំពូកទី៧៖ ភាពស៊ាំ និងការចាក់ថ្នាំការពារ (ការចាក់វ៉ាក់សាំង)
ភាពស៊ាំ: តើសត្វទប់ទល់នឹងមេរោគយ៉ាងដូចម្ដេច? ..........១៥៥
ក.មាន់..........១៧០
ខ.ជ្រូក..........១៧១
គ.គោ..........១៧១
ជំពូកទី៨៖ បសុឱសថ និងការប្រើប្រាស់
១. វីតាមីន និងសារធាតុរ៉ែ..........១៧៥
២- ថ្នាំអង់ទីប៊ីយ៉ូទិក (Antibiotics)..........១៨៣
៣- ថ្នាំប្រឆាំងការរលាក..........១៩២
៤. ថ្នាំកំចាត់បរាសិត..........១៩៨
៥- ថ្នាំអរម៉ូន..........២០៣
៦- វ៉ាក់សាំង..........២០៤
៧- ថ្នាំរម្ងាប់មេរោគ..........២០៧
៨-ថ្នាំបន្សាប..........២០៨
ជំពូកទី៩៖ បរាសិត
ក- វដ្តរបស់បរាសិត..........២២១
១- វដ្តជីវិតល្វតលាស់ដោយផ្ទាល់..........២២១
២-វដ្តជីវិតល្វតលាស់មិនផ្ទាល់..........២២៣
ខ- បរាសិតខាងក្រៅ..........២២៤
១-ឥទ្ធិពលរបស់បរាសិតខាងក្រៅ..........២២៤
២-ការត្រួតពិនិត្យបរាសិតខាងក្រៅ..........២២៦
គ-អំពីបរាសិតខាងក្នុង..........២៣០
១-ឥទ្ធិពលរបស់បរាសិតខាងក្នុង..........២៣០
២-ការត្រួតពិនិត្យបរាសិតខាងក្នុង..........២៣៤
ជំពូកទី១០៖ ជំងឺបក្សី
ក. ជំងឺមានរោគសញ្ញាផ្លូវដង្ហើម..........២៤៥
១. ជំងឺដង្កោ(ញូវកាស)..........២៤៥
២. ជំងឺរលាកទងសួត..........២៤៧
៣. ជំងឺផ្ដាសាយបក្សី..........២៤៨
៤. ជំងឺអាសន្នរោគបក្សី..........២៥១
៥. ជំងឺរលាកបំពង់សម្លេង និងបំពង់ខ្យល់ (ILT)..........២៥២
ខ. ជំងឺមានរោគសញ្ញាផ្លូវរំលាយអាហារ..........២៥៥

១. ជំងឺកុកស៊ីដ្យូស ........ ២៥៥
២. ជំងឺសាល់ម៉ូ ........ ២៥៦
ជំពូកទី១១៖ ជំងឺជ្រូក
ក-ជំងឺប៉េស្តជ្រូក ........ ២៧៥
ខ-ជំងឺអុតក្តាម (Foot and Mouth Disease) ........ ២៧៩
គ-ជំងឺត្រចៀកខៀវ PRRS ........ ២៨១
ឃ-ជំងឺផ្លូវដង្ហើម ........ ២៨៥
ង-ជំងឺរលាកពោះវៀន ........ ២៨៩
ច-ខ្វិតជើង (LAMENESS) ........ ២៩៥
ឆ-ជំងឺស្បែក (SKIN DISEASES) ........ ២៩៩
ជ- ជំងឺផ្លូវបន្តពូជ ........ ៣០៤
ឈ-ជំងឺលើប្រពន្ធ័ប្រសាទ ........ ៣១៤
ជំពូកទី១២៖ ជំងឺសំខាន់ៗគោ ក្របី
ក-ជំងឺឈាមខ្មៅ ........ ៣២១
ខ-ជំងឺបូសខ្យល់ ........ ៣២២
គ-ជំងឺសារទឹក (HS) ........ ៣២៣
ឃ- ជំងឺអុតក្តាម (FMD) ........ ៣២៥
ង- ជំងឺផ្លូវដង្ហើម ........ ៣២៧
ច-ជំងឺរលាកពោះវៀន ........ ៣២៩
ឆ-បញ្ហាស្បែក ........ ៣៣៥
ជ-ខ្វិតជើង ........ ៣៣៩
ឈ- សភាពដងខ្លួនមិនល្អ ........ ៣៤១
ញ-ជំងឺលើប្រដាប់បន្តពូជ ........ ៣៤៣





# ជំពូកទី១៖ កាយវិភាគវិទ្យាសត្វ








➢ **រន្ធគូថ:** ជារន្ធសម្រាប់បញ្ចេញលាមកនិងសារធាតុរាវផ្សេងៗ (ទឹកនោម ទឹកកាម...) ឯបក្សីញីសម្រាប់ពងផងដែរ។






➢ **ក្រញាំជើង:** មាន់មានក្រញាំបួនជើងនីមួយៗ មានក្រញាំបីតម្រង់ទៅមុខ និងមួយទៀតតម្រង់មកក្រោយ ដើម្បីឲ្យសត្វឈរមានលំនឹង។

**លក្ខណៈខុសគ្នារវាងជើងមាន់និងជើងទា**

➢ **ក្រញាំជើងទា:** ជើងនីមួយៗមានក្រញាំ ដែលនៅចន្លោះក្រញាំនីមួយៗមានភ្ជាប់ស្បែកយឺត ដែលជួយឲ្យទាហែលបាន។



## ២-ការពិពណ៌នាផ្នែកខាងក្នុង

### ២.១ អំពីគ្រោងឆ្អឹង




គ្រោងឆ្អឹងជួយឲ្យមាន់ក្រោកឈរនិងការពារសរីរាង្គខាងក្នុងនិងការពារ ជាលិកា។ ប្រព័ន្ធគ្រោងឆ្អឹងមាន់តូចចង្អៀត ស្រាល រឹងមាំ។ ឆ្អឹងកងកន្ទុយ និងកងក អាចបត់បែនបាន ឯឆ្អឹងកង ដងខ្លួនមិនអាចបត់បែនបានទេ។

**មាន់មានឆ្អឹងពិសេសពីរប្រភេទគឺ:**

**ឆ្អឹងខ្យល់:** ជាឆ្អឹងប្រហោងភ្ជាប់នឹងថង់ខ្យល់ អាចឲ្យមាន់ដកដង្ហើមបាន។ ឆ្អឹងខ្យល់មានដូចជា លលាដ៍ក្បាល ឆ្អឹងស្លាប ឆ្អឹងដងកាំបិត ឆ្អឹងសន្ទះទ្រូង និងប្រភេទឆ្អឹងខ្នងមួយចំនួនទៀត។

**ឆ្អឹងមានខួរ:** ជាប្រភពសំខាន់របស់ជាតិកាល់ស្យូមសម្រាប់មាន់ពង។ ឆ្អឹងដែលមានខួរ រួម មាន: ឆ្អឹងស្មងជើង ឆ្អឹងភ្លៅ ឆ្អឹងជំនីរ ឆ្អឹងស្លាប ឆ្អឹងក្រញាំជើង និងឆ្អឹងស្លាបប្រចៀវ។

## ២.២ អំពីសរីរាង្គ




### ២.២.១ អំពីប្រព័ន្ធរំលាយអាហារ

➢ **ចំពុះ ឬមាត់**

- មាន់:ចំពុះមាន់សម្រាប់ចឹកស៊ីចំណីបញ្ចូលក្នុងមាត់។ អណ្តាតសម្រាប់ រុញចំណីចូលក្នុងមាត់ ដើម្បីឲ្យលេបបាន។





ទា: ចំពុះទាសម្រាប់ហួរទឹក និងរកចំណី។ រន្ធច្រមុះស្ថិតនៅក្បែរក្បាល ផ្នែកខាងលើគល់ចំពុះ ដែលអាចឲ្យវារកចំណីនៅក្នុងទឹកបាន។



➢ **ប្រព័ន្ធរំលាយអាហាររួមមាន:**

-**បំពង់អាហារ:** ជាបំពង់នាំចំណី អាចបត់បែនបាន តភ្ជាប់ពីមាត់ ទៅកាន់គៃ និងទងកោះ។

-**គៃ:** ជាថង់សម្រាប់ផ្ទុកចំណីស្ថិតនៅខាងក្រៅរបស់បំពង់អាហារ ។ ទាគ្មានគៃទេ។

-**ទងកោះ** ជាក្រពះពិតប្រាកដរបស់មាន់។

-**កោះ** ជាក្រពះមានសាច់ដុំរឹងមាំ អាចផ្ទុកដុំគ្រួសតូចៗសម្រាប់កិនបំបែកគ្រាប់ចំណី។

-**ពោះវៀនតូច** ជាផ្នែកដំបូងនៃពោះវៀន ដែលមានតួនាទីទទួលសារធាតុទឹកពីលំពែង និងទឹកប្រមាត់ ពីថ្លើមដើម្បីជួយរំលាយអាហារ និងបន្សាបជាតិពុល ។

-**ថ្នក់ពោះវៀន** ជាថង់ពីរ ស្ថិតនៅកន្លែងពោះវៀនតូច និងពោះវៀនធំភ្ជាប់គ្នា។

-**ពោះវៀនធំ** ខ្លីជាងពោះវៀនតូច។

-**ក្លូអាក់ (ផ្ចុំរន្ធភេទ និងរន្ធគូថ)** ជាកន្លែងកាកសំណល់អាហារលាយជាមួយទឹកនោមមុននឹងចេញមកក្រៅ។




➢ **អំពីប្រព័ន្ធដកដង្ហើមរួមមាន:**

-**រន្ធខ្យល់:** ជាចំណុចចាប់ផ្ដើមរបស់ប្រព័ន្ធដកដង្ហើម។ រន្ធខ្យល់បិទពេលចំណីឆ្លងកាត់ ដើម្បីកុំឲ្យចំណីធ្លាក់ចូលក្នុងទងសួត។





-បំពង់ខ្យល់: ជាឆ្អឹងខ្ចីរាងដូចចិញ្ចៀន។

-បំពង់ខ្យល់: ចែកជាបំពង់តូចពីរ ហៅថាទងសួត។







-សួត: រាងតូច មិនរីក ស្អិតជាប់នឹងឆ្អឹងជំនីរ។

ប្រព័ន្ធដកដង្ហើមមានលក្ខណៈជាក់លាក់។ បក្សីដកដង្ហើមតាមសួត ដោយ ថង់ខ្យល់ទាំង៩។ ថង់ខ្យល់ ជាថង់ប៉ោង ដែលកើតឡើងពីភ្នាសថ្លាស្តើងនៅខាងចុងប្រពន្ធ័ខ្យល់។ ថង់ខ្យល់បញ្ចប់ត្រឹមឆ្អឹងខ្យល់ ដូចជាឆ្អឹងដើម ស្លាប។






- អំពីប្រដាប់បន្តពូជ

ការសង្កេតលើសរីរាង្គបន្តពូជ មេមាន់ ប្រដាប់បន្តពូជមេមាន់កំណត់ដូចខាងក្រោម:



-អូវែ: អូវែ និងបំពង់អូវុលខាងឆ្វេង ដែលដំណើរការ។ អូវែគឺជា ចង្កោមវិវឌ្ឍស៊ុតលឿង។




-បំពង់អូវុល ចែកជា៤ផ្នែក: ផ្នែកទី១ អិនហ្វានឌីប៊ុយលុម ដែលស៊ុតលឿងត្រូវបានបញ្ចូល។
ផ្នែកទី២ ម៉ាញុម ជាកន្លែងបន្ថែមពណ៌ស។ ផ្នែកទី៣ និងផ្នែកទី៤ ជាកន្សោមពង និងជាកន្លែងផលិតសំបកស៊ុត។
-រន្ធភេទ ជាសាច់ដុំនិងជួយរុញស៊ុតចេញមកក្រៅ។




មាន់ឈ្មោល
សរីរាង្គបន្តពូជ របស់មាន់ឈ្មោល
មាន់ឈ្មោលមាន ពងស្វាសពីរនៅក្បែរតម្រងនោម(ក្រលៀន) មានទំហំប៉ុនគ្រាប់ស្វាយចន្ទី។




បំពង់បង្ហូរទឹកកាមចូលទៅក្នុងគ្រាប់តូចៗក្នុងប្រជុំរន្ធភេទ។ គ្រាប់តូចៗជា សរីរាង្គបន្តពូជ។




ចំពោះទាមានលិង្គពិតប្រាកដ។




- ស៊ុត: សមាសធាតុផ្សំរបស់ស៊ុតគឺះ
  - **ស៊ុតលឿង** មានពី៣២ ទៅ ៣៥%នៃផ្នែកទាំងមូលរបស់ស៊ុត ដែលផលិតឡើងដោយជាតិលីពីដ និងប្រូតេអ៊ីន
  - **ស៊ុតស** មានពី៥២ ទៅ៥៨%នៃផ្នែកទាំងមូលរបស់ស៊ុត ផលិត ដោយប្រូតេអ៊ីន និងទឹក ។
  - **ខ្សែរាងជាឺស័រ** គឺជាខ្សែត្រកូញចូលគ្នារាងជាស្ពៀរ ដើម្បីទប់លំនឹងឲ្យស៊ុតលឿងស្ថិតនៅកណ្តាលស៊ុតស។
  - **បន្ទប់ខ្យល់** ជាផ្នែកទទេស្ថិតនៅចុងរបស់ស៊ុត។
  - **សំបកស៊ុត** មានពី៩ ទៅ១៤%នៃផ្នែកទាំងមូលរបស់ស៊ុត។






# ខ- ជ្រូក

## ១-ការពិពណ៌នាផ្នែកខាងក្រៅ

- ក មិនអាចកំណត់ឲ្យបានជាក់លាក់ទេ

-ច្រមុះ ជាឆ្អឹងខ្ចីរឹងមាំ អាចឈូសដីបាន







-ក្រចកជើង: ជើងនីមួយៗមាន ក្រចក៤



ចង្កូម: ជ្រូកឈ្មោលមានចង្កូម អាចដុះជាបន្តបន្ទាប់



-សម្បុរជ្រូក អាស្រ័យទៅតាមពូជ។







## ២-ការពិពណ៌នាផ្នែកខាងក្នុង

### ២.១ អំពីគ្រោងឆ្អឹង

- គ្រោងឆ្អឹង ផ្គុំឡើងពីតួឆ្អឹង និងសន្លាក់ គ្របដណ្តប់ដោយភ្នាសដ៏រឹងមាំ។ នៅកណ្តាលឆ្អឹងផ្សំឡើងដោយដុំស្ពោត (ផលិតកោសិកាឈាម)។







-សន្លាក់ផ្គុំឡើងដោយចុងឆ្អឹងពីរភ្ជាប់គ្នា រុំព័ទ្ធដោយសំបកដ៏រឹងមាំ នៅខាងចុង ឆ្អឹងនីមួយៗមានទ្រនាប់ឆ្អឹងខ្ចីទន់។



### ២.២ អំពីសរីរាង្គ

ប្រព័ន្ធរំលាយអាហារ គឺចាប់ផ្តើមពីមាត់រហូតដល់ចុងពោះវៀន។

➢ **ការពិពណ៌នាពីប្រព័ន្ធរំលាយអាហារ**

-មាត់ ជាកន្លែងដែលចំណី និងខ្យល់ ឆ្លងកាត់។ មាត់តភ្ជាប់ទៅដើមក និងមានធ្មេញចំនួន៣៦។








-បំពង់អាហារៈ ជាបំពង់សាច់ដុំធ្វើចលនាឲ្យចំណីផ្លាស់ទីចូលក្នុងក្រពះ។
-ក្រពះមានមួយថត (ជ្រូកជាពូកក្រពះទោល) មានចំណុះប្រហែល៧,៥លីត្រ។ ផាលស្ថិតជាប់ខាងលើក្រពះ។ -ពោះវៀនតូច អាចមានប្រវែង ១៨ម។ -ថ្នក់(ខ្ទែង)ពោះវៀនៈជាកន្លែងតភ្ជាប់រវាងពោះវៀនតូច ជាមួយនឹងពោះវៀនធំ។-ពោះវៀនធំ មានប្រវែងជិត៥ម។
-ចុងពោះវៀននិងរន្ធគូថ។



-ថ្លើមមាន៥ក្លែប ពណ៌ត្នោតចាស់និងមានប្រមាត់មួយ។ បំពង់ថ្លើម និងលំពែងភ្ជាប់ទៅដល់ពោះវៀនតូច។

- ប្រព័ន្ធដកដង្ហើម
    - រន្ធច្រមុះសម្រាប់ស្រូបខ្យល់ចេញ ចូល



-ឆ្អឹងទែរប៊ីន ជាឆ្អឹងស្តើង ចំនួន៤រាងអង្កាញ់ក្នុងច្រមុះជ្រូក



-ដើមបំពង់ក និងកន្លើត ស្ថិតនៅខាងក្រោយមាត់។




-បំពង់ខ្យល់ ស្ថិតក្នុងបំពង់ក តភ្ជាប់ទៅក្នុងប្រអប់ទ្រូងចែកចេញជាទងសួតពីរ។
- សួតជាដុំសាច់ទន់ស្ពោត មាន ៧ក្លែប។




-ខ្នែងទងសួត បែកពីទងសួតតូចៗ និងបន្តទៅខ្នែងផ្សេងទៀត។ ទំហំខ្នែងទងសួតរួមតូចទៅៗដើម្បីក្លាយជាទងសួតឆ្មារ ដែលបញ្ចប់ដោយថង់ខ្យល់តូចហៅថាកូនថង់សួត(រន្ធសំបុកឃ្មុំ)។




ប្រព័ន្ធដកដង្ហើមត្រូវបានតភ្ជាប់ដោយសន្ទានទន់ ហៅថាសន្ទានភ្នាសសើម ព្រោះវាផ្សើមដោយភ្នាសសើមស្អិតជាប់។

➤ ប្រព័ន្ធបន្តពូជ

ការពិពណ៌នាអំពីប្រព័ន្ធបន្តពូជរបស់មេជ្រូក

-អូវៃ ជាក្រពេញតូចដែលផលិតអូវុល។ វៃរុំព័ទ្ធដោយភ្នាសស្តើងដែលហៅថាអិនហ្វាន់ឌីប៊ុយលុម។

-អិនហ្វាន់ឌីប៊ុយលុម ប្រមូលអូវុល និង បញ្ជូន ទៅដៃស្បូន។

-បំពង់នាំអូវុលមានប្រវែង១៥ទៅ២៥ស.ម និង ជាកន្លែងបង្កកំណើត។

-ស្បូន មានដៃស្បូនពីរដែលមានប្រវែង ១.៥ ម៉ែត្រ ពេលមានកូននៅខាងក្នុង។

-កស្បូន ជាសាច់ដុំ និងជាច្រកចូលទៅស្បូន ហើយ អាចបិទ បើកបាន។

-ផ្លូវយោនី ជាផ្លូវតភ្ជាប់ពីខាងក្រៅទៅកាន់ស្បូន។

-បង្ហូរនោមចេញមកក្រៅតាមផ្លូវយោនី។

-យោនី:ជាផ្លូវបើកភ្ជាប់ទៅផ្លូវយោនី។












ការពិពណ៌នាប្រព័ន្ធបន្តពូជរបស់ជ្រូកឈ្មោល

-ស្រោមពងស្វាស ជាស្បែកការពារពងស្វាស

-ពងស្វាស មានពីរសម្រាប់ផលិតទឹកកាម





-បំពង់បង្ហូរទឹកកាមភ្ជាប់នឹងពងស្វាស នៅខាងក្នុងមានបំពង់វែងដែលទឹកកាមចេញនៅពេលវាមានចំណង់ដល់កម្រិត។ បំពង់ផ្សេង ទៀតបន្តពីបំពង់ទឹកកាម ដែលបំពង់តូចៗទាំងនេះនាំទឹកកាមទៅកាន់បង្ហូរនោម។




-បំពង់បង្ហូរនោម ជាបំពង់បញ្ចេញរួមគ្នារបស់ទឹកកាម និងទឹកនោមពីប្លោកនោមទៅកាន់ក្បាលលិង្គ។

-លិង្គ ជាសរីរាង្គសម្រាប់រួមសង្វាស វាមានចុងរាងស្រួចនិងវែងពេលវាបះឡើង។

-ក្បាលលិង្គដូចជាប្រដាប់មូលដកច្នុកដប។




លិង្គរបស់ជ្រូកបា
ក ស្ថានភាពមិនទាន់ឡើងរឹង
ខ ស្ថានភាពឡើងរឹង

- ការពិពណ៌នាអំពីកន្សោមដោះ

# គ-គោ ក្របី

## ១-ការពិពណ៌នាផ្នែកខាងក្រៅ




ភាពខុសគ្នានៃផ្នែកខ្លះ រវាងគោ និងក្របី:

-ស្នែង: ក្របីមានស្នែងវែង ជាងគោនិងមានពណ៌ខ្មៅ។





-ស្បែក: ក្របីមានសម្បុរ ប្រផេះចាស់ ឬខ្មៅ ឬឃ្មៀច និងមានរោមស្តើង។





-ក្រចក: ក្របីមានក្រចក ញែកជាងគោ។





## ២-ការពិពណ៌នាផ្នែកខាងក្នុង

### ២.១ អំពីគ្រោងឆ្អឹង

គ្រោងឆ្អឹងគោ ក្របីមានសភាពដូចគ្នានឹងសត្វបំបៅដោះដទៃទៀត។




ភាពខុសគ្នាខ្លះអាចមើលឃើញដូចជា:
-គោមានធ្មេញមុខ៨ នៅលើអញ្ចាញក្រោម។ គោ គ្មានធ្មេញលើទេ។ អញ្ចាញ ជួយឲ្យវាបូងស្មៅបានស្រួល។
-គោមានស្នែង កសិករត្រូវដឹងពីទម្រង់ស្នែងរបស់គោនៅពេលគេចង់កាត់ស្នែងវាចេញ។







### ២.២ សរីរាង្គខាងក្នុង

➢ អំពីប្រព័ន្ធរំលាយអាហារ

ក្រពះរបស់គោពេញវ័យមានលក្ខណៈជាក់លាក់ និងមាន ៤ ថត (ផ្នែក) ។ ថតនីមួយៗរបស់ក្រពះកើតឡើងដោយរចនាសម្ព័ន្ធជាលិកាផ្សេងៗគ្នា ដែលសម្រប ទៅនឹងមុខងាររបស់វា។



-ពោះធំស្ថិតនៅខាងឆ្វេងនៃដងខ្លួន និងមាន ចំណុះប្រហែល ១៦០លីត្រ។



-ពោះចក មានចំណុះប្រហែល ៩.៥ លីត្រ។ ផាលស្ថិតជាប់ខាងលើពោះចក និងលើផ្នែកខ្លះ នៃពោះធំ។



-ពោះស្រទាប់មានចំណុះប្រហែល ១៥លីត្រ។



-ពោះកន្សែង ហៅថា ក្រពះពិតប្រាកដ មាន ចំណុះប្រហែល២០ លីត្រ។



ក្រពះទាំង៤ ជាប្រពន្ធ័រំលាយអាហារ តភ្ជាប់ទៅពោះវៀន
-ពោះវៀនតូច តភ្ជាប់ ពីពោះកន្សែង មានប្រវែងប្រហែល ៤០ម៉ែត្រ។
-ពោះវៀនធំ តភ្ជាប់ពីពោះវៀនតូចរហូតដល់ចុងពោះវៀន មានប្រវែងប្រហែល១០ម។



សរីរាង្គ ក្រពេញ មួយចំនួនតភ្ជាប់ទៅនឹងប្រដាប់រំលាយអាហារដូចជា:

-ថ្លើមមានទម្ងន់ពី៤ទៅ១០គក្រ មិនបានចែកជាដុំៗឱ្យបានជាក់លាក់នោះទេ។ បំពង់ថ្លើម និងថង់ទឹកប្រមាត់ ផ្លោកនោមតភ្ជាប់ទៅពោះ វៀនតូច។




➢ ប្រព័ន្ធរំលាយអាហាររបស់កូនគោ

កូនគោមានអាយុ ពី២ទៅ៣ខែ ក្រពះទាំង៤មិនទាន់វិវឌ្ឍ និងមានលក្ខណៈពេញលេញទឹកដោះចូលផ្ទាល់ទៅក្នុងពោះស្រទាប់ និងពោះកន្ទ្បែងដោយរំលងពោះធំ និងពោះចក។




➢ ប្រព័ន្ធដកដង្ហើម

គោ ក្របីមានសួតតូច មិនសមាមាត្រទៅនឹងទំហំខ្លួន ។សួតស្ថិតនៅជ្រៅក្នុងប្រអប់ទ្រូង។

ផ្នែកផ្សេងៗគ្នានៃប្រព័ន្ធដកដង្ហើមរបស់គោ ក្របីរួមមាន:

-មាត់ និងរន្ធច្រមុះ

-បំពង់ក

-បំពង់ខ្យល់

-សួត។

ក្រពះគោពេញវ័យ








បំពង់កស្ថិតនៅខាងក្រោយមាត់តភ្ជាប់ទៅបំពង់ខ្យល់ ទៅក្នុងប្រអប់ទ្រូង ដែលជាកន្លែងបែងចែកជាទងសួតពីរ។ទងសួតទាំងពីរតភ្ជាប់ទៅក្នុងទងសួតតូចៗ។ ប្រព័ន្ធដកដង្ហើមតភ្ជាប់គ្នាដោយភ្នាសទន់ដែលគេហៅថាភ្នាសសើមព្រោះវាផ្សើមស្អិតដោយជាតិរំអិល។




➢ ប្រព័ន្ធបន្តពូជរបស់គោ ក្របីញី

ផ្នែកផ្សេងៗគ្នានៃប្រព័ន្ធបន្តពូជគោក្របីញីរួមមាន:




-អូវែ មាន២ មួយនៅផ្នែកខាងស្តាំ និងមួយទៀតនៅផ្នែកខាងឆ្វេងដែលតភ្ជាប់ដោយ ដៃស្បូនសងខាង

-ដៃស្បូន(បំពង់នាំអូវុល) ជាបំពង់តូចភ្ជាប់ពីអូវែរទៅស្បូន មានប្រវែង២៥សម និងអង្កត់ផ្ចិតតូចជាង១សម ។

-ស្បូនមានដៃស្បូនពីរ

-កស្បូន ជាទ្វារ ចូលទៅស្បូន អាចបើក បិទបាន

-ផ្លូវយោនី ជាបង្ហួរនោមដែលតភ្ជាប់នៅផ្ទៃបាតរបស់ផ្លូវយោនី

-យោនី ជាផ្នែកខាងក្រៅរបស់ប្រដាប់បន្តពូជ។



➢ ប្រព័ន្ធបន្តពូជរបស់គោឈ្មោល

សរីរាង្គដែលអាចមើលឃើញគឺពងស្វាសពីរ ដែល គ្របដោយស្បែក








ក្នុងពេលបន្តពូជ ក្បាលលិង្គនិងលិង្គយើងអាចមើលឃើញ




-បំពង់បង្ហូរទឹកកាម តភ្ជាប់នឹងពងស្វាស សម្រាប់ផ្ទុកទឹកកាម ។ បំពង់បង្ហូរនោមជាបំពង់នៅក្នុងលិង្គសម្រាប់បញ្ចេញទឹកកាម និងទឹកនោម។

-ប្រូស្តាត ជាក្រពេញសម្រាប់ផលិតទឹកកាម និងជាថង់ទឹកកាមសម្រាប់ការពារទឹកកាម (ស្ពែម៉ាតូសូអ៊ីត)។

- កន្សោមដោះ:

កន្សោមដោះមេគោមាន៤ផ្នែក ដាច់ដោយឡែកពីគ្នា និងមានក្រពេញទឹកដោះ ដែលផ្សំឡើងដោយ:

-ជាលិកាបញ្ចេញ (ថង់តូចៗ)

-ប្រពន្ធ័បំពង់ដែលប្រមូលទឹកដោះពីថង់តូចៗទៅដាក់ក្នុងកន្លែងស្តុក។

-កន្លែងស្តុកពីរ: មួយក្នុងក្រពេញដោះមានចំណុះទឹកដោះពី ២៥០ទៅ៥០០មល និងមួយទៀតនៅក្នុងក្បាលដោះមានចំណុះទឹកដោះពី ២០ទៅ ៤០ ម.ល។

-ក្បាលដោះ មានកន្លែងស្តុកទឹកដោះ ដែលបិទជិតដោយសាច់ដុំរាងមូល (សាច់ដុំខ្ចិប) ក្បែរចុងដោះ។


















# ជំពូកទី២៖ សរីរវិទ្យាសត្វ






# ក-បក្សី

## ១- ការរំលាយអាហារ

➢ មុខងាររបស់ប្រព័ន្ធរំលាយអាហារ

ប្រដាប់រំលាយអាហាររបស់បក្សីខ្លះ ចំបាច់ក្នុងការបំលែងចំណី ទៅជាសារធាតុចិញ្ចឹមដល់រាងកាយដែលត្រូវការ ដើម្បីទ្រទ្រង់ការធំធាត់ លូតលាស់ និងការផលិត ដូចជាការផលិតស៊ុត។ ចំណីត្រូវបានបំបែកទៅជាផ្នែកសំខាន់ៗដូចជា ប្រូតេអ៊ីន ខ្លាញ់ ស្ករ ថាមពល និងវីតាមីន ។ល។

➢ ដំណើរការរបស់ប្រព័ន្ធរំលាយអាហារ

- មាន់ចឹកចំណីនឹងចំពុះ ហើយអណ្តាត រុញចំណីចូលក្នុងមាត់ ។






- បំពង់អាហារ ជាបំពង់បត់បែនបាន ដែលនាំចំណីពីមាត់ទៅទងកោះ និងទៅគែ។ ចំណី ទឹក ស្តុកក្នុងគែរហូតដល់ពេលវេលាកំណត់ ដែលត្រូវរុញទៅខាងចុងប្រដាប់រំលាយអាហារ។ គែបញ្ហាពេលបក្សីស៊ីដោយវត្ថុផ្សេងៗដូចជា ខ្សែសរសៃវែង ជាដើម។

-.ទងកោះ បង្កើតជាតិអាស៊ីត និងអង់ស៊ីម ដើម្បីជួយរំលាយចំណី។ ការរំលាយចំណីចាប់ផ្តើមក្នុងទងកោះដែលចំណីលាយជាមួយទឹកក្រពេញ (អាស៊ីត និងអង់ស៊ីម) មើលទៅសើម និងខាប់ដោយមានកម្ទេច






ចំណីលាយជាមួយ។

- កោះជាសាច់ដុំរឹងសម្រាប់កិនចំណី និងរំលាយអាហារ។




- ពោះវៀនតូច ទទួលអង់ស៊ីមរំលាយអាហារពីលំពែងនិងពីថ្លើមតាមទឹកប្រមាត់។ អង់ស៊ីមសម្រាប់រំលាយប្រូតេអ៊ីន (បំបែកជាអាស៊ីតអាមីណេ) ។ ទឹកប្រមាត់សម្រាប់រំលាយខ្លាញ់។




- ថ្នក់(ខ្នែង)ពោះវៀន ស្ថិតនៅកន្លែងប្រសព្វគ្នា រវាងពោះវៀនធំ និងពោះវៀនតូច។ មុខងាររបស់ ថ្នក់(ខ្នែង)ពោះវៀន គឺធ្វើឱ្យឡើងមេ (ល្បើងមេ) សម្រាប់ផលិតវីតាមីនបេ៨ប្រភេទ។ ផ្ទៃរបស់ថ្នក់(ខ្នែង)ពោះវៀន នៅទំនេរពី២ឬ៣ដងក្នុងមួយថ្ងៃ។លាមកប្រែពណ៌ពីត្នោតខ្ចី ទៅត្នោតចាស់ និងមានក្លិនស្អុយ។



- ពោះវៀនធំ ជាកន្លែងចុងក្រោយដែលស្រូបទឹកចូលជាថ្មី។
- ក្នុងក្លូអាក់(ប្រជុំរន្ធភេទ) មានកាកសំណល់អាហារលាយជាមួយទឹកនោម ធ្វើឲ្យលាមកមានសភាពដូចជាម្សៅពណ៌ស។ ទឹកនោមបក្សី ជាអាស៊ីតអ៊ុយរិច។



ពោះវៀនតូច និងពោះវៀនធំ ដំណើរការបានដោយបាក់តេរីមីក្រូផ្លូរ៉ា ពពួកមីក្រូផ្លូរ៉ាជួយរំលាយអាហារ

ជំងឺពោះវៀនអាចកើតមានដោយមីក្រុបដ៏ទៃទៀតធ្វើឲ្យមីក្រូផ្លូរ៉ាបាត់លំនឹង ធ្វើឲ្យសត្វរាគ ខ្វះជាតិទឹក ស្រេកទឹកយ៉ាងខ្លាំង មិនឃ្លានចំណី ខ្សោយ ស្រកទម្ងន់ និងល្ងួតលាស់ឃើត។

➢ លាមក បក្សី

សណ្ឋាន និងពណ៌លាមក ជាសញ្ញាសំខាន់សម្រាប់សម្គាល់ជំងឺរបស់បក្សី។ **បក្សីមានសុខភាពធម្មតា:** លាមកពណ៌ខ្មៅនិងស្រោបអាស៊ីតអ៊ុយរិកពណ៌ស។



➢ **លាមកបក្សីឈឺ:**

- លាមកមានលាយឈាមជាសញ្ញាជំងឺកុកស៊ីដ្យូស



➢ លាមកពណ៌ខៀវជាសញ្ញារបស់ព្រូន

ព្រូនអាចមើលឃើញដោយផ្ទាល់









➢ លាមករាគពណ៌បៃតង សង្ស័យជំងឺដង្កោ (ញូវកាស)...

- លាមករាគពណ៌ប្រផេះ សង្ស័យជំងឺអ៊ីកូលី ...
- ប្រព័ន្ធទឹកនោម

មាន់គ្មានផ្លោកនោមទេ។ បំពង់ទឹកនោម នាំទឹកនោមពីតម្រងនោម ទៅប្រជុំរន្ធគូថ (ក្លូអាក់)។ អាស៊ីតអ៊ុយរិចក្នុងទឹកនោម ចូលក្នុងក្លូអាក់ (ប្រជុំរន្ធគូថ) និងបញ្ចេញមកក្រៅជាមួយលាមក លាមក មាន សណ្ឋានជាម្សៅ ពណ៌ស ។

## ២- ការដកដង្ហើម

- មុខងាររបស់ប្រព័ន្ធដកដង្ហើម

 ប្រព័ន្ធដកដង្ហើម ស្រូបយកអុកស៊ីសែន និងបញ្ចេញឧស្ម័នកាបូនិច ។

 ការដកដង្ហើមមានការទាក់ទងជាមួយនឹងសីតុណ្ហភាពក្នុងខ្លួន។

- តើបក្សីដកដង្ហើមយ៉ាងដូចម្តេច?

 បក្សីដកដង្ហើម មិនដូចសត្វចិញ្ចឹមកូនដោយទឹកដោះទេ។

- ផ្លូវដកដង្ហើមបក្សីចាប់ពីរន្ធខ្យល់។ រន្ធខ្យល់បិទពេលចំណីឆ្លងកាត់ទៅបំពង់ក ដើម្បីការពារមិនឲ្យចំណីធ្លាក់ចូលក្នុងសួត។




- ខ្យល់ចូលទៅបំពង់ខ្យល់ ពេលបំពង់ខ្យល់បែកជាទងពីរ មាន់មានប្រអប់សំលេងមួយហៅថា បំពង់ សំលេង មាន់ឈ្មោលចេះរងាវ ចំណែកមាន់ញីក៏អាចរងាវដែរ ប៉ុន្តែវាមិនរងាវដោយសារគ្មានអ័រម៉ូនដែលជំរុញឲ្យវារងាវ។




-ខ្យល់ឆ្លងកាត់ទងបំពង់ខ្យល់ និងផ្នែកចុងក្រោយរបស់បំពង់ខ្យល់ដែលថង់ខ្យល់ទាំង៩បែកចេញក្រៅ ថង់ខ្យល់ទាំងនេះស្តើង គ្មានពណ៌ និងប៉ោងដូចបាល់ក្នុងប្រហោងរាងកាយ។



-សួត សម្រួលការផ្លាស់ប្តូរអុកស៊ីសែន និង ឧស្ម័នកាបូនិក ប៉ុន្តែសួតមិនអាចប៉ោង បាន។ ការប៉ោងហើយតឹងណែន របស់ថង់ខ្យល់ គឺមិនមែនដោយសារសួតធ្វើឲ្យខ្យល់ចេញ ចូលនោះទេ។




ការដកដង្ហើម គឺជាចលនារបស់គ្រោងឆ្អឹង និងឆ្អឹងជំនី។

ការកាន់បក្សីដោយសង្កត់ខ្លាំងធ្វើ ឲ្យ ឆ្អឹង ជំនីរពិបាកចលនា និងថប់ដង្ហើម បញ្ហានេះច្រើនកើតចំពោះក្មេងកាន់កូនមាន់។



មាន់អាចងាប់ ពេលដឹកជញ្ជូនដាក់ក្នុងទ្រុងលើសចំណុះ ដោយសារវាមិនអាចដកដង្ហើមបាន។



## ៣- ការបង្កកំណើត

- ការផលិតស៊ុត

មេមាន់ចាប់ផ្តើមផលិតស៊ុត ដែលអាចបង្កកំណើតបាន នៅពេលមានអាយុពី ៥ទៅ៦ខែ។

- ការវិវឌ្ឍន៍ស៊ុតលឿង

អូវែជាកញ្ចុំសម្រាប់វិវឌ្ឍន៍ស៊ុតលឿង។ មេមាន់ផលិតស៊ុតលឿងបានពី ២០០០ទៅ ១០០០០ គ្រាប់ក្នុងមួយជីវិតរបស់វា។ ការកកើតស៊ុតលឿងរហូតដល់ទំហំធម្មតាដែល



# ក-បក្សី

## ១-ការពណ៌នាផ្នែកខាងក្រៅ:




- **សិរមាន់:** ជាដុំសាច់ផ្នែកខាងលើក្បាល មានពណ៌ក្រហមស្រស់។
- **ភ្នែក:** មានភ្នែកពីរនៅសងខាងក្បាលពណ៌ខ្មៅភ្លឺថ្លា។
- **ត្រចៀក:** មានត្រចៀកពីរនៅសងខាងក្បាល។
- **ចំពុះ:** ផ្នែកខាងលើ និងផ្នែកខាងក្រោម ដែលមានសណ្ឋានជាស្នែង ភាគច្រើនមានពណ៌លឿង។
- **ណង់:** ជាស្បែកខ្ចី តោងជាប់ក្រោមចំពុះមានពណ៌ក្រហម។

- ស្លាប:គ្របដណ្តប់ដោយរោម ដែលអាចហើរបាន។



- **ទ្រូង:** ស្ថិតនៅផ្នែកខាងមុខនៃដងខ្លួន។




- **រោមកន្ទុយ:** មានពណ៌ផ្សេងៗគ្នា និងបះទៅលើ។

មើលឃើញក្នុងស៊ុតមានរយៈពេលប្រហែល១០ ថ្ងៃ ។ ស៊ុតលឿងផ្តល់ចំណីសម្រាប់ការវិវឌ្ឍនកូនមាន់ និងភាពស៊ាំពីមេដើម្បីការពារកូនមាន់ ប្រឆាំងនឹងភ្នាក់ងារបង្កជំងឺ។ ពណ៌របស់ស៊ុតលឿងអាស្រ័យនឹងរបបចំណី ជាពិសេសជាតិពណ៌ដែលមាននៅក្នុងពោត។

អូវុលទុំ គឺជាការបញ្ចេញស៊ុតលឿងពីអូវែទៅក្នុងបំពង់អូវុល កើតមានរយៈពេលពី៣០ទៅ៦០នាទី បន្ទាប់ពីស៊ុតចាស់ចេញក្រៅ។ អូវុលទុំ ច្រើនកើតនៅពេលព្រឹក។ ស៊ុតវិវឌ្ឍនក្នុងបំពង់អូវុល។ បំពង់អូវុល ជាបំពង់វែងផ្ទុកដោយសរសៃឈាមជាច្រើន និងក្រពេញដូចជាៈ




- ផ្នែកទី១នៃបំពង់អូវុល ហៅថាអ៊ីនហ្វេនឌីប៊ុយលុមគឺជាកន្លែងដែលស៊ុតអាចចាប់បង្កកំណើតកូន ក្នុងករណីមានវត្តមានទឹកកាម។

-បន្ទាប់មកស៊ុតឆ្លងកាត់ទៅផ្នែកទី ២ហៅថាម៉ានុមដែលជាកន្លែងបង្កើតអាល់ប៊ុយមីន(ជាតិស)រុំជុំវិញស៊ុតលឿង ត្រូវការរយៈពេលប្រហែល៣ម៉ោងកន្លះ។

-បន្ទាប់មកស៊ុតឆ្លងកាត់ផ្នែកទី៣ ហៅថា អិសថ្មុសដែលជាភ្នាសសំបករុំព័ទ្ធជុំវិញស៊ុត ប្រើរយៈពេល១ម៉ោងកន្លះ។

-បន្ទាប់មកស៊ុតធ្លាក់ទៅកន្សោមពង ជាតិកាល់ស្យូមរុំព័ទ្ធជុំវិញស៊ុតដែលកំពុងវិវឌ្ឍន ត្រូវការពេលប្រហែល ២០ ម៉ោង។ សំបករឹងស៊ុតជួយ ការពារ ទប់ស្កាត់ផលប៉ះពាល់ពីមជ្ឈដ្ឋានខាងក្រៅ។

➢ ការកកើតស៊ុត



-ស៊ុតឆ្លងកាត់ប្រជុំរន្ធភេទ(ក្លូអាក់)យ៉ាងលឿនមុនវាពង។ ការករកើតស៊ុតថ្មី ប្រើរយៈពេល ពី២៥ទៅ២៦ម៉ោង។

-មាន់ពងបានច្រើនសំបុក មួយសំបុកមានស៊ុតតិចឬច្រើនអាស្រ័យដោយពេលវេលា។ ទំហំស៊ុត និងចំនួនស៊ុតក្នុងមួយសំបុក និងចំនួន សំបុកដែលបានផ្តល់ក្នុងមួយវដ្តអាស្រ័យតាមពូជ។ មេមាន់ចិញ្ចឹមលែងផ្តល់ស៊ុតប្រមាណ ១០គ្រាប់ ក្នុងមួយសំបុក និង ៦ ដងក្នុងមួយឆ្នាំ។

➢ ការជាន់មេ

មាន់ឈ្មោល សម្រាប់បង្កាត់ពូជ អាយុ៦ខែដែលស្ពែមរបស់វាមានគុណភាពល្អ។ មាន់ឈ្មោលគ្មានលិង្គ វាឡើងពាក់មេដោយដាក់រន្ធគូទវាលើរន្ធគូទមាន់ញី។ ដើម្បីបានផលល្អមាន់ឈ្មោលមួយក្បាលសម្រាប់មាន់ញីពី៨ ទៅ១០ក្បាល។ បើមាន់ ឈ្មោលច្រើនពេកការបង្កកំណើតទាបដោយសារវាជល់គ្នា។



➢ **ការករកូន**

អ៊ីនហ្វេនឌីប៊ុយលុម ជាកន្លែងផ្ទុកស្ពែរម៉ាតូសូអ៊ីត និងជាកន្លែងចាប់ផ្ដើមករកូន។ នៅក្បែរទីប្រសព្វប្រជុំរន្ធភេទ មានក្រពេញមួយអាចផ្ទុកទឹកកាមពី១០ទៅ១៥ថ្ងៃ។ ពេលស៊ុតមួយចេញមកក្រៅទឹកកាមអាចចេញពីក្រពេញ និងផ្លាស់ទីទៅផ្នែកទីមួយរបស់បំពង់អូវុល-ដើម្បីករកូនលើស៊ុតមួយទៀត។ ទឹកកាមអាចរស់បាននៅសីតុណ្ហភាពរបស់រាងកាយ។

ដំណុះដុំមូល (germinal disc) គឺជាចំណុចមូលតូចពណ៌សនៅលើស៊ុតលឿង វាជាកន្លែងដែលទឹកកាមចូលទៅក្នុងស៊ុត។



- ការក្រាបពង (ឬភ្ញាស់)

-ស៊ុតត្រូវការសីតុណ្ហភាពនិងសំណើមសមស្រប សម្រាប់ញាស់គឺពី ៣៨-៣៩ អង្សាសេ។

សីតុណ្ហភាពនិងសំណើមសម្រាប់ ក្រាបពង ជាអំណោយផលដ៏ល្អសម្រាប់ការលូតលាស់ របស់បាក់តេរី ដូចនេះ កុំភ្ញាស់ស៊ុត ដែលកខ្វក់ (ការលាងស៊ុតមិនមែនជាការល្អនោះទេ ព្រោះវាបំផ្លាញការការពារពីធម្មជាតិរបស់ស៊ុត)។

-មេមាន់ក្រាបពងក្នុងសំបុក ដែលមានស៊ុតពី៨ទៅ១៣គ្រាប់ មេមាន់ចុះរកស៊ីចំណីប្រមាណ១៥នាទីប៉ុណ្ណោះ ជារៀងរាល់ថ្ងៃ ដូចនេះវាត្រូវមានសុខភាពល្អ មុនចាប់ផ្ដើមក្រាបពង។

-មេមាន់បង្វិលពងជាទៀងទាត់ដោយប្រើចំពុះរបស់វា ដើម្បីកុំឲ្យអ៊ីនហ្វេនឌីប៊ុយលុមស្អិតជាប់នឹងសំបកខាងក្នុង និងផ្ដល់អុកស៊ីសែន។

-មាន់ក្រាបពងមានរយៈពេល២១ថ្ងៃ។





➢ ការឆ្លុះស៊ុត

គោលបំណងនៃការឆ្លុះស៊ុតគឺ ដើម្បីឲ្យដឹងថាស៊ុតនោះកកូនឬអត់។ ស៊ុតដែលភ្ញាស់បានមួយអាទិត្យ ឃើញសរសៃសំបុកពីងពាងរុំជុំវិញចំណុចខ្មៅ បញ្ជាក់ថាខ្ទុរកូនកំពុងវិវឌ្ឍនល្អ។

ការបញ្ចាំងពន្លឺលើស៊ុត ដោយ ប្រើពន្លឺតូចជាងទំហំរបស់ស៊ុត។

➢ ការញាស់កូនមាន់

- ការញាស់មានរយៈពេលពី៤ទៅ១២ម៉ោង
- កូនមាន់ ញាស់ចេញដោយខ្លួនឯងហើយ ខ្លួនសើម និងអស់កំលាំង កូនមាន់នៅស្ងៀម ពី២ទៅ៣ម៉ោង ក្រោយមកខ្លួនវាស្ងួត រោម ត្រសុស និងមានកម្លាំងខ្លាំងក្លា- ចង់ស៊ុតលឿងក្នុងខ្លួនកូនមាន់អាចចិញ្ចឹមវាបាន៤៨ម៉ោង។

## ៤-ការជ្រុះរោម

ជាធម្មតារៀងរាល់ឆ្នាំមាន់ ជ្រុះរោម និងជ្រុះស្លាបចាស់ៗ។ ការជ្រុះរោមចាប់ពីក្បាល ក ដងខ្លួន និងចុងក្រោយគឺស្លាប និងកន្ទុយ។ ការជ្រុះរោមមានរយៈពេលពី៦ទៅ៧អាទិត្យ ក្នុងអំឡុងពេលនេះ ជាទូទៅមាន់ឈប់ពង។



## ៥- ការត្រួតពិនិត្យកំដៅដងខ្លួន

សីតុណ្ហភាពរបស់មាន់ជំទង់ប្រែប្រួល ពី ៣៩.៨ ទៅ ៤៣.៦ អង្សាសេ។ ដើម្បីសម្រួលសីតុណ្ហភាពក្នុងខ្លួន ពេលអាកាសធាតុក្តៅ មាន់ដង្ហក់ វាដងង្ហើមដោយបើកចំពុះនិងត្រដាងស្លាបដើម្បីទទួលភាពស្រស់ស្រាយ។ បក្សីមិនចេញញើស។



កូនមាន់ដែលទើបញាស់ ត្រូវការកម្តៅបន្ថែមរយៈពេល២អាទិត្យ ជាពិសេសនៅពេលយប់ ។មាន់ចិញ្ចឹមលែង មេមាន់ជាអ្នកផ្តល់កម្តៅដល់កូន។



ដោយឡែកការចិញ្ចឹមកូនមាន់ក្នុងទ្រុងចាំបាច់ត្រូវផ្តល់កំដៅនៅពេលយប់។



# ខ-ជ្រូក

## ១-ប្រព័ន្ធរំលាយអាហារ

ជ្រូកជាសត្វមានក្រពះទោល(ក្រពះមួយ)ដូចមនុស្សដែរ ។

➤ មុខងាររបស់ប្រព័ន្ធរំលាយអាហារ

ប្រដាប់រំលាយអាហារជាបំពង់វែងមួយដែលចំណីឆ្លងកាត់។ ចំណីត្រូវបានបំបែកជា ចំណែកតូចៗ ទៅជាសារធាតុចិញ្ចឹម ហើយស្រូបចូលទៅក្នុងឈាម ប្រសិនបើមិនបានស្រូប វានឹងចេញមកក្រៅតាមលាមក និងទឹកនោម។






ឧទាហរណ៍ប្រូតេអ៊ីនៈ ប្រូតេអ៊ីន ដែលមាននៅក្នុងចំណី នឹងត្រូវបំបែកទៅជាអាស៊ីតអាមីណេ ដោយឆ្លងកាត់លុយមែនរបស់ពោះវៀន ចូលទៅក្នុងឈាម ដើម្បីផ្តល់ទៅសរីរាង្គនានា។

- មុខងាររបស់សរីរាង្គ



- មាត់ ជាផ្លូវដែលចំណីចូលក្នុងប្រដាប់រំលាយអាហារ និងជាកន្លែងចាប់ផ្តើមបំបែកចំណី។ ធ្មេញបំបែកចំណីទៅជាដុំតូចៗ ចំណីជ្រើមដោយទឹកមាត់ ហើយអណ្តាតជួយរុញ ចំណី ទៅកាន់បំពង់អាហារ។
- បំពង់អាហារ ជាបំពង់ដែលមានប្រព័ន្ធសាច់ដុំកន្ត្រាក់សម្រាប់រុញចំណីចូលទៅក្រពះ ។




- ក្រពះ ជាកន្លែងដែលសារធាតុគីមីបានបន្ថែមក្នុងចំណី។ កោសិកាលើជញ្ជាំងក្រពះ បញ្ចេញអាស៊ីតអ៊ីដ្រូក្លរិច និងអង់ស៊ីម។ សារធាតុគីមី ជួយបំបែកចំណីទៅជាកាបូអ៊ីដ្រាត ប្រូតេអ៊ីន និងខ្លាញ់។
- ក្រពះស្រូបកាបូអ៊ីដ្រាត ប្រូតេអ៊ីន និងខ្លាញ់ ចូលទៅក្នុងសរសៃឈាម ហើយផ្នែកដែលក្រពះមិនអាចស្រូប ឆ្លងចូលក្នុងពោះវៀនតូច។
- ពោះវៀនតូច ជាបំពង់ស្មុគស្មាញ ជាលិកាលើជញ្ជាំង
- ពោះវៀនតូច ផលិតអង់ស៊ីម។ ផ្នែកទី១ របស់វៀនតូចមានសារធាតុរាវដែលបញ្ចេញពីថ្លើម និងលំពែង។ សារធាតុរាវ ដែលបញ្ចេញពីថ្លើមបានរក្សាទុកក្នុងថង់ទឹកប្រមាត់។ ទឹកប្រមាត់ ជួយរំលាយជាតិខ្លាញ់។ រសរំលាយអាហារចេញពីលំពែង ឆ្លងចូលទៅពោះ



វៀនតូច សារធាតុទាំងនេះ មានជាតិ អង់ស៊ីមដែល ចាំបាច់សម្រាប់បំបែកខ្លាញ់ កាបូអ៊ីដ្រាត និងប្រូតេអ៊ីន។ សារធាតុចិញ្ចឹមដែលមិនបានបំបែក បានឆ្លងទៅ ពោះវៀន ធំ។



- ពោះវៀនធំ ជាអាងស្តុកកាកសំណល់ (លាមក) មុខងាររបស់ពោះវៀនធំ គឺ ស្រូបទឹក។ សារធាតុចិញ្ចឹមមួយចំនួន ដែលនៅសេសសល់ មិនបានបំបែកក្នុង ពោះវៀនតូច ត្រូវបានដំណើរការក្នុង ពោះវៀនធំទៀត។
- ចំណែកចុងក្រោយរបស់ពោះវៀនធំហៅ ថាចុងពោះវៀន។ការកន្ត្រាក់សាច់ដុំ ដើម្បីរុញលាមកទៅរន្ធគូថ។

## ២-ប្រព័ន្ធដកដង្ហើម

➢ មុខងាររបស់ប្រព័ន្ធដកដង្ហើម គឺស្រូបអុកស៊ីសែន និងបញ្ចេញឧស្ម័នកាបូនិច។

➢ ដំណើរការ(សរីរវិទ្យា)របស់ប្រដាប់ដកដង្ហើម:




- ឆ្អឹងទុយប៊ីន ក្នុងរន្ធច្រមុះ រាងអង្កាញ់ អាច សំអាតខ្យល់ និងសម្របសម្រួលសីតុណ្ហភាព របស់រាងកាយ។
- កម្ទេចកំទីចូលក្នុងបំពង់ខ្យល់ និងទងសួត ធ្វើឲ្យសត្វក្អក ខាក។ បំពង់ខ្យល់ និងទងសួត ការពារដោយជាលិកាអេពីតេលីយ៉ូម និង ក្រពេញក្អាសសើម ។ មេរោគខ្លះ ដូចជាមីក្រូផ្លាស្មាបំផ្លាញរនាំងការពារនេះ និងធ្វើឲ្យ មេរោគដ៏ទៃទៀតងាយរាតត្បាតដល់សួត។ ពពួកមេរោគ ដូចជាបាក់តេរី វីរុស អាចឆ្លងចូលដល់កូនថង់សួត ហើយបំផ្លាញភាពស៊ាំ (ម៉ាក្រូហ្វា)។ ឧទាហរណ៍ជំងឺគ្រុនចៀកខៀវ អាចបំផ្លាញភាពស៊ាំ(ម៉ាក្រូហ្វា) នឹងធ្វើឲ្យសួតមិនអាចទប់ទល់ការរាលដាលរបស់មេរោគ ដូចជាមេរោគប៉ាស្ទឺរ៉ែឡា។

- ការប្តូរឧស្ម័នក្នុងថង់សួត

ខ្យល់ស្រូប ចូលក្នុងសួត តាមបំពង់ខ្យល់ ទងសួត នឹងទៅដល់ថង់សួត។ ខ្យល់ចូលក្នុងថង់សួត សំបូរអុកស៊ីសែន និងមានឧស្ម័នកាបូនិចតិចតួច។




- អុកស៊ីសែន ភាយចេញពីថង់សួត ចូលទៅក្នុង កោសិកាឈាមក្រហមក្នុងសរសៃឈាមឆ្មារ ក្នុងពេលជាមួយគ្នានោះកោសិកាឈាមក្រហមក្នុងសរសៃឈាមឆ្មារៗបញ្ចេញឧស្ម័នកាបូនិច ហើយឧស្ម័នកាបូនិចភាយចូលទៅក្នុងកូនថង់សួត។

- ឧស្ម័នកាបូនិចត្រូវបានបញ្ចេញពីរាងកាយក្នុងពេលដកដង្ហើម។










➢ មុខងាររបស់ឈាម

ឈាមក្រហមនាំអុកស៊ីសែនពីសួតទៅសរីរាង្គ ។ ឈាមក្នុងសរសៃឈាមក្រហម(សរសៃអាក់ទែរ)មានពណ៌ក្រហម ព្រោះមានអុកស៊ីសែនច្រើន។

ឈាមខ្មៅនាំឧស្ម័នកាបូនិចពីសរីរាង្គទៅសួត។ ឈាមក្នុងសរសៃឈាមខ្មៅ (សរសៃវ៉ែន) មានពណ៌ខៀវ ព្រោះមានឧស្ម័នកាបូនិចច្រើន និងមានអុកស៊ីសែនតិចតួច។

➢ មុខងាររបស់បេះដូង

បេះដូង ជាសាច់ដុំ ដូចជាស្នប់ សម្រាប់សប់ឈាម ដែលនាំឈាមពីសួតទៅសរីរាង្គ និងពីសរីរាង្គទៅសួត ។

បេះដូងចែកជា ៤ ថត:

- សរសៃឈាមក្រហម(អាក់ទែរ)នាំឈាមចេញពីបេះដូងនិងនាំអុកស៊ីសែន
- សរសៃឈាមខ្មៅ(សរសៃវ៉ែន)នាំឈាមចូលទៅក្នុងបេះដូង និងនាំឧស្ម័នកាបូនិច។




## ៣-ប្រព័ន្ធបន្តពូជ

- វដ្តនៃការរកឈ្មោល
  - ការរកឈ្មោលដំបូង របស់មេជ្រូកក្រមុំ អាចនៅអាយុ ៦ ខែ
  - មេជ្រូកខ្លះអាចរកឈ្មោលសារជាថ្មី ពី ៥ទៅ៧ថ្ងៃ បន្ទាប់ពីផ្តាច់ដោះ
  - ប្រសិនបើ មេជ្រូកស្គមខ្លាំង ការរកឈ្មោល អាចអូសបន្លាយច្រើនអាទិត្យ
  - បើមេជ្រូក ឬមេក្រមុំ ពេលរកឈ្មោលហើយមិនបានបង្កាត់ រកឈ្មោលសារជាថ្មីនៅ ២១ថ្ងៃក្រោយមក។

➢ កំណត់ការរកឈ្មោល:

- បើមានជ្រូកបានៅក្បែរមេជ្រូក ហើយ ច្រមុះរបស់វាប៉ះគ្នា ពេលនោះមេជ្រូក បះត្រចៀកឡើងហើយជ្រូកបាចាប់ផ្តើមមានអារម្មណ៍។




- យោនីរីកឡើងក្រហម ប៉ុន្តែ សញ្ញានេះអាចកើតមានតិចតួច។


វដ្តរដូវរបស់មេជ្រូក


វដ្តរដូវរបស់ជ្រូកក្រមុំ

- សញ្ញាដែលប្រាកដគឺមេជ្រូកនៅស្ងៀម នៅពេលយើងឡើងជិះលើខ្នងវា។



ពិនិត្យការនៅស្ងៀម របស់មេជ្រូក

**រយៈពេលល្អសម្រាប់ដាក់បង្កាត់ក្នុងអំឡុងពេលពី១២ ទៅ ២៤ ម៉ោង។**

- ការវិវឌ្ឍនអំប្រីយ៉ុង និងការកកូន
  - ការបង្កកំណើតកើតមាននៅថ្ងៃបង្កាត់តែម្តង
  - កំឡុងពេល១ម៉ោងបន្ទាប់ពីការបង្កាត់ ទឹកកាមធ្វើចលនាទៅដល់បំពង់អូវុល
  - នៅថ្ងៃទី២អំប្រីយ៉ុងបំលាស់ទីចូលទៅក្នុងស្បូន
  - នៅថ្ងៃទី៣ អំប្រីយ៉ុងមានទំហំ០,២ ទៅ០,៣ ម.ម
  - ចាប់ពីថ្ងៃទី៤ទៅថ្ងៃទី១២ អំប្រីយ៉ុងផ្លាស់ទីទៅនៅចន្លោះដៃស្បូន។





កូនអាយុ៦០ថ្ងៃ

  - ការមានគភ៌ៈ អំប្រីយ៉ុងតោងជាប់នឹងស្បូនដោយបង្កើតជាសុកចាប់ពីថ្ងៃទី ១២ ទៅថ្ងៃទី ១៤ បន្ទាប់ពីដាក់បាអំប្រីយ៉ុងមានទំហំពី ៥ ទៅ ១០ ម.ម។ បន្ទាប់ពី ១ ខែ អំប្រីយ៉ុងក្លាយជាកូនដែល នឹងវិវឌ្ឍនរហូតដល់ពេលកើត។

➢ ការរកឈ្មោលឡើងវិញ:

- មេជ្រូកបង្ហាញសញ្ញារកឈ្មោលឡើងវិញបន្ទាប់ពីដាក់ឈ្មោលឬបង្កាត់ដោយសិប្បនិម្មិត ពី ១៨ ទៅ ២២ ថ្ងៃ
- ការរកឈ្មោលឡើងវិញដោយសារគុណភាពទឹកកាមមិនល្អ ឬសត្វមានជំងឺរ៉ាំរ៉ៃ
- ការរកឈ្មោលឡើងវិញ អាចកើតឡើងប្រហែល៣៥ថ្ងៃបន្ទាប់ពីដាក់ឈ្មោលករណីនេះដោយសារកើតជំងឺមួយចំនួនដូចជា ជំងឺគ្រុនចៀកខៀវ ប៉េស្ត និងប៉ាវ៉ូ។

**ការផើម:** រយៈពេលផើម គឺ១១៤ថ្ងៃ(៣ខែ ៣អាទិត្យ ៣ថ្ងៃ) ។ជាការចាំបាច់ត្រូវគណនាថ្ងៃកើតកូន ដើម្បីត្រៀមរៀបចំឲ្យបានល្អ ពេលខ្លះការកើតកូនអាចយឺតជាង១១៥ថ្ងៃ ដូចនេះយើងត្រូវចាក់ថ្នាំប្រូស្តាក្លង់ឌីន ដើម្បីបង្កើនអត្រារស់របស់កូនជ្រូក។កូនជ្រូកចាប់ផ្តើមកើតពី ២ទៅ៣ម៉ោងបន្ទាប់ពីចាក់ថ្នាំរួច។




- មុនកើតកូន ចាំបាច់ត្រូវកំណត់សញ្ញា:
  - ១០ ថ្ងៃមុនកើតកូនកន្សោមដោះឡើងធំ និងយោនីរីកធំ
  - នៅ ៨ ទៅ ១២ ម៉ោងមុនកើតកូន បើយើងច្របាច់ក្បាលដោះ មានទឹកដោះចេញ
  - នៅ ៣០ ទៅ ៩០ នាទីមុនកើតកូន មានបែកទឹកភ្លោះ និងមានឈាមលាយអាចម៍ព្រៃ។



ពេលកើតកូន

- ដំណាក់កាលនៃការកើតកូន ជាធម្មតា រយៈពេល ពី៣០ទៅ៩០នាទីបន្ទាប់ពីចេញអាចម៍ព្រៃ កូនជ្រូកទី១នឹងចាប់ផ្តើមលេចចេញ(កើត)




- បន្ទាប់ពីកូនជ្រូកកើតហើយភ្លាម ទងសុកជាប់នឹង មេជ្រូក ទងសុក នឹងដាច់ចេញ ពេល កូនដើរទៅរកដោះមេ
- កូនជ្រូកកើតក្នុងអំឡុងប្រហែល ១៥ នាទី ម្តងយឺតបំផុតគឺ ៣០ នាទី
- រយៈពេលសរុបរបស់ការកើតកូន ជាធម្មតា មានរយៈពេលតិចជាង ២.៥ ម៉ោង
- ជាធម្មតាសុកធ្លាក់ពី ២ ទៅ ៤ ម៉ោង បន្ទាប់ពីកូនចុងក្រោយកើត។



- ការផ្តាច់ដោះ
  - មេជ្រូកបំបៅដោះកូន ពី ២១ ថ្ងៃ ទៅ ២៨ថ្ងៃ
  - មេជ្រូកមិនរកឈ្មោលក្នុងអំឡុងពេលបំបៅកូន
  - មេជ្រូករកឈ្មោលសារជាថ្មីនៅថ្ងៃទី៥ ទៅថ្ងៃទី១០ បន្ទាប់ពីផ្តាច់ដោះលើកលែងតែជ្រូកនោះស្គមពេក។



កូនជ្រូកអាយុ២៨ថ្ងៃ ជាពេលវេលាផ្តាច់ដោះ

- ទឹកកាម
  - ចំណុះទឹកកាម ពី២០០ ទៅ ៥០០ ម.ល
  - ទឹកកាមមានពណ៌ស រាងក្រែម
  - រយៈពេលនៃការចេញទឹកកាមពី៥ទៅ២០នាទី។



- សីតុណ្ហភាពទឹកកាមគឺ៣៧,៥ អង្សាសេ ដូច្នេះពងស្វាសត្រូវការសីតុណ្ហភាពទាប
- ស្ពែម៉ាតូសូអ៊ីត វិវឌ្ឍន រយៈពេល៤សប្តាហ៍ ក្នុងពងស្វាស និង ទុំក្នុងបំពង់បង្ហូរទឹកកាម ជាង២សប្តាហ៍
- ទឹកកាមស្ថិតក្នុងមេជ្រូករយៈពេលពី ៣០-៤៨ ម៉ោង
- គុណភាពទឹកកាមអាស្រ័យកំហាប់ និងចលនារបស់ ស្ពែម៉ាតូសូអ៊ីត ។ (ចំនួនស្ពែម៉ាតូសូអ៊ីតលើសពី ១០០ លាន ក្នុងមួយមិល្លីលីត្រ)។



ទឹកកាមមានគុណភាពល្អ





ទឹកកាមមានគុណភាពមិនល្អ

សម្គាល់: មានកត្តាជាច្រើនដែលធ្វើឲ្យគុណភាព ទឹកកាម ធ្លាក់ចុះ ដូចជា: អាកាសធាតុ ចំណី ស្ត្រេស ជំងឺ និងកត្តាផ្សេងៗទៀត។

# គ-សត្វគោ ក្របី

## ១-ប្រព័ន្ធរំលាយអាហារ

គោ ក្របីជាសត្វទំពារអៀង មានប្រដាប់រំលាយអាហារសាំញ៉ាំ ផលិតថាមពល និង ប្រូតេអ៊ីនពីចំណី(ស្មៅ) និងជាតិសរសៃបាន ដូចជា ចំបើង។

➢ <u>ពោះធំ</u> មានសណ្ឋានជាថង់ធំមួយសម្រាប់ល្បើងមេ មានចំណុះលើសពី១០០លីត្រ និងមានពពួកមីក្រុបជាច្រើនបំបែកខ្លួននៅខាងក្នុងពោះធំ។ មីក្រុបទាំងនេះជាបាក់តេរី ប្រូតូសូអ៊ែរ និងផ្សិត។ ទឹករស់ពោះធំ១ម.ល មានបាក់តេរី ពី១០ ទៅ៥០ពាន់លាន និង<u>១ លាន</u> ប្រូតូសូអ៊ែរ។






គោ ក្របី មានសុខភាពល្អ ពោះធំ ធ្វើចលនាពី១ ទៅ ២ ដងក្នុងមួយនាទី ដើម្បីឲ្យមីក្រុបលាយជាមួយ ចំណី និងរុញល្បាយក្នុងពោះធំចេញ ។

**មីក្រុបមានមុខងារខុសៗគ្នា:**

- មីក្រុបខ្លះអាចរំលាយជាតិសរសៃ
- មីក្រុបខ្លះអាចរំលាយជាតិម្សៅ
- មីក្រុបខ្លះអាចរំលាយជាតិប្រូតេអ៊ីន។




**- ថាមពល**

ចំណីឡើងមេ ក្នុងពោះធំ មានជាតិសរសៃ ម្សៅនិងស្ករសម្រាប់ផលិតអាស៊ីត (អាស៊ីតខ្លាញ់) និងឧស្ម័ន (ឧស្ម័នកាបូនិច និងមេតាន)។

សត្វស្រូបអាស៊ីតខ្លាញ់ ដើម្បីប្រើជាប្រភព ថាមពល សម្រាប់ចលនា ផលិតទឹកដោះ ផលិតសាច់ និងសម្រាប់ចិញ្ចឹមមីក្រុប។

មីក្រុបបំបែក ខ្លួនយ៉ាងច្រើន ដើម្បីបានជាប្រភពប្រូតេអ៊ីន។

ក្នុងអំឡុងដំណើរការនេះ បរិមាណរបស់ឧស្ម័ន ភាគច្រើន ជាពិសេសឧស្ម័នកាបូនិច និងមេតានត្រូវ បានផលិត ក្នុងពោះធំ។ គោ ក្របីភើ ដើម្បីបញ្ចេញឧស្ម័ន។

- **ប្រូតេអ៊ីន**

ប្រូតេអ៊ីនមានសារៈសំខាន់ក្នុងការផលិតទឹកដោះនិងសាច់ ។ ប្រូតេអ៊ីនបំលែងជាអាស៊ីត អាមីណេ ដើម្បីឲ្យសរីរាង្គស្រូបបាន។

- ប្រូតេអ៊ីន ឬជាតិអ៊ុយរេ ត្រូវបំបែកដោយមីក្រុបក្នុងពោះធំនិងបំលែងទៅជាអាម៉ូញាក់ ។ជាតិអាម៉ូញាក់និងថាមពលដែលត្រូវបានប្រើដោយមីក្រូសរីរាង្គរបស់ពោះធំ ដើម្បីបំបែកខ្លួនជាមីក្រុបរាប់ពាន់លាន។ មីក្រុបទាំងនេះ ៨០%ជាប្រូតេអ៊ីន ចូលក្នុងពោះវៀន ដើម្បីបញ្ចប់ការរំលាយអាហារ។




- ប្រូតេអ៊ីនមានប្រភពពីស្លឹករុក្ខជាតិ មិនអាចបំបែកដោយមីក្រុបក្នុងពោះធំបានដូចនេះវាចូលផ្ទាល់ទៅក្នុងពោះវៀន ដើម្បីបញ្ចប់ ការរំលាយអាហារ ហៅថាប្រូតេអ៊ីនចូលដោយផ្ទាល់។

- **តម្រូវការរបស់មីក្រុប**

មីក្រុបរស់នៅក្នុងពោះធំ ត្រូវការសារធាតុចិញ្ចឹម សម្រាប់ធំធាត់ និងបំបែកខ្លួនដើម្បីធានាការ រំលាយអាហារ។

ប្រសិនបើលក្ខខណ្ឌចាំបាច់ សីតុណ្ហភាព pH និងសារធាតុចិញ្ចឹមមិនមានក្នុងពោះធំ ពពួកមីក្រុបមិនអាចវិវត្ត និងបំលែងចំណីទៅជាថាមពលនិងប្រូតេអ៊ីនបានទេ។

**តម្រូវការសម្រាប់ការលូតលាស់របស់មីក្រុប រួមមាន:**

- ប្រភពជាតិសរសៃ (ស្មៅ ចំបើង) ឬជាតិម្សៅ (ពោត មើមដំឡូង) ដើម្បីផ្តល់ថាមពល
- ប្រភពអាសូត ផ្សំដើម្បីផលិតអាម៉ូញាក់
  សារធាតុចិញ្ចឹមទាំងនេះអាចត្រូវបានផ្តល់តាមរយៈឧស្មន ស្លឹកឈើ ឬអ៊ុយរ៉េ
- ប្រភពរ៉ែ ដូចជាផូស្វរ័ កាល់ស្យូម និងម៉ាញេស្យូម
- ប្រភពសមាសធាតុបន្ទាប់បន្សំដូចជា ទង់ដែង សង្ក័សី ម៉ងកាណែស ដែក និងស្ពាន់ធរ័ ប្រភពវីតាមីន អាដេអឺ ADE ត្រូវបានផ្តល់តាមរយៈចំណីដែលមានគុណភាព ឬប្រេមិច។ សត្វទំពារអៀងអាចផលិតពពួកវីតាមីនក្រុមបេបានដោយខ្លួនឯង។

- **ពោះចក**

ពោះចក មានសណ្ឋានជាថង់ និងជាស្ទប់សម្រាប់ទំពារអៀង ដើម្បីរុញចំណីត្រឡប់ទៅបំពង់អាហារ និងមាត់វិញ។

- ការទំពារអៀងមានសារៈសំខាន់ព្រោះវាបំបែកធាតុសរសៃទៅជាចំណែកតូចៗ ដើម្បីសម្រួល ធ្វើឲ្យឡើងមេ
- ពេលគោទំពារអៀងបានបន្ថែមទឹកមាត់ ៥០លីត្រក្នុងមួយថ្ងៃ ដើម្បីការពារឡើងជាតិអាស៊ីតក្នុងពោះធំ និងផ្តល់នូវជាតិអ៊ុយរ៉េជាច្រើន
- គោចំណាយពេលដើម្បីទំពារអៀងពី ៣៥ ទៅ ៥០% រាល់ថ្ងៃ ។






- **ពោះស្រទាប់ និងពោះកន្ត្រៀង**
  - មុខងាររបស់ពោះស្រទាប់គឺស្រូបទឹកពីចំណី
  - ពោះកន្ត្រៀង ជាក្រពះពិតប្រាកដ ដូចជាក្រពះជ្រូកដែរ ពោះកន្ត្រៀងសំបូរជាតិអាស៊ីតដែលមីក្រុបមិនអាចរស់បាន ហើយការរំលាយអាហារអាស្រ័យអង់ស៊ីម។

- **<u>ពោះវៀន</u>**
  - ចំណីនិងផ្នែកតូចៗ ឆ្លងកាត់ពោះកន្ត្រៀង និងទៅកាន់ពោះវៀនតូចដែលជាកន្លែងសារធាតុចិញ្ចឹមត្រូវបានស្រូបសម្រាប់ចិញ្ចឹមសរីរាង្គ។ ពោះវៀនតូចទទួលរសទឹកប្រមាត់ពីថ្លើម និងពីលំពែង ដើម្បីជួយក្នុងការរំលាយអាហារ។
  - ដំណើរការរំលាយអាហារភាគច្រើនត្រូវបានបញ្ចប់នៅពោះវៀនតូច។
  - កាកសំណល់ដែលមិនបានប្រើប្រាស់ ឬស្រូប ត្រូវចូលទៅក្នុងពោះវៀនធំ ហើយ

ដំណាក់កាលចុងក្រោយនៃការរំលាយអាហារចំពោះគោ



ពោះវៀនធំស្រូបទឹកពីកាកសំណល់
- ដំណាក់កាលចុងក្រោយកាកសំណល់ (លាមក) ត្រូវបានបញ្ចេញតាមទ្វារធំ ដែលសំបូរសារធាតុសរីរាង្គ អាសូត ផូស្វ័រ ប៉ូតាស្យូម និងស្ពាន់ធ័រដែលជាជីដ៏ល្អ។



- ប្រព័ន្ធរំលាយអាហាររបស់កូនគោ
  - បន្ទាប់ពីកើត អំឡុងពេលប៉ុន្មានអាទិត្យដំបូង ពោះធំ ពោះចក និង ពោះស្រទាប់ មិនទាន់វិវត្តនៅឡើយទេ។
  - ពោះកន្ត្រៀងជាផ្នែកដ៏សំខាន់របស់ក្រពះកូនគោ ពីព្រោះទឹកដោះចូលផ្ទាល់ទៅពោះកន្ត្រៀង។




- កូនគោនៅបៅដោះ ពោះធំមិនទាន់មាន ការលូតលាស់និងបំពេញមុខងាររបស់វាបាននៅឡើយ។
  - ពេលកូនគោចាប់ផ្តើមស៊ីគ្រាប់ធញ្ញជាតិស្មៅចំនួនមីក្រុបនឹងចាប់ផ្តើម មានក្នុងពោះធំ និង ពោះចក ។ ពោះធំ និងពោះចកចាប់ផ្តើមលូត លាស់និងបំពេញមុខងារបាន។

## ២-ប្រព័ន្ធដកដង្ហើម

- គោ ក្របីមានសួតតូច បើប្រៀបធៀបទៅនឹងសត្វដទៃដូចជាសត្វសេះ សួតស្ថិតនៅជ្រៅក្នុងប្រអប់ទ្រូងដូចនេះហើយគោក្របីងាយទទួលជំងឺដង្ហើម ពេលវីរុសឬបាក់តេរី ចូលក្នុងសួត ពីព្រោះមេរោគងាយស្រួលរស់នៅនិងបង្កជំងឺ។

| | មេគោ | សេះ |
|---|---|---|
| ចំណុះសួត | ១២,៤លីត្រ | ៤២លីត្រ |



◦ស្ងួតមានការខូចបន្តិចបន្តួចក៏អាចបណ្តាល ឲ្យមានបញ្ហាខ្លាំងដែរ។

◦ការដកដង្ហើមធម្មតាគឺ:

- សម្រាប់សត្វពេញវ័យ ពី១០ ទៅ ២០ ដង ក្នុង មួយនាទី
- សម្រាប់កូនគោពី១៥ ទៅ ៣០ ដងក្នុង មួយនាទី។

## ៣-ការបន្តពូជ

◦ជាធម្មតាសត្វអាចបន្តពូជបានចាប់ផ្តើមពីអាយុ ១.៥ឆ្នាំ ទៅ ៣ ឆ្នាំ។

◦ការពេញវ័យ គឺជាពេលវេលានៃការរកឈ្មោលលើកដំបូងរបស់សត្វ

◦ដើម្បីពិនិត្យពីការពេញវ័យរបស់-គោ មានកត្តាជាច្រើនគឺ: ការធំលូតលាស់ និង ទម្ងន់ដងខ្លួន លឿនជាងអាយុ ។

◦ចំណីអាហារមិនគ្រប់គ្រាន់ធ្វើឲ្យយឺតយ៉ាវដល់ការពេញវ័យរបស់គោ។

- **ការរកឈ្មោល**

មេគោចាប់ផ្តើមរកឈ្មោលដោយអូវែបញ្ចេញអូវុលទៅក្នុងបំពង់អូវុលហើយអូវុលអាចបង្កកំណើតជាមួយមេជីវិតរបស់គោឈ្មោល:




- ថ្ងៃទី ២ ទៅថ្ងៃទី៤ អង្គលឿងមានរូបរាង ហើយបញ្ចេញប្រូហេ្សស្តេរ៉ូន
- បើមិនមានការបង្កកំណើតទេ ពីថ្ងៃទី ៥ ទៅ ថ្ងៃ ទី១៧ អង្គលឿងនឹងបាត់ទៅវិញ
- ថ្ងៃទី២១ អូវុលថ្មីនឹងបញ្ចេញពីគ្រាប់ហ្វូលីគុលដែល ទុំ គឺជាពេលវេលានៃការរកឈ្មោលសារជាថ្មី



- បើគ្មានការបង្កកំណើត ការរកឈ្មោលសារជាថ្មី ជាមធ្យមគឺចាប់ពី ២០ ទៅ ២១ ថ្ងៃ ។ ចំពោះគោហ្សេប៊ុយ(Zebu)គឺចាប់ពី ១៧ ទៅ ២៤ ថ្ងៃ
- រយៈពេលនៃការរកឈ្មោលរបស់គោគឺមានតែប៉ុន្មានម៉ោងប៉ុណ្ណោះ ជាមធ្យមគឺ ១២ ម៉ោង ដូចនេះកសិករត្រូវប្រុងប្រយ័ត្នពីសញ្ញានៃការរកឈ្មោល
- សញ្ញានៃការរកឈ្មោល មានសារៈសំខាន់សម្រាប់កំណត់ពេលវេលាត្រឹមត្រូវដើម្បីបង្កាត់
- សញ្ញាទាំងនេះឃើញច្បាស់ចំពោះគោ:
    - លិទ្ធ និងត្រដុសសត្វផ្សេងទៀត
    - ហិតយោនីសត្វមួយទៀត
    - ឡើងពាក់មេគោផ្សេងទៀត
    - ឈរស្ងៀមរងចាំមេគោផ្សេងទៀតឡើងពាក់
    - ហូរទឹកថ្លាៗតាមយោនី។





- ពេលខ្លះមេគោមិនរកឈ្មោលបន្ទាប់ពីកើតកូនហើយឬរកឈ្មោលឡើងវិញដដែលៗ បន្ទាប់ពីបង្កាត់ក្នុងន័យនេះហៅថាការមិនផ្តល់កំណើត(គោអា)បញ្ហាចម្បង បណ្តាលមកពី:
    - លក្ខខណ្ឌរាងកាយមិនត្រឹមត្រូវ មេគោស្គមពេក និងអូវែ "ដេក"
    - ការចម្លងជំងឺពុំរ៉ៃលើស្បូនដែលជះឥទ្ធិពលដល់ការវិវត្តរបស់អំប្រីយ៉ុង និងសុក
    - ដុះសាច់ (គីស្ត)លើអូវែបង្កឲ្យមានបញ្ហាអរម៉ូន។

## ការបង្កាត់

ដើម្បីបង្កើនការបង្កកំណើត ត្រូវធ្វើការបង្កាត់ ចាប់ ពី ១២ ទៅ ២៤ ម៉ោង បន្ទាប់ពីមានសញ្ញានៃការរកឈ្មោលចាប់ផ្តើម។ ពេលវេលាល្អបំផុតម្រាប់បង្កាត់គឺ១៨ម៉ោង បន្ទាប់ពីការរកឈ្មោល។



- **ការផើម**

ការផើម គឺជាអំឡុងពេលចាប់ពីការបង្កកំណើត រហូតដល់ពេលកើត ក្នុងអំឡុងពេលផើម មេគោមិនរកឈ្មោលទេ។-រយៈពេលផើមគិតជាមធ្យមគឺប្រមាណ២៨៥ថ្ងៃ

- ដើម្បីកំណត់មេគោផើម: ត្រូវសង្កេតពីការមិនរកឈ្មោលឡើងវិញក្នុងរយៈពេល៣សប្តាហ៍បន្ទាប់ពីដាក់ឈ្មោលរួច
- មេគោផើមបាន ៧ ខែ ឃើញលេចចេញច្បាស់នៅផ្នែកខាងស្តាំ។



➢ សុក

| | |
|---|---|
| - សុកជាសរីរាង្គដែលមានទំនាក់ទំនង ជាមួយនឹងភ្នាសរបស់ស្បូន សម្រាប់ការលូតលាស់កូន<br>- កូនគោទទួលសារធាតុចិញ្ចឹមរាងកាយ បញ្ចេញ កាកសំណល់ និងផ្លាស់ប្តូរអុកស៊ីសែននិងឧស្ម័នកាបូនិច តាមរយៈឈាមមេ<br>- សត្វទំពារអៀងមានសុកកូទីលេដុង ប្រហែល ពី ៧៥ ទៅ ១២៥ ដុំ ដែលប៉ោងដូចជាកូនសុកជាច្រើន។ |  |
| - ជាធម្មតា សុកនឹងធ្លាក់ពី៦ ទៅ ១២ម៉ោង ក្រោយបន្ទាប់ពីកើតកូនរួច។ |  |

- **ការកើតកូន**

**ដំណាក់កាលទី១មានរយៈពេល ២ទៅ៦ម៉ោង:**



- មេគោនៅមិនស្ងៀម ពោះធ្លាក់ ស្បូនចាប់ផ្តើមកន្ត្រាក់
- បន្ទាប់មកថង់ទឹកភ្លោះ លេចចេញ។

**ដំណាក់កាលទី២មានរយៈពេល ១ទៅ២ម៉ោង:**



- មេគោដេកចុះ ចលនា កន្ត្រាក់ពោះកើនឡើង
- កូនគោចូលទៅក្នុងទីតាំង ដើម្បីកើតតាមស្ថានភាពធម្មតា
- មេគោប្រឹងសង្កត់ពោះយ៉ាងខ្លាំង ក្នុងពេលរុញកូនចេញផ្នែកក្បាល និងទ្រូង
- បន្ទាប់ពីនេះមេគោដកដង្ហើមខ្លីៗមុននឹងរុញ ជើងកូនចេញ។

**ដំណាក់កាលទី៣ចាប់ផ្តើមបន្ទាប់ពីកើត:**



- មេគោចាប់ផ្តើមលិទ្ធកូន បើមេគោមិនលិទ្ធកូន យើងត្រូវយកអំបិលលាបកូនគោដើម្បីឲ្យមេលិទ្ធ
- សុកធ្លាក់ពី ៦ ទៅ ១២ ម៉ោងក្រោយ បន្ទាប់ពីកើតកូនរួច។

- **ការផលិតទឹកដោះ**

- មុខងាររបស់ទឹកដោះគឺដើម្បីចិញ្ចឹមកូនគោដែលទើបកើត






- ជាលិកាក្រពេញនៅជ្រៅក្នុងកន្សោមដោះមានថង់តូចៗរាប់លានថង់ដែលហៅថា កូនថង់ទឹកដោះ។ចំណុះ១៥ សងទីម៉ែត្រ គូប នៃកន្សោមដោះមានកូនថង់ទឹកដោះប្រហែល ១លាន។

- រាល់ កូនថង់ទឹកដោះ មានកោសិកាផលិតទឹកដោះជាជួរ
- កោសិកាផលិតទឹកដោះស្រូបសារធាតុ ចិញ្ចឹម ពីឈាម និង ផលិតទឹកដោះ សំយោគខ្លាញ់ ប្រូតេអ៊ីន ស្ករ។
- ផ្នែកខ្លះរបស់ទឹកដោះដូចជា វីតាមីន រ៉ែមួយចំនួន ដែល មិនបានសំយោគ នៅក្នុងកូនថង់ទឹកដោះទេ ប៉ុន្តែ-ត្រូវបាន ច្រោះ-ពីឈាមចូលក្នុងទឹកដោះ។
- ការផ្តល់ឈាមយ៉ាងច្រើនទៅក្នុងកន្សោមដោះ ដើម្បីបានទឹក ដោះមួយលីត្រ ឈាមបានឆ្លងកាត់កន្សោមដោះ៤០០លីត្រ។
- រន្ធកូនថង់ទឹកដោះ ព័ទ្ធជុំវិញដោយកោសិកា សាច់ដុំដែលកន្ត្រាក់ កៀបកដោះពីរន្ធតូចៗ

  ឲ្យកូនបៅ ។

- ដោះរំញោចឲ្យទឹកដោះចេញ ការបញ្ចេញទឹកដោះមានរយៈ ពេលប្រហែល ៦ នាទីតែប៉ុណ្ណោះ។






ឈាមផ្តល់សារធាតុចិញ្ចឹមដល់ថង់តូចៗ









ទឹកដោះប្រមូលផ្តុំក្នុងរន្ធកូនថង់ទឹកដោះ ក្នុងបំពង់ទឹកដោះ និងថង់ទឹកដោះ ។ ពេលបំបៅដោះ ទឹកដោះ ចេញតាមបំពង់ក្បាលដោះ។







# ជំពូកទី៣៖ ការស្វែងយល់ អំពីជំងឺសត្វ និងសកម្មភាពរបស់ ភ្នាក់ងារសុខភាពសត្វភូមិ





# ការស្វែងយល់អំពីជំងឺសត្វ

និយមន័យអំពីសុខភាព និងជំងឺសត្វ:

១- សុខភាព គឺជាភាពសុខសាន្តលើរាងកាយ និងផ្លូវចិត្ត ធ្វើឲ្យការរស់រានមានជីវិត និងការលូតលាស់ធំធាត់បានល្អប្រសើរ និងជៀសផុតពីការរាតត្បាតនៃជំងឺផ្សេងៗ ព្រមទាំងពន្លឿននូវសក្តានុពល សម្រាប់ផលិតកម្ម និងបន្តពូជ។

២-ជំងឺ គឺជាភាពមិនប្រក្រតី ឬសភាពប្រែប្រួលខុសប្លែកពីធម្មតានៃរាងកាយ ដែលអាចបង្កឡើងពីការរាតត្បាតនៃមេរោគ ឬមកពីការប្រែប្រួលនៃបរិស្ថាន ចំណីអាហារ និងការរស់នៅ។ល។ ធ្វើឲ្យសត្វចុះខ្សោយកម្លាំង ផលិតផលសត្វថយចុះ ឬអាចបណ្តាលឲ្យសត្វងាប់បាន ។

## ក. មូលហេតុនៃការឆ្លងជំងឺ:

១- ភ្នាក់ងារចម្លងជំងឺ: វីរុស បាក់តេរី ផ្សិត ប្រូតូសូអ៊ែ
២- បរាសិត: ខាងក្នុង និងខាងក្រៅ
៣- កង្វះអាហារូបត្ថម្ភ
៤- ការឈឺចាប់ របួស និងពុល
៥-ការតានតឹងអារម្មណ៍






## ១. ភ្នាក់ងារចម្លងជំងឺ

### ១.១ វីរុស:

- វីរុស ជាមេរោគដ៏តូចបំផុត ដែលបង្កជំងឺ និងមិនអាចមើលឃើញដោយមីក្រូទស្សន៍ធម្មតាបានទេ។





ឧទាហរណ៍: វីរុសជំងឺអុតក្តាមអាចមើលឃើញ បានដោយមីក្រូទស្សន៍អេឡិចត្រូនិច (ទំហំរបស់វីរុស គឺប្រហែល០,០០០០០០៣ ម.ម)

- វីរុសមិនអាចលូតលាស់ ឬបន្តពូជក្រៅកោសិកាសត្វបានទេ។
- វីរុសរាតត្បាត លើកោសិការស់ និងបំបែកខ្លួន ព្រមទាំងបញ្ចេញសារធាតុគីមី ធ្វើឲ្យខូចខាត ឬបំផ្លាញកោសិការបស់សត្វ ដែលវាចម្លង។
- ពេលវីរុសនៅក្រៅខ្លួនសត្វ មិនអាចបំបែកខ្លួនបានទេ វាស្ថិតក្នុងសភាពនឹងថ្កល់ ប៉ុន្តែពួកវាអាចរស់បានច្រើនខែនៅក្នុងបរិយាកាស ដូចជាមេរោគជំងឺដង្កោរ អាចរស់នៅបានច្រើនអាទិត្យនៅក្នុងបរិយាកាសក្តៅ និងសើម និងនៅលើរោមបក្សី លាមក និងសម្ភារៈដទៃ
- សញ្ញាគ្លីនិកអាស្រ័យលើសរីរាង្គដែលវីរុសបានរាតត្បាត ឧទាហរណ៍ ជំងឺប៉េស្ត ដែលវីរុសរាតត្បាត និងធ្វើឲ្យខូចខាត កោសិការបស់សរសៃឈាមតូចៗធ្វើឲ្យបែកគ្រាប់ឈាមកក្នុងសរីរាង្គ ឬលើស្បែក។







ថ្នាំអង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាពប្រឆាំងវីរុសទេ។

### ១.២ បាក់តេរី

- បាក់តេរីជាមេរោគដែលអាចបង្កជំងឺ និងមិនអាចមើលឃើញដោយភ្នែកទទេបានទេ តែអាចមើលឃើញដោយមីក្រូទស្សន៍អុបទិច។ បាក់តេរីរស់នៅលើ ឬក្នុងគ្រប់សម្ភារៈនិងបរិស្ថាន។ ប៉ុន្តែបាក់តេរីចំនួនតិចតួចប៉ុណ្ណោះដែលជា ប្រភេទបង្កជំងឺ ក្នុងចំណោមបាក់តេរីរាប់លានប្រភេទ។ មានបាក់តេរី ដែលមានប្រយោជន៍រាប់លានកោដ នៅក្នុងពោះគោក្របីដែលចាំបាច់សម្រាប់ការចិញ្ចឹមរាងកាយ។



ពពួកស្ត្រិបតូកុកដែលមានរាងមូល

- បាក់តេរីមានកោសិកាតែមួយ និងមានទំហំ ជាមធ្យមប្រហែល ០,០០១ម.ម (ធំជាងវីរុស ៣០០០ដង)
- កោសិកាបាក់តេរីមានទម្រង់បីប្រភេទគឺ៖ រាងមូល(កុកស៊ី) រាងដំបង ដូចជា(បាក់ស៊ីលិស) និងរាងជាកង់ៗ ដូចរឺស័រ។



រាងដំបង(បាក់ស៊ីលីរបស់អឺកូលី

បាក់តេរីមានរចនាសម្ពន្ធ័គ្រឹះដូចគ្នា:

- ជញ្ជាំងកោសិកាមួយនិងភ្នាសស្រោបកោសិកាដែលអាចការពារ និងធ្វើឲ្យមានរូបរាង
- ស៊ីតូប្លាស: ជាសមាសធាតុម្យ៉ាងផ្សំឡើងដោយទឹកដែលផ្ទុកដោយសារធាតុចិញ្ចឹមបាក់តេរី
- ឧបករណ៍សេនេទិច (DNA) ដែលអណ្តែត ជុំវិញស៊ីតូប្លាស
- កន្ទុយធ្វើឲ្យវាបំលាស់ទីក្នុងបរិស្ថាន
- ភីលី(Pili) ជាប្រភេទរោមភ្ជាប់ទៅនឹងសរីរាង្គរបស់បាក់តេរី។






ពួកអឺកូលី

- បាក់តេរី ក៏ដូចជាកោសិកាដ៏ទៃទៀត ត្រូវការចំណីជាមូលដ្ឋាន ពួកបាក់តេរីត្រូវការប្រភពថាមពល អាសូត និងកាបូន (សារធាតុសរីរាង្គមានក្នុងកម្រាលទ្រុង សាកសពសត្វ សម្រាម ...ទាំងនេះអាចផ្តល់សារធាតុចិញ្ចឹម) ទឹក,សារធាតុដ៏ទៃទៀត និង អុកស៊ីសែនក៏ចាំ បាច់ផងដែរ។



- ការបន្តពូជរបស់បាក់តេរីធ្វើឡើងតាមការបំបែកខ្លួន: កោសិការីកធំធាត់ បង្កើត DNA ស្ទួនហើយនៅពេលដែលវារីកធំស្មើ ទំហំខ្លួនវាពីរដង វានឹងបំបែកចេញជាបាក់តេរីពីរដូចគ្នា។

ការបំបែកខ្លួនរបស់បាក់តេរី












បាក់តេរីអាចបង្កកំណើតយ៉ាងលឿន ឧទាហរណ៍ : អ៊ីកូលីអាចបំបែកខ្លួនរៀងរាល់ ២០នាទី ប្រសិនបើមានបាក់តេរីអ៊ីកូលីចំនួន ១០ នៅក្នុងបរិស្ថាន សមស្របសម្រាប់ការបំបែកខ្លួន ១២ ម៉ោងក្រោយអ៊ីកូលី នឹងមានចំនួន៦០០ពាន់លាន ដូចនេះការព្យាបាលជំងឺដែលបង្កដោយអ៊ីកូលី ត្រូវព្យាបាលឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ជាសំណាងល្អ បាក់តេរីជាច្រើនត្រូវងាប់ទៅវិញដោយ ប្រព័ន្ធរាងកាយសត្វ ប្រឆាំងនឹងបាក់តេរីទាំងនោះ។

មានបាក់តេរីមួយចំនួនដែលបង្កឲ្យមានជំងឺ។ គ្រប់សត្វ និងមនុស្សដែលបានឆ្លងដោយបាក់តេរី បាក់តេរីទាំងនោះរស់នៅលើរាងកាយ ស្បែក សួត ពោះវៀន ហើយបញ្ចេញបាក់តេរីទៅក្នុងបរិយាកាស ទឹក ដី និងចំណី។

ជាទូទៅសត្វមានអង្គបដិបក្ខ(អង្គទីគ័រ) ពីធម្មជាតិ ដូចនេះបាក់តេរីមិនសូវធ្វើឲ្យសត្វគ្រោះថ្នាក់នោះទេ។ ការចម្លងអាចមើលឃើញចំនុចតូចៗដែលកើតមានដោយការប្រយុទ្ធគ្នារវាងបាក់តេរី និងរាងកាយសត្វ នៅពេលដែលអង្គបដិបក្ខ(អង្គទីគ័រ)ពីធម្មជាតិរបស់សត្វចុះខ្សោយ ដោយសារស្ត្រេស ខ្សោយ អស់កម្លាំង បរាសិត ឬជំងឺដទៃទៀត.....ឬនៅពេលបាក់រីនៅក្នុងបរិស្ថានច្រើន សត្វឈឺបញ្ចេញបាក់តេរីនៅក្នុងក្រុមរបស់វា ឬនៅពេល បាក់តេរីមានសកម្មភាពខ្លាំង ការចម្លងខ្លាំង នោះការចម្លងនឹងចាប់ផ្តើមភ្លាម។

ជំងឺបង្កដោយបាក់តេរីកើតមាននៅពេលដែលវាចូលទៅក្នុងខ្លួន ការភ្ជាប់ទៅនឹងសរីរាង្គ រួចចាប់ផ្តើមបំបែកខ្លួន និងចូលទៅក្នុងឈាម។

**១.៣ ផ្សិត**

- ប្រភេទផ្សិតដែលបង្កឲ្យកើតជាជំងឺគឺជាពួកដែលមានសសៃជាលិកាច្រើន ដែលផ្សិតផ្សំឡើងដោយសសៃឆ្មារៗ អាចមើលឃើញពេលវាលូតលាស់ក្នុងកែវបណ្តុះ។





ក្រោមមីក្រូទស្សន៍ផ្សិតមានទំហំប្រហែល០,០០៥ម ម=ធំជាងបាក់តេរី៥ដង

- ផ្សិតមាននៅគ្រប់ទីកន្លែង ដែលធ្វើឲ្យសត្វអាចប្រឈមនឹងពួកផ្សិត។ ជាទូទៅ សត្វឈឺដែលបង្កឡើងដោយពពួកផ្សិត អាស្រ័យដោយសុខភាពសត្វចុះខ្សោយ ឬ ដោយសារមានជំងឺផ្សេងៗ ឬដោយភាពស៊ាំសត្វថយចុះ។





- ផ្សិត មានឈ្មោះថា អាស្ពែស៊ីលុស ដែលមានឥទ្ធិពល លើសុខភាពសត្វ:
  - តាមរយៈការលូតលាស់នៃមីកូតុកស៊ីន: អាផ្លាតុកស៊ីនមាននៅក្នុងវត្ថុធាតុដើមដែលដុះផ្សិតជាពិសេសពោត។ការឲ្យសត្វស៊ីវត្ថុធាតុដើម ទាំងនោះជាទៀតទាត់ ធ្វើឲ្យខូចថ្លើម និងបំផ្លាញ ភាពស៊ាំ (សមត្ថភាព ប្រឆាំងពួកមេរោគចុះខ្សោយ)

- តាមរយៈការចម្លងដោយកន្លែងៈ ស្រែងកើតលើស្បែកជ្រូកឬស្បែកគោ គឺជាការចម្លងដោយពពួកផ្សិត។



- ឬតាមរយៈការចម្លងជាលក្ខណៈប្រព័ន្ធ ជំងឺបង្កដោយពពួកផ្សិតលើកូនមាន់ជាជំងឺទូទៅ បន្ទាប់ពីវាលេបដោយពពួកផ្សិត។



## ២. បរាសិត

ពពួកបរាសិតដែលអាចរស់នៅក្នុងរាងកាយសត្វ ហៅថាបរាសិតខាងក្នុង ឬ រស់នៅខាងក្រៅលើស្បែក ឬក្នុងស្បែក ហៅថាបរាសិតខាងក្រៅ។ ជាទូទៅ បរាសិតមានគ្រោះថ្នាក់ដល់សុខភាពសត្វ ដូចនេះចាំបាច់ត្រូវត្រួតពិនិត្យជាប្រចាំ។

- **ឥទ្ធិពលរបស់បរាសិត**

  សត្វលូតលាស់យឺតដោយសារៈ

- បរាសិតខាងក្នុងស្រូបសារធាតុចិញ្ចឹមក្នុងចំណីនៅក្នុងពោះវៀនសត្វ
- បរាសិតខាងក្រៅបឺតឈាម ធ្វើឲ្យសត្វស្លេកស្លាំង ខ្សោយ ឬបង្កឲ្យសត្វរមាស់ និងដំបៅលើស្បែក។
- ជំងឺបង្កដោយបរាសិតខាងក្នុងមួយចំនួនអាចធ្វើឲ្យខូចសរីរាង្គខាងក្នុង ដូចជាថ្លើម ឬខូះមុខងាររបស់សរីរាង្គ ដែលធ្វើឲ្យកើតជាជំងឺរាក។





➢ **ការឆ្លងជំងឺ**

ពេលបរាសិតខាងក្រៅខាំសត្វ សត្វនោះអាចឆ្លងជំងឺឆ្លង។ឧទាហរណ៍ មូសខាំ ចម្លងជំងឺអុតបក្សី។


មូសចម្លងជំងឺអុត

➢ **វដ្តបរាសិត**

បរាសិតមានវដ្តជីវិត សម្រាប់ការបន្តពូជ មានតំណាក់កាលផ្សេងៗគ្នា គឺចាប់ពីស៊ុតរហូតដល់ពេញវ័យ:

- ស៊ុត



- កូនដង្កូវ



- ដង្កូវពេញវ័យ



- វដ្តរបស់បរាសិតអាចកើតមានដោយផ្ទាល់នៅក្នុងខ្លួនសត្វតែមួយ គឺគ្រប់តំណាក់កាលនៃការវិវត្តពីស៊ុតទៅពេញវ័យ ឧទាហរណ៍: វដ្តជីវិតរបស់ព្រូនអាស្ការីស។

វដ្តរបស់បរាសិតអាចកើតមានដោយមិនផ្ទាល់នៅពេលដែលការវិវត្តរបស់បរាសិតកើតមាននៅក្នុងខ្លួនសត្វពីរផ្សេងគ្នា ឧទាហរណ៍: វដ្តជីវិតរបស់ដង្កូវថ្លើម។

- **បរាសិតខាងក្រៅ**

អង្កែ ដង្កៃ ចៃ រុយ ជាបរាសិតខាងក្រៅ មានឥទ្ធិពលអាក្រក់លើសុខភាពសត្វបណ្តាលឲ្យ:

- ស្លាកស្នាមលើស្បែក: ធ្វើឲ្យរលាក រោលស្បែក រមាស់ខ្លាំង ធំលូតលាស់យឺត និងងាយឲ្យសត្វឆ្លងជំងឺផ្សេងទៀត។


ស្លាកស្នាមជាចំណុចក្រហមៗ និងការត្រដុស

- ការបាត់បង់ឈាម ដោយសារដង្កែបឺតឈាមដើម្បីចិញ្ចឹមខ្លួនវា។




ដង្កែញីមួយក្បាលបឺតឈាមបានរហូតដល់២ម.ល



-រំខានដល់ការសម្រាក ធ្វើឲ្យសត្វស្រេ្គស ជាពិសេសរុយពេលវាខាំមានចំនួនច្រើន។



- ការឆ្លងជំងឺ: បរាសិតខាងក្រៅជាភ្នាក់ងារចម្លង និងពេលខ្លះជាអ្នកផ្ទុកជំងឺផងដែរ។
- រុយទុំលើលាមកអាចនាំមេរោគអ៊ីកូលី សាល់ម៉ូណេឡា ឬកុកស៊ីឌីយ៉ា
- ដង្កែអាចចម្លងជំងឺដូចជាជំងឺបាបេស្យាអាណាផ្លាស្មា
- មូស ជាអ្នកចម្លងជំងឺអុត។

- **បរាសិតខាងក្នុង**

ព្រូនអាស្ការីស តុស្វូការរ៉ា ព្រូនក្រហម តេញ៉ា កុកស៊ីឌីយ៉ូស ជាបរាសិតខាងក្នុង។ សត្វដើររកស៊ីចំណីដោយសេរី ងាយឆ្លងចូលបរាសិតខាងក្នុង ព្រោះវាលេបស៊ុត និងកូនដង្កូវដែលមាននៅលើដី។

បរាសិតខាងក្នុងមានឥទ្ធិពលអាក្រក់ លើសុខភាពសត្វ បណ្តាលឲ្យ:

- ស្ថានភាពខ្លួនសត្វមិនល្អ បណ្តាលមកពីព្រូនស្រូបយកសារធាតុចិញ្ចឹមសំខាន់ៗ




- កូនគោនិងកូនក្របីអាចងាប់បណ្តាលមកពីព្រូនតុកស្វូការ៉ា
- បរាសិតខាងក្នុង អាចបំផ្លាញសរីរាង្គខាងក្នុងដូចជាថ្លើម ពោះវៀន សួត ដែលធ្វើឲ្យសត្វរាក និងក្អក

រាគបង្កដោយកុកស៊ីឌីយ៉ូស





- បរាសិតខាងក្នុងអាចឆ្លងទៅមនុស្ស និង ធ្វើឲ្យប៉ះពាល់ដល់សុខភាពមនុស្ស ដូចជាតេញ៉ា និង ទ្រីជីណេឡា។

## ៣. កង្វះអាហារូបត្ថម្ភ

ជំងឺមួយចំនួន កើតឡើងដោយសារកង្វះអាហារូបត្ថម្ភ ដូចជាកូនជ្រូកដែលមិនទទួលបានជាតិដែកគ្រប់គ្រាន់ធ្វើឲ្យសត្វស្លេកស្លាំង។ជាទូទៅរាល់កង្វះខាតចំណីអាហារធ្វើឲ្យសមត្ថភាពរបស់សត្វប្រឆាំងនឹងជំងឺថយចុះ ហើយប៉ះពាល់ដល់ការលូតលាស់ និងបន្តពូជ។

**សារធាតុចិញ្ចឹមចាំបាច់សម្រាប់សត្វឲ្យមានសុខភាពល្អ គឺ:**

### ៣.១ ទឹក



ចាំបាច់ត្រូវផ្តល់ទឹកស្អាតឲ្យបានគ្រប់គ្រាន់

ទឹកជាមូលដ្ឋាននៃសារធាតុរាវរបស់រាងកាយសត្វ:

- ឈាមរត់ត្រូវការជាតិទឹក ដើម្បីចលនាផ្លាស់ទី
- ការរំលាយអាហារត្រូវការជាតិសើមដើម្បីបំបែកចំណី
- ទឹកត្រូវការចាំបាច់ដើម្បីផលិតទឹកដោះនិងទឹកនោម



ការផ្តល់ទឹកមិនគ្រប់គ្រាន់ធ្វើឲ្យសត្វមិនឃ្លានចំណី បង្កើនគ្រោះថ្នាក់លើតំរងនោមធ្វើឲ្យរាងកាយមិនអាចបញ្ចេញជាតិពុលបាន។

### ៣.២ ថាមពល

- រាងកាយត្រូវការថាមពលដើម្បីទ្រទ្រង់ជីវិតនិងធ្វើសកម្មភាព
- ប្រភពថាមពលសំខាន់បានមកពីជាតិស្ករ (ឧទាហរណ៍ មើមដំឡូងមី សំបូរជាតិម្សៅ) ពីជាតិខ្លាញ់(ឧទាហរណ៍ កន្ទុកសំបូរជាតិប្រេង)
- ករណីខ្វះថាមពល សត្វនឹងប្រើខ្លាញ់បម្រុងរបស់វា និងធ្វើឲ្យវាស្រកទម្ងន់។



មេជ្រូកស្គមនៅពេលផ្តាច់ដោះ

ឧទាហរណ៍ មេជ្រូកក្នុងកំឡុងពេលបំបៅដោះត្រូវការថាមពលច្រើនដើម្បីផលិតទឹកដោះឲ្យកូនបៅ ប្រសិនបើស៊ីចំណីមិនបានគ្រប់គ្រាន់ទេជ្រូកស្គមនៅ



ប្រូតេអ៊ីនមិនគ្រប់គ្រាន់=កំណើនទម្ងន់យឺត

ពេលផ្តាច់ដោះ ព្រមទាំងមានបញ្ហាសុខភាពហើយការរកឈ្មោលលើកក្រោយត្រូវយឺតយ៉ាវច្រើនសប្តាហ៍។ ផ្ទុយទៅវិញ បើសត្វស៊ីចំណីមានថាមពលច្រើនពេកវាធាត់ខ្លាំងនឹងជួបបញ្ហាពេលក្រោកឈរ និងពិបាកកើតកូន។

## ៣.៣ ប្រូតេអ៊ីន


ប្រូតេអ៊ីន១៦%

- ប្រូតេអ៊ីនជាមូលដ្ឋានគ្រឹះសម្រាប់កសាងរាងកាយសត្វ
- ប្រូតេអ៊ីន កើតឡើងដោយសារអាស៊ីតអាមីណេ វាជាអ្នកផ្គត់ផ្គង់វត្ថុនានាដើម្បីបង្កើតជាលិការាងកាយ ជាពិសេសសាច់ដុំ
- ជ្រូកនិងបក្សីត្រូវការអាស៊ីតអាមីណេចាំបាច់ដូចជាលីស៊ីន មេទីយ៉ូនីន ដែលសារធាតុទាំងនេះ ត្រូវផ្តល់តាមរយៈចំណី ប៉ុន្តែសត្វពាហនៈអាចសំយោគ រាល់អាស៊ីតអាមីណេបាន


ចាក់ជាតិដែកនៅ២ថ្ងៃបន្ទាប់ពីកើត

- បក្សី និងជ្រូកត្រូវផ្តល់ប្រូតេអ៊ីនតាមរយៈចំណី (ម្សៅត្រីមានប្រូតេអ៊ីនច្រើន ជាង៥០% សណ្តែកសៀង៤០% ពោត៨% ស្រូវ២%) ប៉ុន្តែសត្វពាហនៈ អាចផលិតប្រូតេអ៊ីន ពីជាតិសសៃបាន
- កង្វះប្រូតេអ៊ីនធ្វើឲ្យសត្វធំធាត់យឺត ដោយសារសាច់ដុំមិនអាចលូតលាស់ និងការផលិតកម្មទឹកដោះថយចុះ ដែលធ្វើឲ្យ កូនជ្រូក និងកូនគោ ក្របីខ្សោយ។

## ៣.៤ សារធាតុរ៉ែ:

- កាល់ស្យូម ផូស្វ័រនិងម៉ង់កាណែសមានសារៈសំខាន់ក្នុងការផ្គត់ផ្គង់ ដើម្បីបង្កើតឆ្អឹង ធ្មេញនិងជាលិកា។ សារធាតុរ៉ែផ្សេងទៀតមានបរិមាណតិចតួចតែចាំបាច់សម្រាប់ដំណើរការរាងកាយ ឧទាហរណ៍ ជាតិដែក ចាំបាច់ណាស់ ត្រូវចាក់ឲ្យកូនជ្រូកទើបកើតដើម្បីការពារការស្លេកស្លាំង។



- កង្វះជាតិកាល់ស្យូម ធ្វើឲ្យឆ្អឹងសត្វក្មេងមិនលូតលាស់ ឬ សំបកស៊ុតស្តើង
- កង្វះជាតិផូស្វ័រ ធ្វើឲ្យសាច់ដុំខ្សោយ និងការបង្កកំណើតទាប។

### ៣.៥ វីតាមីន

វីតាមីន ជាសារធាតុសំខាន់ធ្វើឲ្យមានតុល្យភាពចំណីអាហារ និងមានមុខងារចម្បងបំលែងអាហារទៅជាថាមពល និងការប្រើប្រាស់សារធាតុចិញ្ចឹម។



តាមការពិតតម្រូវការវីតាមីនមានចំនួនតិចតួចតែប៉ុណ្ណោះ គេហៅថាជាសមាសធាតុត្រូសត្រាយផ្លូវ។

វីតាមីនមានមុខងារចាំបាច់បំផុត បើពិនិត្យលើទិដ្ឋភាពស្បែក មានន័យថាបើស្បែកមានពណ៌ស្រអាប់ មិនភ្លឺរលោង គឺសត្វខ្វះវីតាមីន តែបើសត្វមានស្បែកល្អ រោមភ្លឺរលោង បញ្ជាក់ថាសត្វមានសុខភាពល្អ និងការផ្តល់វីតាមីនបានគ្រប់គ្រាន់។

## ៤- សុខុមាលភាពសត្វ

### ៤.១ របួស

របួស ជាមូលហេតុចម្បងធ្វើឲ្យសត្វមានជំងឺ និងមានផលអាក្រក់លើសុខភាពសត្វទៅតាមស្ថានភាពផ្សេងៗគ្នា:



- **របួសលើស្បែក និងក្រោមស្បែក** បណ្តាលឲ្យមានមេរោគឆ្លងនៅលើកន្លែងនោះ។
  - មុខរបួស ជាសះស្បើយឡើងវិញ ត្រូវការពេលយូរ បើមិនបានព្យាបាលឲ្យបានត្រឹមត្រូវនោះទេ។
  - ការព្យាបាល ត្រូវកាត់រោមជុំវិញដំបៅ រួចដុសលាងសម្អាតជាមួយទឹក និងសាប៊ូ ជារៀងរាល់ថ្ងៃ បើដំបៅខ្លាំងក្លា ត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិក ដែលមានសកម្មភាពវែង។

- **ការឆ្លងចូលមេរោគ តាមរយៈ**

- **ការខាំ:** ត្រូវប្រុងប្រយ័ត្ននិងស្វែងយល់ពីគ្រោះថ្នាក់នៃជំងឺឆ្កែឆ្កួត នៅពេលសត្វត្រូវបានឆ្កែខាំ។

- បច្ចេកទេសមិនត្រឹមត្រូវ ពេលខ្លះមេរោគអាចឆ្លងចូលក្នុងខ្លួនសត្វ ដោយសារការអនុវត្តន៍ មិនបានត្រឹមត្រូវដូចជារបួសឬដំបៅបន្ទាប់ពីការចាក់ថ្នាំ ការកាត់ធ្មេញ កាត់កន្ទុយ។ល។

- **ដំបៅ:** មេរោគផ្សេងៗឆ្លៀតឱកាសជ្រាតចូលក្នុងខ្លួនសត្វតាមមុខរបួសលើស្បែក ឬភ្នាសស្តើង និងបង្កជំងឺទូទៅ ដូចជាស្រ្តិបតូកុក តេតាណូស។ល។

ចាក់ថ្នាំខុសកន្លែង+ម្ជុលមិនស្អាត=បូស(abcess)





កម្រាលមិនល្អធ្វើឲ្យមានដំបៅលើជង្គង់=ងាយស្រួលជ្រាបចូលពីពពួកស្រ្តិបតូកុក

- **ការឈឺចាប់**

ការឈឺចាប់ជាច្រើនថ្ងៃធ្វើឲ្យការស៊ីចំណី និងផឹកទឹកថយចុះ បណ្តាលឲ្យសត្វចុះខ្សោយ និងងាយទទួលជំងឺផ្សេងៗ

- ការឈឺកែងជើង: ឈឺចាប់នៅសន្លាក់ឬលើជើង ធ្វើឲ្យសត្វពិបាកដើរទៅផឹកទឹកនិងស៊ីចំណីបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរដល់សុខភាពសត្វ។



- ភ្នែក: ដំបៅលើភ្នែក ឬរបួសលើកែវភ្នែក ឬលើភ្នាសស្តើងភ្នែកក្រហម និងមានហូរទឹកភ្នែកគឺជាសញ្ញានៃការបុករបស់អ្វីមួយដែលធ្វើឲ្យសត្វឈឺចាប់ខ្លាំង ហើយមិនចង់ដើរ។ ជាការចាំបាច់ត្រូវចាក់ថ្នាំបន្ថយ ការឈឺចាប់ ដូចជាថ្នាំប៉ារ៉ាសេតាម៉ុល ឬផេនីលប៊ុយតាសូន ។

## ៤.២ ថ្នាំពុល ឬសារធាតុពុល

គ្រោះថ្នាក់នៃការពុលកើតមានខ្ពស់ចំពោះសត្វដើរស៊ីដោយសេរី ការពុលជាទូទៅបង្កឡើងដោយ៖



➢ ការពុលដោយជីអ៊ុយរេ: គោស៊ីជីអ៊ុយរ៉េ ដែលនៅសល់ក្នុងបាវ។ រោគសញ្ញារួមមាន៖

- ហើមពោះខ្លាំង
- កន្ត្រាក់សាច់ដុំធ្វើឲ្យសត្វបាត់បង់ជំហរ ដើរដូចស្រវឹង
- ងាប់ក្នុងកំឡុងពេល២ម៉ោង

ត្រូវការព្យាបាលជាបន្ទាន់ ដោយប្រើទឹកខ្មេះលាយទឹក ២-៥លីត្រឲ្យសត្វផឹក។

➤ ពុលដោយថ្នាំសំលាប់សត្វល្អិត:
រោគសញ្ញា គឺសត្វចេញទឹកមាត់ខ្លាំង (មិនអាចច្រលំជាមួយជំងឺអុតក្តាមទេ ព្រោះវាមានសភាពស្រួចស្រាវជាង) សត្វនៅមិនសុខ អស់កំលាំង អាចងាប់បើវាស៊ីថ្នាំនោះច្រើន។ ត្រូវព្យាបាលដោយចាក់ថ្នាំអាត្រូពីន (Atropine) ចាក់សាច់ដុំ។



➤ រុក្ខជាតិមួយចំនួនមិនប្រាកដជាធ្វើឲ្យសត្វពុលទេ ប៉ុន្តែវាបង្កឲ្យរលាករោល នៅប្រទេសយើងច្រើនកើតការរលាករោលដោយពន្លឺថ្ងៃ។ បន្ទាប់ពីស៊ីចំរុក្ខជាតិខ្លះ ហើយវានៅក្រោមកម្តៅថ្ងៃខ្លាំង គោអាច បង្ហាញស្លាកស្នាមដំបៅលើស្បែកដែលអាចធ្វើឲ្យកាន់តែធ្ងន់ធ្ងរ។ នៅពេលដែល រោគសញ្ញាលេចឡើង ត្រូវទុកគោឲ្យនៅក្នុងម្លប់និងចាក់ថ្នាំដិចសាមេតាសូន។



## ៥- ស្ត្រេស

ស្ត្រេស ជាលក្ខខណ្ឌកើតឡើងនៅពេលដែលការគ្រប់គ្រងមិនបានត្រឹមត្រូវ និងបរិស្ថានមិនអំណោយផល ដែលធ្វើឲ្យភាពស៊ាំរបស់សត្វចុះខ្សោយ និងងាយរងនូវជំងឺផ្សេងៗ។

ឥទ្ធិពលរបស់ស្ត្រេសមានច្រើន ប៉ុន្តែអ្វីដែលសំខាន់នោះគឺ៖

- បន្ទាប់ពីផ្តាច់ដោះក្នុងអំឡុង១០ថ្ងៃដំបូង កូនជ្រូកងាយរងនូវជំងឺផ្សេងៗដូចជា រាគ ក្អក និងស្រកទម្ងន់។ល។ អាស្រ័យដោយការផ្លាស់ប្តូរចំណី ការផ្លាស់ប្តូរទីកន្លែង ទ្រុងថ្មី ការខាំគ្នាជា មួយកូនជ្រូកដទៃ។ ដូចនេះ ត្រូវផ្តល់ថ្នាំអង់ទីប៊ីយ៉ូទិកលាយក្នុងចំណីឲ្យកូនជ្រូកទើបផ្តាច់ដោះ។
- ចំនួនសត្វច្រើនហួស និងគ្មានផាសុខភាព
- សីតុណ្ហភាពប្រែប្រួលខ្លាំង ដូចជា ពេលថ្ងៃក្តៅខ្លាំង ហើយពេលយប់ត្រជាក់ខ្លាំង ធ្វើឲ្យសត្វងាយឆ្លងលើប្រព័ន្ធដង្ហើម និងស្ត្រេស ដោយសារមិនអាចសម្របទៅនឹងការផ្លាស់ប្តូរបរិយាកាសច្រើនលើកក្នុងមួយថ្ងៃ។



មាន់មានកន្លែងគ្រប់គ្រាន់ដើម្បីដើរ ក្រាបដេក ប្រកបដោយផាសុខភាព

- ការផ្លាស់ប្តូរទៅទ្រុងថ្មី វាធ្វើឲ្យសត្វស្ត្រេសខ្លាំង ឧទាហរណ៍ការប្តូរមេជ្រូកទៅកាន់ទ្រុងកើតកូន មេជ្រូកស៊ីតិច មិនចង់ក្រោកឈរ ហើយច្រើនកើតបញ្ហាក្តៀន។
- ការដាក់សត្វចូលគ្នា ហើយខាំគ្នា ជាទូទៅកើតចំពោះកូនជ្រូកពេលផ្តាច់ដោះ ឬចាប់ផ្តើមបំប៉ន។
- កសិករដាក់ជ្រូកដែល មានទំហំប៉ុនៗគ្នានៅក្នុងទ្រុងតែមួយ ដែលយកមកពីសំបុកផ្សេងៗគ្នា វានឹងខាំគ្នា បណ្តាលឲ្យស្ត្រេស ធ្វើឲ្យវាស៊ីចំណីតិច និងស្រកទម្ងន់
- ចំណីមិនគ្រប់គ្រាន់ និងចំណីខ្វះគុណភាព ដែលសត្វមានអារម្មណ៍ឃ្លានចំណីខ្លាំង ក៏ជាមូលហេតុស្ត្រេសផងៗ



ការខាំគ្នាធ្វើឲ្យវាឈឺ ចាប់មានការចម្លងតាមស្បែកនិងស្ត្រេសខ្លាំង



តើគោនេះរីករាយឬទេ?

## ខ. ការរាតត្បាតនៃជំងឺ

### ១. តើភ្នាក់ងារចម្លងជំងឺរាតត្បាតយ៉ាងដូចម្តេច?

តើជំងឺអាចចូលទៅក្នុងកសិដ្ឋាន ឬភូមិមួយយ៉ាងដូចម្តេច?

ប្រសិនបើយើងដឹងពីវិធីផ្សេងៗដែលធ្វើឲ្យជំងឺរាតត្បាត យើងអាចកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងទៅកាន់កសិដ្ឋាន ឬភូមិបាន។

➢ **សត្វឈឺ:** មេរោគរាតត្បាតតាមរយៈ៖
- លាមក
- ទឹកសំបោរ: មានន័យថានៅពេលមានការប៉ះពាល់ជិតស្និតជាមួយសត្វឈឺវីរុស បាក់តេរី ផ្សិត ឬ បរាសិត ត្រូវបានឆ្លងចូល ទៅសត្វមានសុខភាពល្អ នឹងធ្វើឲ្យសត្វឈឺ។

➢ **ការសម្ងំនៃមេរោគ:** ជាពេលវេលាដែលសត្វត្រូវបានឆ្លងជំងឺ រហូតដល់ការបង្ហាញរោគសញ្ញាជាលើកដំបូង។ ក្នុងដំណាក់កាលសម្ងំនៃមេរោគ សត្វហាក់ដូចជាមានសុខភាពល្អប៉ុន្តែបញ្ចេញវីរុស និងចម្លងទៅសត្វដទៃ។

ត្រឡប់មកពីផ្សារដោយយកមាន់មកជាមួយ មាន់មើលទៅហាក់មានសុខភាពល្អ តើអ្នកប្រាកដទេថាមាន់មិនផ្ទុកជំងឺញូវកាស ឬផ្តាសាយបក្សី?



➤ មនុស្សអាចនាំ និងបញ្ជូនមេរោគតាមរយៈ៖
- ស្បែកជើងពាក់ប្រឡាក់ជាប់ដី ឬលាមកបក្សី ដែលមានមេរោគ ត្រឡប់មកកាន់ផ្ទះវិញ ហើយអាចចម្លងទៅមាន់របស់ពួកគាត់។
- ស្បែក ជាពិសេសស្បែកដៃដែលមានកំដៅ សមល្មម និងសំណើម ជាបរិយាកាសល្អ បំផុតសម្រាប់មេរោគលូតលាស់។ ពេលប៉ះ សត្វ ឬសម្ភារៈ ដៃរបស់យើងបាននាំមេរោគ តាមរយៈ ទឹកសំបោរ លាមកជាដើម ដូចនេះ ត្រូវលាងដៃជាមួយទឹក នឹងសាប៊ូដើម្បីឲ្យដៃ ស្អាត។




➤ **រថយន្ត និងសម្ភារៈប្រើប្រាស់៖**
- កង់រថយន្តប្រឡាក់ ជាពិសេសលាមក និង សារធាតុសរីរាង្គពីកសិដ្ឋាន ដែលអាចឆ្លង ពីកសិដ្ឋានមួយទៅកសិដ្ឋានមួយ។ សម្ភារៈប្រើប្រាស់ ដូចជាផ្លា កញ្ច្រែងដាក់ស៊ុត អាចចម្លងនៅពេលយកត្រឡប់ពីផ្សារវិញ ឬ ស្នូកទឹក ស្នូកចំណីនៅពេលដែលទិញពី កន្លែងលក់ ដែលប៉ះពាល់ដោយអ្នកចិញ្ចឹមជា ច្រើននៅទីនោះ។



កង់ផ្ទុកមេរោគពីកសិដ្ឋានមួយទៅកសិដ្ឋានមួយទៀត

➤ **សត្វចង្រៃ**
- សត្វល្អិត ជាភ្នាក់ងារចម្លងជំងឺដូចជា មូស ចម្លងជំងឺអុត។
- សត្វកកេរ ចម្លងជំងឺសាល់ម៉ូណែឡា អ៊ីកូលី និងធ្វើឲ្យចំណីនិងទឹកកខ្វក់។ សត្វកកេរជា អ្នកផ្ទុកជំងឺឡិបតូស្ពីរ៉ូ ដែលចម្លងមកកាន់ មនុស្ស និងសត្វ។



➢ **ទឹក**

ទឹកជាកត្តាសំខាន់ក្នុងការចម្លងជំងឺផ្តាសាយបក្សី។ បក្សីទឹកដូចជាទា មើលទៅមានសុខភាពល្អ ប៉ុន្តែវាបញ្ចេញវីរុសយ៉ាងច្រើនក្នុងទឹក។ វីរុសអាចរស់នៅបាន ច្រើនថ្ងៃក្នុងទឹក ហើយអាចឆ្លងទៅសត្វពេលប្រើប្រាស់ទឹកនោះ។



ទាហាក់ដូចជាមានសុខភាពល្អ តែវាបញ្ចេញមេរោគ H5N1

មេរោគជំងឺផ្តាសាយបក្សីអាចរស់បានច្រើនថ្ងៃនៅក្នុងទឹក

## ២. មូលដ្ឋានគ្រឹះនៃជីវសុវត្ថិភាព

នៅពេលយើងដឹងពីរបៀបនៃការរាតត្បាតជំងឺ ចាំបាច់ត្រូវអនុវត្តឲ្យបានល្អនូវវិធានជីវសុវត្ថិភាពដើម្បីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីជំងឺនោះ។ ប្រាកដណាស់ថា ជីវសុវត្ថិភាពមានភាពងាយស្រួលអនុវត្តនៅក្នុងកសិដ្ឋានពាក់កណ្តាលឧស្សាហកម្ម ដែលសត្វត្រូវបានដាក់ក្នុងទ្រុង ជាងនៅក្នុងភូមិដោយសត្វលែងឲ្យដើរសេរី។

➢ ការការពារការឆ្លងជំងឺពីសត្វឈឺ

- គ្រោះថ្នាក់ខ្ពស់ ពេលទិញមាន់ ទា ឬកូនជ្រូក ដែលមិនដឹងប្រភពច្បាស់លាស់។
- ត្រូវទិញសត្វមានសុខភាពល្អ។ ការទិញសត្វ ដែលមានសភាពមិនល្អដើម្បីបាន
- តំលៃថោក មិនជាការត្រឹមត្រូវទេ។
- បង្ខាំងសត្វទើបទិញថ្មីទោះបីមើលទៅវាមានសុខភាពល្អក៏ដោយ ព្រោះអាច មានមេរោគសម្ងំ។

  រយៈសម្ងំជំងឺអាចពី២ទៅ១៥ថ្ងៃ។ បើអ្នកបង្ខាំងសត្វ១៤ ថ្ងៃ ដើម្បីពិនិត្យមើលសុខភាពសត្វ ប្រសិនបើសត្វឈឺ ក៏មិនអាចចម្លងទៅសត្វដទៃទៀតក្នុងកសិដ្ឋាននោះទេ។



ទ្រុងដាច់ដោយឡែកផ្តល់ភាពងាយស្រួលក្នុងការបំបែកជ្រូកទើបទិញ



មាន់បំបែកដាក់ក្នុងទ្រុងបែបប្រពៃណី ដាក់នៅកន្លែងឆ្ងាយនិងស្អាត

➢ គ្រោះថ្នាក់ខ្លាំងនៅពេលដាក់បាផ្ទាល់ ព្រោះយើងមិនដឹងសុខភាពបាវាយ៉ាងណា និងបានពាក់មេនៅកន្លែងណាពីមុននេះ។ ដូចនេះ ត្រូវអនុវត្តការបង្កាត់ដោយសិប្បនិម្មិត ព្រោះមេជ្រូកមិនប៉ះពាល់ផ្ទាល់ជាមួយបា ។


បំពង់តូចនេះផ្ទុកទឹកកាមដែលយកពីបា

➢ គោអាចបញ្ចេញពងបរាសិតដោយគ្មានរោគសញ្ញា។ នៅពេលកសិករទិញគោចាំបាច់ត្រូវទម្លាក់បរាសិត(មើលក្នុងជំពូកទី៩បរាសិត)។



➢ ការការពារការរាតត្បាតមេរោគតាមរយៈមនុស្ស : ត្រូវកំហិតការចូលមើលកសិដ្ឋាន ឬកន្លែងចិញ្ចឹម។ កសិករ ភ្នាក់ងារសុខភាពសត្វភូមិ បសុពេទ្យ ម្ចាស់សត្វ ម្ចាស់កសិដ្ឋាន ឬម្ចាស់កន្លែងចិញ្ចឹម ដែលមកពីផ្សារ ជាមនុស្សដែលមានគ្រោះថ្នាក់ព្រោះពួកគាត់ មកពីកន្លែងដែលមានមេរោគប្រមូលផ្តុំ។ ដូចនេះត្រូវ:

- លាងដៃគឺជាការសំខាន់ព្រោះស្បែកដៃក្តៅនិងសើមជាមជ្ឈដ្ឋានល្អសម្រាប់ការលូតលាស់របស់មេរោគ
- អ្នកដទៃ ហាមចូលដោយគ្មានការអនុញ្ញាត ជាពិសេសឈ្មួញទិញសត្វ ត្រូវរង់ចាំច្រកចូលខាងក្រៅកសិដ្ឋាន/ផ្ទះ
- ភ្នាក់ងារសុខភាពសត្វភូមិ បសុពេទ្យ ត្រូវផ្លាស់ប្តូរសម្លៀកបំពាក់ និងស្បែកជើងមុនពេលចូល និងចេញពីកសិដ្ឋាន/ផ្ទះ ។



➢ ការការពារ ការរាតត្បាតមេរោគ ដោយរថយន្ត និងសម្ភារៈប្រើប្រាស់:

- ម៉ូតូ រថយន្តដែលមកពីផ្សារ លក់សត្វ/កន្លែងចិញ្ចឹមសត្វ ត្រូវលាងសម្អាត
- គ្រប់មធ្យោបាយធ្វើដំណើរ ហាមចូលកន្លែងចិញ្ចឹមសត្វ ដោយគ្មានការអនុញ្ញាត

មាន់ត្រូវបានប្រមូល និងដាក់ក្នុងទ្រុងដោយម្ចាស់ ហើយឈ្មួញមិនត្រូវចូលក្នុងកសិដ្ឋានទេ



- ស្នូកទឹក ចំណីដែលទិញមកពីកន្លែងលក់ត្រូវលាងនិងរម្ងាប់មេរោគមុនប្រើ ព្រោះមានកសិករជាច្រើនត្រូវបានប៉ះពាល់នៅទីនោះ ហើយនាំមេរោគទៅជាមួយ



ទើបមកពីផ្សារ នេះជាការអនុវត្ត មិនត្រឹមត្រូវ



ទើបមកពីផ្សារ នេះជាការអនុវត្តត្រឹមត្រូវ

- ចាំបាច់ត្រូវលាងស្នូកទឹក ចំណីឲ្យទៀងទាត់ដើម្បីការពារការរីកលូតលាស់នៃមេរោគក្នុងចំណីដែលសល់។



ដុះលាងជាមួយសាប៊ូ និងច្រាស់



ធ្វើការរម្ងាប់មេរោគ



ហាលស្នូកទឹក ស្នូកចំណី

➢ **ការពារសត្វចង្រៃ**

- **សត្វកកេរ** សំខាន់ត្រូវត្រួតពិនិត្យកណ្ដុរជាប្រចាំ ។
- **សត្វល្អិត** ចំនួនរុយនិងមូសអាស្រ័យលើ ការសម្អាត និងការធ្វើអនាម័យ
  - ចាំបាច់ត្រូវត្រួតពិនិត្យកន្លែងរុយរស់នៅ។ រុយពេញវ័យមួយក្បាលពងបាន ៥០០ស៊ុត ហើយវដ្តពេញវ័យ មានរយៈពេលតែ៨ថ្ងៃ។ ដូចនេះត្រូវប្រមូល និងសម្ងួតលាមក សម្អាតកម្ទេចចំណីនៅក្នុងទ្រុង លាងសម្អាតស្នូកទឹកចំណីគឺជាវិធានការដ៏មានប្រសិទ្ធភាព
  - ដើម្បីបំបាត់មូសចាំបាច់ ត្រូវកាត់ស្មៅជុំវិញរោងចិញ្ចឹម លុបថ្លុក ឬក្រឡុក មិនឲ្យមានដក់ទឹកកខ្វក់។



ឆ្មាកំចាត់កណ្ដុរប៉ុន្តែវាអាច ពាំនាំមេរោគទៅចំណី




រ៉ាកូមិនសម្លាប់កណ្ដុរ៥ទៅ៧ ថ្ងៃបន្ទាប់ពីវាស៊ី



ដង្កូវ



រុយពេញវ័យ ទំលើលាមក

➢ ជាទូទៅអនាម័យ មានសារសំខាន់ក្នុងការ ការពារសត្វចង្រៃ និងការបំបែកខ្លួនរបស់មេរោគ ។ ទីកន្លែងសើម និងក្តៅល្មមដែលមានសារធាតុកខ្វក់ជាមជ្ឈដ្ឋានដ៏ល្អសម្រាប់ការលូតលាស់របស់មេរោគ។

ការសម្អាតភូមិ ជាប្រចាំបានបង្ហាញថា អត្រាឈឺ ងាប់របស់សត្វមានការថយចុះគួរឲ្យកត់សម្គាល់។










- ការការពារការឆ្លងទៅក្នុងទឹក

- ទឹកបូមពីអណ្តូងដាក់ក្នុងពាង ឬធុងត្រូវគ្របនិងដាក់ក្លរីន (chlorine) ដើម្បីសម្លាប់វីរុស និងបាក់តេរី។ ទឹកថ្លាហើយស្អាតដោយដាក់ក្លរីនក្នុងទឹករយៈពេល២០នាទី មុនពេលយកមកប្រើ។




## ៣. ការរំងាប់មេរោគ

អ្វីជាថ្នាំរំងាប់មេរោគ?

ថ្នាំរំងាប់មេរោគជាសារធាតុគីមីដែលអាចសម្លាប់មេរោគ(បាក់តេរី វីរុស និងផ្សិត)។ថ្នាំរំងាប់មេរោគមាននៅលើទីផ្សារ និងអាចជ្រើសរើសបាន អាស្រ័យលើកំហាប់(0.៥% ...) និងប្រសិទ្ធភាពរបស់វាស្របតាមគោលបំណងដែលចង់បាន

ថ្នាំសម្លាប់មេរោគត្រូវបាញ់នៅតែកន្លែងស្អាតតែប៉ុណ្ណោះ



- **ប្រភេទថ្នាំរំងាប់មេរោគ ដូចជា:**

  -**អ៊ីយ៉ូឌីន** (Iodine) ជាថ្នាំរំងាប់មេរោគដ៏ល្អ និងមិនធ្វើឲ្យមានគ្រោះថ្នាក់ ប៉ុន្តែការប្រើលើកាកសំណល់មិនមាន ប្រសិទ្ធភាព និងបាត់បង់ប្រសិទ្ធភាពបើប្រើក្រោមកំដៅថ្ងៃ

  - **កំបោររស់** វាមានប្រសិទ្ធភាពលើសារធាតុសរីរាង្គហើយអាចកម្ទេចកាកសំណល់ និងមេរោគ ប្រើសម្រាប់ដាក់លើសាកសព(ក្រោមលក្ខខ័ណ្ឌសំណើម)

- **របៀបរំងាប់មេរោគ**

  បាញ់ថ្នាំរំងាប់មេរោគនៅកន្លែងស្អាត

- បើកន្លែងកខ្វក់ត្រូវសម្អាតជាមុន ដូចជា:
  - ប្រមូលកាកសំណល់ចេញ ដូចជាកម្ទេចកំទី លាមក ចំបើង ចំណី ។ល។

  ត្រាំទឹកលាងជាមួយសាប៊ូដុសច្រាស់បាញ់ទឹកសម្អាត និងទុកឲ្យស្ងួតមុនរំងាប់មេរោគ។

- ត្រូវលាយល្បាយថ្នាំរំងាប់មេរោគឲ្យបានត្រឹមត្រូវ
- បរិមាណថ្នាំរំងាប់មេរោគ ត្រូវគណនាលើទំហំដីត្រូវបាញ់ថ្នាំរំងាប់មេរោគ
- ត្រូវមានសម្ភារៈបរិក្ខាឲ្យបានគ្រប់គ្រាន់។

ចំណាំ ត្រូវថែទាំសុខភាពអ្នក ព្រោះគ្រប់សារធាតុទាំងអស់សុទ្ធតែពុលហើយ គ្រោះថ្នាក់នៅពេលវានៅសុទ្ធ មានន័យថា ពេលមិនទាន់លាយ។

## (ដាក់ក្នុងជំនួយស្មារតី) សកម្មភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ

សកម្មភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិពេលទៅពិនិត្យសត្វឈឺមាន៦ដំណាក់កាល:

១- ពិនិត្យកន្លែងសត្វរស់នៅ

២- សួរម្ចាស់សត្វ អំពីបញ្ហាដែលកើតឡើងចំពោះសត្វរបស់គាត់

៣- វាស់កម្ដៅសត្វ

៤- ពិនិត្យរោគសញ្ញាលើខ្លួនសត្វ

៥- ធ្វើសេចក្ដីសន្និដ្ឋាន លើមូលហេតុនៃជំងឺ

៦- ជ្រើសរើសយកវិធីព្យាបាល ដើម្បីឲ្យសត្វបានជាសះស្បើយឡើងវិញ។



១- ពិនិត្យកន្លែងសត្វរស់នៅ:

- កន្លែងមានអនាម័យឬទេ?
- កន្លែងចង្អៀតឬទេ?
- ក្តៅពេក ឬត្រជាក់ ឬសើម
- ប្រមើលមើលពីចរិតលក្ខណៈរបស់សត្វសប្បាយចិត្តឬទេ?
- សត្វអាចឆ្លងជំងឺពីសត្វផ្សេងឬទេ?។

២- សួរម្ចាស់សត្វ អំពីបញ្ហាដែលបានកើតឡើងចំពោះសត្វរបស់គាត់:

-សួរព័ត៌មានពីសត្វឈឺ និងសត្វផ្សេងទៀត

- មេដើមឬមេបំបៅកូន?
- អាយុប៉ុន្មាន?
- សត្វស៊ីចំណីឬទេ?
- សត្វចាប់ឈឺប៉ុន្មានថ្ងៃហើយ?
- ក្រៅពីនេះ តើម្ចាស់សត្វបានឃើញអ្វីខ្លះ?
- តើបានព្យាបាលឬទេ? ហើយព្យាបាលតាមវិធីណា? ថ្នាំបូរាណឬថ្នាំសម័យ?



- បើថ្នាំសម័យ ប្រើថ្នាំអ្វីខ្លះ? តើប្រើចាប់តាំងពីពេលណា?
- តើសត្វផ្សេងទៀតក្នុងហ្វូងជាមួយគ្នាមានឈឺដែរឬទេ?
- តើសត្វផ្សេងទៀតក្នុងភូមិជាមួយគ្នាឬភូមិផ្សេងមានឈឺដែរឬទេ?។



៣- វាស់កម្តៅសត្វ:

- កម្តៅធម្មតារបស់គោ ក្របី ៣៨-៣៩ អង្សាសេ
- កម្តៅធម្មតារបស់ជ្រូក ៣៨.៥-៣៩.៥ អង្សាសេ
- កម្តៅធម្មតារបស់មេជ្រូកកើតកូន ឬកំពុងបំបៅកូន ៣៩-៤០ អង្សាសេ។ ការវាស់កម្តៅសត្វមានសារសំខាន់ណាស់ សម្រាប់ជាមូលដ្ឋានលើការធ្វើរោគវិនិច្ឆ័យ។

ប្រសិនសត្វឡើងកម្តៅអាចសង្ស័យមានមេរោគកំពុងរាតត្បាតក្នុងខ្លួនសត្វ តែផ្ទុយទៅវិញ ខ្លួនសត្វអាចឡើងកម្តៅ នៅពេលធ្វើការច្រើន ឬសត្វនៅក្រោមកម្តៅថ្ងៃ ដូចនេះជាការប្រសើរ ពេលវាស់កម្តៅសត្វ ត្រូវឲ្យសត្វសម្រាកក្រោមម្លប់ត្រជាក់។
ដោយឡែកមាន់ឬបក្សីផ្សេងទៀតមានកម្តៅក្នុងខ្លួនខ្ពស់ដូចនេះមិនចាំបាច់វាស់កម្តៅវទេ។

## ៤- ការពិនិត្យរោគសញ្ញា

ក្រោយពេលវាស់កម្តៅរួច ត្រូវពិនិត្យឲ្យបានច្បាស់លាស់ លើឥរិយាបទ ចរិត ចលនា និងសញ្ញាដែលមាននៅលើដងខ្លួនសត្វឲ្យបានច្បាស់លាស់ ក្រៅពីនេះត្រូវពិនិត្យផ្នែកខាងក្រៅរបស់សត្វ តាមលំដាប់លំដោយដូចខាងក្រោម:

➢ **ពិនិត្យច្រមុះ**
- តើសត្វមានហៀរសំបោរ ឬទឹករំអិល ឬខ្ទុះ ឬទេ?
- មានពងដោរឬពងបែកលើច្រមុះឬទេ?
- មានធំក្លិនស្អុយខុសប្លែកពីធម្មតាឬទេ ពេលសត្វដកដង្ហើម?


គោកើតជំងឺអុតក្តាម ទឹករំអិលមានខ្ទុះហូរចេញពីច្រមុះ (អាចជំងឺហើមសួត)

➢ **មាត់ និងអណ្តាត**
- តើមានទឹកមាត់ហូរច្រើនឬទេ?
- ចំពោះជំងឺសារទឹក មានទឹកមាត់ហូរតិច
- មានសង្កៀតធ្មេញឬទេ? បើមាននេះជាសញ្ញាឈឺចាប់
- ពិនិត្យអណ្តាតមានស្នាមដាច់ ឬពងដោរ ឬដំបៅ ឬទេ?
- ពិនិត្យអញ្ចាញធ្មេញមានស្នាមដាច់ ឬពងដោរ ឬដំបៅ ឬទេ? ។ល។



ជំងឺអុតក្តាម



ជំងឺប៉េស្ត







- ➤ **ពិនិត្យភ្នែក**
  - មានហូរទឹកភ្នែក ឬអ្វីផ្សេងឬទេ?
  - ភ្នាសស្តើងខាងក្នុងភ្នែកមានពណ៌អ្វី?
  - ប្រស្រីភ្នែកមានពណ៌អ្វី? ល្អក់ ពណ៌ស ឬពណ៌ខៀវ ។ល។



ជំងឺប៉េស្តជ្រូក



ស្លេកស្លាំងខ្លាំង



ការពិនិត្យភ្នែក

- ➤ **ពិនិត្យក្បាល និងក**
  - តើមានហើមនៅក្រោមថ្គាម ឬទេ?
  - តើមានហើមនៅកន្លែងផ្សេងទៀតដែរ ឬទេ?



ហើមមុខ ក្បាល ក (ជំងឺសារទឹក)



ហើមក្រោមថ្គាម (ជំងឺដង្កូវថ្លើម)

➢ ពិនិត្យដងខ្លួន
- ស្តាប់ចង្វាក់បេះដូង
- ស្តាប់សំឡេងសួត
- ទាញស្បែកមើលភាពយឺតរបស់វា
- ច្របាច់បំពង់ក ថ្មមៗ តើសត្វក្អកឬទេ? ។ល។

➢ ពិនិត្យស្បែក
- តើមានដំបៅ ពងបែក ឬស្លាកស្នាមផ្សេងទៀតនៅលើស្បែកឬទេ?
- តើមានហើមក្រោមស្បែកឬទេ? អាចជាកូនកណ្តុរ។ល។


ជំងឺប៉េស្តជ្រូក ជំងឺឡឺកូស៊ីស

➢ ពិនិត្យកន្សោមដោះ ប្រដាប់បន្តពូជ និងគូថ
- តើកន្សោមដោះហើម ឬក្តៅខុសពីធម្មតាដែរឬទេ?
- តើមានរបួសលើក្បាលដោះឬទេ?
- តើការចេញទឹកដោះតិចជាងធម្មតាដែរឬទេ?
- តើមានទឹករំអិលឬខ្ទុះហូរចេញពីយោនីឬលិង្គ ដែរឬទេ?
- តើសត្វរាគ ឬទល់លាមក? ។ល។



**ពិនិត្យជើង**

- តើសត្វដើរខ្វក់ដែរឬទេ?
- មើលជើង រកស្នាមរបួស ដំបៅ ហើម ឬមានការឈឺចាប់ពេលស្ទាប។ល។



## ៥- ធ្វើសេចក្តីសន្និដ្ឋាន លើមូលហេតុនៃជំងឺ

ពេលដែលអ្នកត្រូវគិត នូវអ្វីដែលបានសួរ បានមើលឃើញ និងបានពិនិត្យជាក់លាក់ លើមូលហេតុបណ្តាលឲ្យសត្វឈឺ ដែលជាមូលដ្ឋានសម្រាប់ធ្វើរោគវិនិច្ឆ័យ។

## ៦- ការជ្រើសរើសយកវិធីព្យាបាល

យើងជ្រើសរើសយកការព្យាបាលមួយឬច្រើនទៅតាមវិធីព្យាបាលទាំង៥ ដូចខាងក្រោម:

-ធ្វើឲ្យសត្វសប្បាយចិត្ត

-ផ្តល់ចំណីអាហារ ទឹកឲ្យបានគ្រប់គ្រាន់

-ប្រើថ្នាំទម្លាក់ព្រូន ឬថ្នាំសម្លាប់ចៃ ដង្កៃ ឬអង្កែ

-ប្រើថ្នាំ: អង់ទីប៊ីយ៉ូទិក ឬថ្នាំប្រឆាំងការរលាក ឬថ្នាំបញ្ចុះកម្តៅនិងបំបាត់ការឈឺចាប់

-ប្រើថ្នាំបន្សាបជាតិពុល។





# ជំពូកទី៩៖ ការគ្រប់គ្រងសុខភាព និងសុខុមាលភាពសត្វ





# ក. ការធ្វើទ្រុងសត្វ

ការធ្វើទ្រុងសត្វ ជាវិធីមួយដ៏ប្រសើរដើម្បីកែលំអរ:

- **ផ្នែកសុខភាព** : ព្រោះនៅពេលសត្វចិញ្ចឹមដាក់ទ្រុង អាចកាត់បន្ថយការប៉ះពាល់ជាមួយនឹងសត្វឈឺ និងការឆ្លងមេរោគ(បាក់តេរី វីរុស និងបរាសិត) ដែលរស់នៅ និងលូតលាស់ក្នុងដី។
- **ផ្នែកផលិតកម្ម** : ព្រោះការដាក់សត្វតូចក្នុងទ្រុង អាចកាត់បន្ថយគ្រោះថ្នាក់ពីកត្តាចង្រៃផ្សេងៗ និងឆាប់ធំលូតលាស់។ ចិញ្ចឹមសត្វដាក់ទ្រុង ត្រូវផ្តល់ចំណី និងទឹកស្អាតឲ្យបានគ្រប់គ្រាន់។

## ១.មាន់

### ១.១ ទ្រុងកូនមាន់





គោលបំណងគឺ:

- កាត់បន្ថយការបំផ្លាញពីកត្តាចង្រៃក្នុងភូមិ រួមមាន: សត្វឆ្កែ ឆ្មា និងម៉ូត្វ ដែលជាមូលហេតុបណ្តាលឲ្យកូនមាន់ងាប់។
- **សុខុមាលភាព** : ពេលកូនមាន់ដាក់ក្នុងទ្រុង អាចការពារភ្លៀង និងខ្យល់ ដើម្បីកុំឲ្យពួកវាបាត់បង់ថាមពល ដែលធ្វើឲ្យវាចុះខ្សោយ
- កូនមាន់នឹងទទួលបានទឹក និងចំណីបានគ្រប់គ្រាន់
- ងាយស្រួលធ្វើវ៉ាក់សាំង
- កាត់បន្ថយគ្រោះថ្នាក់ និងជំងឺផ្សេងៗ ដោយសារវាមិនបានប៉ះពាល់ជាមួយសត្វឈឺ និងដើរស៊ីនៅកន្លែងដែលមានមេរោគពពួកសាល់ម៉ូណែឡា (Salmonella) និងប៉ាស្ទឺរ៉ែឡា (Pasteurella) ។

## ១.២ ទ្រុងមេមាន់(ត្រូវបន្ថែមទំហំ)

ជាទូទៅមេមាន់ដើររកចំណី និងក្រាបពង។ ដូចនេះទ្រុងមេមាន់ផ្តល់អត្ថប្រយោជន៍ដូចជា:

- ផ្តល់កន្លែងដែលមានម្លប់ និង ស្ងាត់ស្ងៀមដើម្បីមេក្រាបពង។
- ត្រូវធ្វើសំបុកត្រឹមត្រូវ សមរម្យ ដូចជាកន្ត្រក ឬល្អីដែលប្រើសម្រាប់ធ្វើជាសំបុក។







មេមាន់ក្រាបពងនៅលើដើមឈើ

- ត្រូវផ្តល់ទឹក និងចំណីក្នុងទ្រុងក្នុងកំឡុងពេលក្រាបពង។
- ការពារមេមាន់ និងស៊ុតពីសត្វចង្រៃ។

## ១.៣ ទ្រុងមាន់សាច់

ធម្មតាមាន់សាច់ គេចិញ្ចឹមលែង ដើម្បីកាត់បន្ថយការចំណាយលើចំណី និងទ្រុង។ ការផ្តល់ជម្រក និងទ្រនំសម្រាប់ពេលយប់ អាចការពារពួកវាពីកត្តាចង្រៃ និងងាយស្រួលប្រមូលលាមក ដើម្បីប្រើជាជី។

សម្រាប់មាន់សាច់ ការដាក់មាន់ក្នុងរបងប្រសើរជាងបង្ខាំងទុកក្នុងទ្រុង ព្រោះកសិករត្រូវផ្តល់ចំណីឲ្យវា។

## ១.៤ ការធ្វើរបង

មាន់ចិញ្ចឹមលែង ច្រើនជួបបញ្ហាញឹកញាប់ និងការចម្លងមេរោគ (សាល់ម៉ូណេឡា ប៉ាស្ទឺរែឡា...) និងការគំរាមកំហែងពីកត្តាចង្រៃ។

ការធ្វើរបងផ្តល់អត្ថប្រយោជន៍ដូចជា:

- កសិករត្រូវផ្តល់ចំណីបន្ថែម

- ងាយស្រួលរក្សាអនាម័យក្នុងទីធ្លា (គ្មានថង់ប្លាស្ទិក និង ក្រលុកកខ្វក់ដែលជាជម្រកលូតលាស់របស់មេរោគ)
- កាត់បន្ថយការប៉ះពាល់ជាមួយមាន់ចិញ្ចឹមលែង និងមាន់ឈើផ្សេងទៀត។
- ជៀសវាងកូនក្មេងលេងនៅកន្លែងប្រឡាក់ប្រឡូសដោយលាមកមាន់។





## ២. ជ្រូក

កសិករខ្លះចិញ្ចឹមជ្រូកលែង ដើម្បីកាត់បន្ថយការចំណាយលើចំណី។ ការធ្វើរបៀបនេះមានគ្រោះថ្នាក់ខ្ពស់ដោយការចម្លងមេរោគពីជ្រូកឈើ ឬ ពីកន្លែងកខ្វក់។ ជ្រូកត្រូវចំណាយថាមពលច្រើនដើម្បីស្វែងរកចំណី និងមានការលូតលាស់ទាប។

បើកសិករចង់ចិញ្ចឹមជ្រូកទទួលបានប្រាក់ចំណេញត្រូវធ្វើទ្រុង។

### ២.១ ទ្រុងសម្រាប់ដាក់មេជ្រូកបង្កាត់ពូជ

បន្ទាប់ពីផ្តាច់ដោះ មេជ្រូកត្រូវឲ្យវារកឈ្មោលលឿនតាមដែលអាចធ្វើទៅបាន។ មេជ្រូកមានសុខភាពល្អ និងរាងកាយមាំមួន វានឹងរកឈ្មោល ចន្លោះពី ៥ទៅ១០ថ្ងៃបន្ទាប់ពី ផ្តាច់ដោះ។

ស្រ្តេស និងពន្លឺមានសារៈសំខាន់ណាស់ដើម្បីជំរុញឲ្យមេជ្រូកឆាប់រកឈ្មោល។

- ទីកន្លែងសម្រាប់បង្កាត់ត្រូវតែភ្លឺ និងមានអំពូលភ្លើងរហូតដល់ម៉ោង ១០យប់ជាការប្រសើរ។
- មេជ្រូកមិនត្រូវស្ថិតក្នុងកន្លែងស្ងៀមស្ងាត់ទេ ត្រូវធ្វើឲ្យរំញោចអារម្មណ៍ ដោយមានជ្រូកបានៅក្បែរ។



## ២.២ ទ្រុងសម្រាប់មេដើម



- មេជ្រូកដើមត្រូវការស្ងាត់ស្ងៀម មិនត្រូវឲ្យវាខាំគ្នាជាមួយមេដ៏ទៃទៀត។ គួរដាក់មេជ្រូកដើមក្នុងទ្រុងដាច់ដោយឡែកតែឯង។
- កំរាលទ្រុងសំខាន់ណាស់ សម្រាប់មេជ្រូកដើម ដើម្បីការពារការខ្វកជើងដោយសាររបួសលើក្រចក និងសន្លាក់ជើង។ ៩០%របស់បញ្ហាខ្វកជើងកើតឡើងដោយកំរាលមិនល្អ ធ្វើឲ្យមេជ្រូកមិនអាចស៊ីចំណី និងផឹកទឹកបានគ្រប់គ្រាន់។



## ២.៣ ទ្រុងសម្រាប់មេជ្រូកកើតកូន / សំបុក

ការធ្វើទ្រុងសម្រាប់មេកើតកូន មានសារៈសំខាន់ណាស់ដល់សុខភាព និងការកើតកូន:

- មេជ្រូកត្រូវមានកន្លែងងាយស្រួលដើម្បីក្រោកឈរ និងមានទឹកផឹកគ្រប់គ្រាន់។
- មេជ្រូកត្រូវដាក់ក្នុងទ្រុង ជៀសវាងការកិនកូនជ្រូក ជាពិសេសនៅប៉ុន្មានថ្ងៃក្រោយពេលកើត។ ទ្រុងត្រូវមានភាពងាយស្រួលសម្រាប់កូនជ្រូកចូលទៅបៅដោះ។








- កូនជ្រូកត្រូវការពារភាពត្រជាក់ និងខ្យល់បក់ខ្លាំង។ នៅពេលយប់ ត្រូវផ្តល់កំដៅក្នុងកំឡុងពេល១០ថ្ងៃដំបូងបន្ទាប់ពីកើត។
- បើកូនជ្រូកត្រជាក់ វានឹងបាត់បង់ថាមពលច្រើន ចុះខ្សោយ និងមិនអាចបៅដោះបាន។
- អាកាសធាតុត្រជាក់ធ្វើឲ្យយឺតយ៉ាវដល់ការបញ្ចេញចោលក្នុងពោះវៀន បណ្តាលឱ្យមេរោគពពួកអ៊ីកូលី (E.Coli) លូតលាស់ និងធ្វើឱ្យកូនជ្រូករាក។


កូនជ្រូកប្រមូលផ្តុំគ្នាព្រោះដោយសាររងារគ្រោះថ្នាក់ដោយសាររាគខ្ពស់


ចាំបាច់ត្រូវផ្តល់កំដៅដល់កូនជ្រូកបន្ទាប់ពីកើត ដើម្បីកុំឱ្យវាបាត់បង់ថាមពល


ការពារកូនជ្រូកពីខ្យល់ខ្លាំង ក្រាលចំបើងស្ងួតលើកំរាល និងផ្តល់ប្រភពកំដៅនៅជិតៗវា។

- កំរាលត្រូវតែស្ងួត ដើម្បីបង្ការការបំបែកខ្លួនរបស់មេរោគ។ កំរាលបន្ទះដែកតូចៗមានលក្ខណៈសម្បត្តិល្អជាងកំរាលស៊ីម៉ង់ត៍ ព្រោះទឹកនោម និងលាមកមិនបានប៉ះពាល់ជាមួយកូនជ្រូក។





កំរាលរាបធ្វើពីស៊ីម៉ង់ត៍ត្រូវសម្អាត និងរក្សាសំណើម

## ២.៤ ទ្រុងកូនជ្រូកផ្តាច់ដោះ

ពេលផ្តាច់ដោះធ្វើឲ្យកូនជ្រូកកើតស្រ្តេសយ៉ាងខ្លាំង:

- ពួកវាបាត់បង់ភាពកក់ក្តៅដែលផ្តល់ដោយខ្លួនមេ ដូចនេះគួរតែផ្តល់ប្រភពកំដៅនៅពេលយប់ក្នុងអាទិត្យទី១។
- ទ្រុងតូចៗច្រើនប្រសើរជាងទ្រុងធំ។ ចាំបាច់ត្រូវដាក់កូនជ្រូកផ្តាច់ដោះជាក្រុមដែលមានទំហំ ប៉ុនៗគ្នាដើម្បីចៀសវាងការខាំ ការប្រជែងស៊ី និងផឹក ធ្វើឲ្យកូនជ្រូកតូចជាងគេកាន់តែខ្សោយ និងស្គម។

ស្នាមរបួសដោយសារការខាំគ្នាមិនធ្ងន់ធ្ងរ ទេបើសិនជាជ្រូកមានទំហំប៉ុនគ្នា






ទ្រុងមានទំហំធំពេកមិនអាចការពារកូនជ្រូកពីខ្យល់ខ្លាំងបាន

- ដើម្បីបង្ការការប្រជែងគ្នា ចំនួនក្បាលបឺតទឹកសម្រាប់ផឹក និងទំហំស្នូកចំណីត្រូវមានគ្រប់គ្រាន់
- កំរាលត្រូវធ្វើពីបន្ទះដែក ដើម្បីការពារភាពកខ្វក់ និងសំណើម
- ទំហំត្រឹមត្រូវរបស់ទ្រុងគឺកូនជ្រូក២ក្បាល/ម៉ែត្រការ៉េ។

## ២.៥ ទ្រុងសម្រាប់ជ្រូកសាច់

- ត្រូវបំបែកជាក្រុម: មានអាយុស្មើគ្នា និងទម្ងន់ប៉ុនៗគ្នា។
- ផ្ទៃក្រឡាសម្រាប់ដាក់ជ្រូកសាច់មួយក្បាលគឺ ១,៥ម៉ែត្រការ៉េ។
- ជញ្ជាំងត្រូវមានកំពស់(១,២ម៉ែត្រ) ដើម្បីបង្ការជ្រូកលោតចេញ។



- ជាការល្អត្រូវធ្វើអាងដាក់ទឹកដើម្បីឲ្យជ្រូកចុះលេង ប៉ុន្តែទឹកត្រូវប្តូរជារៀងរាល់ថ្ងៃ ដើម្បីបង្ការការលូតលាស់របស់មេរោគក្នុងទឹក។
- ផ្តល់ទឹកឲ្យកូនជ្រូក តាមរយៈក្បាលបឺត។ ជ្រូកដាក់ក្នុងទ្រុងបំប៉ន ពេលមានទម្ងន់២៥គីឡូក្រាម រហូតដល់៩០គីឡូក្រាម។ ដូចនេះក្បាលបឺតខ្លះត្រូវដាក់នៅកម្ពស់៣០សង់ទីម៉ែត្រ និងក្បាលបឺតខ្លះទៀតត្រូវដាក់នៅកម្ពស់៦០សង់ទីម៉ែត្រ។



## ២.៦ ទ្រុងសម្រាប់ជ្រូកបា

ទ្រុងជ្រូកបាត្រូវមាន:

- កម្រាលត្រូវមានស្ថានភាពល្អ ដើម្បីបង្ការការខូក ជាពិសេសការចុះខ្សោយ ឬឈឺចាប់លើជើងក្រោយដែលធ្វើឱ្យពិបាកបង្កាត់។
- ទ្រុងត្រូវមានបរិយាកាសល្អ បើក្តៅពេកធ្វើឲ្យគុណភាពទឹកកាមធ្លាក់ចុះ។
- ដើម្បីឲ្យជ្រូកបាធ្វើចលនាបានស្រួល ផ្ទៃទ្រុងត្រូវមាន ពី៦ទៅ៩ម៉ែត្រការ៉េ ។





### ៣. គោ

កសិករភាគច្រើនចិញ្ចឹមគោចងទុកនៅក្រោមផ្ទះ ឬក្នុងក្រោលក្បែរផ្ទះ។



- ត្រូវដាក់មុងការពារមូសព្រោះវាខាំរំខានគោនៅពេលយប់ ធ្វើឱ្យគោចុះខ្សោយ។



- គោត្រូវការកន្លែងម្លប់ (ក្រោមដើមឈើ ឬដំបូល ដែលជៀសផុតពីភ្លៀង និងពន្លឺ) ជាពិសេសពេលស៊ីនិងទំពារអៀង ។
- ការផ្តល់ស្មៅត្រូវដាក់ក្នុងឡាំង (ទ្រុងចំណី) ដើម្បីជៀសវាងការខ្ជះខ្ជាយ និងឲ្យគោទាំងអស់ងាយស៊ីបាន។




- ត្រូវធ្វើសាឡុងដើម្បីចាប់គោសម្រាប់ពិនិត្យ ឬចាក់ថ្នាំឲ្យបានត្រឹមត្រូវ ដើម្បីឲ្យមានសុវត្ថិភាពដល់កសិករ និងបសុពេទ្យ។

## ខ. ការផ្តល់ចំណីសត្វ

### ១. មាន់-ទា

#### ១.១ ការផ្តល់ចំណី



កសិករត្រូវផ្លាស់ប្តូររបៀបចិញ្ចឹម ពីការចិញ្ចឹមលែងទៅជាពាក់កណ្តាលពាណិជ្ជកម្ម និងដាក់ទ្រុង។ កសិករត្រូវផ្តល់ចំណីឲ្យសត្វបានគ្រប់គ្រាន់ដោយប្រើចំណីផ្សំ (លាយចំណីផ្សំប្រហែល ២០% ជាមួយវត្ថុធាតុដើមក្នុងស្រុក) ឬ ផលិតចំណីដោយ

ខ្លួនឯងផ្ទាល់ ដោយលាយវត្ថុធាតុដើម ជាមួយសារធាតុបន្ថែម ដូចជាវីតាមីន សារធាតុរ៉ែមួយចំនួន និងអាស៊ីតអាមីណេ។
ជាការល្អត្រូវផ្តល់ចំណីសម្រេច ឲ្យកូនមាន់ រហូតដល់វាមានអាយុ២១ថ្ងៃ ដើម្បីឲ្យកូនមាន់លូតលាស់បានល្អ និងរឹងមាំ។



## ១.២ វត្ថុធាតុដើម

វត្ថុធាតុដើមប្រើជាទូទៅ សម្រាប់ជាចំណីបន្ថែមដល់មាន់ចិញ្ចឹមលែង។

➢ **ស្រូវ និងអនុផលរបស់ស្រូវ**

ប្រើសម្រាប់ជាចំណីបន្ថែមរួមមាន: ចុងអង្ករ បាយ ស្រូវ កន្ទក់។ កន្ទក់ជាចំណីផ្តល់ថាមពល និងប្រូតេអ៊ីន ពី៨ទៅ១២% និងសម្បូរជាតិផូស្វ័រ និងវីតាមីនបេ ។

➢ **ពោត**

ពោតជាចំណីបន្ថែមសម្រាប់ផ្តល់ឲ្យមាន់ ប៉ុន្តែមិនត្រូវបានប្រើជាទូទៅទេ។ កសិករត្រូវប្រើកំទេចពោត ជាប្រភពថាមពល និងមានប្រូតេអ៊ីន ពី៩ទៅ១០%។

ពោតផ្តល់ជាតិពណ៌លឿងលើស្បែកនិងស៊ុត។



➢ **ដើមចេក**

គេប្រើជាទូទៅ ប៉ុន្តែមានប្រូតេអ៊ីនទាប។

➢ **ដង្កូវ**

កូនដង្កូវ សត្វល្អិត គេផលិតឡើងពីកាកសំណល់ផ្ទះបាយ និងបន្លែដែលដាក់ក្នុងធុងធ្វើជាកំប៉ុស្ត។ ដើម្បីបង្កើនដង្កូវ កសិករអាចដាក់បន្ថែមលាមកមាន់ទៅក្នុងធុងហើយត្រូវគ្របក្នុងពេលក្តៅខ្លាំង ដើម្បីជៀសវាងពងដង្កូវងាប់។ កូនដង្កូវលូតលាស់ក្នុងពេល ៥ទៅ១០ថ្ងៃ ហើយអាច យកវាឲ្យមាន់ស៊ីបាន។



- **ជន្លេន**



កសិកររៀបចំសារធាតុដើម្បីចិញ្ចឹមជន្លេន៖ លាយលាមកគោ ស្នូលពោត ស្លឹកឈើស្រស់ ជាមួយទឹក ដោយគ្របថង់ប្លាស្ទិចដើម្បីធ្វើឲ្យឡើងមេរយៈពេល២អាទិត្យ។ ជន្លេនត្រូវចិញ្ចឹមក្នុងធុងក្រោមម្លប់ និងផ្សើមទឹកជាប្រចាំ។ ជន្លេនអាចយកឲ្យមាន់ស៊ីបន្ទាប់ពីរយៈពេលមួយខែ។

- **កណ្តៀរ**



ចិញ្ច្រាំចំបើង លាយជាមួយលាមកគោ ដាក់ក្នុងក្អមធ្វើពីដី និងផ្សើមវា រួចយកមាត់ក្អមនេះដាក់ពីមុខរន្ធដំបូកកណ្តៀរដែលកំពុងពូន។ ពី៣ទៅ៤អាទិត្យក្រោយមកពពួកកណ្តៀរថ្មីនឹងក្លាយជាកូនដង្កូវបង្កើតនៅក្នុងក្អមនោះសម្រាប់ជាចំណីមាន់។

## ១.៣ តម្រូវការចំណី

- **ថាមពល** : មាន់ចិញ្ចឹមលែងចំណាយថាមពលច្រើន ដើម្បីស្វែងរកចំណី។ ថាមពលផ្តល់តាមរយៈជាតិម្សៅ (ស្រូវ ពោត) និងខ្លាញ់ (មានក្នុងកន្ទក់)។
- **ប្រូតេអ៊ីន** : ប្រូតេអ៊ីន និងអាស៊ីត អាមីណេ ចាំបាច់សម្រាប់ការលូតលាស់ និងផលិតស៊ុត។ ឧទាហរណ៍ ការចិញ្ចឹមមាន់សាច់ពាក់កណ្តាលពាណិជ្ជកម្ម ចាប់ពី២១ថ្ងៃ ត្រូវការប្រូតេអ៊ីន១៩% និងមាន់យកស៊ុត ត្រូវការ ១៦% ក្នុងចំណី។ តម្រូវការប្រូតេអ៊ីនជាបញ្ហាចម្បង ព្រោះកសិករមិនមានលទ្ធភាពទិញម្សៅត្រី ឬសណ្តែកសៀងបានទេ។ ដូច្នេះកសិករអាចរកជន្លេន ដង្កូវ កណ្តៀរ ខ្យង (សម្រាប់ទា) និងសត្វល្អិតដែលសម្បូរប្រូតេអ៊ីនជំនួសវិញ។ពន្លកស្មៅខ្ចីៗជួយបំពេញបន្ថែមបញ្ហាកង្វះប្រូតេអ៊ីនបាន។

មេទីត្យូនីនជាអាស៊ីតអាមីណេ
ចាំបាច់សម្រាប់បង្កើតរោម



លីស៊ីនជាអាស៊ីតអាមីណេ
ចាំបាច់សម្រាប់បង្កើតសាច់

គ្រកូន (ស្មៅទឹក)ចញ្ច្រាំ និងលាយជាមួយ
ចុងអង្ករ និងកន្ទុកដើម្បីផ្តល់ប្រូតេអ៊ីនបន្ថែម



➢ **វីតាមីន និងសារធាតុរ៉ែ**

ជាតិកាល់ស្យូម (Ca) និងផូស្វ័រ (P) ក្នុងចំណីមានកម្រិតទាបសម្រាប់មាន់ចិញ្ចឹមលែង។ កាល់ស្យូម និងផូស្វ័រ ងាយស្រួលផ្តល់ឲ្យសត្វតាមរយៈកំទេចសំបកខ្យងខ្ចៅ (៣ ទៅ ៤ ក្រាមក្នុងមួយថ្ងៃសម្រាប់មេមាន់មួយក្បាល)។

## ១.៤ ស្នូកទឹក និងស្នូកចំណី

ដើម្បីជៀសវាងការខ្ជះខ្ជាយ និងងាយស្រួលដល់សត្វ ចំណីទឹកត្រូវដាក់ក្នុងស្នូកទឹក និងស្នូកចំណី នៅកន្លែងស្អាត។



➢ មេមាន់១០ក្បាល ត្រូវការផឹកទឹក៥លីត្រក្នុង១ថ្ងៃ។

➢ មាន់សាច់ទម្ងន់១គីឡូក្រាម ៥០ ក្បាលត្រូវការផឹកទឹក១០លីត្រក្នុង១ថ្ងៃ។

# ២. ជ្រូក

## ២.១ ការផ្តល់ចំណី

ក្នុងការចិញ្ចឹមជ្រូក ចំណីគឺមានការចំណាយប្រាក់ច្រើនជាងការចំណាយផ្សេងៗ ជាការចាំបាច់ ត្រូវដឹងពីតម្រូវការចំណីដើម្បីបង្ការការខ្វះខាត និងលូតលាស់បានល្អ។

➢ **ចំពោះជ្រូកសាច់:** គោលបំណងគឺផលិតសាច់ច្រើន និងមានខ្លាញ់តិច ហើយមានការលូតលាស់លឿន។



អ្នកបរិភោគនៅទីក្រុងចូលចិត្តសាច់ប្រភេទនេះ

ការចិញ្ចឹមជ្រូកសាច់ ត្រូវចែកជាដំណាក់កាល ហើយដំណាក់កាលនិមួយៗមានចំណីជាក់លាក់(ប្រូតេអ៊ីន និងថាមពល)។

ពេលផ្តាច់ដោះ ចំណីឆ្ងាញ់ទាក់ទាញ
កូនជ្រូកឲ្យស៊ីច្រើន



- **ដំណាក់កាលទី១:** កូនជ្រូកបន្ទាប់ពីផ្តាច់ដោះទម្ងន់៧ទៅ១២គីឡូក្រាម ត្រូវការចំណីដែលមានសភាពទន់និងសម្បូរដោយប្រូតេអ៊ីនងាយស្រួលក្នុងការរំលាយ (រយៈពេល២អាទិត្យ) ។ កូនជ្រូកកូនកាត់ត្រូវការប្រូតេអ៊ីន២០%។ ដូច្នេះចំណីផ្សំសម្រាប់កូនជ្រូកផ្តាច់ដោះត្រូវមានឱជារសឆ្ងាញ់និងមានវត្ថុធាតុដើមជាក់លាក់ (ជាតិទឹកដោះ និងប្រូតេអ៊ីន សណ្តែកសៀង ពោត...) ងាយស្រួលរំលាយ ដើម្បីទាក់ទាញកូនជ្រូកស៊ីបានច្រើន និងធំធាត់លឿន។
- **ដំណាក់កាលទី២:** រយៈពេលនេះជ្រូកមានទម្ងន់ពី ២៥ទៅ៣០គីឡូក្រាម (អាយុប្រហែល២ខែកន្លះ)។ កូនជ្រូកកូនកាត់ត្រូវការចំណីដែលមានប្រូតេអ៊ីន១៨%។
- **ដំណាក់កាលលូតលាស់:** ពី៣០ទៅ៦០គីឡូក្រាម (អាយុប្រហែល៤ខែកន្លះ)។ ជ្រូកកូនកាត់ត្រូវការប្រូតេអ៊ីន១៦%។
- **ដំណាក់កាលបំប៉ន:** ពី៦០គីឡូក្រាមរហូតដល់លក់ មានទម្ងន់ពី៨០ទៅ៩០គីឡូក្រាម (អាយុ៦ខែ)។ ជ្រូកកូនកាត់ត្រូវការប្រូតេអ៊ីន១៤%។

➢ **ចំពោះជ្រូកពូជ**

- **មេជ្រូកផើម:** ក្នុងកំឡុង៣អាទិត្យដំបូង កសិករត្រូវផ្តល់ចំណីបន្ថែម (៥០០ក្រាមលើសពីពេលមុន) ព្រោះមេជ្រូកត្រូវការដើម្បីចិញ្ចឹមកូន។ ក្នុងកំឡុង៣អាទិត្យមុនពេលកើត ចាំបាច់ត្រូវបន្ថែមបរិមាណចំណី ៥០០ក្រាមក្នុងមួយថ្ងៃ។ ត្រូវផ្តល់ចំណីដែលជួយផលិតខ្លាញ់ ព្រោះមេជ្រូកត្រូវការថាមពលដើម្បីផលិតទឹកដោះក្នុងពេលបំបៅដោះ និងបម្រុងទុក។

- **មេជ្រូកបំបៅដោះ:** មេជ្រូកត្រូវការថាមពល និងប្រូតេអ៊ីនច្រើនដើម្បីផលិតទឹកដោះ។ ចំណីត្រូវផ្តល់យ៉ាងហោចណាស់៣ដងក្នុងមួយថ្ងៃ ដើម្បីជំរុញឲ្យស៊ីបានច្រើន។ បរិមាណចំណីត្រូវបន្ថែមចាប់ពីថ្ងៃទី១ ប្រហែល១គីឡូក្រាម រហូតដល់១អាទិត្យបន្ទាប់ពីកើតកូន ។ បរិមាណចំណីសរុប អាស្រ័យទៅនឹងចំនួនកូនជ្រូក។


មេជ្រូកស៊ីច្រើនពេលបំបៅដោះកូន និងត្រូវការប្រូតេអ៊ីនថែមទៀតដើម្បីផលិតទឹកដោះឲ្យបានគ្រប់គ្រាន់

**ឧទាហរណ៍:** មេជ្រូកមានកូន៦ក្បាលត្រូវការចំណី៥គីឡូក្រាម និងមេជ្រូកមានកូន ១០ក្បាលត្រូវការចំណីយ៉ាងតិច៦,៥គីឡូក្រាម។

- **ជ្រូកបា:** ត្រូវការផលិតទឹកកាម និងត្រូវផ្តល់ចំណីសម្រាប់មេជ្រូកដើមឲ្យស៊ី។ ត្រូវផ្តល់ចំណីបន្ថែមឱ្យបានទៀងទាត់ដែលមានវីតាមីន និងអាស៊ីតអាមីណេ។

## ២.២ ការផ្តល់ចំណី និងការលូតលាស់

- **ស្ថានភាពសុខភាព:** ក្អករ៉ាំរ៉ៃ រាកប៉ះពាល់ដល់ការលូតលាស់។ ពពួកមីកូប្លាស្មា (Mycoplasma) កាត់បន្ថយការលូតលាស់ប្រហែលជា២០%។
- **ពូជ:** ការបង្កាត់ជ្រូកពូជក្នុងស្រុកជាមួយបាពូជឌុយរ៉ុក (Duroc) ឡាចវ៉ាយ (Largewhite) ឡេនដ្រាស ឬ ម៉ាក្សស្ទែរ (Landrace or Maxter) បានធ្វើឲ្យប្រសើរឡើងដល់ការលូតលាស់ និងប្រសិទ្ធភាពស៊ីចំណី។

ចំពោះជ្រូកក្នុងស្រុក សូម្បីចំណីល្អ ក៏មិនអាចមានការលូតលាស់ល្អទេ




របបចំណីត្រឹមត្រូវមានឥទ្ធិពលលើការលូតលាស់របស់ជ្រូកកូនកាត់

**ចំណី:** ប្រូតេអ៊ីនមានសារៈសំខាន់ណាស់ដើម្បីផលិតសាច់ក្រហម។ ប្រសិនចំណីមានប្រូតេអ៊ីនទាបពេក និងថាមពលច្រើន នោះជ្រូកធំលូតលាស់យឺត និងមានខ្លាញ់ច្រើន។ តែបើចំណីមានប្រូតេអ៊ីន និងថាមពលទាបពេក ជ្រូកនឹងស្គម។

ដើម្បីគណនាការលូតលាស់:

- **កំណើនទម្ងន់ប្រចាំថ្ងៃ:** គឺស្មើនឹងកំណើនទម្ងន់ជាក្រាមរៀងរាល់ថ្ងៃ។បើគណនាកំណើនទម្ងន់ប្រចាំថ្ងៃ ពីពេលផ្តាច់ដោះរហូតដល់លក់ កសិករត្រូវថ្លឹងទម្ងន់របស់ជ្រូកនៅពេលផ្តាច់ដោះ។




**ឧទាហរណ៍:** កូនជ្រូកមានទម្ងន់៨គីឡូក្រាមពេលផ្តាច់ដោះ បន្ទាប់មក កសិករត្រូវថ្លឹងទម្ងន់ នៅពេលលក់។ បើជ្រូកមានទម្ងន់ ៨២គីឡូក្រាម ដូចនេះកំណើនទម្ងន់គឺ ៨២-៨=៧៤គីឡូក្រាម ឬស្មើ៧៤០០០ក្រាម។ កសិករត្រូវគិតថា តើត្រូវប្រើពេលប៉ុន្មានថ្ងៃ បន្ទាប់ពីផ្តាច់ដោះរហូតដល់ពេលលក់?

**ឧទាហរណ៍:** គាត់បំប៉នកូនជ្រូកនៅអាយុ២៨ថ្ងៃ និងលក់នៅអាយុ៦ខែស្មើនឹង១៨០ថ្ងៃ។ ដូច្នេះមានរយៈពេល១៥២ថ្ងៃ អាចគណនាកំណើនទម្ងន់ប្រចាំថ្ងៃ ដោយយក ៧៤០០០ក្រាមចែកនឹង១៥២ថ្ងៃ មានន័យថា កំណើនទម្ងន់ប្រចាំថ្ងៃ ប្រហែល៤៨៧ក្រាម។

**បើគាត់អាចបង្កើនទម្ងន់ជ្រូកដល់ ៥៥០ក្រាមក្នុងមួយថ្ងៃ** គាត់នឹងអាចលក់ជ្រូកនៅទម្ងន់ ៨២គីឡូក្រាម នៅរយៈពេល១៣៤ថ្ងៃ ដោយជំនួសឲ្យការលក់នៅអាយុ ១៥២ថ្ងៃវិញ។

*ការគណនាកំណើនទម្ងន់ប្រចាំថ្ងៃ និងបរិមាណស៊ីចំណី ដើម្បីផលិតបានសាច់ ត្រូវតែថ្លឹងជ្រូក និងចំណី*





- **បរិមាណស៊ីចំណី:** ដើម្បីផលិតបានសាច់ ត្រូវគណនា បរិមាណចំណីដែលបានស៊ីចូល។ កសិករត្រូវថ្លឹងទម្ងន់កូនជ្រូកនៅពេលផ្តាច់ដោះ និងពេលលក់ ដោយបានគណនារួច គឺកំណើនទម្ងន់ស្មើនឹង៧៤គីឡូក្រាម។ កសិករគណនាបរិមាណចំណីដែលបានផ្តល់ឲ្យវាក្នុងកំឡុងពេលនេះ ឧទាហរណ៍: ២៦០គីឡូក្រាម ដូច្នេះចំណីចំនួន២៦០គីឡូក្រាម ផលិតបានជ្រូកទម្ងន់៧៤គីឡូក្រាម នោះបរិមាណស៊ីចំណីដើម្បីផលិតបានសាច់គឺ ២៦០ចែកនឹង៧៤ស្មើនឹង៣,៥គីឡូក្រាម។ ប្រសិនបើកសិករបង្កើនការគ្រប់គ្រង មានពូជល្អ ចំណីល្អ សុខភាពល្អ គាត់អាចទទួលបានបរិមាណស៊ីចំណីត្រឹម៣គីឡូក្រាម ដើម្បីផលិតបានសាច់ នេះមានន័យថា ដើម្បីបានជ្រូកទម្ងន់៨២គីឡូក្រាម គាត់ចំណាយចំណីត្រឹមតែ ២២២គីឡូក្រាម នោះគាត់ចំណេញបានលុយច្រើនជាងមុន។
  - **កសិដ្ឋានចិញ្ចឹមជ្រូកកូនកាត់ខ្នាតតូច ទិន្នផលរំពឹងទុកគួរតែ :**
    - អាយុផ្តាច់ដោះ ២៨ថ្ងៃ ទម្ងន់ ៨គីឡូក្រាម
    - ទម្ងន់បន្ទាប់ពីដំណាក់កាលទី១ (ប្រើចំណីបំប៉នរយៈពេល២អាទិត្យ): ១២ គីឡូក្រាម
    - អាយុ២ខែកន្លះ ទម្ងន់២៥គីឡូក្រាម
    - អាយុ៤ខែកន្លះ ទម្ងន់៦០គីឡូក្រាម
    - អាយុប្រហែល៦ខែ ទម្ងន់៨០គីឡូក្រាម
    - កម្រាស់ខ្លាញ់ : ១៥មីល្លីម៉ែត្រ
    - អត្រាងាប់ ក្រោយពេលផ្តាច់ដោះរហូតដល់លក់ត្រូវតែតិចជាង ៥%។

## ២.៣ ការលូតលាស់ និងប្រព័ន្ធផ្តល់ចំណី

កសិករផ្តល់ចំណីប្រភេទផ្សេងៗគ្នាអាស្រ័យនឹងចំនួនសត្វ និងថវិកាដែលមាន។

- **ចំណីឧស្សាហកម្ម:** កំណើនទម្ងន់ប្រចាំថ្ងៃ(ADG) ប្រហាក់ប្រហែល៧០០ក្រាម មានន័យថាជ្រូកលូតលាស់ជាមធ្យម គឺ៧០០ក្រាមរៀងរាល់ថ្ងៃ ពីទម្ងន់៣០ គីឡូក្រាមរហូតដល់ពេលលក់ មានទម្ងន់ប្រហែល៨០គីឡូក្រាម។
- **ចំណីផ្សំតាមផ្ទះ** (កាកសំណល់ផ្ទះបាយ ជាមួយបាយនិងកន្ទក់) នោះកំណើនទម្ងន់ប្រចាំថ្ងៃអាចប្រហាក់ប្រហែលនឹង៣០០ក្រាម។
- **ចំណីផ្សំតាមផ្ទះជាមួយម្សៅត្រី (១០%)** កំណើនទម្ងន់ប្រចាំថ្ងៃអាចប្រហាក់ប្រហែលនឹង៤៥០ក្រាម។

- **ចំណីផ្សំតាមផ្ទះជាមួយសារធាតុផ្សំដែលមានជាតិវីតាមីន រ៉ែ និងអាស៊ីតអាមីណោលីស៊ីន** កំណើនទម្ងន់ប្រចាំថ្ងៃអាចប្រហាក់ប្រហែលនឹង៦០០ក្រាម។

**បទពិសោធន៍នេះបង្ហាញថា** ក្នុងល័ក្ខខ័ណ្ឌដូចគ្នា ពូជជ្រូកដូចគ្នា នោះការលូតលាស់ពាក់ព័ន្ធនឹងរបបចំណីអាហារ។ ត្រូវមានតុល្យភាពរបបចំណីអាហារ នោះការលូតលាស់នឹងលឿន។ ការចំណាយក្នុងការផ្តល់ចំណីល្អ ធ្វើឲ្យចំណេញច្រើនសម្រាប់កសិករពេលគាត់ចិញ្ចឹមជ្រូកកូនកាត់ដែលមានសុខភាពល្អ។

## ២.៤ វត្ថុធាតុដើម និងសារធាតុបន្ថែមក្នុងចំណីរបស់ជ្រូក

- ប្រូតេអ៊ីនមានសារៈសំខាន់ ដើម្បីផលិតសាច់ដុំ។ វត្ថុធាតុដើមមានបរិមាណប្រូតេអ៊ីនផ្សេងៗគ្នា:
- ម្សៅត្រី មានប្រូតេអ៊ីន ពី៥០ទៅ៦៥%
- សណ្តែកសៀង មានប្រូតេអ៊ីន៤០%
- កន្ទក់ស្រូវសាលី មានប្រូតេអ៊ីន ១២ទៅ១៥%
- កន្ទក់ មានប្រូតេអ៊ីន ៩ទៅ១២%
- ពោត មានប្រូតេអ៊ីន ៩%
- ស្រូវ មានប្រូតេអ៊ីន ៦%
- ដំឡូងមី មានប្រូតេអ៊ីនត្រឹមតែ២%

*របៀបផ្សំចំណីសម្រាប់ជ្រូក*







➢ **អាស៊ីតអាមីណោដែលចាំបាច់:**

មានអាស៊ីតអាមីណោសំខាន់ ចំនួន៨ ហើយ៤ ចាំបាច់សម្រាប់ការលូតលាស់:

- លីស៊ីន (Lysin) : ចាំបាច់បំផុត
- មេត្យូនីន (Methionin): ជាទូទៅមានគ្រប់គ្រាន់ក្នុងវត្ថុធាតុដើម
- ត្រេអូនីន (Threonin): សំខាន់ទី២ បន្ទាប់ពីលីស៊ីន
- ទ្រីបតូផាន (Tryptophan): សារធាតុនេះមានគ្រប់គ្រាន់ក្នុងស្រូវ

➢ **ថាមពលសម្រាប់ជ្រូក:**

- សណ្តែកសៀង និងកន្ទក់ ផ្តល់ថាមពលច្រើនព្រោះវាផ្ទុកជាតិប្រេង។
- ស្រូវ ដំឡូងមី ពោត ផ្តល់ថាមពលព្រោះវាមានជាតិម្សៅ។


សណ្តែកសៀងមានខ្លាញ់២០% ត្រូវការចំអិនរយៈពេល២០នាទី ព្រោះវាមានផ្ទុកជាតិពុល

➢ **វីតាមីន និងរ៉ែ:**

វីតាមីន និងរ៉ែ គឺមិនមានគ្រប់គ្រាន់ក្នុងវត្ថុធាតុដើមសម្រាប់ការលូតលាស់របស់ជ្រូកទេ។ ចាំបាច់ត្រូវទិញផលិតផលដែលហៅថាប្រេមិច (Premix) ដែលផ្តល់នូវសារធាតុចាំបាច់ ដូចជា វីតាមីន អា ដេ អឺ បេ (Vitamin A, D, E, B)...និង សារធាតុរ៉ែ ដូចជា ដែក ស័ង្កសី ម៉ាញ៉េស្យូម ...។ ត្រូវលាយវាជាមួយរបបចំណីរៀងរាល់ថ្ងៃ។


ស្បែកស្ងួត និងអង្គែរកើតពេលជ្រូកចិញ្ចឹមឲ្យស៊ីកន្ទក់សុទ្ធ និងកង្វះជាតិសង្ក័សី

**ឧទាហរណ៍:** រូបមន្តចំណីជ្រូក ពី៣០ទៅ៩០គីឡូក្រាមគឺ:

- ពោត ៣៥%
- ចុងអង្ករ ១០%
- កន្ទក់ ៤០%
- សណ្តែកសៀង (ចំអិន) ១០%
- ម្សៅត្រី ៤%
- ប្រេមិច (Premix) ១% ។


មានទឹកគ្រប់គ្រាន់ និងសុវត្ថិភាពល្អជាចំណុចចាប់ផ្តើមដើម្បីចិញ្ចឹមជ្រូក

➢ **ទឹក:**

ទឹកជាសារធាតុចិញ្ចឹមសម្រាប់ជ្រូកដើម្បីឲ្យមានការលូតលាស់ល្អ។ បរិមាណផឹកទឹកជាមធ្យមគឺ:

- មេផើម ៣០លីត្រក្នុង១ថ្ងៃ
- មេបំបៅដោះ៤៥លីត្រក្នុង១ថ្ងៃ
- ការលូតលាស់ និងបំប៉នគឺ ១៥%នៃទម្ងន់របស់វា គឺស្មើនឹងទឹក១,៥លីត្រសម្រាប់ជ្រូក១០គីឡូក្រាម។

# ៣. គោ ក្របី

## ៣.១ បច្ចេកទេសផ្តល់ចំណី

ការប្រឈមក្នុងការផ្តល់ចំណីដល់គោក្របីមានរយៈពេល៦ខែក្នុងមួយឆ្នាំ ដោយរួមផ្សំតម្រូវការកំលាំងពលកម្មផងដែរ។

- ការរកស្មៅ:
  - តាមវាលស្រែ
  - ផ្ទៃដីគ្មានដំណាំ និងភ្លឺស្រែ
  - ជុំវិញស្រែ
  - ចិញ្ចើមផ្លូវ
  - ផ្ទៃដីវាលស្មៅធម្មជាតិ ឬព្រៃ
- ការផ្តល់ចំណីដាក់ក្នុងទ្រុងនៅឯផ្ទះ
  - "ដោយកាត់និងប្រមូលស្មៅ"
  - ចំបើង



ម្ចាស់មិនអាចធ្វើការងារអ្វីផ្សេងទៀតបាន

ការរកស្មៅតាមវាលស្រែ



ការកាត់និងប្រមូលស្មៅ ធ្វើឲ្យកសិករចំណាយពេលយ៉ាងច្រើន



ក្មេងៗមិនបានទៅសាលា

ការរកស្មៅតាមដងផ្លូវ និងក្នុងព្រៃ



ការរក្សាទុកចំបើងត្រឹមត្រូវក្នុងខែភ្លៀងមិនមែ
ជាការប្រើងប្រែងឥតប្រយោជន៍នោះទេ

## ៣.២ តម្រូវការរបស់គោក្របី

សរីរៈវិទ្យានៃការរំលាយអាហាររបស់គោ ក្របី បង្ហាញថាចំណីមានសារធាតុចិញ្ចឹមពីរប្រភេទ:

- សារធាតុចិញ្ចឹមសម្រាប់មីក្រុបក្នុងពោះធំ ដើម្បីផលិតប្រូតេអ៊ីន និងថាមពល
- សារធាតុចិញ្ចឹមសម្រាប់គោ ក្របីស្រូបដោយផ្ទាល់

**តម្រូវការរបស់គោ ក្របីផ្លាស់ប្តូរអាស្រ័យដោយ:**

- ស្ថានភាពរបស់គោ : ដើម បំបៅដោះ ធ្វើការនៅស្រែ ឬបំប៉ន
- ទម្ងន់រាងកាយ: គោទម្ងន់១៥០គីឡូក្រាមត្រូវការចំណីតិចជាងគោទម្ងន់៣០០គីឡូក្រាម។

➢ **ទឹក:**

- កង្វះទឹក ធ្វើឲ្យកាត់បន្ថយការស៊ីចំណី។ មេគោទម្ងន់២៥០គីឡូក្រាម ត្រូវការទឹកប្រហែល៣៥លីត្រ ប៉ុន្តែបរិមាណនេះនឹងកើនឡើងច្រើនប្រសិនបើ:



- សីតុណ្ហភាពខ្ពស់
- មេគោផលិតទឹកដោះ
- គោ ក្របី ធ្វើការអូសទាញ

គោ ក្របីចិញ្ចឹមដោយឲ្យស៊ីចំបើង

➢ **បរិមាណចំណី:**

សត្វមិនអាចប្រើប្រាស់សារធាតុចិញ្ចឹមក្នុងចំណី ប្រសិនបើវាមិនបានស៊ីគ្រប់គ្រាន់។

- ចំណីមានគុណភាពទាប សត្វស៊ីមិនគ្រប់គ្រាន់ និងមិនទទួលសារធាតុចិញ្ចឹមបានត្រឹមត្រូវ។
- ប្រសិនបើចំណីផ្ទុកសារធាតុចិញ្ចឹមទាប បើទោះជាគោស៊ីរហូតដល់ពេញពោះក៏វាមិនអាចទទួលបានសារធាតុចិញ្ចឹមគ្រប់គ្រាន់ដែរ។



គោទាំងនេះមិនមែនឈឺទេ ពួកវាស៊ីតែចំបើងមួយមុខ និងមិនអាចស៊ីបានគ្រប់ចំនួនដើម្បីឆ្លើយតបនឹងតម្រូវការរបស់វា

> **ថាមពល:**

ថាមពលត្រូវការចាំបាច់ដូចជា:

- **ការទ្រទ្រង់ (ការថែទាំ)**: ដើម្បីទ្រទ្រង់មុខងាររាងកាយ (ការរំលាយអាហារ ដកដង្ហើម កំដៅ...)
- **មេផើម** : ត្រូវការថាមពលច្រើននៅមួយខែមុនពេលកើត និងពេលកូនក្នុងពោះរីកចំរើនលឿន។
- **ការបំបៅដោះ** : កង្វះថាមពលមានឥទ្ធិពលដល់ការផលិតទឹកដោះ។ មេគោត្រូវប្រើប្រាស់សារធាតុបម្រុងរបស់ខ្លួន ធ្វើឲ្យវាចុះស្គម។



បង្កើនរបបចំណីថាមពល បង្កើនការផលិតទឹកដោះ កូនគោធំលូតលាស់ល្អ និងខ្លាំងក្លា មេគោមិនស្រកទម្ងន់

- **ការបំប៉ន** : ថាមពលដែលនៅសល់អាចប្រើ ដើម្បីកើនទម្ងន់
- **ការអូសទាញ** : ការភ្ជួររាស់ សត្វត្រូវការថាមពលខ្លាំង ប្រសិនបើគោមិនបានស៊ីចំណីគ្រប់គ្រាន់ក្នុងពេលភ្ជួររាស់ វានឹងបាក់កំលាំង និងធ្វើការយឺត។
- **ថាមពល** ត្រូវបានផ្តល់តាមរយ: ៖
- **ជាតិសរសៃ** (សៃលុយឡូស) : ចំណីសត្វ និងចំបើងមានជាតិសរសៃច្រើន
- **ម្សៅ** មានច្រើនក្នុងមើមដំឡូងមី ពោត និងកន្ទក់
- **ខ្លាញ់** មានក្នុងកន្ទក់ស្រូវ។

> **ប្រូតេអ៊ីន:**

ការផ្តល់ប្រូតេអ៊ីនដល់សត្វទំពារអៀងមានពីរប្រភេទ:

- **ប្រូតេអ៊ីនមានដើមកំណើតពីរុក្ខជាតិ:** ដូចជា រុក្ខជាតិខ្ចីៗ ស្លឹកឈើ : ស្មៅស្ងួតមានប្រូតេអ៊ីន ៧% ស្តេចស្មៅមានប្រូតេអ៊ីន៨% ស្លឹកកន្ទុំថេតមានប្រូតេអ៊ីន១៨% និងស្លឹកដំឡូងមីមានប្រូតេអ៊ីន២៤%។



ស្តេចស្មៅ



ស្លឹកកន្ទុំថេត



ស្លឹកដំឡូងមីត្រូវសម្ងួតដោយពន្លឺថ្ងៃ មុនឲ្យគោស៊ី

- **មីក្រូសរីរាង្គក្នុងពោះធំ** : បានជួយរំលាយ និងផ្តល់ជាប្រូតេអ៊ីនដល់គោ។ គោអាចប្រើជាតិអ៊ុយរ៉េផងដែរ ដែលវាបំលែងជាអាម៉ូញ៉ាក់ដើម្បីទៅចិញ្ចឹមមីក្រូសរីរាង្គ។ អ៊ុយរ៉េជាសារធាតុផលិតប្រូតេអ៊ីន ដែលមានចំពោះតែសត្វទំពារអៀងប៉ុណ្ណោះ។

តម្រូវការរបស់សត្វប្រែប្រួល:

- **សម្រាប់ការទ្រទ្រង់** : ចំណី (ប្រូតេអ៊ីននៅមាន៧%) គ្រប់គ្រាន់សម្រាប់តម្រូវការប្រូតេអ៊ីនរបស់មេគោ។
- **សម្រាប់បំបៅដោះ** : ទឹកដោះមានប្រូតេអ៊ីនខ្ពស់ ។ ប្រូតេអ៊ីនមួយផ្នែកបានមកពីចំណី និងមួយផ្នែកផ្សេងទៀតបានមកពីសាច់ដុំរបស់គោ ដូចនេះវាធ្វើឲ្យគោចុះស្គម ប្រសិនបើផ្តល់តែស្មៅ និងចំបើង។
- **កំឡុងពេលផើម** : ក្នុងពេលផើម កូនគោលូតលាស់ពិសេសខែចុងក្រោយ ដូចនេះយើងត្រូវបន្ថែមប្រូតេអ៊ីនក្នុងចំណីក្នុងកំឡុងពេលនេះ ដោយផ្តល់ចំណីផ្សំ ឬកន្ទក់ ឬ ចំបើងផ្អាប់ដោយអ៊ុយរ៉េ (ដែលមានប្រូតេអ៊ីន ៧ទៅ១២%) តែចំបើងមានប្រូតេអ៊ីន ២ទៅ៤%។

- **ការលូតលាស់** : សាច់ដុំមានប្រូតេអ៊ីនលើសពី៥០% ដូចនេះ ការលូតលាស់ត្រូវការប្រូតេអ៊ីនយ៉ាងច្រើន។




- **ការភ្ជួររាស់** : ចំណីតែមួយមុខ គោមិនអាចស៊ីគ្រប់គ្រាន់ដើម្បីបំពេញថាមពល និងប្រូតេអ៊ីន ដែលបានបាត់បង់ក្នុងពេលធ្វើការក្នុងស្រែទេ។ ដូច្នេះត្រូវផ្តល់ចំណីផ្សំបន្ថែម ដើម្បីកុំឲ្យគោចុះស្គម។

➢ **សារធាតុរ៉ែ:**

សារធាតុរ៉ែមានតិចតួចក្នុងចំណីគោ ប៉ុន្តែគោត្រូវការសារធាតុរ៉ែនេះច្រើន សម្រាប់ទ្រទ្រង់ លូតលាស់ និងការផលិត។ សារធាតុរ៉ែម៉ាក្រូចំនួន៧ប្រភេទ រួមមាន: កាល់ស្យូម ផូស្វ័រ ម៉ាញ៉េស្យូម សូដ្យូម ប៉ូតាស្យូម ក្លរ និងស្ពាន់ធ័រ (Ca, P, Mg, Na, K, Cl, S)


ការផ្លាស់ប្តូរពណ៌រោម ជ្រុះរោម ជាសញ្ញានៃការកង្វះជាតិរ៉ែ ជាពិសេសជាតិសង្កសី និងទង់ដែង

សារធាតុរ៉ែចំនួន១៨ ដែលចាំបាច់មាន: ដែក ទង់ដែង កូបាល់ សង្កសី អ៊ីយ៉ូត ម៉ង់កាណែស សេលីញ៉ូម ... (Fe, Cu, Co, Zn, I, Mn, Se...)

សមាសភាពរ៉ែក្នុងរុក្ខជាតិ និងក្នុងដីអាចមានផលប៉ះពាល់ដល់គោ។ ឧទាហរណ៍: ពេលគោខ្វះជាតិរ៉ែ យើងអាចសង្កេតឃើញរោមសត្វមានពណ៌ស្រអាប់ និងបញ្ហាបន្តពូជ។ កសិករគួរដាក់នំគោដែលមានជាតិរ៉ែឲ្យវាលិទ្ធរៀងរាល់ថ្ងៃដើម្បីទទួលបានជាតិរ៉ែគ្រប់គ្រាន់។

- **វីតាមីន:**

វីតាមីនចាំបាច់ណាស់ដើម្បីប្រើប្រាស់សារធាតុផ្សេងៗទៀតឲ្យមានប្រសិទ្ធភាព។

- វីតាមីនអា (Vitamin A) សំខាន់ជាងគេបំផុតសម្រាប់គោ។ សម្រាប់ការលូតលាស់ បន្តពូជ ទ្រទ្រង់ស្បែក និងការលូតលាស់ឆ្អឹង។ ចំណី និងស្លឹកឈើដែលមានគុណភាព ផ្តល់បរិមាណវីតាមីនអាគ្រប់គ្រាន់ ប៉ុន្តែចំបើងមិនមានទេ។
- ក្រុមវីតាមីនបេ (Vitamin B) ត្រូវបានសំយោគក្នុងពោះធំ។

## ៣.៣ ការរៀបចំចំណីបន្ថែម



នៅក្នុងពេលបំបៅដោះ ពេលសត្វធ្វើការបាក់កំលាំង ឬពេលគោស្គម ការផ្តល់ចំណីតែមួយមុខ នោះមិនមានគុណភាពគ្រប់គ្រាន់នោះទេ។ កសិករអាចរកស្មៅដែលមានគុណភាពខ្ពស់ មានដូចជាស្តេចស្មៅ ហ្គីណៀរ ណាពៀ និងស្លឹករុក្ខជាតិដូចជា រលួស កន្ទុំថេត ។

- **រូបមន្តនៃការផលិតចំណីផ្សំ :**
  - កន្ទក់ស្រូវ ១២គីឡូក្រាម
  - មើមដំឡូងមីស្ងួតចំណិតតូចៗ ៧គីឡូក្រាម
  - ម្សៅស្លឹកដំឡូងមីស្ងួត ៣គីឡូក្រាម
  - អ៊ុយរ៉េ ០, ៣គីឡូក្រាម
  - អំបិល ០,២៥គីឡូក្រាម
  - ស្ករត្នោត០,២៥គីឡូក្រាម

➢ ការឲ្យគោស៊ី ២០០ក្រាមក្នុងមួយថ្ងៃ ដើម្បីបង្កើនគុណភាពរបបចំណីរបស់គោទម្ងន់ ២០០គីឡូក្រាម និង ៥០០ក្រាមក្នុងមួយថ្ងៃ អាចជួយដល់គោធ្វើការ និងផលិតទឹកដោះ។

ការផ្តល់១ទៅ២គីឡូក្រាមក្នុងមួយថ្ងៃរយៈពេល៦អាទិត្យ សម្រាប់បំប៉នមុនលក់។ គួរផ្តល់បរិមាណចំណីពាក់កណ្តាលនៅពេលព្រឹក និងពាក់កណ្តាលទៀតពេលយប់។

➢ ការផលិតស្លឹកដំឡូងមីស្ងួត (ប្រូតេអ៊ីន ២៥%)

- ដាំដំឡូងមីលើថ្នាលដែលមានគម្លាត ៤០, ៦០ សង់ទីម៉ែត្រពីដើម និងពីជួរនិមួយៗ

- ដំឡូងមីអាចប្រមូលផលលើកទីមួយ បន្ទាប់ពីដាំបាន ៣ ទៅ ៤ខែ។ ដំឡូងមីអាចប្រមូលផលលើកទី២ នៅចន្លោះពីរខែបន្ទាប់មកទៀត ដើម្បីផលិតម្សៅស្លឹកដំឡូងមីស្ងួត បន្ទាប់ពីការលាស់ស្លឹកសារជាថ្មី។ គេអាចប្រមូលពី ៤ទៅ៥ដងសម្រាប់ពេញមួយឆ្នាំ។

- បន្ទាប់ពីប្រមូលផល ស្លឹកដំឡូងមីត្រូវសម្ងួត (១ ទៅ ២ថ្ងៃ) ដើម្បីផលិតជាម្សៅ។

- ដំឡូងមីមានជាតិពុលដែលគេហៅថា អាស៊ីតស្យានិត (HCN )។ ការសម្ងួតអាចកាត់បន្ថយកម្រិតជាតិពុលលើសពី ៩០% ហើយពេលនេះស្លឹកអាចឲ្យសត្វស៊ីបាន។

- ការសម្ងួតដោយព្រះអាទិត្យត្រូវសម្ងួតរហូតដល់ស្ងួតក្រៀម។ ស្លឹកដំឡូងមីអាចរក្សាទុកបានច្រើនអាទិត្យ។


ដំឡូងមី

ការប្រមូលផលស្លឹកដំឡូងមី



ចិញ្ច្រាំ និងហាលថ្ងៃ


ទុកដាក់ក្នុងបាវបានរាប់ខែ

➢ **ការធ្វើចំណីផ្សំ**

- គ្រប់សមាសធាតុផ្សំទាំងអស់ត្រូវលាយច្របល់ដោយប្រុងប្រយ័ត្នដោយដៃ
- កូរស្ករជាមួយទឹកឲ្យសព្វបន្ទាប់មកប្រស់ (ស្រោច)លើគំនរចំណី និងច្របល់ឲ្យសព្វល្អ។













## ៣.៤ ចំបើងផ្អាប់ដោយអ៊ុយរ៉េ

គោលបំណងដើម្បីបង្កើនសារធាតុចិញ្ចឹមរបស់ចំបើង។

អ៊ុយរ៉េ ត្រូវលាយជាមួយទឹក និងចំបើង។

- អាម៉ូញ៉ាក់ដែលមាននៅក្នុងអ៊ុយរ៉េ ធ្វើឲ្យគុណភាពចំបើងកើនឡើង ដូចជាធ្វើឲ្យជាតិសសៃរឹងងាយរលាយ (ចំបើងអាចងាយរំលាយ)
- អាម៉ូញ៉ាក់បង្កើនការផ្ទុកនីត្រូសែនក្នុងចំបើង និងជួយដល់ការលូតលាស់របស់ពួកមីក្រុបក្នុងពោះធំ
- ការផ្អាប់ចំបើងជាមួយអ៊ុយរ៉េ នឹងបង្កើនគុណភាពសារធាតុចិញ្ចឹម និងបរិមាណស៊ីចំបើងបានច្រើន។

➢ **ការធ្វើចំបើងផ្អាប់ដោយអ៊ុយរ៉េ**

កត្តាសំខាន់ៗរួមមាន៖

- បរិមាណអ៊ុយរ៉េគឺ ៥គីឡូក្រាមសម្រាប់ផ្អាប់ជាមួយចំបើងស្ងួត១០០គីឡូក្រាម
- បរិមាណសំណើមគឺ អ៊ុយរ៉េ១គីឡូក្រាមលាយជាមួយទឹក១០លីត្រ
- រយៈពេលផ្អាប់គឺ ចំបើងអាចឲ្យគោស៊ីនៅពីរអាទិត្យបន្ទាប់ពីផ្អាប់ក្នុងខែក្តៅ ព្រោះវាមានសីតុណ្ហភាពលើសពី៣០អង្សាសេ ប៉ុន្តែយើងត្រូវរង់ចាំ៣អាទិត្យក្នុងខែត្រជាក់ ពីព្រោះវាត្រជាក់ និងដំណើរការផ្អាប់មានសភាពយឺត។
- ការគ្របចំបើង ត្រូវគ្របឲ្យជិតចៀសវាងខ្យល់ចូលប៉ះជាមួយនឹងចំបើង។


ចំបើងត្រូវរៀបចូលក្នុងអាងជាស្រទាប់ៗដែលទម្ងន់ប្រហែល២០គីឡូក្រាម


កសិករជាន់បង្ហាប់ចំបើងជាស្រទាប់ៗ


ថ្លឹងអ៊ុយរ៉េ


អ៊ុយរ៉េ១គីឡូក្រាមសម្រាប់ទឹក១០លីត្រ


ល្បាយទឹកអ៊ុយរ៉េត្រូវស្រោចលើចំបើងមួយស្រទាប់ម្តងមួយស្រទាប់ម្តង


គ្របកៅស៊ូលើអាងដើម្បីប្រាកដថាខ្យល់មិនបានប៉ះពាល់ជាមួយចំបើង


៣អាទិត្យក្រោយទៀតចំបើងរួចរាល់សម្រាប់ឲ្យគោស៊ី


ការផ្អាប់ដោយអ៊ុយរ៉េបង្កើននិជារស


បន្ទាប់ពីឲ្យចំបើងបានមួយខែ ស្បែក និងសភាពរាងកាយកែលំអរយ៉ាងខ្លាំង

- **ការស៊ីចំបើងផ្អាប់**
  - គោមួយក្បាលទម្ងន់៣០០គីឡូក្រាម អាចស៊ីចំបើងផ្អាប់៦គីឡូក្រាមក្នុងមួយថ្ងៃ។
  - គោពីរក្បាល ស៊ី១២គីឡូក្រាមក្នុងមួយថ្ងៃ
  - រយៈពេលផ្អាប់គឺ៣អាទិត្យ ដូចនេះកសិករត្រូវរៀបចំបរិមាណចំបើងដើម្បីផ្តល់ឲ្យគោក្នុងពេល៣អាទិត្យ គឺស្មើនឹង១២គីឡូក្រាម គុណនឹង២១ថ្ងៃ ស្មើនឹង២៥២គីឡូក្រាម។
  - បរិមាណ១០០គីឡូក្រាមចំបើងផ្អាប់ដោយអ៊ុយរ៉េ គឺប្រហែល១ម៉ែត្រគូប ដូចនេះអាងត្រូវមានទំហំធំជាង២,៥ម៉ែត្រគូប។
  - ពេលគោស៊ីចំបើងក្នុងអាងទី១ កសិករត្រូវរៀបចំផ្អាប់ក្នុងអាងទី២ទៀត ពេលគោស៊ីនៅអាងទី១អស់បន្ទាប់ពី៣អាទិត្យ នោះអាងទី២ក៏រួចរាល់សម្រាប់បើកឲ្យគោស៊ីដែរ។ ពេលគោចាប់ផ្តើមស៊ីនូវអាងទី២ កសិករត្រូវចាប់ផ្តើមផ្អាប់អាងទី១ជាថ្មីទៀត។

- ដើម្បីផ្តល់ចំបើងផ្អាប់ដោយអ៊ុយរ៉េជាចំណីគោ កសិករត្រូវសាងសង់អាងពីរដែលមានទំហំ៣ម៉ែត្រគូប។



អាងពីរដែលមានទំហំដូចគ្នាត្រូវបានសាងសង់រួច




អាងទាំងពីរនឹងត្រូវរៀបចំបើងពេញនៅ៣អាទិត្យក្រោយមកពេលគោចាប់ស៊ីចំបើងផ្អាប់ក្នុងអាងទី១





# ជំពូកទី៥៖ ការចាប់ និងការពិនិត្យសត្វ





ការចាប់ និងការពិនិត្យសត្វ៖

- ត្រូវធ្វើឲ្យសត្វមានសុវត្ថិភាព
- មិនត្រូវធ្វើឲ្យសត្វស្ត្រេស
- ត្រូវមានជំនាញដើម្បីចាប់សត្វ និងព្យាបាលសត្វ

# ក-បក្សី

## ១-ការពិនិត្យហ្វូងសត្វ

➢ **ទិដ្ឋភាពទូទៅ**

មាន់ដែលមាំមួនមានពោម ស្លាបភ្លឺរលោង ការលូតលាស់រាងកាយល្អ គឺជាសញ្ញាសត្វមានសុខភាពល្អ។

- ពេលឃើញមាន់ងាប់ក្នុងសភាពល្អ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវសង្ស័យជាបន្ទាន់ទៅលើជំងឺស្រួចស្រាវដែលសម្លាប់មាន់ក្នុងរយៈពេលខ្លីដូចជាជំងឺផ្តាសាយបក្សី ដង្កោ(ញូវកាស)... ។



រាងវៃ ស្លាបភ្លឺរលោង ស៊ីចំណី



ស្គម មិនស៊ីចំណី មិនស្វរ មានពោម

➢ **ឥរិយាបថ**

- មាន់ត្រូវមានជងខ្លួនត្រង់ មាំមួន រវៀសរវៃ
- ពេលមាន់នៅបែកពីគេ ហើយបង្ហាញភាពស្ពឹកស្រពន់ និងងាយស្រួលចាប់នោះ ប្រហែលជាមានជំងឺហើយ។

ក្បាល និងកន្ទុយបះឡើង





បិទភ្នែក និងអស់កម្លាំង

➢ **ការដើរ**

- មាន់ចិញ្ចឹមជាលក្ខណៈគ្រួសារ ត្រូវមានជើងមាំ ដើម្បីស្វែងរកចំណី។ **ជើងខ្វិច:** មាន់ដើររកស៊ីចំណីដោយខ្លួនឯង តែងមានរបួស ធ្វើឲ្យវាឈឺជើង វាមិនអាចរកចំណីស៊ី បានគ្រប់គ្រាន់។ បើមិនមានការព្យាបាលត្រឹមត្រូវ មាន់នឹងចុះស្គម ហើយសត្វចង្រៃងាយចាប់ស៊ី។



មានជើងរឹងមាំដើម្បីស្វែងរកចំណីក្នុងភូមិ

ចំពោះមាន់ដើររកស៊ីចំណីដោយខ្លួនឯងដែលពិការ គឺមិនអាចរស់បានទេ



## ២-ការពិនិត្យផ្ទាល់

➢ **ការចាប់ (កាន់)**

អំឡុងពេលសង្កេតលើហ្វូងសត្វ មានសារៈសំខាន់ណាស់ ក្នុងការកំណត់សត្វ ដែលឈឺ (ខ្សោយ អស់កម្លាំង ឈឺជើង...)។ចាំបាច់ត្រូវចាប់មាន់ឈឺ និងកាន់វា ឲ្យបានត្រឹមត្រូវ ដើម្បីធ្វើការពិនិត្យឲ្យបានច្បាស់លាស់។ ការពិនិត្យនេះអាចកត់សម្គាល់នូវសញ្ញាគ្លីនិកមួយចំនួន ដែលជួយក្នុងការធ្វើរោគវិនិច្ឆ័យ។



➢ **ការពិនិត្យលើក្បាលមាន់**

- សិរ និងណង់ត្រូវមានពណ៌ក្រហមភ្លឺរលោង
- ភ្នែកត្រូវតែមានពន្លឺភ្លឺថ្លា និងវាងវៃ
- រន្ធច្រមុះត្រូវស្អាត មិនមានហៀរសំបោរ និងមិនឮសម្លេងដកដង្ហើម។



ហូរសំបោរ

➤ **ការពិនិត្យលើទ្រូងមាន់**

- បើពិនិត្យមើលមាន់ធាត់ ឬ ស្គម គឺជាគន្លឹះសំខាន់ ដើម្បីកំណត់ពីការផ្តល់ចំណីគ្រប់គ្រាន់ ឬមានជំងឺរ៉ាំរ៉ៃ ។ពេលខ្លះមានការពិបាកមើលចំពោះមេមាន់ ព្រោះរោម ស្លាបដុះច្រើន)។



➤ **ការពិនិត្យរន្ធគូថមាន់**

- ពិនិត្យមើលសញ្ញារាកនិងពិនិត្យមើលបរាសិត។





រន្ធគូថប្រឡាក់ដោយលាមក

➤ **ការពិនិត្យលើស្បែកមាន់ លើដងខ្លួន និងលើជើង**

- ពិនិត្យមើលស្លាកស្នាមរបួស
- ពិនិត្យមើលស្នាមប្រឡាក់
- ពិនិត្យមើលក្រមរ និងរន្ធគល់ស្លាប
- ពិនិត្យមើលបរាសិត។



ចៃ



ជើងក្រិន

# ខ-ជ្រូក

## ១-ការពិនិត្យទូទៅ

➤ **ស្វាហាប់ (មាំមួន)៖** ជាធម្មតាពេលយើងដើរមកក្បែរទ្រុង ជ្រូកក្រោកឈរ ព្រោះវាប្លែក តែបើជ្រូកខ្លះនៅតែដេក ប្រមូលគ្នាគឺជាសញ្ញាសត្វមានជំងឺ។

ជ្រូកទាំងអស់ រៀសរវៃ និងស៊ីចំណីបានល្អ



ជ្រូកប្រមូលផ្តុំគ្នានៅជ្រុងម្ខាង និងដេក



គ្មានជ្រូកណាមួយនៅក្បែរស្នូកចំណី

- **សភាពជងខ្លួន (រាងកាយ):** ជ្រូកប៉ុនៗគ្នាជាសញ្ញានៃការថែរក្សា និងសត្វមានសុខភាពល្អ។ ជ្រូកមិនធំធាត់ក្នុងទ្រុងតែមួយ ជាសញ្ញានៃជំងឺពុំរ៉ៃ ឬផ្តល់ចំណីមិនបានគ្រប់គ្រាន់។



ជ្រូកមានសភាពរាងកាយល្អ និងទំហំប៉ុនៗគ្នា



ជ្រូកមានសុខភាពល្អប៉ុន្តែមិនមានចំណីគ្រប់គ្រាន់

- **ការធ្វើចលនា:** វាមានសារៈសំខាន់សម្រាប់បសុពេទ្យ ដើម្បីពិនិត្យមើលថាតើសត្វអាចធ្វើចលនាបានធម្មតាឬទេ។ ជ្រូកនៅក្នុងទ្រុង ត្រូវដេញឲ្យក្រោកឈរ ប្រសិនបើមិនចង់ក្រោកឈរ ឬឈឺជើងដើម្បីធ្វើរោគវិនិច្ឆ័យ។



ជ្រូកអង្គុយចុះ ច្រត់ទ្រលើតែជង្គង់ (ច្រើនឃើញចំពោះជ្រូកកើតជំងឺប៉េស្ត)

- **ការស៊ីចំណី:** ការសង្កេតលើស្នូកចំណី បង្ហាញថាសត្វស៊ីចំណីបានល្អ ឬស៊ី មិនបានល្អ។ ពេលសត្វឈឺខ្លាំង វាឈប់ស៊ីចំណី។



សត្វស៊ីចំណីបានល្អ អស់ពីស្នូក



ចំណីនៅពេញស្នូក តែគ្មានជ្រូកស៊ី

- **ការក្អក:** ពេលយើងមកជិតទ្រុង ជ្រូកនឹងក្រោកឈរ និងផ្លាស់ទី ហើយបង្កឲ្យជ្រូកក្អក ជាពិសេសពេលព្រឹកព្រលឹម។ ប្រសិនបើជ្រូកនៅតែដេក យើងមិនអាចកំណត់បានទេ។

- **លាមក:** ត្រូវធ្វើការពិនិត្យអាចឃើញលាមករាកនៅលើផ្ទៃក្រាល ឬលើបន្ទះក្រោមផ្ទៃក្រាល។ ការទល់លាមកចំពោះមេជើម មានសារៈសំខាន់ណាស់។

កូនជ្រូករាក ឃើញក្រោមកម្រាលបន្ទះជ្រុង



រាក (ជំងឺកុកស៊ីដ្យូស) ឃើញលើកម្រាល និងជាប់លើជញ្ជាំង



## ២-ការពិនិត្យផ្ទាល់

ការពិនិត្យជ្រូកតែម្នាក់ឯងមានការលំបាក ព្រោះជ្រូកធ្ងន់ និងរើបម្រាស់លឿន ដូចនេះត្រូវមានគ្នាពីរនាក់ជាការប្រពៃ។

➢ **ការវាស់សីតុណ្ហភាព** ជាការសំខាន់ណាស់ ត្រូវវាស់នៅពេលព្រឹក ។សីតុណ្ហភាពឡើងខ្ពស់ជាសញ្ញានៃការឆ្លងជំងឺ។ សីតុណ្ហភាពធម្មតារបស់ជ្រូកគឺក្រោម៣៩អង្សាសេប៉ុន្តែអាចមានដល់៣៩,៥អង្សាសេ បើវាស់មិនច្បាស់ត្រូវវាស់ពេលបន្ទាប់មកទៀត។



➢ **ការពិនិត្យលើភ្នែក:**

- ភ្នែកមានហៀរអាចម៍ភ្នែក(ពពឹកភ្នែក) ជាទូទៅជាជំងឺប៉េស្តជ្រូក។
- ហើមត្របកភ្នែកជាការសម្គាល់របស់ជំងឺហើម។



ភ្នែកធម្មតា



ការឆ្លងជំងឺ (ប៉េស្តជ្រូក ត្រចៀកខៀវ...)

➢ **ការពិនិត្យលើស្បែក:**

- ដើម្បីកំណត់ការចេញឈាមក្រោមស្បែក (អាចជាជំងឺប៉េស្តជ្រូក)
- មានពណ៌ក្រហម និងលេចចេញចំណុចបូនជ្រុង អាចជាជំងឺកញ្ជ្រិល
- ស្នាមអុច និងក្រមរ អាចអង្គែ... ។



អង្គែ



ប៉េស្តជ្រូក

➢ **ការពិនិត្យលើច្រមុះ**

ដើម្បីមើលការហៀរសំបោរ ឈាម ឬខ្ទុះ ចំពោះជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ និងពងដោរ ចំពោះជំងឺអុតក្តាម (FMD)។



ខ្ទុះ (ជំងឺសារទឹក (ប៉ាស្ទឺរ៉ែឡា)



ឈាម(ជំងឺអាក់ទីណូបាក់ស៊ីលុស)

- **ការពិនិត្យលើយោនី** និងកម្រាលទ្រុង ដើម្បីកំណត់:
  - ការហូរសារធាតុរាវចេញពីយោនី ជាសញ្ញារលាកផ្លោកនោម ឬរលាកស្បូន
  - ការហើមយោនីជាសញ្ញានៃការរកឈ្មោល។



ខ្ទុះអាចចេញពីស្បូន ឬផ្លោកនោម



រកឈ្មោល (មករដូវ)

- **ការពិនិត្យលើកន្សោមដោះ:** មានភាពងាយស្រួល ពេលមេជ្រូកស្ថិតនៅក្នុងទ្រុងកើតកូន។ ការពិនិត្យនេះ ដើម្បីរកជំងឺរលាកស្បូន លាសដោះ និងអត់ទឹកដោះ(MMA) ឬជំងឺលាសដោះ ឬស្នាមរបួសលើក្បាលដោះ។



គ្មានទឹកដោះបន្ទាប់ពីកើតកូន: បញ្ហា រលាកស្បូន លាសដោះ និងអត់ទឹកដោះ



របួសក្បាលដោះដោយកូនជ្រូកខាំ

- **ការពិនិត្យលិង្គ និងពងស្វាស** ជ្រូកបា:
  - រកមើលមុខរបួស ឬការឆ្លងមេរោគផ្សេងៗ
  - ពិនិត្យមើលពងស្វាសទន់ មិនស្អិតជាប់ និងមានទំហំប៉ុនៗគ្នា។





ពងស្វាសលូតលាស់មិនបានល្អ

- **ការពិនិត្យលើរន្ធលាមក** អាចឲ្យយើង:
  - កំណត់ថា ជ្រូកមួយណារាក
  - ឃើញលៀនក្រសាល់គូថចេញមកក្រៅ។





➢ **ការពិនិត្យលើជើង:** ពេលមេជ្រូកដេក អាចឲ្យយើងសង្កេតទៅលើក្រចក:

- ដើម្បីមើលស្លាកស្នាមដំបៅជើងធ្ងន់ធ្ងរ
- ដើម្បីមើលស្លាកស្នាមនៃជំងឺអុតក្ដាម។





## ៣-ការចាប់ជ្រូក

➢ **កូនជ្រូក:** កូនជ្រូកនៅក្នុងទ្រុង ត្រូវចាប់កាន់ជើងក្រោយ ដើម្បីដាក់កន្លែងផ្សេងសម្រាប់ចាក់ថ្នាំ គ្រៀវ កាត់ធ្មេញ...។



ការចាប់កូនជ្រូកក្នុងទ្រុង

ការបញ្ច្រូកថ្នាំ



➢ **ជ្រូកសាច់ :** ជាទូទៅការចាក់ជ្រូកដោយមិនបានចាប់កាន់ឲ្យបានត្រឹមត្រូវ បណ្ដាលឲ្យការចាក់ថ្នាំខុសទីតាំង និងមិនតាមលក្ខណៈបច្ចេកទេស។ ដើម្បីឲ្យជ្រូកនៅស្ងៀម ដូចនេះត្រូវប្រើប្រដាប់ទាក់ចាប់ជ្រូក។ ប្រដាប់ទាក់ចាប់ជ្រូកអាចជាខ្សែមួយ ដែលមិនរអិល។ពេលចាប់ថ្គាមលើ ជ្រូកថយក្រោយខ្លាំង ហើយបើខ្សែជាប់ស្អិត វាមិនអាចរើទៀតទេ។



ចាប់ជ្រូកទម្ងន់៥០គីឡូក្រោម ដោយចាប់ត្រចៀកនិងកន្ទុយ



➢ **មេជ្រូក:** ប្រដាប់ទាក់ចាប់ជ្រូក អាចប្រើសម្រាប់ទាក់ចាប់មេជ្រូក ផងដែរ ប៉ុន្តែបើមេជ្រូកនៅក្នុងទ្រុងដាច់តែឯង ការអនុវត្តអាចមិនចាំបាច់ចាប់វាទេ។



# គ-គោ

## ១-ការពិនិត្យទូទៅ

➢ **ស្ថានភាពដងខ្លួន (រាងកាយ)**

ស្ថានភាពស្គមអាចជាសញ្ញាកង្វះចំណីជំងឺរ៉ាំរ៉ៃ ឬចម្លងបរាសិត។ សត្វស្គមមិនងាយជាឆាប់រហ័សនោះទេ។ផ្ទុយមកវិញពេលសត្វមានស្ថានភាពរាងកាយល្អ តែវាឈឺត្រូវសង្ស័យទៅលើជំងឺស្រួចស្រាវ។





➢ **ទិដ្ឋភាពស្បែក:**

- វាជាសញ្ញាសំខាន់ចំពោះគោក្របី: រោមស្រអាប់ ខូចពណ៌ក្រមរ...កើតឡើងដោយសារកង្វះជាតិវីតាមីន និងសារធាតុរ៉ែ គោក្របីទាំងនេះខ្សោយក្នុងការទប់ទល់នឹងការឆ្លងជំងឺ។


កង្វះខាតសារធាតុរ៉ែ និងវីតាមីន


របួសដោយប្រតិកម្មចាញ់ពន្លឺថ្ងៃ

- ប្រតិកម្មចាញ់ពន្លឺថ្ងៃកើតមាន ជាទូទៅក្នុងប្រទេសកម្ពុជានិង ងាយស្រួលក្នុងការកំណត់បញ្ហានេះ។

➢ **ការធ្វើចលនា (ការដើរ)**

- ដំបូងត្រូវសង្កេតលើគោក្របី ដែលក្រោកឈរ ដើម្បីកំណត់ពីភាពខ្សោយរបស់វា។ ឧទាហរណ៍ វាកើតមានដោយសារកង្វះសារធាតុបន្ទាប់ពីកើតកូន ឬឈរមិននឹងបណ្តាលមកពីជំងឺសរសៃប្រសាទ ដូចជាជំងឺពុលដោយការស៊ីចំណីមិនស្អាត (Botulism)។







ពេលគោ ក្របីដើរ ងាយស្រួលដើម្បីពិនិត្យមើលការខ្វកជើង:

- សត្វក្រោក ប៉ុន្តែប្រឹងចៃរជើងមួយទៅមួយទៀត មេគោបន្ទន់ខ្លួនចុះនៅប៉ុន្មាននាទីក្រោយមកសត្វមិនអាចទ្រខ្លួនលើជើងតែម្ខាង។

➢ **ការដកដង្ហើម:**




- ការដកដង្ហើមជាធម្មតា ចលនាតាមទ្រូង និងពោះ ដោយធ្វើចលនារួមគ្នានឹងមានចង្វាក់១០ទៅ២០ដងក្នុងមួយនាទី សម្រាប់សត្វពេញវ័យ។
- ពេលសីតុណ្ហភាពក្តៅ ឬពេលមានជំងឺផ្លូវដង្ហើមនោះ ចង្វាក់ដកដង្ហើមកើនឡើងយ៉ាងច្បាស់ មាត់សត្វអាចបើក។
- ការក្អកងាយស្រួលក្នុងការពិនិត្យឃើញពេលសត្វធ្វើចលនា។

➢ **លាមក:**

ការពិនិត្យលាមកអាចផ្តល់នូវព័ត៌មានដូចជា:




- ពណ៌ពីខ្មៅដូរទៅជាខៀវ អាស្រ័យលើចំណីនិងមុខងាររបស់ថ្លើម
- មានឈាម ឬសំបោរដូចជាជំងឺដង្កូវថ្លើម
- រាកបណ្តាលពីស៊ីស្មៅខ្ចីច្រើនពេក ឬមានព្រូន
- គៀនពេលគោក្របីស៊ីមិនគ្រប់គ្រាន់ពីព្រោះសីតុណ្ហភាពក្តៅ។

## ២-ការពិនិត្យផ្ទាល់

➢ **ពិនិត្យសីតុណ្ហភាព:**

- សត្វពេញវ័យ ពី៣៨ ទៅ៣៩អង្សាសេ
- កូនគោពី៣៩ទៅ៤០អង្សាសេ។
- ជាទូទៅសីតុណ្ហភាពខ្ពស់ជាសញ្ញានៃការឆ្លងជំងឺ។



➢ **ពិនិត្យលើភ្នែក** អាចកំណត់ពី:

- ការឆ្លងមេរោគលើភ្នាស ស្តើងខាងក្នុងភ្នែកធ្វើឲ្យហូរទឹកភ្នែក
- របួសលើភ្នែកជារឿយៗសត្វបិទភ្នែក
- កំណត់ពណ៌ភ្នាសស្តើងភ្នែក: បើភ្នាសស្តើងខាងក្នុងភ្នែកស្លេកស្លាំងជាសញ្ញាកង្វះឈាមក្រហមច្រើនកើតចំពោះសត្វដែលមានជំងឺដង្កូវថ្លើម។







➢ **ពិនិត្យលើមាត់:**

ក្រអូម និងមាត់ត្រូវពិនិត្យជាពិសេសពេលសត្វមានចេញទឹកមាត់ខុសប្រក្រតី វាអាចបណ្តាលមកពីរបួសមុតឈើ ឬដែកឬស្លាកស្នាមនៅលើអញ្ចាញនិងអណ្តាតដោយសារជំងឺអុតក្តាម។







➢ **ពិនិត្យលើស្បែកមានសារៈសំខាន់ដើម្បី:**

- មើលបរាសិតខាងក្រៅដូចជាដង្កែ
- សង្កេតពីក្រមរ ដែលអាចបង្ក
- ដោយអង្កែ ឬការដាច់រលាត់
- ការវាយតំលៃពីដំបៅ។






➤ **ពិនិត្យជើង:** ចាំបាច់ត្រូវពិនិត្យបាតជើង ក្រចក និងសន្លាក់ ដើម្បីដឹងពីមូលហេតុ ដែលបណ្ដាល ឲ្យមានបញ្ហាខ្ចកជើង។






➤ **ការពិនិត្យលើកន្សោមដោះ និងទឹកដោះ** : ពេលកូនគោមិនបៅដោះ ឬ រាគ ឬ លូតលាស់មិនល្អ ចាំបាច់ត្រូវពិនិត្យមើលកន្សោមដោះ

- ដំបូងត្រូវពិនិត្យ បើក្បាលដោះមិនធំពេក ឬ មានរាងខុសធម្មតា
- បន្ទាប់មកបសុពេទ្យត្រូវពិនិត្យថា តើកន្សោមដោះរឹង និងមានទឹកដោះចេញធម្មតាឬទេដើម្បីវិនិច្ឆ័យលើជំងឺលាសដោះ។





➤ **ពិនិត្យលើលិង្គ និងពងស្វាស:**

- លិង្គត្រូវតែមានប្រវែងល្មម គួរលៀនមកស្មើរតែដល់ចន្លោះជើងមុខទាំងពីរ នៅពេលវាមានចំណង់និងលៀនចេញ។ គោឈ្មោលដែលមានលិង្គខ្លីមិនអាចបង្កាត់ពូជបានទេ។
- ពងស្វាសគួរតែកម្រើកបានដោយសេរីខាងក្នុងស្បែកស្រោបពងនិងមានទំហំប៉ុនគ្នា។



➢ **ពិនិត្យលើរន្ធគូថ**

- បច្ចេកទេសនេះមានសារៈសំខាន់ដើម្បីបញ្ជាក់ថា: គោផើមរហូតដល់៤ខែ ពីព្រោះស្បូនធ្ងន់និងធ្លាក់ចុះក្នុងពោះ
- តាមការសិក្សាការពិនិត្យនេះ អាចឲ្យយើងដឹងពីដុំពក(គីស្ត)នៅលើដៃស្បូន។



## ៣-ការចាប់

➢ **ការចាប់កូនគោ**

មនុស្សម្នាក់អាចចាប់កូនគោទើបកើតបាន ប៉ុន្តែ ពេលចាប់កូនគោអាយុពី៦ខែ ត្រូវការមនុស្សពីរនាក់ ដើម្បីជួយ។

➢ **ការចាប់គោពេញវ័យ**





ជាធម្មតាការចងគោជាប់នឹងដើមឈើ ដើម្បីចាក់ថ្នាំ មិនមានសុវត្ថិភាព និងមិនងាយស្រួលក្នុងការអនុវត្តលើសត្វទេ។ បច្ចេកទេសនេះអាចប្រើបានចំពោះការចាក់ថ្នាំតែមួយម្ជុល ឬការអនុវត្តលឿន។

- ការចាប់ច្រមុះឲ្យខ្លាំង អាចមិនឲ្យសត្វរើបាន ប៉ុន្តែបច្ចេកទេសនេះអាចប្រើបាន ចំពោះតែសត្វដែលស្លូត និងសត្វមិនធំពេកទេ។





- មានវិធីងាយៗជាច្រើនត្រូវបានប្រើដើម្បីចាប់សត្វ។




បច្ចេកទេសល្អបំផុត ក្នុងការចាប់គោ ត្រូវធ្វើសាឡុង ដើម្បីងាយស្រួលក្នុងការអនុវត្តនិងមានសុវត្ថិភាពទាំងសត្វ និងមនុស្ស។

- **ការផ្តួលគោ**

ប្រើខ្សែប្រវែងប្រហែល១០ម៉ែត្រ ដើម្បីផ្តួលគោពេញវ័យឲ្យដួលដោយសុវត្ថិភាព និងគ្មានគ្រោះថ្នាក់។

# ក. មាន់

## ១. ការប្រើប្រាស់បសុឱសថ

### ១.១ ការបន្តក់ភ្នែក:

ច្រើនធ្វើពេលបន្តក់វ៉ាក់សាំង។ ជាការប្រសើរត្រូវប្រើទឹកលាយ ដែលមានពណ៌ ដើម្បីមើលឃើញច្បាស់នូវតំណក់វ៉ាក់សាំង បានចូលក្នុងភ្នែកកូនមាន់។



ការធ្វើវ៉ាក់សាំងញូវកាសចំពោះកូនមាន់អាយុមួយថ្ងៃ

### ១.២ ការចាក់ថ្នាំ:

- ប្រើសម្រាប់ចាក់វ៉ាក់សាំង ឬ ថ្នាំផ្សេងៗ ដូចជាថ្នាំអង់ទីប៊ីយ៉ូទិក។
- ថ្នាំភាគច្រើនចាក់លើសាច់ដុំទ្រូង
- ថ្នាំមួយចំនួនអាចពុលពេលចាក់លើជើង ព្រោះថ្នាំនឹងចូលទៅផ្ទាល់ក្នុងក្រលៀន។

ការចាក់ថ្នាំអុកស៊ីតេត



### ១.៣ ការជួសស្លាប:

ចាក់ទម្លុះផ្នែកស្តើងនៃសន្ទះស្លាប ដើម្បីចាក់វ៉ាក់សាំងការពារជំងឺអុតបក្សី។



### ១.៤ ការដាក់ក្នុងទឹក:

វ៉ាក់សាំង ថ្នាំអង់ទីប៊ីយ៉ូទិក និងវីតាមីន អាចដាក់ក្នុងទឹក។ ដើម្បីប្រាកដថា សត្វទាំងអស់នឹងផឹកថ្នាំបានគ្រប់គ្នា ត្រូវដកស្នូកទឹកចេញ ១ ទៅ ២ម៉ោងមុន។ បន្ទាប់មកលាយថ្នាំជាមួយទឹករួចទើបយើងចាប់ផ្តើមឲ្យវាផឹក ហើយស្របពេលសត្វស្រេកទឹក នោះវានឹងផឹកបានគ្រប់គ្នា។

ថ្នាំឬវ៉ាក់សាំងលាយក្នុងទឹក សម្រាប់ឲ្យមាន់ទាំងអស់ផឹក



## ១.៥ ការដាក់ក្នុងចំណី:

ថ្នាំខ្លះមិនរលាយ ឬពេលខ្លះកសិករប្រើថ្នាំសម្រាប់មនុស្សជំនួស ដូច្នេះងាយស្រួលលាយក្នុងចំណី។ ប៉ុន្តែត្រូវដឹងថាមាន់ឈឺនៅបន្តផឹកទឹក តែឈប់ស៊ីចំណី។

## ២. ការវះកាត់

រាល់ការវះកាត់សត្វដែលឈឺ និងងាប់ អាចធ្វើទៅបានត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់មន្ត្រីបសុពេទ្យ

ការវះកាត់ពិនិត្យសាកសព ជាការត្រួតពិនិត្យលើសាកសពសត្វ ក្នុងគោលបំណងពិនិត្យមើលស្លាកស្នាមដំបៅរបស់សរីរាង្គ ដើម្បីជួយក្នុងការធ្វើរោគវិនិច្ឆ័យជំងឺ។ ឧបករណ៍ចាំបាច់ដើម្បីវះកាត់សាកសពបក្សី គឺកាំបិតមុតស្រួច។ បន្ទាប់ពីការវះកាត់រួច សាកសព ត្រូវដុត ឬកប់។ ចូរកុំបោះវាចោលពាសវាលពាសកាល ព្រោះវាអាចសាយភាយមេរោគ។

**ការប្រុងប្រយ័ត្ន:** ជំងឺមាន់មួយចំនួនអាចចម្លងមកមនុស្ស យើងត្រូវតែពាក់ស្រោមដៃផ្លាស្ទិកពេលដំណើរការវះកាត់សាកសព និងលាងដៃដោយប្រុងប្រយ័ត្នជាមួយសាប៊ូ បន្ទាប់ពីធ្វើការវះកាត់រួច។

- *ក្នុងករណីសង្ស័យជំងឺផ្តាសាយបក្សី (អត្រាបក្សីងាប់ខ្ពស់ ហើយលឿន) យើងមិនត្រូវធ្វើការវះកាត់សាកសពទេ និងត្រូវផ្ញើសាកសពមកកាន់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល។*

### ២.១ ការពិនិត្យលើក្បាល:

- **ភ្នែក:** ការហើម ឡើងក្រហមខុស ធម្មតា គឺជាសញ្ញាជំងឺផ្លូវដង្ហើម។
  ការស្អិតត្របកភ្នែកបានឃើញចំពោះជំងឺកូរីសា (Coryza) និងការហូរទឹកភ្នែកចំពោះជំងឺផ្តាសាយបក្សី និងជំងឺរលាកទងសួត។ ជំងឺម៉ារិក (Marek) បង្កជាដុំសាច់លើប្រស្រីភ្នែក និងធ្វើឲ្យខ្វាក់ភ្នែក។



ការហូរទឹកភ្នែកចំពោះជំងឺផ្តាសាយបក្សី

- **ខាងក្នុងមាត់:** ខ្ទុះឬស្លេះជាសញ្ញាជំងឺផ្លូវដង្ហើម មានដូចជា ជំងឺកូរីសា មីកូផ្លាស្មា អាសន្នរោគ ឬជំងឺរលាកទងសួត។ ការរលាកភ្នាស និងដំបៅ ជាសញ្ញាជំងឺអុតបក្សី។





## ២.២ ការពិនិត្យបំពង់ក:

**បំពង់ខ្យល់:** ការកាត់ដើមក និងបំពង់ខ្យល់ ដើម្បីសង្កេតឲ្យបានច្បាស់នូវសញ្ញានៃជំងឺរលាកទងសួត។ ស្លេះលាយឈាម មានលើជំងឺផ្តាសាយបក្សី រលាកដើមក និងរលាកបំពង់ខ្យល់ និងជំងឺញូវ កាស (ដង្កោវែក)។ ជាទូទៅឃើញមានព្រូនពណ៌ក្រហម កើតលើមាន់ដែលចិញ្ចឹមលែង។



## ២.៣ ការពិនិត្យសាច់ដុំ:

ការរះបកស្បែកគ្របពោះ និងទ្រូង (ពី ក ដល់ប្រដុំរន្ធភេទ ឬរន្ធគូថ) ដើម្បីមើលភាពស្ថិតរបស់សាច់ដុំ។ ក្នុងករណីជំងឺរាំរ៉ៃ ឬការចុះស្គមចំណីមិនគ្រប់គ្រាន់បណ្តាលឲ្យចេញឈាមតាមសរសៃតូចៗនៅលើភ្លៅ ឬការចម្លងដោយស្តាហ្វីឡូកុកគុស ឬជំងឺហ្គុមបូរ៉ូ។


ការបើកស្បែកចេញ

ការចេញឈាមដោយជំងឺហ្គុមបូរ៉ូ (Gumboro)



## ២.៤ ការពិនិត្យពោះ

**ថង់ខ្យល់ និងថ្លើម** លេចឡើងបន្ទាប់ពីកាត់សាច់ដុំពោះ។ ថង់ខ្យល់ធម្មតា មានការលំបាកក្នុងការពិនិត្យមើល ពីព្រោះវាជាភ្នាសថ្លាស្តើងមួយ។



- ក្នុងករណីជំងឺកូលីបាក់ស៊ីឡូស មីកូផ្លាស្មា ឬជំងឺរលាកទងសួត
- ធ្វើឲ្យភ្នាសក្លាយជាល្អក់ និងរុំព័ទ្ធដោយស្លេះ ឬខ្ទុះ។







- **ថ្លើម:** រាងធំ នៅជុំវិញថង់ទឹកប្រមាត់មានពណ៌ខៀវ ជាការធម្មតា។ មានស្លាកស្នាមអាចកំណត់បានដូចជា ការហើមមានពណ៌ខៀវ ជាជំងឺសាល់ម៉ូណែឡា ការហើមមួយផ្នែកមានពណ៌ប្រផេះ ជាជំងឺអាសន្នរោគ។
- ថ្លើមមានដុំពកតូចៗពណ៌ប្រផេះចំពោះជំងឺម៉ារិក ឬព័ទ្ធដោយសរសៃឆ្មារៗ ក្នុងករណីជំងឺមីកូផ្លាស្មា និងកូលីបាក់ស៊ីឡូស។










បន្ទាប់ពីយកថ្លើមចេញ យើងអាចបន្តពិនិត្យសរីរាង្គផ្សេងទៀត។

- **កាពិនិត្យផាលដែលរីកធំ** ចំពោះជំងឺសាល់ម៉ូណែឡូស។
- **ការពិនិត្យប្រដាប់រំលាយអាហារ**



- ជាទូទៅការរលាកពោះវៀន ពិនិត្យឃើញចំពោះជំងឺសាល់ម៉ូណែឡូស។
- ការកាត់ទងកោះ កោះ ពោះវៀន និងខ្នែងពោះវៀន:
  នៅក្នុងកោះមានចេញឈាម ចំពោះជំងឺញូវកាស ព្រូនអាស្ការីស មានទូទៅចំពោះមាន់ដែលចិញ្ចឹមលែង និងខ្នែងពោះវៀនមានឈាមពេញ ក្នុងករណីជំងឺកុកស៊ីដ្យូស៊ីស។



















- **សួត:** ជាប់នឹងឆ្អឹងជំនីមានពណ៌ផ្កាឈូក បើប្រែជាពណ៌ប្រផេះ អាចជាជំងឺសាល់ម៉ូណែឡូស បើមានឈាមអាចជាជំងឺអាសន្នរោគ និងផ្តាសាយបក្សី។







- **ដុំកញ្ចួញគូថ:** គឺជាថង់លៀនចេញមកខាងក្រោយតំបន់ប្រដុំរន្ធភេទ ឃើញមានសភាពហើមដោយការចេញឈាម និងរាងខាប់អន្ធិល អាចជាជំងឺហ្គុមបូរ៉ូ។






# ខ. ជ្រូក

## ១. ការប្រើប្រាស់ថ្នាំ

### ១.១ ការចាក់ថ្នាំក្រោមស្បែក:

- ចំពោះកូនជ្រូកក្រោយពេលផ្តាច់ដោះ មានការចាក់
- ក្រោមស្បែកនៅផ្នែកកខាងមុខស្មា។

មេជ្រូក ដោយសារខ្លាញ់នៅកក្រាស់ មិនអាចចាក់ថ្នាំនៅទីនោះបានដូច្នេះ

- ត្រូវចាក់វានៅក្រោមកន្ទុយ។




មេជ្រូក ដោយសារខ្លាញ់នៅកក្រាស់ មិនអាចចាក់ថ្នាំនៅទីនោះបានដូច្នេះត្រូវចាក់វានៅក្រោមកន្ទុយ។

### ១.២ ការចាក់សាច់ដុំ

កម្រាស់ខ្លាញ់ ជាពិសេសមេជ្រូកអាចជ្រើសរើសទីតាំងដែលកម្រាស់ខ្លាញ់មិនក្រាស់ និងត្រូវប្រើម្ជុលដែលមានប្រវែងត្រឹមត្រូវ។






នេះជាកន្លែងដែលល្អ
សម្រាប់ចាក់ថ្នាំ

កន្លែងនេះមិនអំណោយ
សម្រាប់ចាក់ថ្នាំទេ ព្រោ
ខ្លាញ់ក្រាស់

ករបស់ជ្រូកត្រូវគេកាត់ទទឹង

- ពេលចាក់ថ្នាំនៅកន្លែងខ្លាញ់ និងនៅកន្លែងគ្មានសាច់ដុំ នោះថ្នាំមិន ជ្រាបបានល្អក្នុងសរសៃឈាមទេ ព្រោះប្រព័ន្ធសរសៃឈាមមិនវិវត្តន៍ក្នុងខ្លាញ់។
- ពេលចាក់ថ្នាំនៅកន្លែងមានខ្លាញ់អាចបង្កជារលួយជាលិកាបណ្តាលឲ្យដំបៅ។

ការចាក់ថ្នាំខុសទីតាំងធ្វើឲ្យកើតដំបៅ
មានកម្រិតខ្ពស់



អាចចាក់ត្រង់តំបន់ក (ផ្នែកខាងលើ) ចំពោះជ្រូកសាច់





ចាក់សាច់ដុំចំពោះកូនជ្រូក



កន្លែងត្រឹមត្រូវសម្រាប់ចាក់មេជ្រូក

## ១.៣ ការចាក់តាមសរសៃវ៉ែន(ចាក់ចូលក្នុងសរសៃឈាមខាងក្រោយស្លឹកត្រចៀក)



- ឧទាហរណ៍: ការចាក់ថ្នាំអុកស៊ីតុកស៊ីន (Ocytocin) ចំពោះមេជ្រូកដែលមានបញ្ហារលាកស្បូន លាសដោះ និងអត់ទឹកដោះ (MMA)។
- ក្រោយចាក់ថ្នាំអុកស៊ីតុកស៊ីន ០,៥សេសេ តាមសរសៃវ៉ែនពី ២ ទៅ ៣ វិនាទីក្រោយមក វានឹងចេញទឹកដោះ ។ ប៉ុន្តែការចាក់ថ្នាំអុកស៊ីតុកស៊ីនតាមសាច់ដុំ មិនមានប្រសិទ្ធិភាពដើម្បីជម្រុញឲ្យចេញទឹកដោះទេ។

## ១.៤ ការច្រកថ្នាំ:



- ការច្រកថ្នាំប្រើសម្រាប់កូនជ្រូក ដើម្បីច្រកថ្នាំអង់ទីប៊ីយ៉ូទិកបំបាត់រាក ឬថ្នាំតុលត្រាហ្ស៊ូរីល (Toltrazuril) ដើម្បីបង្ការជំងឺកុកស៊ីដ្យូស៊ីស។
- ថ្នាំលាយដាក់ក្នុងដប ដែលមានប្រដាប់សប់សម្រាប់ផ្តល់ឲ្យកូនជ្រូកបានត្រឹមត្រូវ។

### ១.៥ ការលាយថ្នាំក្នុងចំណី:



- វិធីនេះងាយស្រួលព្យាបាលជ្រូកក្នុងក្រុម ឬ ព្យាបាលរយៈពេលយូរ។ ឧទាហរណ៍ ជំងឺផ្លូវដង្ហើមត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិករយៈពេល ពី៧ ទៅ ១០ថ្ងៃ។
- ប្រសិនបើជ្រូកឈឺ មិនស៊ីចំណី ឬស៊ីតិច ត្រូវប្រើថ្នាំសម្រាប់ចាក់។
- ប្រសិនបើជ្រូកស៊ីបានពាក់កណ្តាលនៃរបបចំណីធម្មតារបស់វា នោះថ្នាំអង់ទីប៊ីយ៉ូទិកដែលវាស៊ី គឺបានត្រឹមពាក់កណ្តាលដែរ។ ដូច្នេះកសិករត្រូវបន្ថែមកម្រិតថ្នាំទ្វេរដង ក្នុងចំណី។

ថ្នាំអាចលាយក្នុងទឹកដែលដាក់ក្នុងធុងតូចសម្រាប់ផ្តល់ទឹកដល់ជ្រូកឈឺក្នុងទ្រុងមួយ



### ១.៦ ការលាយថ្នាំក្នុងទឹក:

- ជ្រូកឈឺឈប់ស៊ីចំណី ប៉ុន្តែវានៅបន្តផឹកទឹក ដូចនេះត្រូវលាយថ្នាំក្នុងទឹកឲ្យបានសព្វល្អ មុននឹងឲ្យជ្រូកផឹកឲ្យបានទាំងអស់។

## ២. ការជួយមេជ្រូកពេលកើតកូន

### ២.១ មុនពេលកើតកូន

សញ្ញាមេជ្រូកជិតកើតកូន មានដូចជា:

- ១០ថ្ងៃមុនពេលកើតកូន: ក្រពេញដោះរីកធំ និងឡើងរឹងតឹង ហើយយោនីឡើងរីកធំ
- ពី៨ទៅ១២ម៉ោងមុនពេលកើតកូន: ទឹកដោះចេញពេលច្របាច់ក្បាលដោះ
- ៣០ទៅ៩០នាទីមុនពេលកើតកូន មានហូរទឹករំអិលលាយឈាមនិងចេញអាចម៍ព្រៃ។
- បន្ទាប់ពីចេញអាចម៍ព្រៃ ពី៣០ ទៅ៩០នាទី កូនទីមួយនឹងលេចចេញ។

## ២.២ បញ្ហាកើតកូនលំបាក




- កូនជ្រូកចុងក្រោយកើតលើសពី៤០នាទី មូលហេតុគឺស្បូនខ្សោយ មិនកន្ត្រាក់ ដូច្នេះត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន ១សេសេ ហើយរង់ចាំ១០នាទី ស្បូននឹងកន្ត្រាក់សារជាថ្មី ហើយកូនជ្រូកបន្ទាប់នឹងរុញចេញ
- កូនស្ថិតនៅទីតាំងខុសប្រក្រតី ឬកូនជ្រូកធំពេក ដូច្នេះត្រូវតែធ្វើការលូកដៃ ដោយស្ទាបថ្នមៗ នោះបសុពេទ្យនឹងអាចវាយតម្លៃពីទីតាំងរបស់កូន និងជើងរបស់វា។ បន្ទាប់ពីលូកហើយ ត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa) ឲ្យមេជ្រូករយៈពេលបីថ្ងៃ។

## ២.៣ ការជួយសង្គ្រោះកូនដែលមានទីតាំងខុសប្រក្រតី

- ការជាប់កូនស្ទះត្រង់ស្មា ត្រូវពន្លាទាញជើងកូនទៅមុខដោយមិនធ្វើឲ្យដាច់ស្បូន
- ការជាប់កូនស្ទះត្រង់ភ្លៅ ត្រូវថ្តក់ម្រាមចង្អុលដៃក្រោមសរសៃពួរកន្លាក់ជើងក្រោយ រួចពន្លាទាញជើង។





ជួយពេលកូនជ្រូកធំពេក ត្រូវចាប់ថ្តក់ក្បាលជាមួយម្រាមដៃ និងប្រើអន្ទាក់ជុំវិញក។





## ២.៤ ការរុញបញ្ចេញកូនជ្រូកចុងក្រោយ

- បើកូនច្រើនលើសពី១០ក្នុងមួយសំបុក
- មេជ្រូកអស់កម្លាំង។
- ការកន្ត្រាក់របស់ស្បូននឹងថយចុះ
- កូនជ្រូកនឹងចុះខ្សោយដោយវាស្ថិតនៅយូរក្នុងផ្លូវកើតកូន។ អាចជួយកូនជ្រូក ១ ឬ ២ក្បាល ពេលពិនិត្យនៅដំណាក់កាលចុងក្រោយរបស់ការកើតកូន។



ជារឿយៗកូនជ្រូកចុងក្រោយត្រូវបានរុំដោយសុក ហើយវាត្រូវការជួយសង្គ្រោះដើម្បីរស់

## ២.៥ ការធ្លាក់សុក

ធម្មតាសុកធ្លាក់ ពី២ទៅ៤ម៉ោងបន្ទាប់ពីកើតកូនចុងក្រោយ។ យកល្អត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន២សេសេតាមសាច់ដុំ ពេលការកើតកូនបានបញ្ចប់ ដើម្បីឲ្យប្រាកដថា មិនមានកូនជ្រូកស្ថិតក្នុងស្បូន និងសុកទាំងអស់បានធ្លាក់ចេញមកក្រៅ។

# ៣. ការថែទាំកូនជ្រូកទើបកើត

## ៣.១ ត្រួតពិនិត្យការដកដង្ហើម



- ស្លេះក្នុងមាត់និងក្នុងរន្ធច្រមុះត្រូវបឺតចេញ ដើម្បីឲ្យកូនជ្រូកដកដង្ហើមបានស្រួល
- ដំបូងកូនជ្រូកខ្សោយ ពួកវានិងមានកម្លាំងឡើងវិញបន្ទាប់ពីសម្ងួត និងជូតរួច។

## ៣.២ ការបៅទឹកដោះដំបូង (កូឡូស្ត្រូម)

ត្រូវជួយកូនជ្រូកដែលខ្សោយ ហើយត្រូវប្រាកដថាកូនជ្រូកទាំងអស់អាចបៅទឹកដោះដំបូងបាន



ទឹកដោះដំបូងចេញតែប៉ុន្មានម៉ោងប៉ុណ្ណោះ។

- ទឹកដោះដំបូង មានថាមពលច្រើន និងមានអង្គបដិបក្ខ (អង់ទីគ័រ)ដែលជួយការពារកូនជ្រូកប្រឆាំងនឹងជំងឺ

បន្ទាប់ពីកើត កូនជ្រូកដែលខ្លាំង រត់ទៅបៅ ប៉ុន្តែកូនជ្រូកខ្សោយ នៅឆ្ងាយពីមេ ដូចនេះ ចាំបាច់ត្រូវជួយឲ្យកូនជ្រូកទាំងអស់បានបៅទឹកដោះដំបូង។

## ៣.៣ ការរៀបចំសំបុកសម្រាប់កូនជ្រូក

ការរៀបចំសំបុកសម្រាប់កូនជ្រូកមានសារៈសំខាន់ណាស់ក្នុងការការពារកូនជ្រូកមិនឲ្យរងារ ពិសេសនៅពេលយប់ ដែលធ្វើឲ្យកូនជ្រូកបាត់បង់ថាមពល ចុះខ្សោយ និងមិនអាចទៅរកដោះបៅបាន ហើយផ្ទៃពោះចុះត្រជាក់ ធ្វើឲ្យពពួកមេរោគអ៊ីកូលីលូតលាស់បណ្តាលឲ្យកើតជំងឺរាក។



ប្រភពកំដៅដែលត្រូវប្រើក្នុងពេលយប់

## ៣.៤ វិធីការពារ

- ការពារការឆ្លងមេរោគ ជាពិសេសពពួកស្រ្តិបតូកុក មានឱកាសចម្លងទៅកូនជ្រូកក្នុងថ្ងៃទីមួយ តាមរយៈទងផ្ចិត។ ការរបួសលើអញ្ចាញបន្ទាប់ពីកាត់ធ្មេញ និងដំបៅពេលកាត់កន្ទុយ អាចបង្កឲ្យមានមេរោគក្នុងឈាម និងរលាកសន្លាក់។
- ការពារកង្វះឈាម: ទឹកដោះមិនអាចផ្តល់ជាតិដែកបានគ្រប់គ្រាន់សម្រាប់កូនជ្រូកទេ ដែលអាចបណ្តាលឲ្យកូនជ្រូកខ្វះឈាម មិនឃ្លានចំណី និងធំលូតលាស់យឺត។
- ការបន្ថែមជាតិដែក ត្រូវចាក់នៅត្រង់ក នៅអាយុពីរថ្ងៃ និងចាក់រំលឹកម្តងទៀតនៅអាយុពី៧ទៅ១០ថ្ងៃក្រោយមក។
- ការពារជំងឺកុកស៊ីដ្យូស ពេលកូនជ្រូកមានអាយុពី៧ទៅ១៥ថ្ងៃ ដែលបណ្តាលឲ្យកើតជំងឺរាកពណ៌ប្រផេះ។ ជំងឺរាគនេះពិបាកព្យាបាលណាស់ ដូចនេះត្រូវធ្វើការការពារដោយប្រើថ្នាំតុលត្រាហ្ស៊ូរីល (Toltrazuril) នៅអាយុបីថ្ងៃបន្ទាប់ពីកើត។ កូនជ្រូកដែលកើតជំងឺនេះមិនបណ្តាលឲ្យងាប់ទេ តែវាមានសភាពដងខ្លួនមិនល្អពេលផ្តាច់ដោះ។



ដើម្បីការពារត្រូវចាក់អាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពវែង (កន្លះសេសេ មួយលើក) នៅ២៤ម៉ោងបន្ទាប់ពីកើត



ចាក់ជាតិដែក (Iron Dextran) ១សេសេនៅ២ថ្ងៃបន្ទាប់កើត ដើម្បីការពារការខ្វះឈាម



បន្តក់តុលត្រាហ្ស៊ូរីល (Toltrazuril) ១សេសេដើម្បីការពារកូនជ្រូករាគនៅអាយុ២អាទិត្យ

## ៣.៥ ការកាត់ទងផ្ចិត

ដើម្បីការពារការឆ្លងចូលពពួកមេរោគតាមទងផ្ចិតត្រូវ:

- ការរម្ងាប់មេរោគ: ទងផ្ចិតត្រូវជ្រលក់ត្រាំក្នុងទឹកអ៊ីយ៉ូឌីន (Iodine) រួចចងនិងកាត់ទងផ្ចិត ព្រោះពេលខ្លះមានចេញឈាម។


ទងផ្ចិតអូសលើ
កម្រាលគខ្វក់




## ៣.៦ ការកាត់ធ្មេញ

ដើម្បីការពារ:

- របួសពេលកូនជ្រូកខាំគ្នា
- របួសក្បាលដោះមេ ពេលកូនជ្រូកបៅ

ត្រូវកាត់ធ្មេញមុនអាយុ៣ថ្ងៃ និងត្រូវប្រយ័ត្នមិនឲ្យរបួសអញ្ចាញធ្មេញ។


ប្រដាប់កាត់ត្រូវរម្ងាប់មេរោគមុនកាត់ធ្មេញ

## ៣.៧ ការកាត់កន្ទុយ

ដើម្បីកាត់បន្ថយការខាំកន្ទុយគ្នា និងការឆ្លងមេរោគពេលកូនជ្រូកធំ

- ប្រើថ្នាំអ៊ីយ៉ូឌីនសម្រាប់រម្ងាប់មេរោគប្រដាប់កាត់ និងលើកន្ទុយ
- ត្រូវកាត់៣ភាគ៤របស់កន្ទុយ
- ត្រូវកាត់ឲ្យបានមុនកូនជ្រូកអាយុ៣ថ្ងៃ។

រាល់ពេលត្រូវរម្ងាប់មេរោគសម្ភារៈប្រើប្រាស់
ដើម្បីសុខភាពកូនជ្រូក





## ៣.៨ ការគ្រៀវកូនជ្រូក

- ការគ្រៀវកូនជ្រូកឈ្មោល ជាការល្អត្រូវគ្រៀវពេលកូនជ្រូកមានអាយុពី៧ទៅ១០ថ្ងៃ។
- ត្រូវធ្វើការរម្ងាប់មេរោគលើឧបករណ៍ប្រើប្រាស់ និងកន្លែងដែលត្រូវវះកាត់តាមលក្ខណៈបច្ចេកទេស។
- មិនត្រូវគ្រៀវកូនជ្រូកដែលកើតក្លូន (អ៊ែកនី)។

កូនជ្រូកនេះអាចគ្រៀវបាន





កូនជ្រូកនេះមិនអាចគ្រៀវបាន



សម្អាតនិងរម្ងាប់មេរោគលើស្បែក



ច្របាច់ពងស្វាសឲ្យតឹងជាមួយម្រាមដៃ



វះចំកណ្តាលជាមួយកាំបិតឡាម



រុញពងស្វាសចេញមកក្រៅស្បែកពងស្វាស



យកពងស្វាសចេញរួចកាត់សរសៃភ្ជាប់ពងស្វាស



រម្ងាប់មេរោគលើរបួសជាមួយអ៊ីយ៉ូឌីន

## ៤. ការបង្កាត់សិប្បនិម្មិត

ការបង្កាត់សិប្បនិម្មិតជាវិធីល្អបំផុតដើម្បីកែលំអរពូជនៅតាមភូមិ និងកាត់បន្ថយការឆ្លងជំងឺ ពីជ្រូកបាដែលដឹកពីកន្លែងមួយទៅកន្លែងមួយទៀត។

បច្ចេកទេសរៀបចំទឹកកាម(មេជីវិតឈ្មោល) ត្រូវធ្វើក្នុងមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិត ព្រោះត្រូវការបទពិសោធន៍ និងសម្ភារៈ។ ការបង្កាត់មេជ្រូកអាចធ្វើដោយបសុពេទ្យភ្នាក់ងារសុខភាពសត្វភូមិ ឬកសិករដែលបានបណ្តុះបណ្តាល។

## ៤.១ ការយកទឹកកាម

- ជ្រូកបាត្រូវបង្ហាត់ឲ្យពាក់មេជ្រូកសិប្បនិម្មិត ដែលជំនួសឲ្យមេជ្រូកពិត។ មេជ្រូកសិប្បនិម្មិតច្រើនធ្វើពីឈើ និងធន់នឹងទម្ងន់របស់ជ្រូកបា។
- នៅពេលជ្រូកបាឡើងពាក់មេជ្រូកសិប្បនិម្មិត វានឹងមានចំណង់ ដូចនេះអ្នកបច្ចេកទេសត្រូវចាប់លិង្គ និងសម្អាតរម្ងាប់មេរោគ។
- ត្រូវចាប់ផ្ដើមស្ទាបអង្អែលលិង្គវា ពីរទៅ បីនាទី រហូតជ្រូកបាចាប់ផ្ដើមចេញទឹកកាម
- ទឹកកាមត្រូវត្រងដោយប្រុងប្រយ័ត្នដាក់ក្នុងកែវពិសេសមួយ ដែលមានស្បៃត្រង ដើម្បីកាត់បន្ថយភាពកខ្វក់ និងផ្នែករឹងរបស់ទឹកកាម (ដែលហៅថាគ្រាប់សាគូ)។


បន្ទាប់ពីបង្ហាត់ជ្រូកបាមានចំណង់ពេលវាឃើញ និងធំក្លិនមេជ្រូកសិប្បនិម្មិត



## ៤.២ ការរៀបចំកម្រិតទឹកកាម

- បច្ចេកទេសត្រួតពិនិត្យគុណភាពទឹកកាម (បរិមាណរបស់ស្ពែម៉ាតូស្ហ៊ីត និងអត្រាងាប់)ដោយមីក្រូទស្សន៍។
- ទឹកកាមត្រូវលាយជាមួយផលិតផល (ឬចំណី) ហៅថាប៊ីធីអេស (BTS) ដែលមានសារធាតុចិញ្ចឹមទឹកកាម និងអាចទុកទឹកកាមបានរយៈពេលយូរ និងមានអង់ទីប៊ីយ៉ូទិកដើម្បីការពារការឆ្លងរបស់បាក់តេរី។
- បន្ទាប់ពីការលាយទឹកកាម ត្រូវច្រកជាកម្រិត ១០០មីលីលីត្រ ដែលមានមេជីវិត (ស្ពែម៉ាតូស្ហ៊ីត) ប្រហែលមួយពាន់លាន។


បន្ទាប់ពីការយកទឹកកាមភ្លាមៗ ត្រូវចាក់ទឹកកាមមួយដំណក់ដើម្បីពិនិត្យ


ទឹកកាមត្រូវបានលាយជាមួយប៊ីធីអេស (BTS)

## ៤.៣ ការដឹកជញ្ជូន និងរក្សាទឹកកាម

- ទឹកកាមអាចរក្សាទុកបានពីរថ្ងៃ ក្នុងមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតដោយដាក់ក្នុងទូរទឹកកកដែលមានសីតុណ្ហភាពថេរ១៦អង្សារសេ។


ច្រកទឹកកាមដែលលាយហើយដាកម្រិតៗ


ការបិទភ្ជិត

- ការដឹកជញ្ជូនពីមជ្ឈមណ្ឌលទៅកាន់កសិដ្ឋាន ត្រូវដាក់ក្នុងធុងទឹកកកនិងមានទឹកកកដើម្បីធានាសីតុណ្ហភាពត្រជាក់ ប៉ុន្តែទឹកកាមមិនត្រូវប៉ះជាមួយទឹកកកនោះទេ។

## ៤.៤ ការបង្កាត់មេក្រមុំ និងមេជ្រូក

- ដំណាក់កាលទី១ គឺត្រូវកំណត់ពេលវេលាឲ្យបានត្រឹមត្រូវសម្រាប់បង្កាត់។ កសិករត្រូវកំណត់ ពេលមេជ្រូកស្កិតនៅស្ងៀម
- មេជ្រូកក្រមុំត្រូវធ្វើការបង្កាត់នៅ១២ម៉ោងបន្ទាប់ពីឃើញសត្វស្កិតនៅស្ងៀម និងមេជ្រូកនៅ២៤ម៉ោងបន្ទាប់ពីឃើញវាស្កិតនៅស្ងៀម
- ត្រូវធ្វើការបង្កាត់លើកទី២នៅ១២ម៉ោងបន្ទាប់ពីការបង្កាត់លើកទី១។


មេជ្រូកត្រូវស្កិតនៅស្ងៀម ដើម្បីប្រាកដថាវារកឈ្មោលស៊ប់


បន្ទាប់ពីសម្អាត និងជូតឲ្យស្ងួតយោនី អ្នកបច្ចេកទេសត្រូវដាក់បញ្ចូលលិង្គសិប្បនិម្មិតដែលភ្ជាប់នឹងបំពង់ទឹកកាម


ត្រូវការពេលពី១ទៅ៣នាទី ដើម្បីបញ្ចូលទឹកកាមឲ្យអស់ពីក្នុងបំពង់

មេជ្រូកស្កិតនៅស្ងៀម

## ៥. វិធីអនុវត្ត

### ៥.១ ការលៀនក្រសាល់គូថ

- ការលៀនក្រសាល់គូថ តែងតែត្រូវខាំដោយជ្រូកដំទៃទៀត។ ជ្រូកត្រូវដាក់ក្នុងទ្រុងដាច់តែឯង និងដោយឡែកពីគេ។
- រុញក្រសាល់គូថដែលលៀនទៅកន្លែងដើមវិញដោយដេរភ្ជិត។

### ៥.២ ស្បូនស្រុត

- ជាការលៀនកស្បូនក្នុងពេលដើមកំពុងវិវត្តន៍ និងសម្ពាធក្នុងពោះកើនឡើង ដោយជាលិការកន្ទ្រាក់ចេញតាមយោនី។
- រុញស្បូនដែលស្រុតចូលកន្លែងដើមវិញនិងដេរភ្ជិតយោនី ដោយទុកប្រហោង ២៥សង់ទីម៉ែត្រ រាងជាមុខកប៉ាល់ដោយមិនតឹងពេកដើម្បីងាយស្រួល បើសិនជាមានការកើតកូនម្តងទៀត។






បច្ចេកទេសក្នុងការដេរមុខរបួសពេលរុញក្រសាល់គូថចូលរួចហើយ






បច្ចេកទេសក្នុងការដេរ

### ៥.៣ អ៊ែកនី (ក្លូន)

- អ៊ែកនីដែលកើតជាញឹកញាប់ គឺអ៊ែកនីលើពោះ និងក្រលៀន។ ភាពទន់ខ្សោយរបស់សាច់ដុំ
- ជុំវិញផ្ចិត ធ្វើឲ្យផ្ចិតមានប្រហោងមិនជិតល្អ ហើយពោះវៀនធ្លាក់ចូល។



- បើអ៊ែកនីមានអង្កត់ផ្ចិតធំជាង៣០ សង់ទីម៉ែត្រ យកល្អគួរលក់ ព្រោះជ្រូកកើតអ៊ែកនីមិនធំធាត់ល្អទេ។
- មិនត្រូវព្យាយាមដោយធ្វើការវះកាត់អ៊ែកនីទេ។

## ៥.៤ ការព្យាបាលដំបៅ

- ដំបៅអាចធូរស្រាលពេលសារធាតុរាវខាងក្នុងហូរចេញ។ ដើម្បីឲ្យប្រាកដយើងត្រូវប្រើម្ជុលជាមួយសឺរ៉ាំងដែលស្អាត ចាក់ចូលផ្នែកទន់របស់ដុំពក ហើយបូមសារធាតុរាវខាងក្នុងចេញ។
- ត្រូវវះដោយកាំបិតមុខស្រួចនៅផ្នែកខាងក្រោមនៃដុំពក រួចបង្ហូរខ្ទុះចេញ និងលាបអ៊ីយ៉ូឌីន។

  ត្រូវចាក់អាម៉ុកស៊ីស៊ីលីន (Amoxicilline) រយៈពេល ៣ទៅ៥ថ្ងៃ (មិនត្រូវចាក់នៅកន្លែងដែលកើតដំបៅនេះទេ)។










## ៥.៥ ហើមកកឈាមលើត្រចៀក

- ជ្រូកអាចហើម កកឈាមលើត្រចៀក ដោយសារវាគ្រវីក្បាល ដោយសារអង្កែរ ឬដោយសារការឆ្លងមេរោគលើត្រចៀក។
- ការហើម កកឈាម នឹងជាឡើងវិញដោយខ្លួនឯងក្នុងពេល៣អាទិត្យ។
- មិនចាំបាច់ធ្វើការព្យាបាទេ លើកលែងតែសត្វកើតអង្កែរ លើត្រចៀក។






# គ. គោ ក្របី

## ១. ផ្លូវបញ្ចូលបសុឱសថ

គ្រប់ការចាក់ថ្នាំទាំងអស់ត្រូវលាងសម្អាតម្ជុល និងសឺរ៉ាំង។

### ១.១ ការចាក់ក្រោមស្បែក

- ឧទាហរណ៍: ចាក់ថ្នាំ អ៊ីវែម៉ិចទីន (Ivermectine) និងវ៉ាក់សាំងជំងឺ អុតក្តាម (FMD)។



ថ្នាំអាចចាក់ក្រោមស្បែកក



ថ្នាំដែលធ្វើឲ្យមានភាពក្រហាល់ក្រហាយមិនធ្វើឲ្យសត្វឈឺចាប់ទេពេលចាក់វានៅត្រង់ប្ញូវ

### ១.២ ការចាក់សាច់ដុំ

- គោ ក្របីដែលត្រូវការចាក់ថ្នាំច្រើនថ្ងៃ ត្រូវអនុវត្តដោយប្រុងប្រយ័ត្ន និងត្រូវចាប់ដោយសុវត្ថិភាពព្រោះត្រូវការពេលដើម្បីបញ្ចូលបរិមាណថ្នាំទាំងអស់ឲ្យបានត្រឹមត្រូវដូចជាថ្នាំអង់ទីប៊ីយ៉ូទិក ដែលមានសកម្មភាពវែងមានសភាពជាប្រេង និងច្រើនប្រើក្នុងកម្រិត ២០ទៅ៣០មីលីលីត្រ។

ការចាក់ថ្នាំរហ័សខុសទីតាំងមិនបានចាប់សត្វឲ្យត្រឹមត្រូវ គឺជាបច្ចេកទេសមិនល្អ



ការចាក់ថ្នាំលើត្រគៀកមិនត្រូវអនុវត្តទេ ប្រភេទថ្នាំដែលក្រហាល់ក្រហាយ និងមានបូស អាចធ្វើឲ្យមានគ្រោះថ្នាក់ដល់សរសៃប្រសាទ





ទះកដើម្បីដាសគោឲ្យដឹងជាមុន



ចាក់ម្ជុលថ្មមៗ



ភ្ជាប់សឺរ៉ាំងបាញ់ថ្នាំតិចៗ

## ១.៣ ការចាក់ថ្នាំតាមសរសៃវ៉ែន

- ប្រើសម្រាប់ចាក់ថ្នាំ ដើម្បីឱ្យថ្នាំជ្រាបបានលឿន
- ត្រូវពិនិត្យថ្នាំឲ្យបានច្បាស់ថា តើថ្នាំណាដែលត្រូវប្រើតាមសរសៃវ៉ែន
- ការចាក់ថ្នាំតាមសរសៃវ៉ែន ត្រូវចាប់សត្វឲ្យបានត្រឹមត្រូវ។


មានភាពងាយស្រួល កំណត់សរសៃវ៉ែន ពេលយើងសង្កត់គល់ក


ចាក់ថ្នាំយឺតៗ ចូលក្នុងឈាម

## ១.៤ ការបញ្ចុកថ្នាំតាមមាត់

- ប្រើសម្រាប់ថ្នាំទម្លាក់ព្រូន ឬថ្នាំបុរាណ
- ដើម្បីការពារការកំពប់ខ្ជះខ្ជាយ ត្រូវអនុវត្តដោយប្រុងប្រយ័ត្នកុំឲ្យថ្នាំចូលទៅក្នុងបំពង់ខ្យល់ និងសួត។


អាចប្រើដបជ័រចំណុះ៥០០មីលីលីត្រ


ឧបករណ៍សម្រាប់បញ្ចុកថ្នាំ ត្រឹមត្រូវចូលជ្រៅក្នុងមាត់ ជៀសវាងការកំពប់



## ១.៥ ការដាក់(សុល)ថ្នាំក្នុងស្បូន

បន្ទាប់ពីកើតកូន ក្នុងករណីដែលសុក មិនធ្លាក់ បសុពេទ្យត្រូវយកវាចេញ។ ជាទូទៅ សុកដែល ស្ថិតនៅក្នុងស្បូន នឹងអាចមានមេរោគឆ្លងចូល បណ្ដាលឲ្យរលាកស្បូន ដែលធ្វើឲ្យមេជ្រូក រកឈ្មោលឡើងវិញ និងមិនបង្កកំណើត។

ដើម្បីការពារការឆ្លងមេរោគ ត្រូវសុលថ្នាំអង់ទីប៊ីយ៉ូទិក ២ ឬ ៣ (គ្រាប់ធំ ១០ក្រាម) ជាទូទៅ ប្រើថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា។


ដៃកាន់គ្រាប់ថ្នាំសុលក្ដោបជារាងសាជី និងបញ្ចូលតិចៗក្នុងស្បូន រួចរុញវាឱ្យបានជ្រៅតាមដែលអាចធ្វើទៅបានក្នុងស្បូន

## ១.៦ ការព្យាបាលដោយបាញ់បញ្ចូលថ្នាំតាមដោះ



- នៅប្រទេសកម្ពុជា មិនទាន់មានការព្យាបាល ដោយបញ្ចូលថ្នាំតាមដោះទេ។
- គុណសម្បត្តិដើម្បីបញ្ជូនថ្នាំទៅក្នុងកន្សោមដោះ ថ្លាងទឹកដោះ និងរន្ធសំបុកឃ្មុំ ដោយផ្ទាល់ ដើម្បីការពារការឆ្លងមេរោគ ដែលបណ្តាលមកពីការលោសដោះ
- បច្ចេកទេសនេះត្រូវបានប្រើក្នុងការចិញ្ចឹមគោ យ

## ១.៧ ការបន្តក់ថ្នាំតាមភ្នែក



ក្នុងករណី:

- មានហូរទឹកភ្នែកច្រើន
- ភ្នែកឡើងស
- ភ្នែកបិទ
- ការបន្តក់ថ្នាំភ្នែក ប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជា: ក្លរ៉មហ្វេនីកុល ហ្សង់តាមីស៊ីន(Gentamycine) និងការពារភ្នែកកុំឲ្យខូច។

## ២. ការប្រើប្រាស់ត្រូកាក្នុងករណីហើមប៉ោងពោះ

- ពេលគោស៊ីស្មៅខ្ចីច្រើន ឬមានវត្ថុអ្វីមួយ ជាប់នៅបំពង់ខ្យល់ ឬពុលអ៊ុយរ៉េ បណ្តាលឲ្យហើមប៉ោងពោះ ដែលបណ្តាលមកពីមានឧស្ម័នច្រើន។ ការហើមប៉ោងពោះអាចតិចតួច (A) មធ្យម (B) ឬ ខ្លាំង (C)។



- ក្នុងករណីហើមប៉ោងពោះខ្លាំង ទាំងសងខាង សត្វដកដង្ហើមតាមមាត់ អណ្តាតលៀន ចេញ ហើយគោក្របី នឹងងាប់។ ក្នុងករណីនេះ ត្រូវចាក់ ត្រូកា ឬបំពង់ឬស្សីស្រួចដើម្បីធ្វើឲ្យ ខ្យល់ក្នុងពោះចេញមកក្រៅ។













## ៣. ការគ្រៀវសត្វឈ្មោល

ការគ្រៀវអាចធ្វើបានលើសត្វគ្រប់វ័យ ប៉ុន្តែយកល្អត្រូវគ្រៀវសត្វ ដែលមានអាយុតិច ជាងពីរខែ។

### ៣.១ ដង្កៀបគ្រៀវ Burdizzo

- ប្រើដង្កៀបគ្រៀវ ដោយគៀប សរសៃឈាម មិនឲ្យឈាម ហូរទៅពងស្វាស និងធ្វើឲ្យពងស្វាសងាប់។
- គៀបបំពង់ទឹកកាមមួយ ម្តងៗ។ ត្រូវគៀបបំពង់ ទាំងពីរនៅទីតាំងខុសគ្នា។
- កូនគោត្រូវធ្វើវ៉ាក់សាំងការពារជំងឺតេតាណូស (Tetanus) និងបូសខ្យល់ មុនធ្វើការគ្រៀវ។






## ៣.២ ការគ្រៀវដោយវះកាត់

- មុនធ្វើការវះកាត់ត្រូវលាងសម្អាតដៃ ស្បោរសម្ភារៈ និងលាងសម្អាតរម្ងាប់មេរោគលើស្បែកពងស្វាសជាមួយអ៊ីយ៉ូឌីន។
- ប្រើកាំបិតដើម្បីវះមួយភាគបី ផ្នែកខាងក្រោមរបស់ស្បែកពងស្វាស ដើម្បីកុំឲ្យហូរឈាមច្រើនពេក។
- រុញពងស្វាសចេញតាមកន្លែងដែលវះ រួចកាត់សន្ទះខាងក្នុង និងរុញបំបែកពីពងស្វាស។ បំពង់រឹងនេះមានសរសៃអាក់ទែ សរសៃវ៉ែន និងបំពង់នាំទឹកកាម។ ចំពោះកូនគោត្រូវទាញ សរសៃឈាមរបស់វា រហូតដល់ដាច់ទាំងបី។





កាត់សន្ទះខាងក្នុង


កាន់សរសៃពួរពងស្វាស និងទាញដើម្បីផ្តាច់សរសៃឈាម

# ៤. ការជួយក្នុងពេលកើតកូន

## ៤.១ កំណត់បញ្ហាពេលកើតកូនគោ

គោកើតកូន អាចចប់សព្វគ្រប់ ក្នុងរយៈពេល ២ម៉ោងបន្ទាប់ពីថង់ទឹកភ្លោះលេចចេញ។ បើមានការយឺតយ៉ាវក្នុងការកើតកូន ត្រូវពិនិត្យ ត្រគៀករបស់មេគោ ដើម្បីឲ្យដឹងពីកម្រិតនៃការបើកមាត់ស្បូន និងទីតាំងរបស់ កូនគោ ដើម្បីជួយសង្គ្រោះ។

ដើម្បីដឹងពីទីតាំងរបស់កូនគោ យើងត្រូវលូកដៃចូលក្នុងស្បូន។ បសុពេទ្យធ្វើការវាយតម្លៃទីតាំងក្បាល និងជើង រួចជួយបង្វិលឲ្យត្រូវទីតាំង



## ៤.២ មូលហេតុពិបាកកើតកូន

- ទីតាំងធម្មតារបស់កូនគោ: គឺជើងមុខស្របចេញមកក្រៅ ចង្ការផ្អៀងមកស្តាំងនៅលើជើងមុខ។
- ទីតាំងមិនប្រក្រតី: ភាគច្រើនគឺបញ្ច្រាសជើងមុខ១ ឬទាំង២ ឬក្បាលត្រឡប់មកក្រោយ។







- នៅកម្ពុជា កម្រមានកូនគោកើតធំពេក ប៉ុន្តែបើកូនគោងាប់ក្នុងស្បូន នោះឧស្ម័ន
- នឹងកើតមានលឿនក្នុងស្បែកសពកូនគោ ហើយវានឹងរីកប៉ោងធំ។ ការជួយសង្គ្រោះ ត្រូវចងជើងកូនគោ ដើម្បីទាញចេញ




- ពេលមេគោខ្សោយ ការកើតកូនអាចប្រើរយៈពេលយូរដោយស្បូនកន្ត្រាក់ខ្សោយ។

ដើម្បីជួយដល់ការកន្ត្រាក់របស់ស្បូន ត្រូវចាក់ ថ្នាំអុកស៊ីតុកស៊ីន 50 UI (Ocytocin) ចំនួន ៥សេសេ (១ សេសេ ស្មើនឹង១០ UI)។

## ៥. ការថែរក្សាកូនគោទើបកើត

- ជូតស្លេសក្នុងមាត់ និងបំពង់កកូនគោ
- បន្ទាប់មកត្រូវជួយកូនគោឲ្យដកដង្ហើម ដោយជូតឲ្យភ្ញាក់ខ្លួន រួចត្បារច្រមុះជាមួយ ចំបើង ឬគោះកូនគោដោយដៃ
- សម្អាតទងផ្ចិតជាមួយអ៊ីយ៉ូឌីន
- បើមេ មិនលិទកូន ត្រូវយកអំបិលលាបលើកូនគោ ដើម្បីឲ្យមេលិទ
- ត្រូវឲ្យកូនគោបានបៅទឹកដោះដំបូង។


ចាំបាច់ត្រូវសម្អាតច្រមុះ និងខាងក្នុងមាត់ ដើម្បីជួយសម្រួលការដកដង្ហើមចំពោះកូនគោទើបកើត


ត្រដុសដើម្បីជាសរា និងផ្តល់កម្លាំង


ឲ្យកូនគោបៅទឹកដោះដំបូងបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីពេលកើតនឹងជួយកូនគោឲ្យមានភាពស៊ាំ

## ៦. សុកមិនធ្លាក់

- បើសុកមិនធ្លាក់ក្នុងរយៈពេល២៤ម៉ោង បន្ទាប់ពីកើតកូន និងមានក្លិនស្អុយខ្លាំងអាចបណ្តាលមកពីការឆ្លងមេរោគក្នុងស្បូនមានកម្រិតខ្ពស់។
- បន្ទាប់ពីកើតកូនបាន២៤ម៉ោង កន្សោមសុកត្រូវយកចេញបើអាចធ្វើទៅបាន។ ជាទូទៅសុកអាចធ្លាក់ចេញទាំងមូល ដោយមិនមានការខូចខាត។



- ផ្តល់ថ្នាំអង់ទីប៊ីយ៉ូទិក ដោយចាក់ ឬ សុលចូល ក្នុងស្បូនដោយផ្ទាល់បន្ទាប់ពី យកសុកចេញអស់។
- ត្រូវចាក់ថ្នាំប្រូស្តាក្លង់ឌីន(លុយតាលីស) (Lutalyse) និងចាក់ឡើងវិញនៅ ១៥ថ្ងៃក្រោយ ដើម្បីធានាថាស្បូនត្រូវបានស្អាត និង មានសុវត្ថិភាព សម្រាប់ការបង្ករកំណើតជាថ្មី។

## ៧. ស្បូនស្រុត

- សុកដែលសល់ត្រូវយកចេញ និង ត្រូវលាងសម្អាតស្បូនជាមួយទឹកស្អាត
- រុញស្បូនចូលទៅក្នុងឱ្យត្រូវតាមទីតាំងដើម និងចាក់ថ្នាំអុកស៊ីតុកស៊ីន៤០UI (៤សេសេ)
- យោនីត្រូវដេរភ្ជិតជាមួយចេសស្វិត ទុករយៈពេលបីថ្ងៃ
- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាតេត្រាស៊ីគ្លីន (Tetracycline) រយៈពេលបីថ្ងៃ។





ស្បូនត្រូវលាងសម្អាតមុនបង្រួញស្បូនដែលស្រុត



យោនីត្រូវដេរជាមួយចេសស្វិត

## ៨. ការបង្កាត់ពូជដោយសិប្បនិម្មិត

ទឹកកាមយកមកពីគោបាពូជល្អ ឧទាហរណ៍ ដូចជាការប្រើប្រាស់ទឹកកាមដែលយកពីគោបាពូជសាន់តាហ្គែត្រូឌុស (Santa Gertrudis) ជួយកែលំអរការផលិតសាច់សម្រាប់ពូជគោក្នុងស្រុក។



គោនេះនៅប្រទេសអូស្ត្រាលី ប៉ុន្តែគេអាច យកទឹកកាមមកប្រើនៅក្នុងប្រទេសកម្ពុជា នៅពេលគេប្រើបច្ចេកទេសបង្កាត់តាមបែបសម្បនិម្មិត



បំពង់ផ្ទុកទឹកកាមត្រូវបានរក្សាទុកក្នុងធុងពិសេសក្នុងសីតុណ្ហភាពក្រោម១៩៦អង្សាសេ

- ទឹកកាមត្រូវបានរក្សាទុកក្នុងបំពង់ដាក់ក្នុងធុងដែលមានអាសូតរាវ។ អាសូតរក្សាសីតុណ្ហភាពក្រោម១៩៦អង្សាសេក្នុងធុង ដូច្នេះទឹកកាមអាចរក្សាទុកបានរាប់ខែ ឬរាប់ឆ្នាំ។
- ការបង្កាត់ដោយសិប្បនិម្មិត ត្រូវធ្វើឡើងក្នុងអំឡុងពេលពី ១២ទៅ២៤ម៉ោងបន្ទាប់ពីការរកឈ្មោលចាប់ផ្តើម។ ពេលល្អបំផុតសម្រាប់ការបង្កាត់ គឺ១៨ម៉ោងបន្ទាប់ពីឃើញមានសញ្ញារកឈ្មោល។
- មានតែអ្នកបច្ចេកទេសដែលមានបទពិសោធន៍ អាចបង្កាត់សិប្បនិម្មិតគោបាន។ បំពង់ទឹកកាមរក្សាទុកក្នុងធុង មានសីតុណ្ហភាពសមស្របពេល អ្នកបច្ចេកទេសយកបំពង់ទឹកកាមចេញពីធុង នោះស្តែម៉ាតូស្សូអ៊ីតនឹង ភ្ញាក់ឡើង។
- ការបង្កាត់អ្នកបច្ចេកទេសត្រូវលូកដៃឆ្វេងតាមគូថសត្វ ហើយចាប់កស្បូន រួចដៃស្តាំរុញបំពង់ទឹកកាមតាមរន្ធយោនី និងឆ្លងកាត់កស្បូន រួចបាញ់កម្រិតទឹកកាមចូលក្នុងស្បូន។ ដើម្បីអនុវត្ត អ្នកបច្ចេកទេសត្រូវប្រើបំពង់ពិសេសដែលហៅថា " កាំភ្លើង" ។

## ៩. ការកាត់តម្រឹមក្រចក

ដោយសារគោបានប្រើសម្រាប់អូសទាញនៅកម្ពុជា ដូចនេះសុខភាពជើងមានសារៈសំខាន់ណាស់ ទាំងការរស់នៅដោយសុខមាលភាព និងដើម្បីធ្វើការងារនៅស្រែផងដែរ។ គោច្រើនមានបញ្ហាខូចជើង និងការឈឺចាប់ដោយការដុះក្រចកវែងពេក។

ក្រចកជើងប្រៀបដូចជាក្រចកដៃ ដុះជាបន្តបន្ទាប់ប្រហែល៥មីលីម៉ែត្រក្នុងមួយខែ។ បញ្ហាមួយចំនួនដូចជា ការផ្តល់ចំណី ស្ថានភាពដី របួស ។ល។ អាចធ្វើឲ្យការលូតលាស់ក្រចកខុសប្រក្រតី ។



ក្រចកមួយបានដុះវែងជ្រុល គោមានការឈឺចាប់

- គោលបំណងនៃការកាត់ក្រចក គឺធ្វើឲ្យជើងគោដែលឈឺត្រឡប់មកសភាពដើមវិញ

- ក្រចកដែលមានសុខភាព គឺត្រូវមានម្រាមក្រចកខ្លី និងកែងខ្ពស់ ពេលដែលក្រចកមានទម្រង់មិនប្រក្រតី នោះមានម្រាមវែង កែងសឹករិច ជ្រុងរបស់ជើងនឹងត្រូវបាំង។ ដោយជើងមិនអាចទ្រទម្ងំខ្លួនរបស់វារួច នោះបណ្ដាលឱ្យមានការឈឺចាប់ និងខ្វក។





ក្រចកមានសុខភាពល្អ មានចំណុចសម្ពាធធំទូលាយ


ក្រចកដុះវែងជ្រុល មានចំណុចសម្ពាធតូចចង្អៀត

- ការកាត់ក្រចកត្រូវការបទពិសោធន៍ និងមានសម្ភារៈគ្រប់គ្រាន់។
- ត្រូវកាត់ក្រចកខាងក្រៅជាមួយកន្ត្រៃ ផ្នែកកែងខាងក្រោមក្រចក និងរូសគែមរបស់វា។







- ប្រសិនបើឃើញជាលិកាពណ៌ផ្កាឈូកត្រូវឈប់ភ្លាម ព្រោះអាចបណ្ដាលឲ្យចេញឈាម។







# ជំពូកទី៧៖ ភាពស៊ាំ និងការចាក់ថ្នាំការពារ (ការចាក់វ៉ាក់សាំង)






# ភាពស៊ាំ: តើសត្វទប់ទល់នឹងមេរោគយ៉ាងដូចម្ដេច?

សំដៅដល់ការឆ្លើយតបទៅនឹងការឆ្លងមេរោគក្នុងខ្លួនសត្វ

➢ ប្រពន្ធ័ភាពស៊ាំ

ប្រព័ន្ធភាពស៊ាំ ជាប្រព័ន្ធការពាររាងកាយប្រឆាំងនឹងការឆ្លងមេរោគ ដែលរាតត្បាតបណ្ដាលឲ្យសត្វឈឺ។ ប្រពន្ធ័ការពាររាងកាយសំខាន់ៗមានពីរយ៉ាងគឺ៖

- **កោសិកាម៉ាក្រូហ្វា**

ជាកោសិកាដែលពទ្ធ័ជុំវិញមីក្រូសរីរាង្គជាពិសេសពេលមេរោគចូលតាមរយៈសួត







- **កោសិកាឡាំហ្វូស៊ីត** ជាកោសិកឈាមសធ្វើចលនាក្នុងរាងកាយ នៅពេល កោសិកាឈាមសប៉ះ ជាមួយវីរុស បាក់តេរី ឬជាតិពុល វានឹងផលិតអង្គបដិបក្ខ (អង់ទីគ័រ) ដើម្បីប្រឆាំងនឹងមេរោគទាំងនោះ។




កោសិកាក្នុងឈាម




អង្គបដិបក្ខចាប់មេរោគ (ភ្នាក់ងារបង្កជំងឺ)
ហើយសម្លាប់មេរោគនោះ

➢ អង្គបដិបក្ខ (អង់ទីគ័រ)

អង្គបដិបក្ខ (អង់ទីគ័រ) មានលក្ខណៈជាក់លាក់: ត្រូវបានផលិតឡើងដើម្បីប្រឆាំងនឹងវីរុស ជំងឺអុតក្ដាម តែមិនមានឥទ្ធិពលលើវីរុសជំងឺប៉េស្ដនោះទេ។ វ៉ាក់សាំងមួយមុខការពារជំងឺបានតែមួយមុខ។ ដូច្នេះវ៉ាក់សាំងជំងឺអុតក្ដាមអាចការពារបានតែជំងឺអុតក្ដាមតែប៉ុណ្ណោះ។

- អង្គបដិបក្ខ (អង់ទីគ័រ) ស្គាល់ និងហ៊ុំព័ទ្ធចាប់បានភ្នាក់ងារបង្កជំងឺ (វីរុស បាក់តេរី ជាតិពុល) ហើយបញ្ឈប់សកម្មភាពរបស់ពួកវា។ កោសិកាស ហៅថា "កោសិការអ្នកពិឃាត" នឹងកម្ទេចភ្នាក់ងារបង្កជំងឺទាំងនោះ។
- អង្គបដិបក្ខ (អង់ទីគ័រ) អាចស្ថិតនៅក្នុងខ្លួនសត្វបានរយៈពេលវែង ឬខ្លីអាស្រ័យលើប្រភេទវ៉ាក់សាំងដែលបានចាក់បញ្ចូល ។




➢ ការបង្ករោគ

- មេរោគមានគ្រប់ទីកន្លែងក្នុងបរិយាកាស និងក្នុងខ្លួន។ មេរោគខ្លះមានអត្ថប្រយោជន៍អាចជួយដល់រាងកាយ ហើយមេរោគខ្លះទៀតមានគ្រោះថ្នាក់ដែលអាចធ្វើឲ្យកើតជំងឺ។ ពេលជំងឺវិវត្តក្នុងខ្លួនសត្វ យើងអាចសង្កេតឃើញរោគសញ្ញាដែលលេចឡើង ហើយរោគសញ្ញាផ្លាស់ប្តូរ អាស្រ័យលើសរីរាង្គដែលមេរោគរស់នៅ:
    - អ៊ីកូលី លូតលាស់ក្នុងពោះវៀន និងធ្វើឲ្យរាគ
    - បាស៊ីវ៉េឡាលូតលាស់ក្នុងសួតនិងធ្វើឲ្យរលាកសួតក្អកដកដង្ហើមញាប់ហូរទឹករំអិលតាមរន្ធច្រមុះ។

ការឆ្លងមេរោគក្នុងឈាមកើតឡើងនៅពេលមេរោគដែលបង្កគ្រោះថ្នាក់លូតលាស់ក្នុងចរន្តឈាម ហើយរាតត្បាតពេញរាងកាយ និងមានរោគសញ្ញាធ្ងន់ធ្ងរ ក្តៅខ្លាំង អស់កម្លាំង និងអាចបណ្តាលឲ្យងាប់លឿន។

កូនជ្រូកទើបកើតបៅទឹកដោះប៉ុន្តែមេជ្រូកមានបញ្ហាលាសដោះដូច្នេះទឹកដោះមានសុទ្ធតែអ៊ីកូលី



អ៊ីកូលីបំបែកខ្លួនយ៉ាងរហ័សក្នុងពោះវៀនជាពិសេសពេលកូនជ្រូករងារ



ប៉ុន្មានម៉ោងក្រោយមករាគនឹងចាប់ផ្តើម





មីកូផ្លាស្មាមផ្លាស់ទីក្នុងកសិដ្ឋានធ្វើឲ្យជ្រូកចាប់ក្អក និងចុះខ្សោយ



ជាទូទៅប៉ាស្ទឺរ៉ែឡាមានក្នុងបំពង់ដកដង្ហើមពេលជ្រូកខ្សោយ និងក្អកពូកវាបំបែកខ្លួនលឿន



នៅប៉ុន្មានថ្ងៃ ជំងឺចាប់ផ្តើមលូតលាស់ និងបង្កជា ជំងឺសួត ដែលមានរោគសញ្ញាដកដង្ហើមលឿន និងហូរខ្ទុះ

- ការឆ្លើយតបរបស់សត្វ នៅពេលមេរោគ (បាក់តេរី ឬវីរុស) ឆ្លងចូលក្នុងខ្លួនសត្វ ពេលនោះខ្លួនសត្វនឹងបង្កើតជាអង្គបដិបក្ខ(អង់ទីគ័រ)ប្រឆាំងនឹងមេរោគនោះ។ មេរោគនឹងបាត់បង់ការលូតលាស់ ក្នុងរាងកាយសត្វដោយសារ:

## ក.កោសិកាម៉ាក្រូហ្វា

នឹងរុំពទ័ មេរោគជាពិសេសពពួកដែលចូលក្នុងឈាមតាមរយៈសួត។ កោសិកាម៉ាក្រូហ្វា ស្ថិតក្នុងកូនថង់សួត កម្ទេចមេរោគ ជាតិពុល... ដែលឆ្លងកាត់សួត។ ប្រពន្ធ័ការពារមានការលូតលាស់ និងមានប្រសិទ្ធភាពតិចតួចពេលសត្វខ្សោយ ឬមានការរាតត្បាតជំងឺដទៃទៀត ដូចជា:

- ជំងឺត្រចៀកខៀវ (PRRS) បំផ្លាញកោសិកាម៉ាក្រូហ្វា និងធ្វើឲ្យមេរោគ បាស្ទឺរ៉ែឡា រាតត្បាតលើសួតដោយងាយស្រួល
- មីកូផ្លាស្មា ធ្វើឲ្យខូចជាលិការអេពីតេលីយ៉ូមរបស់បំពង់ដកដង្ហើម ដែលធ្វើឲ្យមេរោគអាចលូតលាស់ និងរាតត្បាតបានយ៉ាងងាយស្រួល។

## ខ.អង្គបដិបក្ខ (អង់ទីគ័រ)

សម្រាប់ប្រឆាំងសកម្មភាពរបស់មេរោគ។ ការផលិតអង្គបដិបក្ខ (អង់ទីគ័រ) អាចត្រូវការពេលច្រើនថ្ងៃ។ ប្រសិនមេរោគបង្កជំងឺកម្រិតខ្ពស់ វានឹងបំបែកខ្លួន ហើយរាលដាលលើសរីរាង្គ និងក្នុងឈាមយ៉ាងលឿនបណ្តាលឲ្យសត្វឈឺធ្ងន់ធ្ងរ អាចងាប់ដោយមិនអាចបង្កើតអង្គបដិបក្ខ (អង់ទីគ័រ) បានទាន់ពេល។ ប្រសិនបើសត្វមានសុខភាព និងសភាពរាងកាយល្អ ពេលមេរោគរាលដាលសត្វនោះអាចតស៊ូបានយូរ និងអាចផលិតអង្គបដិបក្ខ (អង់ទីគ័រ) ដើម្បីប្រឆាំងសកម្មភាព របស់មេរោគទាំងនោះ។ ប៉ុន្តែបើសត្វមានសុខភាពនិងសភាពរាងកាយមិនល្អ សត្វនោះនឹងឈឺធ្ងន់ធ្ងរហើយឆាប់រហ័ស។


ក្របីនេះបានឆ្លងជំងឺសារទឹក ការឆ្លងបាក់តេរីប៉ាស្ទឺរ៉ែឡាវិវត្តក្នុងពេលប៉ុន្មានម៉ោង រួចហើយផលិតជាតិពុល


ក្របីងាប់ក្នុងពេលតិចជាង២៤ម៉ោង វាគ្មានពេលគ្រប់គ្រាន់ដើម្បីផលិត អង់ទីគ័រ នឹងសម្លាប់ (បន្សាប)បាក់តេរីប៉ាស្ទឺរ៉ែឡាទេ

ប្រសិនបើ មេរោគជាប្រភេទបាក់តេរី ចាំបាច់ត្រូវប្រើ **ថ្នាំអង់ទីប៊ីយ៉ូទិក** ព្រោះអង់ទីប៊ីយ៉ូទិកអាចសម្លាប់ បាក់តេរី ឬបញ្ឈប់ការលូតលាស់ (បំបែកខ្លួន)របស់បាក់តេរីបាន ប៉ុន្តែ ថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធ ភាពលើវីរុសទេ មានតែអង់ទីគ័រនៅក្នុងខ្លួនសត្វទេ ដែលអាចប្រឆាំងនឹងវីរុសបាន។ ការប្រើអង់ទីប៊ី យ៉ូទិកលើសត្វដែលឆ្លងជំងឺបង្កដោយវីរុស ព្រោះសត្វចុះខ្សោយ ហើយបាក់តេរីបង្កគ្រោះថ្នាក់អាច លូតលាស់បានងាយស្រួល។

ឧទាហរណ៍ជ្រូកសាច់កើតជំងឺប៉េស្ត ជារឿយៗមានការឆ្លងជំងឺឱកាសនិយម ដែលបង្កដោយប៉ាស្ទឺរ៉ែឡា ឬសាល់ម៉ូណែឡា។

## ការចាក់វ៉ាក់សាំង

- សត្វមិនអាចទប់ទល់ជាមួយមេរោគបង្កជំងឺកម្រិតខ្ពស់ ឧទាហរណ៍ ជំងឺផ្តាសាយបក្សី អុតក្តាម សារទឹក...) ព្រោះជំងឺទាំងនេះបំបែកខ្លួនយ៉ាងលឿនហើយប្រព័ន្ធភាពស៊ាំមិនមានពេល គ្រប់គ្រាន់ដើម្បីចាប់និងកម្ទេចមេរោគបង្កជំងឺទាំងនោះបាន។
- គ្មានថ្នាំដែលអាចកម្ទេច ឬបញ្ឈប់ការលូតលាស់របស់វីរុសបានទេ មានតែប្រព័ន្ធភាពស៊ាំដែលអាចបញ្ឈប់ការរាតត្បាតរបស់វីរុសបានប្រកបដោយប្រសិទ្ធភាពតាមរយៈការចាក់វ៉ាក់សាំង។
- ការចាក់វ៉ាក់សាំង គឺជាការចាក់បញ្ចូលមេរោគ (វីរុស ឬបាក់តេរី) ដើម្បីជម្រុញឲ្យមានការផលិតអង់ទីគ័រ។
- វីរុស ឬបាក់តេរីរស់ត្រូវបានគេបំលែងដោយសារធាតុគីមី ឬមេរោគទាំងនោះ ត្រូវបានសម្លាប់ និងជម្រុញឲ្យមានការឆ្លើយតបភាពស៊ាំ ផលិតអង់ទីគ័រ ប៉ុន្តែវាមិនធ្វើឲ្យកើតជំងឺទេដោយសារមេរោគត្រូវបានសម្លាប់ ឬបំលែងរួចហើយ។
- អង់ទីគ័រកើតដោយការចាក់វ៉ាក់សាំង នឹងមានក្នុងខ្លួនសត្វច្រើនខែ ពេលវីរុស ឬបាក់តេរីរាលដាលក្នុងខ្លួនសត្វ អង្គបដិបក្ខ(អង់ទីគ័រ)ត្រៀមជាស្រេច ដើម្បីប្រឆាំងនឹងមេរោគនោះភ្លាមៗ។



ពីរអាទិត្យបន្ទាប់ពីការចាក់វ៉ាក់សាំង
អង់ទីគ័រត្រូវបានកើតឡើង(រូបភាពពណ៌លឿង) ស្ថិតក្នុង
ឈាមត្រៀមប្រឆាំងការមកដល់របស់មេរោគ។




អង់ទីគ័រត្រៀមរួចស្រេចដើម្បីចាប់ និងសម្លាប់វីរុស

- វ៉ាក់សាំងប្រើសម្រាប់ការពារតែប៉ុណ្ណោះ មិនមែនប្រើសម្រាប់ព្យាបាលទេ។ ក្រោយការចាក់វ៉ាក់សាំង វាត្រូវការពេលពី១ទៅ២អាទិត្យដើម្បីផលិតជាអង្គបដិបក្ខ(អង់ទីគ័រ)
- វ៉ាក់សាំងត្រូវប្រើលើសត្វដែលមានសុខភាពល្អតែប៉ុណ្ណោះ ព្រោះពេលចាក់បញ្ចូលទៅក្នុង ខ្លួនសត្វ ទោះបី វីរុស ឬបាក់តេរីទាំងនោះត្រូវបានបំលែង ក៏ដោយ ក៏វាធ្វើឲ្យសត្វអស់កម្លាំងប៉ុន្មានថ្ងៃដែរ ។ ដូចនេះតម្រូវឲ្យសត្វមានសុខភាពល្អ ដើម្បីផលិតអង្គបដិបក្ខ(អង់ទីគ័រ)បានគ្រប់គ្រាន់។
- វ៉ាក់សាំងមានលក្ខណៈជាក់លាក់ដូច ជា វ៉ាក់សាំងអុតក្តាមប្រភេទអូ (o) ជម្រុញឲ្យមានការផលិតអង្គបដិបក្ខ (អង់ទីគ័រ) ប្រឆាំងវីរុសអុតក្តាមប្រភេទអូ (o) ។ ប្រសិនបើមានផ្ទុះជំងឺអុតក្តាមប្រភេទអូ (o) គោ ក្របីត្រូវ បានការពារតែផ្ទុយទៅវិញប្រសិនបើមាន ផ្ទុះជំងឺអុតក្តាមប្រភេទអា (A) ឬ អេស៊ា១ (Asia1) គោ ក្របីនោះមិនអាចការពារ




វ៉ាក់សាំងដែលមានប្រភេទទាំង
បីចូលគ្នា គឺអូ+អា+អាស៊ា១

- ប្រឆាំង នឹងវីរុសប្រភេទអា (A) ឬអេស៊ា១ (Asia1) បានទេ។ នៅកម្ពុជា មានជំងឺអុតក្តាម៣ប្រភេទ គឺប្រភេទអូ (o) អា(A)និង អេស៊ា១ (Asia1) ដូចនេះដើម្បីឲ្យមានប្រសិទ្ធភាពត្រូវចាក់វ៉ាក់សាំងអុតក្តាមដែលមានប្រភេទ ទាំងបីរួមចូលគ្នា គឺ អូ+អា+អេស៊ា១ (Trivalent O+A+Asia1)

➢ ប្រពន្ធ័ត្រជាក់

វ៉ាក់សាំងជាថ្នាំដែលផ្ទុកមីក្រុបដែលបំលែងរួច ឬ មីក្រុបងាប់។ វ៉ាក់សាំង ត្រូវរក្សាទុកក្នុង កន្លែងត្រជាក់ (ទូទឹកកក ឬធុងទឹកកកមាន ទឹកកកគ្រប់គ្រាន់) ពី២-៨ អង្សាសេ ចាប់តាំង ពីការ ផលិត ការដឹកជញ្ជូនទៅគ្រប់ទិសទី ការដាក់លក់ ការស្តុកទុក រហូតដល់ការប្រើប្រាស់ត្រូវបានបញ្ចប់ ហៅថាប្រព័ន្ធត្រជាក់។ ត្រូវដាក់ វ៉ាក់សាំងនៅក្នុងបរិយាកាសធម្មតាពី ២ ទៅ ៣នាទីមុនចាក់ឲ្យសត្វ។ ប្រសិនបើ ប្រពន្ធ័ត្រជាក់ មិនដំណើរការវាធ្វើឲ្យវ៉ាក់សាំងគ្មាន គុណភាព។



សីតុណ្ហភាពសម្រាប់រក្សាទុកបញ្ជាក់យ៉ាងច្បាស់ លើស្លាកសញ្ញា




ការរក្សាទុកក្នុងហាងចែកចាយ

ភ្នាក់ងារសុខភាពសត្វភូមិទៅកាន់កសិដ្ឋាន វ៉ាក់សាំងដាក់ក្នុងប្រពន្ធ័ត្រជាក់




រហូតដល់ប្រើវ៉ាក់សាំងវាត្រូវបានរក្សាក្នុងធុងទឹកកក

សម្រាប់ជំងឺញូវកាស មានវ៉ាក់សាំងមួយប្រភេទហៅថា អាយធូ (I2) គេអាចដឹកជញ្ជូនដោយមិនចាំបាច់មានប្រពន្ធ័ត្រជាក់ ប៉ុន្តែត្រូវការពារពីសីតុណ្ហភាពក្តៅខ្លាំង។

➢ ប្រភេទវ៉ាក់សាំង

វ៉ាក់សាំងមានពីរប្រភេទ៖

• វ៉ាក់សាំងដែលបង្អាក់សកម្មភាព ឬងាប់: ជាទូទៅ វាមានទម្រង់ខាប់ (ប្រេង) និងរាវ (សារធាតុអាលុយមីន)។ ប្រភេទវ៉ាក់សាំងនេះ អាចប្រើដោយគ្រាន់តែអនុវត្តតាមការណែនាំជាការស្រេច។ វ៉ាក់សាំងត្រូវប្រើក្នុងពេលមួយកំណត់ ប៉ុន្តែគេអាចរក្សាទុកចំណែកដែលនៅសល់ក្នុងដបដាក់ ក្នុងកន្លែងត្រជាក់ (ទូរទឹកកក ឬធុងទឹកកក) ដើម្បីប្រើនៅថ្ងៃបន្ទាប់។

• វ៉ាក់សាំងរស់: មីក្រុប មានលក្ខណៈជាម្សៅ យើងដាច់ខាតត្រូវលាយជាមួយទឹកសម្រាប់លាយ ដែលមានភ្ជាប់ជាមួយវ៉ាក់សាំង។ នៅពេលលាយបញ្ចូលគ្នាម្សៅវ៉ាក់សាំង និងទឹកសម្រាប់លាយត្រូវមាន សីតុណ្ហភាពដូចគ្នា។ វ៉ាក់សាំងទាំងនេះត្រូវប្រើជាបន្ទាន់

បន្ទាប់ពីលាយ។ ហាមដាច់ខាតមិនត្រូវទុក ចំណែកដែលនៅសល់សម្រាប់ប្រើថ្ងៃបន្ទាប់។ វ៉ាក់សាំងគ្មានប្រសិទ្ធភាព។




ឧទាហរណ៍វ៉ាក់សាំងប្រឆាំងជំងឺបួសខ្យល់ជាប្រភេទវ៉ាក់សាំងងាប់

វ៉ាក់សាំងប្រឆាំងជំងឺប៉េស្តជាប្រភេទវ៉ាក់សាំងរស់




## របៀបលាយវ៉ាក់សាំងរស់ /លាយវ៉ាក់សាំងជំងឺដង្កោ (ជំងឺញូវកាស)




➢ ស្លាកសញ្ញារបស់វ៉ាក់សាំង

មានភាពចាំបាច់ណាស់ក្នុងការអានស្លាកសញ្ញាវ៉ាក់សាំងតែជាអកុសល ស្លាកសញ្ញាតែងសរសេរជាភាសាបរទេសហើយបសុពេទ្យត្រូវសុំអនុសាសន៍ឲ្យបានច្បាស់ពីអ្នកចែកចាយ។

ស្លាកដែលបិតជាប់ដបនឹងប្រាប់យើងអំពី :

- សមាសធាតុ: វីរុសប្រភេទអ្វីស្ថិតនៅខាងក្នុងដបវាមានភាពស្មុគស្មាញក្នុងការបកស្រាយឈ្មោះរបស់ប្រភេទវីរុស

នេះមាននយ័ថាវ៉ាក់សាំងនេះបង្ការប្រឆាំងជំងឺបួសខ្យល់ និងឈាមខ្មៅ




- ឈ្មោះរបស់វ៉ាក់សាំង ផ្តល់នូវព័ត៌មានពីជំងឺជាទូទៅជាភាសាបរទេស (ប៉េស្តអុតក្តាម សារទឹក ...) ដូចនេះកសិករមិនអាចយល់បានទេ។ កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ ត្រូវសុំការ ជួយពីអ្នកចែកចាយថ្នាំ ដែលទទួលបានព័ត៌មានជាក់លាក់ពីក្រុមហ៊ុន។




វ៉ាក់សាំងសម្រាប់ជ្រូកប្រឆាំងជំងឺប៉េស្ត




វ៉ាក់សាំងប្រឆាំងហុកគូលេរ៉ា វាជាឈ្មោះមួយផ្សេងទៀតសម្រាប់ជំងឺប៉េស្ត

វ៉ាក់សាំងសារទឹកគោ




វ៉ាក់សាំងសារទឹកគោ




- កម្រិតប្រើ:

ជាទូទៅចំពោះវ៉ាក់សាំងរស់មន្ទីរពិសោធន៍មិនបង្ហាញពីបរិមាណ (ប៉ុន្មានមីលីលីត្រណាក្នុង១ក្បាលសត្វ) ប៉ុន្តែវាបង្ហាញចំនួនកម្រិតសម្រាប់ចាក់ (=ចំនួនសត្វ)។

តាមពិតទៅវ៉ាក់សាំងរស់ត្រូវលាយជាមួយទឹកលាយមុនពេលប្រើ ឬអាចលាយក្នុងទឹកសម្រាប់សត្វផឹកតែម្តង។ យើងត្រូវគណនា កម្រិតសម្រាប់ចាក់ឲ្យសត្វ ១ក្បាល បន្ទាប់ពី លាយជាមួយទឹករួច។





កម្រិតប្រើប្រាស់កម្របញ្ជាក់សម្រាប់វ៉ាក់សាំង



កូនដបចំណុះ១០០មីលីលីត្រមាន៥០កម្រិត។ ១កម្រិត=២មីលីលីត្រ







វ៉ាក់សាំងដែលអាចចាក់បានរួចរាល់សម្រាប់ចាក់ឲ្យសត្វវាបង្ហាញពីកម្រិតយ៉ាងច្បាស់ដើម្បីចាក់។ ប្រសិនបើ កម្រិតវ៉ាក់សាំងដែលចាក់បានតិចពេកសត្វមិនអាចបង្កើតអង្គការពារបានគ្រប់គ្រាន់ ហើយសត្វមិនអាច ការពារពីជំងឺបានល្អទេ តែបើប្រើ កម្រិតថ្នាំច្រើនេ ឲ្យខាតបង់ប្រាក់។

ចំនួនកម្រិតបង្ហាញយ៉ាង ច្បាស់លើកូនដប លាយក្នុងទឹកសម្រាប់បន្តក់ភ្នែក ឬលាយក្នុងទឹកឲ្យផឹក។ ដបវ៉ាក់សាំងប្រើច្រើនបំផុតសម្រាប់១០០០ក្បាល




ទឹកលាយពណ៌ខៀវប្រើសម្រាប់បន្តក់ភ្នែក ពេលម្សៅលាយជាមួយទឹកនេះវានឹងមាន ១០០០ដំណក់ដើម្បីធ្វើវ៉ាក់សាំងកូនមាន់




ម្សៅមានបរិមាណវីរុសជំងឺញូវកាសដើម្បីធ្វើវ៉ាក់សាំងមាន់១០០០ក្បាល

- ផ្លូវបញ្ចូលវ៉ាក់សាំង

ចំពោះវ៉ាក់សាំងគោ ក្របី ជ្រូកត្រូវចាក់តាមសាច់ដុំ ឬក្រោមស្បែក។ ចំពោះមាន់មានផ្លូវផ្សេងៗទៀតសម្រាប់អនុវត្ត(បណ្ដក់ភ្នែក លាយទឹកឲ្យផឹក ចាក់ក្រោមស្បែក...) ។



បន្តក់ភ្នែក



ចាក់ក្រោមស្បែកក្នុងក



បញ្ជូកតាមមាត់



ដាក់ក្នុងទឹកផឹក



ជួសស្លាបសម្រាប់អុត

- ការប្រុងប្រយ័ត្ន

• ហាមប្រើថ្នាំរម្ងាប់មេរោគ ដើម្បីសម្អាតសឺរ៉ាំងសម្រាប់ចាក់វ៉ាក់សាំងរស់ ពីព្រោះសារធាតុរម្ងាប់មេរោគមានតែបន្តិចវានឹងសម្លាប់មីក្រុបដែលមានក្នុងវ៉ាក់សាំង។

•ពេលលាយវ៉ាក់សាំងរស់ក្នុងទឹកឲ្យផឹក ត្រូវប្រាកដថាទឹកនោះមិនដាក់ជាតិក្លរ ឬអ៊ីយ៉ូឌីន...។ ទឹកដែលផ្តល់ដោយប្រពន្ធ័ទឹករបស់ទីក្រុង ជាទូទៅត្រូវបានរម្ងាប់មេរោគ ហើយមិនអាចលាយ ជាមួយវ៉ាក់សាំង បានទេ។

•វ៉ាក់សាំងសម្រាប់ការពារជំងឺបង្កដោយបាក់តេរីដូចជា បូសខ្យល់ សារទឹក អាសន្នរោគ មិនអាចចាក់ឲ្យសត្វដែលកំពុងព្យាបាលដោយអង់ទីប៊ីយ៉ូទិកទេ។

- ថ្ងៃខែផុតកំណត់

ថ្ងៃខែផុតកំណត់សម្រាប់វ៉ាក់សាំងមានសារៈសំខាន់ណាស់ ជាមួយនេះ ប្រពន្ធ័ត្រជាក់ត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួនចាប់តាំងពីថ្ងៃផលិតរហូតដល់ពេលចាក់។










- ប្រតិកម្ម របស់វ៉ាក់សាំង អាចកើតមានមួយចំនួនបន្ទាប់ពីការចាក់វ៉ាក់សាំងរួចៈ
    - ជាទូទៅសត្វមិនស៊ីចំណីមួយថ្ងៃ និង-គ្រុនក្តៅ
    - ហើម និងឈឺចាប់នៅកន្លែងចាកអាច កើតមានពី២ទៅ៣ថ្ងៃ
    - ការតក់ស្លុតៈ ឧទាហរណ៍




ចំពោះវ៉ាក់សាំងអូហ្សេស្គី ធ្វើឲ្យជ្រូកតក់ស្លុត ស្បែករបស់មេជ្រូកឡើងក្រហម ហើយបង្ហាញអាការៈពិបាកដកដង្ហើម ហៀរទឹកមាត់ខ្លាំង សត្វអាចងាប់។ ដើម្បីកាត់បន្ថយប្រតិកម្មនេះ មិនត្រូវធ្វើឲ្យសត្វស្ត្រេស មុននិងក្រោយចាក់វ៉ាក់សាំង។ ការចាក់វ៉ាក់សាំងត្រូវធ្វើក្នុងពេលត្រជាក់ ពេកព្រឹកព្រលឹម ជាការល្អមិនគួរឲ្យចំណីមុនចាក់វ៉ាក់សាំងទេ។ ក្នុងករណីសត្វតក់ស្លុត ត្រូវចាក់ថ្នាំជិចសាមេតាសូន។

- ការខុសប្រក្រតី: ឧទាហរណ៍ចំពោះវ៉ាក់សាំងជំងឺប៉េស្ត បន្ទាប់ពីចាក់វ៉ាក់សាំងរួច ពេលខ្លះជ្រូកមានរោគសញ្ញាមិនសូវស្រួចស្រាវ ពេលខ្លះទៀតបង្កឲ្យមានរោគសញ្ញាធ្ងន់ធ្ងរ ដូចជាកម្តៅខ្ពស់ មិនស៊ីចំណី ពេលខ្លះងាប់។ ការចាក់វ៉ាក់សាំង ចាំបាច់សត្វត្រូវមានសុខភាពល្អ។
- បូសជារឿយៗកើតឡើយដោយការចាក់ខុសទីតាំង ឬបរិក្ខារ សឺរ៉ាំង ម្ជុល គ្មានអនាម័យ
- រោគសញ្ញានៃជំងឺដែលបានចាក់វ៉ាក់សាំង ដូចជាវ៉ាក់សាំងវ៉ាក់សាំងរស់ការពារជំងឺអុតអាច បង្កើតជាទម្រង់នៃជំងឺនេះដែរ ។ លើដុំពកនៃកន្លែងចាក់វ៉ាក់សាំងនោះគ្មានសញ្ញាធ្ងន់ធ្ងរទេ។

# អង្គបដិបក្ខ (អង់ទីគ័រ)

**និយមន័យ:** សត្វមានអង្គបដិបក្ខ-(អង់ទីគ័រ) ក្នុងរាងកាយ អាស្រ័យដោយ ពួកវាធ្លាប់មានជំងឺពីមុនហើយសត្វផលិតអង្គបដិបក្ខ(អង់ទីគ័រ)ដែលអាចស្ថិតក្នុងខ្លួនច្រើនខែ ឬដោយសារពួកវា ត្រូវបានចាក់វ៉ាក់សាំង ទប់ទល់នឹងជំងឺនេះនិងបានចាក់រំលឹកឡើងវិញជាទៀងទាត់។

- <u>ឧទាហរណ៍</u> មេជ្រូកមានអង្គបដិបក្ខ(អង់ទីគ័រ)ប្រឆាំងនឹងជំងឺប៉េស្ត ដោយសារជ្រូកត្រូវបានចាក់វ៉ាក់សាំងជំងឺប៉េស្តជាទៀងទាត់ ឬពេលខ្លះវីរុសជំងឺប៉េស្ត បានរាលដាលក្នុងកសិដ្ឋានធ្វើឲ្យជ្រូកឈឺតិចតួច ហើយ វាបានផលិតអង្គបដិបក្ខ(អង់ទីគ័រ)ដោយខ្លួនវា។

- បន្ទាប់ពីកើតកូនពី២ទៅ៣ម៉ោងមេជ្រូក ផលិតទឹកដោះពិសេសដែលហៅថាទឹកដោះដំបូង (កូឡូស្រ្តូម) ។ ទឹកដោះនេះផ្តល់ ថាមពលយ៉ាង ច្រើនដល់កូនជ្រូកទើបកើត និងជាពិសេសមាន អង្គបដិបក្ខ (អង់ទីគ័រ)ច្រើន

- ប្រសិនបើមេជ្រូកបានចាក់វ៉ាក់សាំងជំងឺប៉េស្ត ប៉ុន្មានអាទិត្យមុនពេលកើត នោះទឹកដោះដំបូងសម្បូរអង្គបដិបក្ខ (អង់ទីគ័រ) ប្រឆាំងនឹងវីរុសប៉េស្តនេះ។ប៉ុន្មានម៉ោងក្រោយមកបន្ទាប់ពីការកើតកូនជ្រូកនឹងទទួលយកអង្គបដិបក្ខ (អង់ទីគ័រ) តាមរយៈទឹកដោះដំបូងធ្វើឲ្យវាអាចការពារប្រឆាំងនឹងវីរុសប៉េស្ត។ ប្រសិនបើវីរុសប៉េស្តរាលដាលក្នុងកសិដ្ឋានកូនជ្រូកមិនឈឺដោយជំងឺនេះទេ។


ភ្លាមៗបន្ទាប់ពីកើតកូនជ្រូករកក្បាលដោះ ហើយវានឹងបៅទឹកដោះដំបូង

អង្គបដិបក្ខ (អង់ទីគ័រ) ទាំងនេះស្ថិតក្នុងកម្រិតខ្ពស់រហូតដល់៧អាទិត្យ ហើយក្រោយមកនឹងចុះយ៉ាងលឿន។ ដូចនេះមិនត្រូវចាក់វ៉ាក់សាំងជំងឺប៉េស្តឲ្យកូនជ្រូកមុនអាយុ ៧ អាទិត្យទេ ពីព្រោះអង្គបដិបក្ខ (អង់ទីគ័រ) ដែលផ្តល់តាមរយៈទឹកដោះដំបូង នឹងបន្សាបវ៉ាក់សាំងនោះ។



ការចាក់វ៉ាក់សាំងឲ្យមេជ្រូកពី២០ថ្ងៃបន្ទាប់ដាក់ឈ្មោលរហូតដល់១០ថ្ងៃមុនពេលកើត វាមិនធ្វើឲ្យរលូតកូនទេ



ត្រូវពិនិត្យថាកូនជ្រូកទើបកើតទាំងអស់បានបៅទឹកដោះដំបូងបន្ទាប់ពីកើត



កូនជ្រូកត្រូវបានការពារដោយអង់ទីគ័រទទួលពីមេ ហើយការចាក់វ៉ាក់សាំងគ្មានប្រយោជន៍មុនវាមានអាយុ៧ថ្ងៃ

**អនុសាសន៍:**

- ត្រូវចាក់វ៉ាក់សាំងឲ្យមេជ្រូកក្នុងអំឡុងពេលផើម ធ្វើឲ្យមេជ្រូកមានអង្គបដិបក្ខ (អង់ទីគ័រ)គ្រប់គ្រាន់ពេលកើតកូន ទឹកដោះដំបូងមានអង្គបដិបក្ខ (អង់ទីគ័រ) ច្រើន ហើយអាចការពារកូនជ្រូកមិនឲ្យកើតជំងឺបាន។
- ត្រូវឲ្យកូនជ្រូកទាំងអស់បៅទឹកដោះដំបូងបានឆាប់បន្ទាប់ពីកើតរួច ដើម្បីឲ្យកូនជ្រូកទទួលបានអង្គបដិបក្ខ (អង់ទីគ័រ) គ្រប់គ្រាន់។

  ចាំបាច់ត្រូវជួយកូនជ្រូកណាដែលកើតមកខ្សោយឲ្យបានបៅទឹកដោះ។
- កូនជ្រូកមិនអាចចាក់វ៉ាក់សាំងជំងឺប៉េស្តនៅពេលណាក៏បាននោះទេ។ ការចាក់វ៉ាក់សាំងឲ្យវានៅអាយុ២អាទិត្យគ្មានប្រសិទ្ធភាពទេប្រសិនបើមេជ្រូកបានចាក់វ៉ាក់សាំងរួចហើយ។ ជាធម្មតាការចាក់វ៉ាក់សាំងជំងឺប៉េស្តឲ្យកូនជ្រូកត្រូវចាប់ផ្តើមពេលដែលអង្គបដិបក្ខ (អង់ទីគ័រ) ទទួលបានពីមេបានថយចុះដូចនេះត្រូវការចាក់វ៉ាក់សាំលើកទី១នៅអាយុ៧អាទិត្យ និងចាក់រំលឹកលើកទី២នៅអាយុ១១អាទិត្យ។

តែផ្ទុយទៅវិញ ប្រសិនបើមិនបានដឹងថាមេជ្រូកបានចាក់វ៉ាក់សាំងក្នុងពេលថ្មីៗនោះទេកម្មវិធីចាក់ វ៉ាក់សាំងឲ្យកូនជ្រូកត្រូវចាប់ផ្តើមនៅអាទិត្យទី៣ ព្រោះកូនជ្រូកអាចការពារជំងឺប៉េស្ត ដោយអង្គបដិបក្ខ (អង់ទីគ័រ) ទទួលបានពីមេ។ ដូចនេះកម្មវិធីចាក់វ៉ាក់សាំងឲ្យកូនជ្រូកត្រូវធ្វើ នៅអាទិត្យទី៣ ទី៧ និងទី១១។

# ការវិភាគឈាម

➢ និយមន័យ

ការវិភាគឈាម គឺសំដៅដល់ការវិភាគរបស់មន្ទីរពិសោធន៍លើសេរ៉ូមឈាម ដើម្បីត្រួតពិនិត្យរកអង្គបដិបក្ខ (អង់ទីគ័រ)។

សេរ៉ូមឈាមគឺជាផ្នែករាវរបស់ឈាមជាធម្មតា វាមានពណ៌ទឹកមាស ឬលឿងដែលនៅសល់ពេលឈាមត្រូវបានធ្វើឲ្យកក។

យើងដឹងថាបន្ទាប់ពីការឆ្លងចូលមេរោគ ឬបន្ទាប់ពីការធ្វើវ៉ាក់សាំងរាងកាយសត្វនឹងផលិតអង្គបដិបក្ខ (អង់ទីគ័រ)ដែលរត់ក្នុងឈាម។ គោលបំណងគឺដើម្បីកំណត់ថាតើអង្គបដិបក្ខ (អង់ទីគ័រ) ណាដែលកំពុងមានក្នុងឈាម។

➢ បច្ចេកទេសយកវត្ថុវិភាគ

បច្ចេកទេសនេះនឹងជួយឲ្យយើង:

- ធ្វើរោគវិនិច្ឆ័យជំងឺ (រាងកាយបានផលិតអង្គបដិបក្ខ (អង់ទីគ័រ) ពិសេសពេលដែលមេរោគណាមួយរាលដាលក្នុងរាងកាយ)
- ពិនិត្យលើការធ្វើវ៉ាក់សាំងបានត្រឹមត្រូវល្អ ឬយ៉ាងណា ពីព្រោះខ្លួនសត្វនឹងផលិតអង្គបដិបក្ខ (អង់ទីគ័រ) ជាក់លាក់បន្ទាប់ពីការចាក់វ៉ាក់សាំងរួច។
- វាចាំបាច់ត្រូវយកវត្ថុវិភាគឈាម ពីសត្វតាមភូមិ ឃុំ ស្រុក ខេត្ត ដើម្បីធ្វើការវិភាគ










- ឈាមត្រូវដាក់ក្នុងបំពង់ "ស្ងួត" (ដែលមានគម្របពណ៌ក្រហម) និងសេរ៉ូមឈាមលេចឡើងប៉ុន្មាននាទីក្រោយមក
- វត្ថុវិភាគត្រូវផ្ញើរទៅវិទ្យាស្ថានស្រាវជ្រាវបសុព្យាបាលនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ដោយដាក់ជាមួយទឹកកកដើម្បីធានាការរក្សាសេរ៉ូមឲ្យបានល្អ។

# វ៉ាក់សាំង និងកម្មវិធីធ្វើវ៉ាក់សាំង

- ការធ្វើវ៉ាក់សាំងគឺជាមធ្យោបាយសំខាន់ដើម្បីការពារការផ្ទុះជំងឺដោយកន្លែង និងជំងឺធ្ងន់ធ្ងរ ។
  ការធ្វើវ៉ាក់សាំងមិនមានប្រសិទ្ធភាព ១០០% ទេទោះបីការអនុវត្តតាមកម្មវិធីធ្វើវ៉ាក់សាំងពេញលេញក៏ដោយក៏សត្វអាចមានឈឺផងដែរ។ ការធ្វើវ៉ាក់សាំងត្រូវផ្សារភ្ជាប់ជាមួយអនាម័យល្អ និងជីវៈសុវត្ថិភាព និងការគ្រប់គ្រងត្រឹមត្រូវ។
- ម្យ៉ាងវិញទៀត វ៉ាក់សាំងមានតម្លៃថ្លៃ ដូចនេះត្រូវធ្វើការវាយតម្លៃពីហានិភ័យ និងឥទ្ធិពលរបស់ជំងឺមុននឹងរៀបចំកម្មវិធីចាក់វ៉ាក់សាំង។ ឧទាហរណ៍ ប្រសិនបើកសិករប្រឈមនឹងបញ្ហារាគ បណ្ដាលពីអ៊ីកូលី (E.Coli) ក្នុងអំឡុងពេលថ្ងៃដំបូងបន្ទាប់ពីកើតពួកគេអាចសម្រេចធ្វើការវ៉ាក់សាំងលើមេជ្រូកប្រឆាំងជំងឺអ៊ីកូលីមុនពេលកើត... ឬពួកគេអាចសម្រេចធ្វើការថែរក្សាអនាម័យឲ្យបានល្អក្នុងទ្រុងកើតកូន និងរៀបចំសំបុកដើម្បីការពារកូនជ្រូកប្រឆាំងនឹងខ្យល់បក់ខ្លាំង និងធាតុអាកាសត្រជាក់នៅពេលយប់។


កូនជ្រូកទើកើតរាគបណ្ដាលដោយអ៊ីកូលី


អនាមយ័ និងសំបុកមានផាសុខភាពសម្រាប់កូនជ្រូកគួរតែគ្រប់គ្រងបញ្ហាទាំងនេះបាន

វ៉ាក់សាំងមិនអាចដោះស្រាយបញ្ហាបានទេនិងវាអាចប្រើតែក្នុងការបំពេញលើការគ្រប់គ្រងបានល្អ




➢ **ការជ្រើសរើសវ៉ាក់សាំង**

- ការធ្វើរោគវិនិច្ឆ័យជំហានដំបូង ដាច់ខាតយើងត្រូវកំណត់ភ្នាក់ងារបង្កជំងឺ។ វ៉ាក់សាំងមានភាពជាក់លាក់ប្រឆាំងនឹងជំងឺ និងការពារជំងឺក្នុងកសិដ្ឋាន ដូចនេះយើងត្រូវច្បាស់អំពីការធ្វើរោគវិនិច្ឆយ័។ ឧទាហរណ៍ជាទូទៅត្រូវធ្វើរោគវិនិច្ឆ័យជំងឺអូជេស្គីនៅពេលមានរោគសញ្ញាប្រសាទដែលធ្វើឲ្យសត្វប្រកាច់សង្កេតឃើញក្នុងដំណាក់កាលក្រោយពេលផ្ដាច់ដោះ។ ប៉ុន្តែជាធម្មតាជំងឺអូជេស្គីបង្កឲ្យមានការប្រកាច់ចំពោះតែកូនជ្រូកទើបកើត ម្យ៉ាងទៀតត្រូវធ្វើការសង្ស័យលើជំងឺអេដេម៉ាពេលកូនជ្រូកផ្ដាច់ដោះ ឬ

កូនជ្រូកប្រកាច់លើមិនមែនជាជំងឺអូជេស្គីទេ ប៉ុន្តែសង្ស័យជាជំងឺស្ទ្រិបតូកុក



ស្ត្រិបតូកុក (Streptococcus) ផងដែរ។ វ៉ាក់សាំងប្រឆាំងជំងឺអូជេស្គីមិនមានប្រយោជន៍ទេ។

- **ប្រភេទមេរោគ** ជំងឺខ្លះអាចបង្ហាញរោគសញ្ញាដូចគ្នា ទោះបីប្រភេទ វីរុសផ្សេងគ្នាក្តី ប្រសិនបើវ៉ាក់សាំងដែលបានប្រើខុសប្រភេទវីរុស អង្គបដិបក្ខ (អង់ទីគ័រ) មិនមានសមត្ថភាពដើម្បីប្រឆាំងនឹងវីរុស។ ឧទាហរណ៍យើងអាចងាយស្រួលស្គាល់រោគសញ្ញារបស់ជំងឺអុតក្តាមលើគោ។ ដើម្បីការពារគោ ក្របីនៅឃុំជិតនោះកសិករត្រូវធ្វើការសម្រេចចិត្តធ្វើវ៉ាក់សាំងគោរបស់ពួកគេ។




ពួកគាត់នឹងទិញវ៉ាក់សាំងដែលមានប្រភេទវីរុសតែមួយមុខគឺប្រភេទអូ (O) ព្រោះវាមានតម្លៃថោក វ៉ាក់សាំងនេះជម្រុញឲ្យមានការផលិតអង្គបដិបក្ខ (អង់ទីគ័រ) ប្រឆាំងវីរុសអុតក្តាមប្រភេទ អូ(O) តែជាអកុសលរោគសញ្ញាជំងឺអុតក្តាមគឺកើតមានជាប្រភេទ អេស៊ា១ (Asia1) ដូច្នេះគោដែលចាក់វ៉ាក់សាំងអុតក្តាម ប៉ុន្តែវាមិនត្រូវបានការពារប្រឆាំងនឹងជំងឺនេះទេដោយសារប្រភេទវីរុសខុសគ្នា។ យើងមិនដែល ដឹងពីប្រភេទវីរុសមុនពេលធ្វើការកំណត់ដោយមន្ទីពិសោធន៍ ហើយរោគសញ្ញាមានភាពដូចគ្នាសម្រាប់គ្រប់ប្រភេទវីរុសអុតក្តាមទាំងអស់។ ដូចនេះត្រូវចាក់វ៉ាក់សាំងដែលមានវីរុសប្រភេទទ្រីវ៉ាឡង់ ដែលនឹងជម្រុញការផលិតអង្គបដិបក្ខ (អង់ទីគ័រ)ប្រឆាំងនឹងប្រភេទអូ អា និងអេស៊ា១។

- **ការផ្លាស់ប្តូរទម្រង់** (Mutation) វីរុសខ្លះអាចប្រែប្រួលរាងពេលវាបំបែកខ្លួន និងពេលវ៉ាក់សាំងមិនមានប្រសិទ្ធភាពតទៅទៀត។ ឧទាហរណ៍ការផ្ទុះជំងឺគ្រុនចៀកខៀវកើតក្នុងឆ្នាំ២០១០ ប្រភេទភ្នាក់ងារបង្កជំងឺកម្រិតខ្ពស់ថ្មីមួយត្រូវបានរកឃើញ និងវ៉ាក់សាំងដែលប្រើនៅអឺរ៉ុប និងអាមេរិកមិនមានប្រសិទ្ធភាពប្រឆាំងនឹងការឆ្លងនេះ។ វ៉ាក់សាំងគ្រាន់តែបាននាំនូវវីរុសថ្មីចូលក្នុងកសិដ្ឋាន និងធ្វើឲ្យស្ថានភាពកាន់តែធ្ងន់ធ្ងរឡើង។ មិនត្រូវចាក់វ៉ាក់សាំងប្រឆាំងជំងឺគ្រុនចៀកខៀវជាដាច់ខាត។

➢ មូលហេតុធ្វើឲ្យបរាជ័យក្នុងការធ្វើវ៉ាក់សាំង

- ប្រពន្ធ័ត្រជាក់ខូច ពេលធ្វើដំណើរពីក្រុមហ៊ុនទៅកសិដ្ឋាន ចំពោះវ៉ាក់សាំងរស់ (វ៉ាក់សាំងងាប់មានភាពសម្របជាមួយកម្តៅច្រើនជាង) ត្រូវដាក់ក្នុងសីតុណ្ហភាពក្រោម៨ អង្សាសេ។ វីរុសក្នុងកូនដបតូចនឹងងាប់មួយចំនួន ឬទាំងអស់ហើយនឹងមិនជម្រុញឲ្យមានការផលិតអង្គបដិបក្ខ (អង់ទីគ័រ)

- វ៉ាក់សាំងមិនមែនផលិតបានត្រឹមត្រូវ និងគុណភាពមិនត្រូវនឹងគំរូ (ស្តង់ដារ) ភាពសុទ្ធ និងកំហាប់មិនគ្រប់គ្រាន់ដើម្បីធានាការផលិតអង្គ-បដិបក្ខ (អង់ទីគ័រ)
- ការត្រួតពិនិត្យថ្ងៃខែផុតកំណត់ដែលបង្ហាញថាវ៉ាក់សាំងបានផុតកាលបរិច្ឆេទ
- កម្រិតអង្គបដិបក្ខ (អង់ទីគ័រ) ដែលទទួលពីមេមានកម្រិតខ្ពស់ វ៉ាក់សាំងត្រូវបានបន្សាបដោយអង្គបដិបក្ខ (អង់ទីគ័រ) និងត្រូវចាក់ជាថ្មីនៅពេលក្រោយដើម្បីធានាភាពធននឹងជំងឺបានខ្លាំង។ អង្គបដិបក្ខ(អង់ទីគ័រ)ទទួលពីមេមានកម្រិតខ្ពស់ក្នុងអំឡុងពេលបៅដោះ។
- ការសម្ងំមេរោគៈសត្វដែលបានធ្វើវ៉ាក់សាំងមើលទៅមានសុខភាពល្អ ប៉ុន្តែវាមានការសម្ងំជំងឺរួចស្រេច។ ការចាក់វ៉ាក់សាំងអាចបង្កឲ្យលេចឡើងនូវជំងឺ និងបង្ខំវាឲចេញរោគសញ្ញា។
- សម្ភារៈសម្រាប់ចាក់វ៉ាក់សាំងមិនស្អាត សារធាតុសរីរាង្គ សំណល់អង់ទីប៊ីយ៉ូទិក ... នឹងបំផ្លាញមីក្រុប។
- សម្ភារៈសម្រាប់ចាក់វ៉ាក់សាំងត្រូវបានរម្ងាប់ដោយសារធាតុគីមីៈ វ៉ាក់សាំងរស់អាចត្រូវបំផ្លាញដោយសូម្បីតែសំណល់តិចតួចរបស់សារធាតុរម្ងាប់មេរោគ។
- បច្ចេកទេសចាក់វ៉ាក់សាំងមិនត្រឹមត្រូវ ជាពិសេសចំពោះការចាក់វ៉ាក់សាំងមេជ្រូកនៅកន្លែងពាក់កណ្តាលជាមួយម្ជុលប្រវែង ២០មីលីម៉ែត្រ ជាតិវ៉ាក់សាំងបានស្ថិតនៅក្នុងខ្លាញ់ និងមិនចូលក្នុងសាច់ដុំ ដូចនេះវាមិនអាចឆ្លងចូលក្នុងចរន្តឈាម។
- ជ្រូកស្ថិតក្នុងការព្យាបាលដោយអង់ទីប៊ីយ៉ូទិក។

➢ ការណែនាំកម្មវិធីធ្វើវ៉ាក់សាំងសម្រាប់កសិដ្ឋានតូចៗ

ចាំបាច់ត្រូវចងចាំថា មានតែសត្វដែលមានសុខភាពល្អទេដែលអាចចាក់វ៉ាក់សាំងបាន។

## ក.មាន់

- **ជំងឺញូវកាស**

កូនមាន់អាយុមួយថ្ងៃ ត្រូវបានចាក់វ៉ាក់សាំងនៅថ្ងៃទី១តាមការបន្តក់ភ្នែក និងទទួលការរំលឹកនៅ ២ទៅ ៣អាទិត្យក្រោយមក។ មេមាន់អាចចាក់ម្តងទៀតនៅ ៧ ទៅ ៨អាទិត្យ។

- **ជំងឺអាសន្នរោគ**

ចាក់ជាពិសេសសម្រាប់មេមាន់នៅអាយុ ១២ ទៅ ១៦អាទិត្យ និងរំលឹកនៅ៤អាទិត្យក្រោយមក។ គោលបំណងគឺត្រូវចាក់រំលឹកនៅ២អាទិត្យមុនពេលពង។

- **ជំងឺអុត**

ក្នុងករណីផ្ទុះជំងឺនេះកើតចំពោះកូនមាន់ពី ១០ថ្ងៃ ទៅ ១០អាទិត្យ។ ត្រូវធ្វើវ៉ាក់សាំងឲ្យទៀងទាត់សម្រាប់មេមាន់ក្រមុំចន្លោះពី ១២ ទៅ ១៦អាទិត្យ។

- **ជំងឺហ្គុមបូរ៉ូ**

វ៉ាក់សាំងនេះអាចធ្វើបានដោយដាក់ក្នុងទឹកឲ្យផឹកនៅអាយុ ២ ទៅ ៣អាទិត្យ។

## ខ.ជ្រូក

- **ជំងឺប៉េស្ត**

ចាក់ឲ្យកូនជ្រូកអាយុ ៣អាទិត្យ (ចំពោះតែមេជ្រូកមិនបានចាក់វ៉ាក់សាំងទៀតទាត់) អាយុ ៧អាទិត្យ និង១១អាទិត្យដើម្បីធានាថាអង្គបដិបក្ខ (អង់ទីគ័រ) ដែលទទួលបានពីមេមិនអាចបន្សាបវ៉ាក់សាំង។ មេក្រមុំ និងមេជ្រូកចាក់នៅអាយុ៦ខែ និងក្រោយមកទៀតនៅ១ខែមុនកើតកូន។ មេជ្រូកត្រូវចាក់វ៉ាក់សាំងពីរដងក្នុងមួយឆ្នាំ។

- **ប៉ាវ៉ូវីរុសលើជ្រូក**

មេក្រមុំ ត្រូវចាក់ពីរដងក្នុងពេល១ខែដោយឡែកពីគ្នា វាអាចចាក់នៅអាយុ៦,៥ខែ និង ៧,៥ខែ ដើម្បីលៃការចាក់លើកទី២នៅប្រមាណ២អាទិត្យមុនពេលដាក់ឈ្មោលមេជ្រូកនៅ១០ថ្ងៃមុនផ្ដាច់ដោះ។

- **អូជេស្គី**
    - មេក្រមុំត្រូវចាក់ពីរដងក្នុងពេល១ខែ នៅអាយុ៦ និង៧ខែ
    - មេជ្រូកត្រូវចាក់នៅ១,៥ខែមុនពេលកើតកូន
    - ជ្រូកសាច់មិនចាំបាច់ចាក់វ៉ាក់សាំងនេះទេ
    - ការធ្វើវ៉ាក់សាំងជំងឺអូជេស្គី គួរត្រូវធ្វើសម្រាប់កសិដ្ឋានខ្នាតមធ្យមតែប៉ុណ្ណោះ។

- **អុតក្ដាម**

វ៉ាក់សាំងជំងឺអុតក្ដាមត្រូវការចាក់រំលឹកជាប្រចាំដើម្បីការពារជ្រូក។ ជ្រូកសាច់ចិញ្ចឹមតែ ៦ខែ និងមិនអាចលូតលាស់ភាពស៊ាំបានរឹងមាំនោះទេ។

កម្មវិធីដែលត្រូវធ្វើវ៉ាក់សាំងគឺសម្រាប់មេក្រមុំ និងមេជ្រូក។ ជ្រូកញី ដែលត្រូវជ្រើសរើសសម្រាប់ការបន្តពូជគួរត្រូវចាក់វ៉ាក់សាំងនៅអាយុ៣ខែ និងការចាក់លើកទី២នៅ១ខែក្រោយមកទៀត។

ការចាក់រំលឹកឡើងវិញត្រូវធ្វើនៅរៀងរាល់៤ទៅ៦ខែ និងចាំបាច់ត្រូវចាក់ឡើងវិញនៅរាល់ពេលមានករណីផ្ទុះជំងឺនេះក្នុងតំបន់។

## គ.គោ

- **អុតក្ដាម**

ការចាក់លើកទី១នៅអាយុ៤ខែ រំលឹកនៅ១ខែក្រោយមកទៀត ហើយបន្ទាប់មកចាក់រៀងរាល់៦ខែ។ ក្នុងករណីមានផ្ទុះនៅភូមិជិតនោះ យើងត្រូវចាក់វ៉ាក់សាំងឲ្យគោទាំងអស់ក្នុងភូមិ ការការពារអាចលូតលាស់បានលឿន ហើយបើទោះជាការចាក់តែមួយដងក៏ដោយគោនឹងត្រូវបានការពារនៅប៉ុន្មានថ្ងៃក្រោយមក។

- **បូសខ្យល់**

ការចាក់លើទី១ នៅ២ខែបន្ទាប់ពីកើត ចាក់រំលឹកនៅ១ខែក្រោយមក នៅ១ឆ្នាំ និង៥ឆ្នាំក្រោយមក។ ជាអនុសាសន៍ត្រូវធ្វើវ៉ាក់សាំងនេះក្នុងភូមិដែលមានប្រវត្តផ្ទុះជំងឺបូសខ្យល់។ បាក់តេរីអាចបំលែងជាស្ព័រ(Spore) និងអាចរស់បានច្រើនឆ្នាំក្នុងដី ហើយជំងឺនេះអាចលេចឡើងគ្រប់ពេល ។

- **សារទឹក**

ជាទម្លាប់ការផ្ទុះជំងឺនេះចាប់ផ្តើមក្នុងខែវស្សា ដូចនេះយកល្អត្រូវចាក់វ៉ាក់សាំងនៅមុនខែវស្សា។ តាមពិតការចាក់វ៉ាក់សាំងជំងឺសារទឹកត្រូវបានធ្វើឡើងតាមរយៈយុទ្ធនាការចាក់វ៉ាក់សាំង និងការបានទទួលវ៉ាក់សាំងនេះសម្រាប់កសិករមិនមែនងាយស្រួលនោះទេ។







# ជំពូកទី៨៖ បសុឱសថ និងការប្រើប្រាស់






បសុឱសថ គឺជាថ្នាំសកម្ម មានន័យថាមានឥទ្ធិពលលើជំងឺសត្វ ទ្រទ្រង់សុខភាពសត្វ ឬ បង្កើនផលិតភាពរបស់សត្វ។

បសុឱសថត្រូវបានប្រើ:

- ដើម្បីការពារសុខភាពសត្វ ដូចជាព្យាបាលសត្វឈឺ ឬការពារជំងឺសត្វ ក្នុងហ្វូងសត្វ
- ដើម្បីបង្កើនផលិតកម្មសត្វឲ្យប្រសើរជាងមុន មានសាច់ ទឹកដោះច្រើន ។

ប្រសិទ្ធភាព និងសុវត្ថិភាពគឺជាក្តីបារម្ភ ពេលប្រើប្រាស់បសុឱសថ។

## ក. ប្រភេទបសុឱសថ

បសុឱសថ ដែលត្រូវប្រើរួមមាន៖

១. **វីតាមីន និងសារធាតុរ៉ែ** មានសារៈសំខាន់ក្នុងការទ្រទ្រង់សុខភាពសត្វ ធានាការលូតលាស់ និងការបន្តពូជបានល្អប្រសើរ។

២. **ថ្នាំអង់ទីប៊ីយ៉ូទិក** មានសារៈសំខាន់ក្នុងការប្រឆាំងការបំបែកខ្លួន និងសម្លាប់បាក់តេរី។

៣. **ថ្នាំប្រឆាំងនឹងការរលាក បញ្ចុះកម្តៅ ឬបំបាត់ការឈឺចាប់:** ជាឱសថបំបាត់ការរលាក ថ្នាំបញ្ចុះកម្តៅ(គ្រុនក្តៅ) និងបំបាត់ការឈឺចាប់។

៤. **ថ្នាំប្រឆាំងបរាសិត** មានប្រសិទ្ធភាពប្រឆាំងបរាសិតលើស្បែក ក្នុងបំពង់រំលាយអាហារ បំពង់ដកដង្ហើម បរាសិតក្នុងឈាម និងពពួកបរាសិតក្នុងសរីរាង្គផ្សេងៗ

៥. **អ័រម៉ូន:** មានប្រសិទ្ធភាពលើសរីរាង្គបន្តពូជញី ឈ្មោល(អង្គជាតិ) និងការបន្តពូជ។

៦. **វ៉ាក់សាំង:** ដើម្បីការពារជំងឺ ដែលបង្កដោយវីរុស និងបាក់តេរី។

៧. **ថ្នាំរម្ងាប់មេរោគ:** អាចសម្លាប់ពួកបាក់តេរី វីរុស ផ្សិតនៅក្នុងបរិស្ថាន។

៨.**ថ្នាំបន្សាប:** ជាសារធាតុសម្រាប់ទប់ស្កាត់ រារាំង និងបំបាត់សារធាតុពុល ដែលបណ្តាលមកពីសារធាតុគីមីផ្សេងៗដូចជាថ្នាំសម្លាប់សត្វល្អិត ប្រតិកម្មដោយសារការចាក់ថ្នាំការពារជាដើម។

## ១. វីតាមីន និងសារធាតុរ៉ែ

### ១.១. មុខងាររបស់វីតាមីន



វីតាមីនអាមានសារៈសំខាន់ សម្រាប់សុខភាពស្បែក

វីតាមីនជាសារធាតុដែលសម្រួលដល់ការប្រើប្រាស់ថាមពល និងប្រូតេអ៊ីន សម្រាប់សុខភាព ការលូតលាស់ និងការបន្តពូជ។



ស្បែកគឺជាសន្ទស្សន៍ត្រឹមត្រូវសម្រាប់ កំណត់ពីកង្វះវីតាមីន និងសារធាតុរ៉ែ

- **វីតាមីនអា** (Vitamin A) មានសារៈសំខាន់សម្រាប់សុខភាពភ្នែក រោម និងស្បែក និង មានឥទ្ធិពលលើការបន្តពូជ។

- **វីតាមីនបេ** (Vitamin B) ជាក្រុម នៃវីតាមីនជាច្រើនប្រភេទដូចជា បេ១ បេ៦ បេ១២...។ ប្រភេទវីតាមីនបេខ្លះមានមុខងារសំខាន់ក្នុងការលូតលាស់ ព្រោះជួយសត្វក្នុងការស្រូបយកប្រូតេអ៊ីន។ កង្វះវីតាមីនក្រុមបេនាំឲ្យសត្វលូតលាស់យឺត និងប្រសិទ្ធភាពក្នុងការស្រូបយកសារធាតុក្នុងចំណីមិនបានល្អ។ វីតាមីនបេ១២មានមុខងារជួយឲ្យសត្វជាសះស្បើយ បន្ទាប់ពីហូរឈាម។
- **វីតាមីនសេ** (Vitamin C) ជាទូទៅ ជាសារធាតុលើកកម្លាំង និងមានមុខងារកាត់បន្ថយឥទ្ធិពលស្ត្រេស។ វីតាមីនសេ អាចលាយជាមួយចំណី ឬទឹកដើម្បីឲ្យសត្វស៊ី ឬផឹក។
- **វីតាមីនដេ** (Vitamin D) មានមុខងារសំខាន់សម្រាប់ការលូតលាស់ ការទ្រទ្រង់ឆ្អឹង និងធ្មេញ ។ វីតាមីនដេជួយជម្រុញការប្រើប្រាស់ជាតិកាល់ស្យូម និងផូស្វ័រ។ កង្វះជាតិវីតាមីនដេបណ្ដាលឲ្យសត្វមានសញ្ញាខ្វះជាតិ កាល់ស្យូម និងផូស្វ័រដែរគឺរោគក្រិសធ្ងន់ធ្ងរ។



ពេលមាន់ដង្ហក់ ត្រូវលាយវីតាមីនសេក្នុងទឹកឲ្យវាផឹក វានឹងកាត់បន្ថយឡើងកម្ដៅ



ការខូចទ្រង់ទ្រាយជើងមុខ និងសន្លាក់រីកធំជាសញ្ញាក្រិស

- **វីតាមីនអឺ** (Vitamin E) មានតួនាទីសំខាន់ ក្នុងការជម្រុញប្រព័ន្ធការពាររាងកាយ(ភាពស៊ាំ) និងជួយជំរុញការបន្តពូជ។

## ១.២. ប្រភពវីតាមីន

- វីតាមីនអា មានប្រភពពីស្មៅ ស្លឹកដំឡូងមី ម្សៅត្រី និងខ្លាញ់ត្រី...
- វីតាមីនបេ មានប្រភពពីគ្រាប់ធញ្ញជាតិគ្រប់ប្រភេទ
- វីតាមីនសេ មានប្រភពពីផ្លែឈើ ស្មៅទឹក...
- វីតាមីនដេ មានប្រភពពីម្សៅត្រី និងខ្លាញ់ត្រី...
- វីតាមីនអឺ មានប្រភពពីគ្រាប់ធញ្ញជាតិគ្រប់ប្រភេទ និងខ្លាញ់...







ការរក្សាទុកវត្ថុធាតុដើមមិនបានត្រឹមត្រូវ ទុករយៈពេលយូរ និងក្រោមកម្ដៅថ្ងៃខ្លាំងពេកនាំឲ្យបំផ្លាញវីតាមីនយ៉ាងលឿន។

សត្វដើរស៊ីចំណីដោយខ្លួនឯង ជាទូទៅជ្រូក និងមាន់ត្រូវការពពួកវីតាមីនជាទៀងទាត់ ដូចនេះ ត្រូវបន្ថែមពពួកវីតាមីនជារៀងរាល់ថ្ងៃ ដើម្បីធានាការលូតលាស់ និងបន្តពូជបានល្អ។

បាក់តេរីក្នុងក្រពះសត្វទំពារអៀង(គោ ក្របី) មានលទ្ធភាពសំយោគវីតាមីនក្រុមបេ។ គោ ក្របីត្រូវការច្រើននូវវីតាមីនអា ដេ និងអ៊ី។

## ១.៣ មុខងារសារធាតុរ៉ែ

សារធាតុរ៉ែមានមុខងារសំខាន់បីយ៉ាងដូចជា៖

- ផ្តល់នូវការលូតលាស់គ្រោងឆ្អឹង
- ជួយជំរុញដល់ដំណើរការប្រព័ន្ធសរសៃប្រសាទ
- ជួយសម្រួលប្រតិកម្មគីមីក្នុងរាងកាយ ការរំលាយអាហារ ការកន្ត្រាក់សាច់ដុំ ដំណើរការប្រព័ន្ធភាពស៊ាំ...។

**សារធាតុរ៉ែសំខាន់ៗមាន៖**

- **កាល់ស្យូម** (Calcium)

កាល់ស្យូមមានប្រហែល២% នៃទម្ងន់ខ្លួន និង៩៩% មាននៅក្នុងឆ្អឹង។ កាល់ស្យូមមានសារៈសំខាន់ ដើម្បីផលិតឆ្អឹង ស៊ុត និងការលូតលាស់បានល្អ។ ម្សៅសំបកខ្យងស្ងួត ផ្តល់ជាតិកាល់ស្យូម។ ការផ្តល់ជាតិកាល់ស្យូមតែមួយមុខ មិនទាន់គ្រប់គ្រាន់ទេ វីតាមីនដេមានសារៈសំខាន់សម្រាប់ការស្រូបជាតិកាល់ស្យូម។ កង្វះជាតិកាល់ស្យូមបង្កឲ្យកើតជំងឺក្រិស ចំពោះបក្សី គោ ក្របី និងជ្រូក។

បក្សីខ្វះជាតិកាល់ស្យូម បណ្តាលឲ្យសំបកស៊ុតស្តើង និងផលិតស៊ុតធ្លាក់ចុះ ដូចនេះចាំបាច់ត្រូវផ្តល់ម្សៅសំបកខ្យងតាមតម្រូវការវា។

គោ ក្របី និងមេជ្រូក ត្រូវការជាតិកាល់ស្យូមច្រើន ពេលវាផលិតទឹកដោះ។ ជាពិសេសក្រោយពេលកើតកូន បរិមាណកាល់ស្យូមបានបាត់បង់ អាចបណ្តាលឲ្យសត្វខ្សោយ និងទន់ជើង។ ត្រូវចាក់កាល់ស្យូមគ្លុយកូណាត (Calcium gluconate)។

- **ផូស្វ័រ** (Phosphorus)

**ផូស្វ័រ** មានតួនាទីសំខាន់ជាមួយកាល់ស្យូម និងសារធាតុរ៉ែដ៏ទៃទៀត សម្រាប់ការលូតលាស់ ឆ្អឹង និងសាច់ដុំ។ ផូស្វ័រមានសារៈសំខាន់សម្រាប់ប្រសិទ្ធភាពបន្តពូជ។៨០% នៃផូស្វ័រមាននៅក្នុងឆ្អឹង។


សំបកស៊ុតទន់បណ្តាលមកពីកង្វះជាតិកាល់ស្យូម

ការផ្តល់ជាតិផូស្វ័របន្ថែម សម្រាប់សត្វ ដើម្បីការលូតលាស់លឿន។ ជាតិផូស្វ័រនិងកាល់ស្យូមត្រូវលាយជាមួយគ្នា ។

ឧទាហរណ៍ ដេសេប៉េ (ឌីកាល់ស្យូមផូស្វាត (Di Calcium Phosphate)) ជាជាតិកាល់ស្យូមនិងផូស្វ័ររួមគ្នាដ៏ល្អ។

មិនត្រូវប្រើជាតិផូស្វាតធម្មជាតិ(ជីគីមី)ដែលប្រើសម្រាប់ដាក់ស្រែ ព្រោះវាមានជាតិពុលដល់សត្វ។

- **ម៉ាញេស្យូម (Magnesium)**

ម៉ាញេស្យូមមានមុខងារដូចគ្នានឹងផូស្វ័រ។ វាមានតួនាទីជាមួយកាល់ស្យូមផងដែរ។ ម៉ាញេស្យូមមានមុខងារសំខាន់ក្នុងប្រតិកម្មគីមីច្រើនក្នុងរាងកាយ។

កង្វះជាតិម៉ាញេស្យូម ប៉ះពាល់ដល់ការកន្ត្រាក់សាច់ដុំ និងប្រព័ន្ធប្រសាទ (ដូចជាញ័រញាក់ ខ្សោយសាច់ដុំ ប្រព័ន្ធប្រសាទខ្សោយ...)។ គ្រាប់ធញ្ញជាតិ និងស្ពៃរង្វ ជាប្រភពដ៏ល្អរបស់ម៉ាញេស្យូម។


ម្សៅដេសេប៉េពណ៌សលាយជាមួយវត្ថុធាតុដើមដើម្បីផ្តល់ជាតិកាល់ស្យូម និងផូស្វ័រក្នុងរបបចំណី

- **ជាតិដែក (Iron)**

ជាតិដែកចាំបាច់សម្រាប់ការលូតលាស់របស់កូនជ្រូក។ ត្រូវផ្តល់ជាតិដែកឲ្យបានសមស្របក្នុងរាងកាយ នៅពេលទើបកើត។ ក្នុងទឹកដោះរបស់មេជ្រូក មិនអាចផ្តល់ជាតិដែកបានគ្រប់គ្រាន់ទេ បន្ទាប់ពីកូនជ្រូកកើតបាន៧ថ្ងៃ ។

កូនជ្រូកទាំងអស់ត្រូវចាក់ជាតិដែកនៅថ្ងៃទី២ បន្ទាប់ពីកើត និងចាក់រំលឹកនៅ១០ថ្ងៃក្រោយ ដើម្បីការពារខ្វះឈាមក្រហម និងខ្សោយ។


កូនជ្រូកទាំងអស់ត្រូវទទួលជាតិដែកមួយកម្រិតនៅអាយុ២ថ្ងៃបន្ទាប់ពីកើត

## ១.៩ បសុឱសថសំខាន់ៗមានលើទីផ្សារ:

តម្រូវការវីតាមីន និងសារធាតុរ៉ែបន្ថែម:

- ការខ្វះវីតាមីន និងសារធាតុរ៉ែ ធ្វើឲ្យសត្វស្គម រោមបះ ឬរោមស្រអាប់ ដូចនេះត្រូវបន្ថែមគ្រប់  ប្រភេទវីតាមីន និងសារធាតុរ៉ែ ដែលសត្វត្រូវការ សម្រាប់ការរំលាយ ការស្រូបប្រូតេអ៊ីន  ដើម្បីជួយឲ្យរាងកាយមានកម្លាំងឡើងវិញ។





- សត្វឈឺពុំរ៉ែ វាស៊ីតិច ប្រព័ន្ធភាពស៊ាំសត្វចុះខ្សោយ។ ដើម្បីឲ្យមានសុខភាពល្អឡើងវិញ  សត្វត្រូវការវីតាមីន និងសារធាតុរ៉ែច្រើនជាងមុន។ ក្នុងករណីមានបរាសិតខាងក្នុង តម្រូវការវីតាមីន ក៏កើនឡើងផងដែរ។
- ក្នុងអំឡុងពេលសត្វឈឺដោយជំងឺស្រួចស្រាវ វាមិនស៊ីចំណីឬស៊ីតិចតួច ហើយពួកវាបានប្រើប្រាស់នូវអាហារបម្រុងក្នុងរាងកាយ ។ ក្រោយពេលសត្វជាពីជំងឺនេះ សត្វត្រូវការបន្ថែមវីតាមីន និងសារធាតុរ៉ែ ដើម្បីបង្កើតអាហារបម្រុងក្នុងសារពាង្គកាយឡើងវិញ និងឲ្យសត្វជាសះស្បើយបានឆាប់រហ័ស។
- ដើម្បីឲ្យសត្វធំធាត់លឿន  ត្រូវលាយសារធាតុរ៉ែ និងវីតាមីនហៅថាប្រេមិច (Premixes) ក្នុងចំណីឲ្យបានគ្រប់គ្រាន់ជារៀងរាល់ថ្ងៃ។

ពូជជ្រូកកូនកាត់លូតលាស់លឿន ត្រូវការវីតាមីននិងរ៉ែច្រើន



ពូជជ្រូកក្នុងស្រុកលូតលាស់យឺត



- ពេលសត្វផលិតទឹកដោះ និងស៊ុត វាបានបញ្ចេញថាមពលបម្រុងក្នុងរាងកាយ ដើម្បីបង្កើនគុណភាពទឹកដោះ និងស៊ុត។ ដើម្បីការពារការបាត់បង់ថាមពលបម្រុងទាំងនោះ ត្រូវផ្តល់ វីតាមីន និងសារធាតុរ៉ែបន្ថែម។

- វីតាមីន និងសារធាតុរ៉ែមួយចំនួន អាចជំរុញមុខងារជាក់លាក់ និងត្រូវផ្តល់ក្នុងពេលកំណត់ជាក់លាក់។ ត្រូវចាក់ វីតាមីនអាដេអឺ ដើម្បីជម្រុញការរកឈ្មោលបន្ទាប់ពីផ្តាច់ដោះ។

ថ្នាំអាចចាក់បាន:

- **វីតាមីនអាដេអឺ (Vitamin ADE)** ប្រើសម្រាប់ចាក់គោ ក្របី និងមេជ្រូក ជាពិសេសបន្ទាប់ពីផ្តាច់ដោះ ដើម្បីជំរុញការរកឈ្មោលឡើងវិញ។







- **វីតាមីនអឺ ជាមួយសេលេនីញ៉ូម (Vitamin E + Selenium)** ប្រើចំពោះមេជ្រូកជើម: ចាក់៣អាទិត្យមុនពេលកើតកូន ដោយចាក់មួយអាទិត្យម្តង ដើម្បីធ្វើឲ្យកូនជ្រូកមានកំលាំងនៅពេលកើតនិងការពារទន់ជើង។







- **ជាតិដែកដិចត្រង់ (Iron Dextran)** ត្រូវចាក់ឲ្យកូនជ្រូកអាយុបាន២ថ្ងៃបន្ទាប់ពីកើត និងចាក់រំលឹកនៅ១០ថ្ងៃបន្ទាប់ ដើម្បីការពារការខ្វះឈាមក្រហម។










វាជាការមិនសមហេតុផលក្នុងការលាយថ្នាំទាំងពីរនេះចូលគ្នា

- **វីតាមីនចម្រុះ៖** រួមបញ្ចូលគ្រប់វីតាមីនសំខាន់ៗទាំងអស់ ដូចជាក្រុមបេ វីតាមីនសេ ជាមួយវីតាមីនអាដេអឺ និងកា។ ជាទូទៅ វីតាមីនចម្រុះនេះ ត្រូវចាក់ម្តងក្នុងមួយអាទិត្យ ដើម្បីជួយឲ្យសត្វឆាប់ជាសះស្បើយ ឬលើសត្វស្គម ដែលខ្វះសារធាតុច្រើនប្រភេទ។










- **វីតាមីនបេ១២** ប្រើសម្រាប់ការខ្វះឈាមក្រហម បន្ទាប់ពីការហូរឈាម ដំបៅក្នុងក្រពះ (ក្រពះចេញឈាមរបស់ជ្រូក ឬក្នុងករណីដង្កូវថ្លើម។

ជារឿយៗ វីតាមីនបេ១២ លាយជាមួយនឹងសារធាតុដទៃទៀត ដូចជាផូស្វ័រ ហៅថាការ៉ាស៊ីល (Carasil ) ជាថ្នាំជំនួយកម្លាំង។ បើលាយជាមួយនឹងជាតិដែកដិចត្រង់ (ហៅថា Iron B12) សម្រាប់ការខ្វះឈាមក្រហមចំពោះកូនជ្រូក។ បើលាយជាមួយសេលេនីយ៉ូម និងម៉ាញេស្យូម ហៅថា(Biodyl) សម្រាប់ពង្រឹងសាច់ដុំ ជាពិសេសបញ្ហាញ្ញែកជើងរបស់កូនជ្រូក។










- **កាល់ស្យូម (Calcium)** អាចចាក់លើមេជ្រូក និងមេគោដែលទើបកើតកូន។ នៅពេលផលិតទឹកដោះ វាទាញយកជាតិកាល់ស្យូមយ៉ាងច្រើន និងធ្វើឲ្យមេចុះខ្សោយ មិនអាចក្រោកឈរនិងដកដង្ហើមញាប់។








**ថ្នាំប្រើតាមមាត់**

- **វីតាមីនសេ (Vitamin C** or Ascorbic Acid) ជាថ្នាំដែលល្អសម្រាប់កាត់បន្ថយឥទ្ធិពល ស្ត្រេស។ ប្រើសម្រាប់មាន់សាច់ លាយក្នុងទឹកឲ្យផឹក:

- ❖ ជំរុញភាពស៊ាំរបស់កូនមាន់អាយុ១ថ្ងៃ បន្ទាប់ពីយកមកដល់ ជាញឹកញាប់គេលាយជាមួយថ្នាំអង់ទីប៊ីយ៉ូទិក។
- ❖ ដើម្បីកាត់បន្ថយកំដៅ ក្នុងអំឡុងពេលលូតលាស់ និងនៅពេលសត្វដង្ហក់ (លាយ៣ក្រាមក្នុងចំណី១០គីឡូក្រាម)
- ❖ ប្រើសម្រាប់ជ្រូកបាក្នុងខែក្តៅ ដើម្បីបង្កើនគុណភាពទឹកកាម (១ក្រាមក្នុងមួយថ្ងៃសម្រាប់បា១ក្បាលរៀងរាល់ថ្ងៃ)







- ប្រេមិច (**Premixes**) គឺជាផលិតផលម្សៅ ដែលផ្តល់វីតាមីន និងសារធាតុរ៉ែទៅដល់សត្វ។ ជាពិសេសផលិតផលនេះ ត្រូវបានប្រើសម្រាប់ជ្រូក និងបក្សី នៅពេលដែលកសិករផលិតចំណីដោយខ្លួនឯងជាមួយវត្ថុធាតុដើមក្នុងស្រុក។ តាមពិតប្រមិចទាំងនេះមានជាស្រេចក្នុងចំណីឧស្សាហកម្ម។

ប្រេមិចត្រូវបានគណនាអាស្រ័យនឹងតម្រូវការតាមប្រភេទផ្សេងៗគ្នា សមាសធាតុផ្សំរបស់ប្រេមិចសម្រាប់ជ្រូកសាច់ ខុសគ្នាពីសមាសធាតុផ្សំរបស់មេជ្រូក (មេជ្រូកត្រូវការវីតាមីនអា ដេ និងអឺ និងជាតិប៊ីយ៉ូទីនច្រើន...)។ ប្រេមិចសម្រាប់មាន់សាច់ គឺខុសគ្នាពីប្រេមិចសម្រាប់មាន់ពង។

ប្រេមិចខ្លះត្រូវបានបញ្ជាក់លើស្លាកសញ្ញា សម្រាប់គ្រប់ប្រភេទសត្វ ដូចជា ត្រី ជ្រូក គោ ក្របី និងមាន់សាច់។ ផលិតផលទាំងនេះជារឿយៗមានគុណភាពទាប។









- **វីតាមីនចម្រុះ (Multivitamins)** ជាម្សៅរលាយក្នុងទឹក ដែលផ្តល់កម្រិតវីតាមីនគ្រប់ប្រភេទខ្ពស់ (កម្រិតខ្ពស់ជាងក្នុងប្រេមិច)និងអាចលាយក្នុងចំណីជ្រូក។ ផលិតផលទាំងនេះត្រូវប្រើសម្រាប់ជួយសត្វឈឺឲ្យជាសះស្បើយឡើងវិញ ឬសត្វខ្សោយដោយការចាក់វ៉ាក់សាំង។












- **កាល់ស្យូម និងផូស្វ័រ**

**កាល់ស្យូម** ប្រើជាពិសេសសម្រាប់មាន់ពង ព្រោះត្រូវការប្រហែល០.៥ក្រាម ជាតិកាល់ស្យូម-រៀងរាល់ថ្ងៃ ដើម្បីផលិតសម្បកស៊ុត។ កាល់ស្យូមប្រភេទជាម្សៅ ផលិតពីសំបកងាវ គ្រំ ខ្យង ខ្ចៅ។ល។

**ជាតិផូស្វ័រ**ត្រូវផ្តល់ក្នុងពេលជាមួយជាតិកាល់ស្យូម ដើម្បីបង្កើនការលូតលាស់ឆ្អឹងបានល្អ ។ កម្រិតដែលត្រឹមត្រូវ គឺត្រូវផ្តល់ដោយដេសេប៉េ វាជាម្សៅពណ៌ស ដែលមិនរលាយក្នុងទឹក និងអាចលាយជាមួយចំណី។ ឧទាហរណ៍ ត្រូវប្រើ១០ ទៅ២០ក្រាមក្នុងមួយថ្ងៃ សម្រាប់ការលូតលាស់របស់ជ្រូក និងមេជ្រូកបំបៅកូន។










## ២- ថ្នាំអង់ទីប៊ីយ៉ូទិក (Antibiotics)

### ២.១ និយមន័យ

ថ្នាំអង់ទីប៊ីយ៉ូទិក ជាពពួកថ្នាំប្រឆាំងនឹងមេរោគ ដែលសម្លាប់ ឬទប់ស្កាត់ការបំបែកខ្លួនរបស់បាក់តេរី។ថ្នាំអង់ទីប៊ីយ៉ូទិកភាគច្រើន គេប្រើដើម្បីព្យាបាលសត្វសម្រាប់ការឆ្លងមេរោគខាងក្រៅ និងខាងក្នុង។

ដោយឡែកការប្រើថ្នាំអង់ទីប៊ីយ៉ូទិកខុសទិសដៅ ជាហេតុនាំឱ្យថ្នាំអង់ទីប៊ីយ៉ូទិកទាំងនោះមិនមានប្រសិទ្ធភាព។ **ថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពប្រឆាំងនឹងវីរុសទេ។**







## ២.២ ប្រភេទថ្នាំអង់ទីប៊ីយ៉ូទិក

ថ្នាំអង់ទីប៊ីយ៉ូទិក ចែកចេញជាពីរក្រុម:

- **អង់ទីប៊ីយ៉ូទិកសម្លាប់បាក់តេរី (Bactericidal antibiotics)**: ពួកវាសម្លាប់បាក់តេរី។ ឧទាហរណ៍ថ្នាំប៉េនីស៊ីលីនបញ្ឈប់ការបង្កើតជញ្ជាំងការពារបាក់តេរី។ បាក់តេរីលូតលាស់ ប៉ុន្តែមិនអាចបំបែកខ្លួន ឬពេលខ្លះធ្វើឲ្យជញ្ជាំងបាក់តេរីផ្ទុះធ្លាយ។







- **អង់ទីប៊ីយ៉ូទិកបញ្ឈប់ការបំបែកខ្លួនបាក់តេរី (Bacteriostatic antibiotics)**: ពួកវាបញ្ឈប់ការបំបែកខ្លួនរបស់ បាក់តេរី។ ឧទាហរណ៍ថ្នាំតេត្រាស៊ីគ្លីនរារាំងការបង្កើតប្រូតេអ៊ីនក្នុងបាក់តេរី ដូច្នេះហើយបាក់តេរីមិនអាចលូតលាស់ ឬបំបែកខ្លួនបានឡើយ។

## ២.៣ វិសាលភាពរបស់ថ្នាំអង់ទីប៊ីយ៉ូទិក

គ្មានថ្នាំអង់ទីប៊ីយ៉ូទិកណា ដែលអាចសម្លាប់បាក់តេរីគ្រប់ប្រភេទនោះទេ។ ប្រភេទថ្នាំអង់ទីប៊ីយ៉ូទិកខ្លះ មានប្រសិទ្ធភាពប្រឆាំងនឹងបាក់តេរីក្រាមបូក ឬបាក់តេរីក្រាមដក។

តាមការពិសោធន៍ដោយដាក់ពណ៌ បាក់តេរីមានពីរប្រភេទគឺ៖

- ក្រាមដក ឡើងពណ៌ផ្កាឈូក ក្រហមបន្ទាប់ពីដាក់ពណ៌ ដូចជាអ៊ីកូលី ប៉ាស្ទឺរ៉ែឡា សាល់ម៉ូណែឡា...
- ក្រាមបូក ឡើងពណ៌ស្វាយ ខៀវ បន្ទាប់ពីដាក់ពណ៌ ដូចជាស្ត្រិបតូកុក ស្តាហ្វីឡូកុក ក្លូស្ទ្រីដ្យូម បាក់ស៊ីលុសអង់ត្រាក់ស៊ីស (ជំងឺបូសខ្យល់ និងជំងឺឈាមខ្មៅ )...


ស្ត្រិបតូកុក


ស្ត្រិបតូកុកបន្ទាប់ពីការដាក់ពណ៌


អីកូលី


អីកូលីបន្ទាប់ពីការដាក់ពណ៌

- **វិសាលភាពរបស់ថ្នាំអង់ទីប៊ីយ៉ូទិក ចែកចេញជាពីរ:**
  - **វិសាលភាពតូចចង្អៀត**សំដៅលើប្រភេទបាក់តេរីជាក់លាក់ដូចជាក្រាមបូក ឬក្រាមដក។ ឧទាហរណ៍ ថ្នាំប៉េនីស៊ីលីន និងគ្រួសារម៉ាក្រូលីត មានប្រសិទ្ធភាពតែលើមេរោគក្រាមបូក ប៉ុន្តែថ្នាំកូលីស្ទីនមានប្រសិទ្ធភាពលើមេរោគក្រាមដកប៉ុណ្ណោះ។
  - **វិសាលភាពធំទូលាយ**សំដៅលើបាក់តេរីច្រើនប្រភេទមានក្រាមបូក និងក្រាមដក។ ឧទាហរណ៍ថ្នាំអង់វ៉ូហ្លុកសាក់ស៊ីន ដុកស៊ីស៊ីគ្លីន មានប្រសិទ្ធភាពលើក្រាមបូក និងក្រាមដក។
- **គ្រួសារថ្នាំអង់ទីប៊ីយ៉ូទិក**

ថ្នាំអង់ទីប៊ីយ៉ូទិក ត្រូវបានចាត់ចំណាត់ថ្នាក់ជាគ្រួសារ។ ថ្នាំអង់ទីប៊ីយ៉ូទិកមកពីគ្រួសារដូចគ្នា ពួកវាមានរចនាសម្ព័ន្ធគីមីដូចគ្នា។ គ្រួសារថ្នាំអង់ទីប៊ីយ៉ូទិកសំខាន់ៗដែលប្រើសម្រាប់សត្វមាន៖

  - **គ្រួសារបេតាឡាក់តាមីន:** ប៉េនីស៊ីលីនអំពីស៊ីលីនអាម៉ុកស៊ីស៊ីលីនសេហ្វាឡូស្ពរីន...
  - **គ្រួសារប៉ូលីប៉ិបទិត:** កូលីស្ទីន បាក់ស៊ីត្រាស៊ីន...
  - **គ្រួសារគីណូឡូន:** ភ្លួយមេគីន អង់វ៉ូផ្លុកសាក់ស៊ីន...
  - **គ្រួសារអាមីណូស៊ីត** : ហ្សង់តាមីស៊ីន ស្ត្រិបតូមីស៊ីន...
  - **គ្រួសារស៊ុលហ្វាមីត** : ស៊ុលហ្វាឌីមីឌីន ស៊ុលហ្វាមេតូស៊ីន ទ្រីមេតូព្រីម...
  - **គ្រួសារហ្វេនីកុល:** ផ្លរហ្វេនីកុល ទីយ៉ាមហ្វេនីកុល ក្លរ៉ង់ហ្វេនីកុល (ថ្នាំនេះត្រូវបានគេហាមប្រើជាច្រើនប្រទេស)...
  - **គ្រួសារតេត្រាស៊ីគ្លីន:** អុកស៊ីតេត្រាស៊ីគ្លីន ដុកស៊ីស៊ីគ្លីន...
  - **គ្រួសារម៉ាក្រូលីត:** ទីឡូស៊ីន ស្ពៀរ៉ាមីស៊ីន អេរីត្រូមីស៊ីន ឡាំងកូមីស៊ីន និងទីយ៉ាមុលីន វាស្ថិតក្នុងគ្រួសារជិតគ្នាបំផុត។
- **ការថ្នាំប្រើអង់ទីប៊ីយ៉ូទិករួមគ្នា**
  - ការរួមបញ្ចូលគ្នារវាងថ្នាំអង់ទីប៊ីយ៉ូទិកពីរមុខអាចធ្វើបាន ដើម្បីទទួលបានវិសាលភាពថ្នាំធំទូលាយ។ ឧទាហរណ៍ អំពីដិចសាឡោន គឺជាការរួមបញ្ចូលថ្នាំ

អំពីស៊ីលីនដែលសម្លាប់បាក់តេរីក្រាមបូក ជាមួយថ្នាំកូលីស្ទីន ដែលសម្លាប់បាក់តេរីក្រាមដក។ ការផ្សំថ្នាំអំពីស៊ីលីន ជាមួយកូលីស្ទីនមានវិសាលភាពធំទូលាយជាងវិសាលភាពរបស់ថ្នាំអំពីស៊ីលីនតែឯង ឬកូលីស្ទីនតែឯង។ ការរួមបញ្ចូលដទៃផ្សេងទៀត គឺប៉េនីស៊ីលីនជាមួយស្រ្តិបតូមីស៊ីន (ប៉ង់ស្រ្តិប) ស៊ុលហ្វាណាមីតជាមួយទ្រីមេតូព្រីម (សិបតូទ្រីល)។

- មិនត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិករួមបញ្ចូលគ្នាលើសពី២មុខ ។ មិនត្រូវទិញថ្នាំណាមួយប្រសិនបើយើងឃើញថ្នាំមានលាយថ្នាំអង់ទីប៊ីយ៉ូទិក៣ ទៅ៤មុខ ឬលើស ព្រោះវាមិនមែនផលិតដោយក្រុមហ៊ុនដែលអាចជឿទុកចិត្តបានទេ។

➢ ការកើនប្រសិទ្ធភាពថ្នាំអង់ទីប៊ីយ៉ូទិកកើតឡើង ពេលឥទ្ធិពលនៃការបូកបញ្ចូលគ្នារបស់ថ្នាំអង់ទីប៊ីយ៉ូទិកពីរប្រភេទ មានឥទ្ធិពលលើសពីការប្រើថ្នាំអង់ទីប៊ីយ៉ូទិកមួយប្រភេទ៖
  - ❖ អំពីស៊ីលីនបូកជាមួយកូលីស្ទីន ស៊ុលហ្វាណាមីតបូកជាមួយទ្រីមេតូព្រីម
  - ❖ តេត្រាស៊ីគ្លីនបូកជាមួយម៉ាក្រូលីត (ទីឡូស៊ីនបូកជាមួយអុកស៊ីតេត្រាស៊ីគ្លីន)
  - ❖ តេត្រាស៊ីគ្លីនបូកជាមួយស៊ុលហ្វាណាមីត

➢ ភាពប្រឆាំងគ្នានៃថ្នាំអង់ទីប៊ីយ៉ូទិកកើតឡើង ពេលដែលប្រសិទ្ធិភាពនៃការបូកបញ្ចូលថ្នាំអង់ទីប៊ីយ៉ូទិកពីរប្រភេទ មានប្រសិទ្ធភាពតិចជាងការប្រើថ្នាំអង់ទីប៊ីយ៉ូទិកតែមួយប្រភេទ។

ឧទាហរណ៍: គ្រួសារបែលតាឡាក់តាមីនបូកជាមួយគ្រួសារម៉ាក្រូលីត ឬគ្រួសារបែលតាឡាក់តាមីនបូកជាមួយគ្រួសារតេត្រាស៊ីគ្លីន។

**ចំណាំ:** ប្រសិនបើអ្នកឃើញថ្នាំ ដែលផ្សំដោយថ្នាំអាម៉ុកស៊ីស៊ីលីននិងថ្នាំអុកស៊ីតេត្រាស៊ីគ្លីន ចូរកុំទិញឲ្យសោះ វាមិនមែនផលិតដោយក្រុមហ៊ុនដែលត្រឹមត្រូវទេ។



ថ្នាំអង់ទីប៊ីយ៉ូទិក ៤មុខរួមបញ្ចូល



ថ្នាំអង់ទីប៊ីយ៉ូទិក៣មុខរួមបញ្ចូលគ្នា

ប្រសិនបើអ្នកឃើញថ្នាំមានផ្សំពីអង់ទីប៊ីយ៉ូទិកលើសពីបីមុខចូរកុំទិញឲ្យសោះវាមិនមែនផលិតដោយក្រុមហ៊ុនដែលត្រឹមត្រូវទេ។

ប្រសិនបើអ្នកឃើញថ្នាំមានក្លរំហ្វេនីកុល ចូរកុំទិញ វាមិនផលិតដោយក្រុមហ៊ុនដែលត្រឹមត្រូវទេ។




## ២.៤ ការជ្រើសរើសថ្នាំអង់ទីប៊ីយ៉ូទិក

- **កំណត់អត្តសញ្ញាណជំងឺ** មានសារៈសំខាន់ ដើម្បីស្គាល់មូលហេតុរបស់ជំងឺដែលបង្កដោយបាក់តេរី។ ប្រសិនបើជំងឺបង្កដោយវីរុស បរាសិត ឬកង្វះសារធាតុចិញ្ចឹម នោះថ្នាំអង់ទីប៊ីយ៉ូទិកមិនអាចព្យាបាលជំងឺបានទេ។







រាគជាមួយនឹងការខ្វះឈាមក្រហម បង្កដោយដង្កូវថ្លើម




- **កំណត់អត្តសញ្ញាណបាក់តេរី**៖មានសារៈសំខាន់ ដើម្បីស្គាល់ប្រភេទបាក់តេរី ដែលបង្កជំងឺ ដើម្បីជ្រើសរើសថ្នាំអង់ទីប៊ីយ៉ូទិកមកព្យាបាលឲ្យបានត្រឹមត្រូវ។ ឧទាហរណ៍ ការក្អកចំពោះជ្រូកបំប៉ន កើតមានជាទូទៅ បង្កដោយមេរោគមីកូប្លាស្មា ប្រសិនបើជ្រើសរើសថ្នាំអាម៉ុកស៊ីលីន វាមានប្រសិទ្ធភាពប្រឆាំងនឹងពួកប៉ាស្ទឺរ៉ែឡា ជ្រូកនឹងមានសភាពប្រសើរឡើងវិញនៅប៉ុន្មានថ្ងៃក្រោយមក ប៉ុន្តែវានឹងលាប់ជំងឺមកវិញ...ព្រោះជាទូទៅប៉ាស្ទឺរ៉ែឡាជាការចម្លងមេរោគទីពីរ (ឱកាសនិយម) ។ ថ្នាំអាម៉ុកស៊ីលីនមិនមានប្រសិទ្ធភាព ដើម្បីសម្លាប់មីកូប្លាស្មាបានទេ ព្រោះមេរោគនេះគ្មានជញ្ជាំង។ ដើម្បីព្យាបាលជំងឺនេះឲ្យបានជោគជ័យ ត្រូវជ្រើសរើសថ្នាំអង់ទីប៊ីយ៉ូទិកប្រឆាំងប៉ាស្ទឺរ៉ែឡា និងមីកូប្លាស្មា ដូចជាថ្នាំតេត្រាស៊ីគ្លីន ឬថ្នាំផ្លរហ្វេនីកុល។





មីកូប្លាស្មាធ្វើឲ្យមានស្លាកស្នាមរបួសលើសួត




មីកូប្លាស្មាជាបាក់តេរីតូចគ្មានជញ្ជាំង គ្រួសារបែតាឡាក់តាមីនគ្មានសកម្មភាពលើបាក់តេរីប្រភេទនេះទេ

- **ការឆ្លងមេរោគទីពីរ (ឱកាសនិយម)**: យើងដឹងហើយថា ថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពប្រឆាំង នឹងវីរុសទេ ប៉ុន្តែសត្វដែលប្រឈមមុខនឹងជំងឺដែលបង្កដោយវីរុស ធ្វើឲ្យវាបាក់កម្លាំងជាខ្លាំង វាមិនអាចស៊ី ផឹកទឹកតិច។ ការចុះខ្សោយនេះនឹងផ្តល់ឱកាសដល់បាក់តេរីលូតលាស់ និងបង្កការឆ្លងជំងឺបន្ថែម ហៅថាការឆ្លងមេរោគទីពីរ (ឱកាសនិយម)។
ឧទាហរណ៍: ជ្រូកកើតជំងឺប៉េស្តប៉ុន្មានថ្ងៃក្រោយមក វានឹងបង្ហាញរោគសញ្ញារាគដែល–បង្កដោយមេរោគសាល់ម៉ូណែឡា និងក្អកបណ្តាលមកពីមេរោគប៉ាស្ទឺរ៉ែឡា។ ត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិក ដែលមានវិសាលភាពធំទូលាយ ដូចជាទ្រីមេតូព្រីមជាមួយស៊ុលហ្វា ដើម្បីកាត់បន្ថយឥទ្ធិពលនៃការឆ្លងជំងឺឱកាសនិយម។

ជំងឺអុតក្តាមបង្កដោយវីរុស



ប៉ុន្តែខ្ទុះនិង Weeping បណ្តាលអោយមាន ការចម្លងមេរោគឱកាសនិយមរបស់ពួកបាក់តេរី

ប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកនឹងធ្វើឲ្យសះមុខរបួសលឿន



## ២.៥ គោលការណ៍ជ្រើសរើសថ្នាំអង់ទីប៊ីយ៉ូទិក

- ការឆ្លងលើស្បែក: អាម៉ុកស៊ីស៊ីលីន ឬឡាំងកូមីស៊ីន ឬទ្រីមេតូព្រីមជាមួយស៊ុលហ្វា
- ជំងឺផ្លូវដង្ហើមគ្រប់ប្រភេទ: តេត្រាស៊ីគ្លីន ផ្សំជាមួយគ្រួសារម៉ាក្រូលីត ឬ ផ្លរហ្វេនីកុល ឬអង់រ៉ូផ្លុកសាក់ស៊ីន
- រលាកស្បូន: អង់រ៉ូផ្លុកសាក់ស៊ីន ឬអាម៉ុកស៊ីស៊ីលីន
- រលាកផ្លោកនោម: អង់រ៉ូផ្លុកសាក់ស៊ីន ឬទ្រីមេតូព្រីម/ស៊ុលហ្វា
- ជំងឺស្រ្តិបតូកុកកូនជ្រូក: អាម៉ុកស៊ីស៊ីលីន ឬប៉េនីស៊ីលីន
- រាគកូនជ្រូកនិងកូនគោ: កូលីស្ទីន ឬអង់រ៉ូផ្លុកសាក់ស៊ីន
- រាគចំពោះជ្រូកបំប៉ន: ទីឡូស៊ីន ឬទីឡូស៊ីនបូកជាមួយហ្សង់តាមីស៊ីន
- ជំងឺកូលីបាក់ស៊ីឡូស៊ីសលើមាន់: អាម៉ុកស៊ីស៊ីលីន ឬហ្លុយមេគីន
- រលាកដោះ: ស៊ុលហ្វា/ទ្រីមេតូព្រីម (មេជ្រូក) ឬអាម៉ុកស៊ីស៊ីលីន (គោ)
- រលាកសន្លាក់: អាម៉ុកស៊ីស៊ីលីន ឬឡាំងកូមីស៊ីន

- ជំងឺកញ្រ្ជិល: អាម៉ុកស៊ីស៊ីលីន ឬទីឡូស៊ីន
- ការពារជំងឺឱកាសនិយមដែលបង្កដោយវីរុស៖ ស៊ុលហ្វា/ទ្រីមេតូព្រីម ឬអុកស៊ីតេត្រាស៊ីគ្លីន

## ២.៦ ថ្នាំអង់ទីប៊ីយ៉ូទិកមានក្នុងទីផ្សារ

ថ្នាំអង់ទីប៊ីយ៉ូទិកដែលបង្ហាញខាងក្រោមនេះ ជាផលិតផលដែលមានលក់ក្នុងខេត្តមួយចំនួន។

- គ្រួសារបេតាឡាក់តាមីន













- គ្រួសារតេត្រាស៊ីគ្លីន













វាមិនគ្រប់គ្រាន់ទេ អ្នកត្រូវលាយ១,៦គក្រ របស់តេរ៉ា៥០០ក្នុងចំណី២០០ គក្រ ដើម្បីមានប្រសិទ្ធភាព

- កូលីស្ទីន (ជាទូទៅបូកជាមួយអាម៉ុកស៊ីស៊ីលីន ឬអំពីស៊ីលីន)













ស្ពិចទីណូមីស៊ីនជាមួយ កូលីស្ទីន

- ស៊ុលហ្វា+ទ្រីមេតូព្រីម













ស៊ុលហ្វាឌីមីឌីន

- គ្រួសារម៉ាក្រូលីត













- គ្រួសារគីណូឡូន













- គ្រួសារហ្វេនីកុល












## ២.៧ ការប្រើថ្នាំអង់ទីប៊ីយ៉ូទិក



- **កម្រិតប្រើ៖** អាស្រ័យតាមការណែនាំមាននៅលើស្លាកសញ្ញា ជាមួយទម្ងន់សត្វឲ្យបានត្រឹមត្រូវ។
  ចំពោះជំងឺដង្ហើម ត្រូវចាក់លើកទីមួយ កម្រិតទ្វេរដង ។
  ដោយឡែកការប្រើម្សៅថ្នាំអង់ទីប៊ីយ៉ូទិក ដើម្បីលាយក្នុងចំណីឲ្យសត្វស៊ី មានការលំបាកដោយទទួលប្រសិទ្ធភាពទាប ព្រោះសត្វឈឺ ស៊ីតិចតួច។ ជាការពិតស្លាកដែលបញ្ជាក់ថា "កម្រិតការពារ" គេប្រើនៅពេលសត្វមានសុខភាពល្អ និងស៊ីធម្មតា។ ស្លាកដែលបញ្ជាក់ថា "កំរិតព្យាបាល" ត្រូវប្រើវាទ្វេរដង ព្រោះសត្វស៊ីតិចនិងដើម្បីឲ្យពួកវា ស្រូបយកថ្នាំអង់ទីប៊ីយ៉ូទិកបានគ្រប់គ្រាន់។
- **ចង្វាក់នៃការផ្តល់ថ្នាំ** (Rhythm) ៖ វាមានសារៈសំខាន់ក្នុងការរក្សានូវបរិមាណកម្រិតទាបរបស់ថ្នាំអង់ទីប៊ីយ៉ូទិកក្នុងឈាមពេញមួយថ្ងៃ និងថ្នាំអង់ទីប៊ីយ៉ូទិកត្រូវផ្តល់ឲ្យបានទៀងទាត់។ សម្រាប់ថ្នាំអង់ទីប៊ីយ៉ូទិកលាយជាមួយចំណីជ្រូក និងមាន់ស៊ីរាល់ថ្ងៃ នឹងទទួលបានកម្រិតថ្នាំមួយជំហានម្តង មួយជំហានម្តង។ ពេលចាក់ថ្នាំអង់ទីប៊ីយ៉ូទិក យើងចាំបាច់ត្រូវគោរពតាមការណែនាំលើស្លាកសញ្ញា។ ឧទាហរណ៍ថ្នាំអំពីដិចសាឡ្ឋន ត្រូវចាក់ពេលព្រឹក និងល្ងាច ប៉ុន្តែថ្នាំសិបត្វូទ្រីល ចាក់តែម្តងក្នុងមួយថ្ងៃ។ ថ្នាំខ្លះមានសកម្មភាពរយៈពេលវែង (Long Acting) និងអាចចាក់រៀងរាល់២ ឬ ៣ថ្ងៃម្តង។ ឧទាហរណ៍ ថ្នាំឡុងអាម៉ុក គឺជាអាម៉ុកស៊ីស៊ីលីនដែលមានរយៈពេលវែង ចាក់វារៀងរាល់ពីរថ្ងៃម្តង។
- **រយៈពេលនៃការព្យាបាល៖** ពី៣ទៅ៥ថ្ងៃ គឺជារយៈពេលធម្មតាសម្រាប់ការព្យាបាល។ ពេលខ្លះការព្យាបាលអាចអូសបន្លាយរយៈពេល៧ថ្ងៃ ជាពិសេសចំពោះជំងឺដង្ហើម ប៉ុន្តែកុំឲ្យតិចជាង៣ថ្ងៃ។
  មិនត្រូវផ្លាស់ប្តូរប្រើថ្នាំអង់ទីប៊ីយ៉ូទិកបន្ទាប់ពីព្យាបាលបានមួយ ឬពីរថ្ងៃ ទោះបីការព្យាបាល មិនទទួលបានជោគជ័យក៏ដោយ។
  
  **ក្នុងករណីព្យាបាលមិនជាសះស្បើយ ចាំបាច់ត្រូវ៖**
  
  - ពិនិត្យសត្វម្តងទៀត ដើម្បីធ្វើរោគវិនិច្ឆ័យឡើងវិញ និងពិនិត្យពីកម្រិតថ្នាំដែលបានប្រើ និងពីទម្ងន់សត្វឲ្យបានត្រឹមត្រូវ
  - ប្រាកដថាគុណភាពរបស់ថ្នាំអង់ទីប៊ីយ៉ូទិកល្អ។ ផលិតផលខ្លះមានតម្លៃថោក ផលិតដោយក្រុមហ៊ុនមិនស្គាល់ប្រភព និងគ្មានធាតុផ្សំអ្វីទាំងអស់។

## ៣- ថ្នាំប្រឆាំងការរលាក

សម្រាប់ព្យាបាលការរលាកក្នុងទីកន្លែងកំណត់ណាមួយ ដែលបណ្តាលមកពីការឆ្លងមេរោគលើរាងកាយ របួសឬក្តៅក្រហល់ក្រហាយ ។ ការរលាកអាចជះឥទ្ធិពលលើសរីរាង្គខាងក្រៅដូចជាសន្លាក់ ហៅថាការរលាកសន្លាក់ និងសរីរាង្គខាងក្នុងដូចជាផ្លោកនោម ហៅថាការរលាកផ្លោកនោម។

ការរលាកលើសរីរាង្គខាងក្រៅ មានសញ្ញាដូចជា៖

- ឡើងក្រហម
- ហើម
- ឈឺចាប់
- ក្តៅដោយកន្លែង







### ៣.១ មុខងារថ្នាំប្រឆាំងការរលាក

ការរលាក គឺជាដំណើរការមួយ ដែលមានរយៈពេលខ្លី ដើម្បីការពាររាងកាយ។ ដូច្នេះត្រូវធ្វើការការព្យាបាល ប្រសិនបើវាបន្តកើតមានរយៈពេលយូរ បង្កជាការឈឺចាប់គួរឲ្យកត់សំគាល់។

ឧទាហរណ៍ ក្នុងករណីរលាកដោះ កន្សោមដោះអាចហើម ក្តៅនិងឡើងរឹង។ វាធ្វើឲ្យមេជ្រូក ឬមេគោនៅមិនសុខ មិនស៊ីចំណីនិងខាំកូនពេលកូនរកបៅដោះ។ ការចាក់ថ្នាំប្រឆាំងការលាកនឹងជួយបញ្ចុះកំដៅកន្សោមដោះ និងទន់ ហើយថ្នាំអង់ទីប៊ីយ៉ូទិកកាន់តែមានប្រសិទ្ធភាពលើជាលិកាដែលចម្លងមេរោគនោះ។




### ៣.២ ប្រភេទថ្នាំប្រឆាំងការរលាក

ថ្នាំប្រឆាំងការរលាកមានពីរប្រភេទ៖

- **ស្តេរ៉ូអ៊ីត**(Steroidal) ដូចជាក័រទីសូន (Cortisone) ប្រេដនីសូឡូន(Prednisolone) ដិចសាមេតាសូន (Dexamethasone) ថ្នាំទាំងនេះមានប្រសិទ្ធភាពខ្ពស់។

ជារឿយៗថ្នាំដិចសាមេតាសូន ត្រូវបានគេផ្សំជាមួយនឹងថ្នាំអង់ទីប៊ីយ៉ូទិក ជាពិសេសថ្នាំសម្រាប់ព្យាបាលការឆ្លងមេរោគលើផ្លូវដង្ហើម ព្រោះការឆ្លងមេរោគបណ្ដាលឲ្យរលាកទងសួត និងសួត (សត្វក្អក) និងធ្វើឲ្យថ្នាំអង់ទីប៊ីយ៉ូទិកមានប្រសិទ្ធភាពខ្ពស់ ។



ការរួមអង់ទីប៊ីយ៉ូទិក២បញ្ចូលគ្នា ដើម្បីប្រឆាំងនឹងមីក្រូប្លាស្មានឹង ប៉ាស៊ីរ៉ែទុក

- **មិនស្តេរ៉ូអ៊ីត**(Non-Steroidal)៖ ដូចជាអាស្ពីរីន (Aspirine) ប៉ារ៉ាសេតាម៉ុល (Paracetamol) អាណាល់ហ្សាំង (Analgin)។ ថ្នាំទាំងនេះមានប្រសិទ្ធិតិចតួចលើការរលាក ប៉ុន្តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្ថយ**ការឈឺចាប់ និងបញ្ចុះកំដៅ**។

## ៣.៣ ការប្រើប្រាស់ថ្នាំប្រឆាំងការរលាក

- *សរីរាង្គដែលរលាកដូចជា៖*

សន្លាក់ (ជំងឺរលាកសន្លាក់) អាចបណ្ដាលមកពីមានមេរោគចូល តាមរយៈរបួស ហើយរាតត្បាតក្នុងសន្លាក់ ដូចជា ស្ត្រិបតូកុក អាចចូលក្នុងរាងកាយកូនជ្រូក ពេលកាត់ធ្មេញ កន្ទុយ ប៉ុន្មានថ្ងៃក្រោយមកមេរោគចូលដល់សន្លាក់ ដែលធ្វើឲ្យរលាកសន្លាក់។


ជំងឺរលាកសន្លាក់គឺជាការរលាកសន្លាក់វាអាចបណ្ដាលមកពីរបួស

ពោះវៀន (ជំងឺរលាកពោះវៀន) អាចបណ្ដាលមកពីបាក់តេរីដូចជា អ៊ីកូលី ឬសាល់ម៉ូណែឡា ដែលរាតត្បាតនិងធ្វើឲ្យខូចភ្នាសពោះវៀនឬដោយវត្ថុម្យ៉ាងដែលធ្វើឲ្យក្តៅក្រហាល់ក្រហាយ ដូចជាសត្វក្មេងស៊ីដីខ្សាច់។


រលាកពោះវៀនមាន់

ផ្លោកនោម(ជំងឺរលាកផ្លោកនោម) បណ្ដាលមកពីការឆ្លងមេរោគ ឬដោយសត្វផឹកទឹកមិនបានគ្រប់គ្រាន់ សារធាតុរ៉ែបង្កើតជាដុំគ្រួស ដែលធ្វើឲ្យដាច់រលាត់ផ្លោកនោម។ មេជ្រូកនោមចេញតិច ព្រោះមានការឈឺចាប់និងពេលឈប់នោមមានខ្ទុះតិចតួច។


នោមចេញច្រើនគឺជាសញ្ញាបញ្ជាក់ថាផ្លោកនោមមានសុខភាពល្អ


ដំណក់ខ្ទុះជាសញ្ញាការរលាកផ្លោកនោម វាគឺជាជំងឺរលាកផ្លោកនោម

បំពង់ខ្យល់ និងទងសួត (ជំងឺរលាកបំពង់ខ្យល់ និងជំងឺរលាកទងសួត) អាចបង្កដោយមេរោគ ដូចជាមីកូប្លាស្មា ដែលបំផ្លាញជញ្ជាំងរបស់ បំពង់ខ្យល់និងទងសួត ឬដោយឧស្ម័នដូចជា អាម៉ូញ៉ាក់ ពេលដែលលាមកមិនទាន់បាន ប្រមូលយកចេញ ធ្វើឲ្យក្រហាយដល់បំពង់ ខ្យល់និងទងសួត។ ករណីទាំងពីរធ្វើឲ្យសត្វ ក្អកខ្លាំង។




ភ្នែក(ជំងឺភ្នែកក្រហម) ភ្នែកមាន ការឈឺចាប់
គ្របកភ្នែកបិទ ភ្នាសសើមភ្នែក ឡើងក្រហមនិងហើមហើយធ្វើ ឲ្យហូរទឹកភ្នែក។

ការហូរទឹកភ្នែកជាលក្ខណៈ ពិសេសក្នុងករណីមានរលាកភ្នែក






- **ការប្រើប្រាស់ថ្នាំប្រឆាំងការរលាក**
  - ជាទូទៅពេលដែលការរលាកបង្ក ដោយការ**ឆ្លងមេរោគ**ជាលក្ខណៈប្រព័ន្ធ (រាក ជំងឺហើមសួត ការឆ្លងមេរោគក្នុង ឈាម...)
  - ត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកជាមួយនឹងថ្នាំ ដិចសាមេតាសូន។
  - ក្នុងករណី**មានការរលាកដោយកន្លែង** (សន្លាក់ ដោះ...) ដិចសាមេតាសូនត្រូវចាក់ ដោយឡែកពីគ្នា ព្រោះត្រូវប្រើកម្រិតថ្នាំ ខ្ពស់។ ជាទូទៅកម្រិតថ្នាំ គឺ១ទៅ២មីល្លីក្រាម របស់ដិចសាមេតាសូនសម្រាប់សត្វ៥០គក្រ។







- **ដំបៅ** (អាប់សែ) គឺជាដំណើរការរលាកផងដែរ។ ប៉ុន្តែករណីនេះថ្នាំប្រឆាំងការរលាក មិនត្រូវប្រើទេ។ ពេលដំបៅអាប់សែឡើងទន់ ត្រូវវះឲ្យខ្ទុះហូរចេញ។




- **របួស** បណ្តាលឲ្យរលាកដោយកន្លែង៖ ស្បែកឡើងក្រហម មានការឈឺចាប់ ឡើងហើម និងក្តៅ។ ប៉ុន្តែការរលាកជាផ្នែកមួយនៃដំណើរការនៃការជាសះស្បើយរបស់មុខរបួស។ **កុំប្រើថ្នាំប្រឆាំងការរលាក ដើម្បីព្យាបាលមុខរបួស។**
- **ថ្នាំមិនស្តេរ៉ូអ៊ីត**( Non-Steroidal medicine)៖ ត្រូវប្រើជារឿយៗសម្រាប់ព្យាបាល**ការឈឺចាប់និងបញ្ចុះកម្តៅ** ។ ប្រភេទថ្នាំនេះមានសារៈសំខាន់ណាស់ ក្នុងការព្យាបាលការខ្វកជើងមេជ្រូក ប្រសិនបើមេជ្រូកឈឺជើង មិនអាចក្រោកឈរធម្មតាបាន មិនអាចស៊ី និងផឹកគ្រប់គ្រាន់ បណ្តាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ។ ការប្រើថ្នាំទាំងនេះដើម្បីកាត់បន្ថយគ្រុនក្តៅ ជួយឲ្យសត្វជាពីជំងឺ ព្រោះសត្វមានអារម្មណ៍ប្រសើរ ផឹកទឹកច្រើននិងស៊ីឡើងវិញ។



- **ប្រតិកម្ម** (allergy)៖ ថ្នាំដិចសាមេតាសូន ក៏ត្រូវបានប្រើសម្រាប់ព្យាបាលប្រតិកម្ម(អាលែស៊ី)។ សត្វខ្លះអាចប្រតិកម្ម(អាលែស៊ី)យ៉ាងខ្លាំងនៅពេលដែលប៉ះពាល់ជាមួយសារធាតុគីមី ថ្នាំរុក្ខជាតិ។
  - ❖ ជាទូទៅប្រតិកម្មលើស្បែក មានពណ៌ក្រហមនិងរមាស់។
  - ❖ មានជ្រូកតែមួយ ក្នុងទ្រុង អាចមានប្រតិកម្មយ៉ាងខ្លាំង ដោយសត្វខាំ ហើយជាទូទៅសត្វនៅតែស៊ីចំណី។
  - ❖ គោ ក្របី ស៊ីរុក្ខជាតិដែលធ្វើឲ្យមានប្រតិកម្មទៅជាចាញ់ពន្លឺថ្ងៃនៅប៉ុន្មានថ្ងៃបន្ទាប់ ហើយអាចលេចចេញដំបៅលើស្បែកជាផ្ទាំងយ៉ាងធំដូចជារលាកដោយសារពន្លឺព្រះអាទិត្យ។ ថ្នាំដិចសាមេតាសូនត្រូវចាក់ក្នុងដំណាក់កាលដំបូង។
  - ❖ ប្រតិកម្មអាចបង្កដោយការចាក់ថ្នាំ ជាញឹកញាប់មេជ្រូកខ្លះប្រតិកម្មយ៉ាងខ្លាំងដោយសារការវ៉ាក់សាំងជំងឺអ្វហ្សស្តី នៅប៉ុន្មាននាទីបន្ទាប់ពីចាក់វ៉ាក់សាំង មេជ្រូកខឹងមួរម៉ៅ ស្បែកឡើងក្រហម ដកដង្ហើមញាប់ និងហូរទឹកមាត់យ៉ាងច្រើន ត្រូវចាក់
    ថ្នាំដិចសាមេតាសូនជាបន្ទាន់ ។ ក្នុងករណីកើតដោយកម្រ មេជ្រូកសន្លប់ និងងាប់។

## ៣.៤ ឥទ្ធិពលថ្នាំ (Side effects)

ថ្នាំប្រឆាំងការរលាកមិនអាចប្រើក្នុងរយៈពេលយូរបានទេ ព្រោះវាមានឥទ្ធិពលច្រើនៈ

- **ដំបៅក្រពះ**

  ជាទូទៅថ្នាំប្រឆាំងការរលាកធ្វើឲ្យក្រហល់ក្រហាយក្រពះធ្វើឲ្យដំបៅក្រពះ ជ្រូកងាយរងផលប៉ះពាល់នេះ អាចឈប់ស៊ីចំណី ។ ត្រូវប្រើថ្នាំប្រឆាំងការរលាកត្រឹមបីថ្ងៃជាកំណត់។

- **រលូត**

  ថ្នាំប្រឆាំងការរលាក(steroidal) អាចបង្កឲ្យរលូតកូន ។ ចំពោះមេជ្រូកអាចរលូតកូនពេល ផើមបាន២ខែកន្លះ ចំពោះមេគោផើមបាន៦ខែ ។ **ហាមប្រើថ្នាំគរ័ទីសូន ឬដិចសាមេតាសូនអំឡុងពេលផើម។**

- **ការចុះខ្សោយប្រព័ន្ធភាពស៊ាំ**

  ថ្នាំគរ័ទីសូន និងថ្នាំដិចសាមេតាសូន ធ្វើឲ្យចុះខ្សោយប្រព័ន្ធភាពស៊ាំ ប្រសិនបើប្រើរយៈពេលយូរ រាងកាយសត្វមិនអាចប្រឆាំងនឹងការឆ្លងមេរោគបានល្អ ជាពិសេសចំពោះជំងឺបង្កដោយវីរុស។ អង់ទីគ័រសម្រាប់ប្រឆាំងនឹងការឆ្លងមេរោគ ហើយថ្នាំគរ័ទីសូនកាត់បន្ថយការផលិតអង់ទីគ័រ។

- មិនត្រូវប្រើគរ័ទីសូន ឬដិចសាមេតាសូន ក្នុងពេលសត្វមានជំងឺបង្កដោយវីរុសទេ។
- មិនត្រូវចាក់វ៉ាក់សាំង និងចាក់ថ្នាំដិចសាមេតាសូនក្នុងពេលជាមួយគ្នាទេ ព្រោះធ្វើឲ្យការបង្កើតភាពស៊ាំមានកម្រិតទាប។

## ៣.៥ ប្រភេទថ្នាំមាននៅទីផ្សារ

- **ថ្នាំចាក់**
  - ❖ **គ្រួសារអាណាហ្សាំង** (Analgin) ឈ្មោះគីមី គឺឌីពីរ៉ូន (Dipyrone)។ មានប្រសិទ្ធភាពលើការឈឺចាប់និងគ្រុនក្តៅ។ ថ្នាំនេះមានសកម្មភាពរយៈពេលខ្លី តែ១ម៉ោង ។ ត្រូវចាក់ក្នុងសាច់ដុំ ដើម្បីកុំឲ្យក្តៅក្រហល់ក្រហាយ ចំពោះជ្រូកមិនត្រូវចាក់ក្នុងខ្លាញ់ ។
  - ❖ **ផេនីលប៊ុយតាសូន** (Phenylbutazone) ជាថ្នាំមិនស្តេរ៉ូអ៊ីត( non steroidal medicine)

    មានប្រសិទ្ធភាពលើការរលាក ការឈឺចាប់និងគ្រុនក្តៅ។ មានសកម្មភាពរហូតដល់២៤ម៉ោង។ ការចាក់ដូចថ្នាំអាណាហ្សាំងដែរ ត្រូវចាក់ក្នុងសាច់ដុំឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។













❖ **តុហ្វេឌីន** (Tofedine) ជាថ្នាំមិនស្តេរ៉ូអ៊ីត(non steroidal medicine ) មានប្រសិទ្ធភាពលើ ការរលាក ការឈឺចាប់ និងគ្រុនក្តៅ។ រយៈពេលមានសកម្មភាព៤៨ ម៉ោង។

មិនមានការក្តៅក្រហាល់ក្រហាយពេលចាក់ថ្នាំនេះទេ។







❖ **គេតូហ្វេន** (Ketofen) ជាថ្នាំមិនស្តេរ៉ូអ៊ីត(non steroidal medicine) មានប្រសិទ្ធភាពលើ ការរលាក គ្រុនក្តៅ និងជាពិសេសការឈឺចាប់។ គេតូហ្វេនគេនិយមប្រើខ្លាំងសម្រាប់ការឈឺចាប់លើសាច់ដុំនៃគ្រោងឆ្អឹង ដែលរបួសជាលិកាទន់ រលាកសន្លាក់ឆ្អឹង ឬបញ្ហាសន្លាក់ និងឆ្អឹងដទៃទៀត។




❖ **ប៉ារ៉ាសេតាម៉ុល** (Paracetamol) ជាថ្នាំមិនស្តេរ៉ូអ៊ីត( non steroidal medicine) មានប្រសិទ្ធភាពលើការរលាក ការឈឺចាប់ និងគ្រុនក្តៅ ប៉ុន្តែមានសកម្មភាព រយៈពេលត្រឹមតែប៉ុន្មានម៉ោងប៉ុណ្ណោះ។

ថ្នាំនេះមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើក្រពះដូចថ្នាំគេតូហ្វេនទេ។





















❖ **ដិចសាមេតាសូន** (Dexamethasone) គឺជាថ្នាំពពួកស្តេរ៉ូអ៊ីត (steroidal medicine) ដែលមានប្រសិទ្ធភាពខ្លាំងលើការរលាក ប៉ុន្តែមិនមានប្រសិទ្ធភាពទៅលើគ្រុនក្តៅ និង ការឈឺចាប់ទេ។ រយៈពេលមានសកម្មភាពរបស់វាអាស្រ័យនឹងការលាយ ។













- **តាមមាត់**

  ❖ **ប៉ារ៉ាសេតាម៉ុល** អាចលាយក្នុង ចំណី ឬក្នុងទឹកផឹក។ចំពោះ មេជ្រូកៈ ដើម្បីបង្កើនការស៊ី ចំណីពេលគ្រុនក្តៅ និងបន្ថយការឈឺចាប់ជាពិសេសឈឺសន្លាក់ និងឈឺជើង ។ ចំពោះមាន់សាច់ៈ ជំរុញការ លូតលាស់ក្នុងរដូវក្តៅ និងធ្វើឲ្យជើងរឹងមាំ។

## ៩. ថ្នាំកំចាត់បរាសិត

បរាសិតជាសត្វល្អិតតូច ដែលរស់ក្នុងរាងកាយ ហៅថាបរាសិតខាងក្នុង ឬរស់នៅលើរាងកាយ ហៅថាបរាសិតខាងក្រៅ។

បរាសិតបណ្តាលឲ្យបាត់បង់សារធាតុចិញ្ចឹម ធ្វើឲ្យសត្វលូតលាស់យឺត អាចចម្លងជំងឺ និងជាប្រភព ធ្វើឲ្យសត្វមិនមានជាសុខភាព។ ការត្រួតពិនិត្យបរាសិតក្នុងខ្លួនសត្វ មានសារៈសំខាន់ណាស់ ដើម្បីសុខភាពសត្វល្អប្រសើរ។

### ៩.១ ការត្រួតពិនិត្យបរាសិតខាងក្រៅ

- **កាបារីល** (Carbaryl)ទម្រង់ជាម្សៅ ប្រើលើបក្សី សម្រាប់បរាសិតខាងក្រៅ ។ **កាបារីល** មានជាតិពុលទាបនិងមានរយៈពេលខ្លី។ ដើម្បីព្យាបាលបក្សី ត្រូវបាញ់ច្រកចូល

និងតំបន់ដែលមានរោម និងខាងក្រោមបក្សី។ ការបាញ់អាចធ្វើលើផ្ទៃក្រាល ដើម្បីការពារសត្វល្អិត (ខ្ទុង)។ ការព្យាបាលឡើងវិញមិនឲ្យលើសពី៤អាទិត្យ ។ **មិនត្រូវ**បាញ់ថ្នាំក្នុងអំឡុងពេល៧ថ្ងៃ លក់ចូលទីសត្តឃាត។ ប្រើកាបារីល៥% ចំនួន៥០០ក្រាមសម្រាប់បក្សី១០០ក្បាល។

- **អាស៊ុនតុល៥០** (Asuntol 50) ៖ ប្រើសម្រាប់ព្យាបាល ដង្កៃ ចៃខាំ សង្កើច និងរុយបឺតឈាម កូនដង្កូវក្នុងដំបៅ និងអង្កែ ចៃលើសត្វស្រុក (លើកលែងឆ្មា)។**អាស៊ុនតុល** ជាម្សៅពណ៌ស ត្រូវលាយជាមួយទឹក (១ក្រាម/១លីត្រទឹក)។ បន្ទាប់ពីលាយ អាចប្រើបានចំនួន៦ខែ។ អាស៊ុនតុលប្រើជាទូទៅសម្រាប់បាញ់ និងកក់លើខ្លួនសត្វ។

  អាស៊ុនតុលពុលខ្លាំង ដោយការហិត ស្រូប និងលេបចូល។ សញ្ញាពុលរួមមាន៖ រាក បែកពពុះមាត់ ពិបាកដកដង្ហើម ជើង និងកឡើងរឹង កូនក្រមុំភ្នែករីកឡើង។
- **អ៊ីវែម៉ិចទីន** (Ivermectin) ៖
  - **អង្កែ៖** ថ្នាំនេះមានសារៈសំខាន់សម្រាប់ព្យាបាលចៃ បឺតឈាម និងអង្កែ។ ដើម្បីកំចាត់អង្កែលើជ្រូក ចាំបាច់ត្រូវចាក់២ដងក្នុងអំឡុងពេលពីរអាទិត្យ ឬលាយអ៊ីវែម៉ិចទីនក្នុងចំណីរយៈពេល៧ថ្ងៃ។
  - **ដង្កៃ៖** អ៊ីវែម៉ិចទីនមិនធ្វើឲ្យដង្កៃងាប់ភ្លាមទេ ប៉ុន្តែវាកាត់ផ្តាច់ការបឺតឈាម និងកាត់បន្ថយចំនួនមេដង្កៃញីជាច្រើន ដែលបង្កើតពង ក្នុងរយៈពេលពីរអាទិត្យ ។
  - **រុយ៖** អ៊ីវែម៉ិចទីនមានប្រសិទ្ធភាពលើរុយ ដែលបង្កកំណើតក្នុងលាមក ព្រោះបន្ទាប់ពីការព្យាបាល កូនដង្កូវមិនអាចលូតលាស់ក្នុងលាមករបស់គោក្របីបានក្នុងរយៈពេល១០ថ្ងៃ។

    ***ត្រូវចាក់អ៊ីវែម៉ិចទីន ក្រោមស្បែក***។

## ៨.២ ការត្រួតពិនិត្យបរាសិតខាងក្នុង

- **ចំពោះបក្សី**

  ជាទូទៅព្រូនកើតមានលើមាន់ ដែលដើររកស៊ីចំណីតាមវាល និងធ្វើឲ្យសត្វខ្សោយងាយទទួលរងជំងឺផ្សេងៗ។ ព្យាបាលដើម្បីការពារ ត្រូវធ្វើរៀងរាល់៣ខែម្តង ដោយប្រើថ្នាំតេត្រាមីសុល( Tetramisole) (១០០ម.ក្រ/មាន់ជំទង់១ក្បាល) ។
- **ចំពោះជ្រូក**

  មានថ្នាំសំខាន់ពីរ គឺ៖ ឡេវ៉ាមីសុល (Levamisole) និងអ៊ីវែម៉ិចទីន (Ivermectin)។ ជាការពិត ថ្នាំអ៊ីវែម៉ិចទីនបច្ចុប្បន្ន ត្រូវបានប្រើទូលំទូលាយព្រោះវាអាចព្យាបាល

ព្រូនខាងក្នុងនិងបរាសិតខាងក្រៅ។ អ៊ីវែម៉ិចទីនអាចចាក់ក្រោមស្បែក ឬលាយក្នុងចំណី (រយៈពេល៧ថ្ងៃ) មានអ៊ីវែម៉ិចទីនច្រើនប្រភេទ ខ្លះជាផលិតផល ដែលមានគុណភាពខ្ពស់ ហើយខ្លះទៀតគុណភាពមិនច្បាស់លាស់។






កម្រិត១០ម.លសម្រាប់ ១០០គក្រចាក់ចូលជ្រៅក្នុងសាច់ដុំ (អ៊ីវែម៉ិចទីនត្រឹមតែ ២ម.ល/១០០គ.ក្រ)

- ចំពោះគោ ក្របី:
  - **ឡេវ៉ាមីសុល** ( Levamisole) អាចសម្លាប់ព្រូនសួត និងព្រូនក្នុងពោះវៀន ។
  - **អ៊ីវែម៉ិចទីន** (Ivermectin) សម្រាប់គោ ក្របី: ថ្នាំអ៊ីវែម៉ិចទីនស៊ុបពែរ (Super)ឬថ្នាំអ៊ីវែម៉ិចទីនអេហ្វ (F) គេបានបញ្ចូលអ៊ីវែម៉ិចទីនជាមួយថ្នាំក្ល័រស៊ុយឡោន (Clorsulone) ដែលមានប្រសិទ្ធភាពចំពោះហ្វាស្យូឡា សម្រាប់ ហ្វាស្យូឡាពេញវ័យតែមិនមានប្រសិទ្ធភាពលើស៊ុតហ្វាស្យូឡាទេ។ ថ្នាំ**អ៊ីវែម៉ិចទីន** ត្រូវប្រើឲ្យបានទៀងទាត់ត្រឹមត្រូវ ដើម្បីឲ្យមានប្រសិទ្ធភាពប្រឆាំងនឹងដង្កូវថ្លើម។
  - **អាល់បង់ដាសុល** (Albendazole)**សម្រាប់**ច្រកតាមមាត់។ ថ្នាំនេះប្រើល្អបំផុត ពេលគោ ក្របីសង្ស័យមានដង្កូវថ្លើមហ្វាស្យូឡា។ ថ្នាំនេះមានប្រសិទ្ធភាពផងដែរលើព្រូនក្នុងសួត និងក្នុងពោះវៀន។


តំបន់ដែលមានគ្រោះថ្នាក់ខ្ពស់ក្នុងការឆ្លងហ្វាស្យូឡា










- ដូវីនិក( Dovenix) ជាផលិតផលដែលល្បីក្នុងប្រទេសកម្ពុជា ព្រោះវាមានប្រសិទ្ធភាពខ្ពស់ប្រឆាំងនឹងដង្កូវថ្លើមហ្វាស្យូឡា ថ្នាំនេះ ត្រូវចាក់ក្រោមស្បែក ឬច្រកតាមមាត់។



## ៨.៣ ប្រូតូសូអែ: ជំងឺកុកស៊ីដ្យូស

ជំងឺកុកស៊ីដ្យូស ជាជំងឺដែលបង្កគ្រោះថ្នាក់ ពិសេសដល់សត្វក្មេងៗ។ ជំងឺកុកស៊ីដ្យូសបណ្តាលឲ្យរាកលាយឈាមចំពោះកូនមាន់ និងកូនគោ និងអាចធ្វើឲ្យសត្វងាប់។ ចំពោះកូនជ្រូកបណ្តាលឲ្យរាករ៉ាំរ៉ៃ ពណ៌ប្រផេះ អូសបន្លាយរហូតដល់កូនជ្រូកផ្តាច់ដោះ កូនជ្រូកមានសភាពរាងកាយមិនល្អ។










- ចំពោះបក្សី:

  តុលត្រាហ្សុយរីល (Toltrazuril) ឬអំប្រូលីយ៉ូម (Amprolium) ឬពពួកស៊ុលហ្វូណាមីតខ្លះ ដូចជា ស៊ុលហ្វាឌីមីឌីន (Sulfadimidine) ឬស៊ុលហ្វាមេតូស៊ីន (Sulfamethoxine) មានប្រសិទ្ធភាពប្រឆាំងនឹងជំងឺកុកស៊ីដ្យូស។ ក្រុមហ៊ុនខ្លះផលិតចំណីសម្រាប់កូនមាន់ (អាយុ០ទៅ២១ថ្ងៃ) មានលាយជាតិសាលីណូមីស៊ីន (Salinomycine) ដើម្បីការពារជំងឺកុកស៊ីដ្យូស។
















- **ចំពោះជ្រូក:**
  គុលត្រាហ្ស៊ុយរីលជាថ្នាំមានប្រសិទ្ធភាព សម្រាប់ព្យាបាល ការពារជំងឺកុកស៊ីដ្យូស តែគ្មានប្រសិទ្ធភាពសម្រាប់ព្យាបាលជំងឺរាកទេ។
- **ចំពោះគោ ក្របី:**
  ស៊ុលហ្វូណាមីត (Sulfonamides) ឬគុលត្រាហ្ស៊ុយរីល (Toltrazuril )ឬអំប្រូលីយ៉ូម(Amprolium)ប្រើសម្រាប់ព្យាបាលជំងឺកុកស៊ីដ្យូស។

## ៨.៤ បរាសិតក្នុងឈាម:







បរាសិតក្នុងឈាម ត្រូវបានចម្លងតាមរយៈដង្កែ ឬរុយ។

គោក្របីក្នុងស្រុក និងគោហ្សេប៊ុយ ជាទូទៅ មានភាពធន់ នឹងជំងឺទាំងនេះ ប៉ុន្តែគោពូជកូនកាត់ ឬ ក្នុងករណីចុះខ្សោយ ពូកបាបេស្យា និងទ្រីប៉ាណូសូម៉ា អាចវិវត្តពីសណ្ឋាន មិនសូវស្រួចស្រាវទៅជាស្រួចស្រាវ។ ការព្យាបាលៈត្រូវប្រើថ្នាំបេរីនីល ឬទ្រីប៉ាមីឌីយ៉ូម (Berenil or Trypamidium)។

ជំងឺទ្រីប៉ាណូសូម សម្លាប់សេះជាច្រើនក្នុងប្រទេសកម្ពុជា ។












## ៥- ថ្នាំអរម៉ូន

ថ្នាំនេះប្រើសម្រាប់ព្យាបាលបញ្ហាបន្តពូជលើគោ ក្របី និងជ្រូក។

- **ដើម្បីជំរុញឲ្យមានវដ្តរដូវ (ការរកឈ្មោល)**
  - **អឺស្ត្រាឌីយ៉ុល {Estradiol** (គរ័ប៊ុយលីន (Corpuline))} ជាពិសេសប្រើសម្រាប់មេជ្រូកក្រមុំ ឬមេគោក្រមុំ ដើម្បីជំរុញឲ្យមានវដ្តរដូវ បន្ទាប់ពីដល់អាយុពេញវ័យ។
  - **ប្រូស្តាក្លង់ឌីន {(Prostaglandin**)( លុយតាលីស( Lutalyse))} អាចចាក់លើមេគោដែលមិនរកឈ្មោល បន្ទាប់ពីផ្តាច់ដោះរួច ព្រោះអូវែអាចរាំងស្ទះដោយគ្រាប់គីស្ត។ ជាការពិតគោ ក្របីស្គមមិនត្រូវការអរម៉ូនទេ ប៉ុន្តែវាត្រូវការចំណីល្អ ដើម្បីរាងកាយមានសភាពល្អ ឆាប់រកឈ្មោល។
- **ជំរុញការកើតកូន:** ពេលមេជ្រូកក្រកើតកូន ពេលផើមបាន១១៥ថ្ងៃ ការចាក់ថ្នាំប្រូស្តាក្លង់ឌីន នឹងជួយជំរុញការកើតកូន បន្ទាប់ពីចាក់បានប៉ុន្មានម៉ោងក្រោយមក។ ជាការពិតកសិករ ត្រូវដឹងប្រាកដពីថ្ងៃដាក់ឈ្មោល និងគណនាថ្ងៃកើតកូនឲ្យបានច្បាស់លាស់។
- **បង្កើនការកន្ត្រាក់របស់ស្បូនក្នុងពេលកើតកូន:**
  តាមធម្មតាកូនជ្រូកកើតប្រហែលរៀងរាល់២០នាទីម្តង។ ប្រសិនបើលើសពី៣០នាទី បន្ទាប់ពីកូនជ្រូកដែលកើតមុន ការចាក់ថ្នាំអុកស៊ីតុកស៊ីន (១មលចូលក្នុងសាច់ដុំ) នឹងជួយបង្កើនកម្លាំងកន្ត្រាក់ និងសម្រួលការរុញកូនចេញមកក្រៅ។
- **សម្រួលការរុញសុកចេញក្រៅ:**
  ដើម្បីឲ្យប្រាកដថា សុកទាំងអស់របស់មេជ្រូកបានធ្លាក់ ត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន (**Ocytocin**) ២ម.ល ក្នុងសាច់ដុំ ក្រោយកើតកូនរួច។
- **សម្រួលឲ្យចេញទឹកដោះ**
  អុកស៊ីតុកស៊ីនជំរុញការបញ្ចេញទឹកដោះបន្ទាប់ពីកើតកូន។ ក្នុងករណីជំងឺលាសដោះ អត់ទឹកដោះ និងរលាកស្បូន (MMA) ចំពោះមេជ្រូកបន្ទាប់ពីកើតកូនរួច ត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន០,៥ម.ល ដើម្បីជំរុញទឹកដោះនិងជាពិសេសទឹកដោះដំបូង (កូឡូស្ត្រូម)។
- **ជំរុញការហូរទឹកខ្ទុះចេញពីស្បូន**
  ពេលដែលស្បូនមានខ្ទុះ ចាំបាច់ត្រូវជំរុញការកន្ត្រាក់ ដើម្បីរុញច្រានវត្ថុកខ្វក់ទាំងអស់ពីស្បូន។ ក្នុងករណីមានការចម្លងមេរោគលើស្បូន យើងត្រូវចាក់ប្រូស្តាក្លង់ឌីន។

ដោយឡែកថ្នាំអុកស៊ីតុកស៊ីន អាចជំរុញការកន្ត្រាក់ក្នុងអំឡុងពេលកើតកូន។







## ៦- វ៉ាក់សាំង

វ៉ាក់សាំងប្រើសម្រាប់**ការពារជំងឺ** (មិនសម្រាប់ព្យាបាលជំងឺទេ) ព្រោះបន្ទាប់ពីការចាក់វ៉ាក់សាំងសត្វផលិតអង់បដិបក្ខ(អង់ទីគ័រ) ដើម្បីប្រឆាំងការរាតត្បាតរបស់មេរោគ។ វ៉ាក់សាំងមិនអាចការពារសត្វបានគ្រប់ជំងឺទេ។ ដូច្នេះជាការចាំបាច់ ក្នុងការជ្រើសរើស វ៉ាក់សាំង អាស្រ័យនឹងជំងឺដែលបង្កគ្រោះថ្នាក់។ ការជ្រើសរើសវ៉ាក់សាំង មានសារៈសំខាន់ក្នុងការអនុវត្តតាមកម្មវិធីចាក់វ៉ាក់សាំង ដើម្បីឲ្យសត្វអាចការពាពីជំងឺដែលបានចាក់វ៉ាក់សាំងមានប្រសិទ្ធភាព។

### ៦.១ វ៉ាក់សាំងសម្រាប់បក្សី:

- **សម្រាប់មាន់ចិញ្ចឹមតាមផ្ទះ**
  - ❖ **វ៉ាក់សាំងជំងឺដង្កោ (ញូវកាស)**

- វ៉ាក់សាំងរស់ មានទម្រង់ជាម្សៅលាយជាមួយទឹកលាយ និងត្រូវប្រើជាបន្ទាន់។ វ៉ាក់សាំងដែលនៅសល់មិនអាចប្រើបានទៀតទេ។វ៉ាក់សាំងត្រូវបន្តក់តាមភ្នែកឬដាក់ក្នុងទឹកឲ្យផឹក។
- វ៉ាក់សាំងងាប់ដែលបានលាយជាស្រេចពីរោងចក្រផលិត ប្រើបានភ្លាម ដោយបូមយកតែប៉ុន្មានកម្រិតតាមតម្រូវការ រួចរក្សាទុកវ៉ាក់សាំង ដែលនៅសល់បានច្រើនថ្ងៃក្នុងសីតុណ្ហភាពពី២ទៅ៨អង្សាសេ។ វ៉ាក់សាំងនេះអាច រក្សាទុកបានរយៈពេលពី២ទៅ៣ម៉ោងក្នុងសីតុណ្ហភាពពី១៥ ទៅ២៥អង្សាសេ ។ វ៉ាក់សាំងត្រូវចាក់ក្រោមស្បែក ឬសាច់ដុំ។












❖ វ៉ាក់សាំងជំងឺអុត ជាវ៉ាក់សាំងរស់មានម្ជុលមុខពីរសម្រាប់ចាក់ទំលុះស្បែកសន្ទះស្លាប។






- សម្រាប់កសិដ្ឋានពាក់កណ្ដាលឧស្សាហកម្ម (មាន់ដែលចិញ្ចឹមដាក់ទ្រុង)

កម្មវិធីចាក់វ៉ាក់សាំងការពារជំងឺបន្ថែមរួមមាន៖

❖ ជំងឺហ្គុមបូរ៉ូ និងជំងឺរលាកសួត







## ៦.២ វ៉ាក់សាំងសម្រាប់ជ្រូក

- សម្រាប់ចិញ្ចឹមខ្នាតតូច

❖ វ៉ាក់សាំងជំងឺប៉េស្ដ: ជាវ៉ាក់សាំងសំខាន់បំផុត ត្រូវចាក់ឲ្យបានទៀងទាត់ស្របតាមកម្មវិធី។




ប្រសិទ្ធភាពបំផុត
នៅតាមភូមិ









❖ វ៉ាក់សាំងជំងឺអុតក្ដាម: ជាវ៉ាក់សាំង ដែល មានបីវ៉ាឡង់ ប្រើសម្រាប់មេជ្រូក ជ្រូកបា និងមេជ្រូកពេញវ័យ




វ៉ាក់សាំងដែលមានវ៉ាឡង់
តែមួយមិនគ្រប់គ្រាន់ទេ






វ៉ាក់សាំងដែលមានវ៉ាឡង់បីអូ អា
អាស៊ា១មានប្រសិទ្ធភាពជាង

- **សម្រាប់កសិដ្ឋានចិញ្ចឹមពាក់កណ្តាលឧស្សាហកម្ម**
  កម្មវិធីចាក់វ៉ាក់សាំងការពារជំងឺបន្ថែម រួមមាន៖




❖ **សម្រាប់ជំងឺប៉ាវ៉ូវីរុស** វ៉ាក់សាំងនេះ សម្រាប់ចាក់មេជ្រូក និងមេជ្រូកពេញវ័យនៅ២អាទិត្យមុនពេលដាក់ឈ្មោល ដើម្បីការពារការបរាជ័យក្នុងការបន្តពូជ។ ជ្រូកបាត្រូវចាក់វ៉ាក់សាំងនេះផងដែរ។ ជារឿយៗវ៉ាក់សាំងនេះមានរួមផ្សំជាមួយវ៉ាក់សាំងជំងឺកញ្ច្រឹល។

❖ **សម្រាប់ជំងឺអូជេស្គី៖** វ៉ាក់សាំងនេះចាក់មេជ្រូក មេជ្រូកពេញវ័យ និងជ្រូកបា។ ត្រូវចាក់វ៉ាក់សាំងនេះនៅពេលមេជ្រូកផើម ។ ជ្រូកបាត្រូវចាក់វ៉ាក់សាំង២ដង ក្នុងមួយឆ្នាំ។

ដោយឡែក ជំងឺរលាកក្តោងច្រមុះ(Atrophic Rhinitis) មីកូប្លាស្មា អ៊ីកូលី ត្រចៀកខៀវ និងសៀកូវីរុស ជាទូទៅមិនចាំបាច់ចាក់វ៉ាក់សាំងទេ។ ប៉ុន្តែអាចចាក់បានលុះត្រាតែធ្វើរោគវិនិច្ឆ័យ និងធ្វើការវាយតម្លៃពីគ្រោះថ្នាក់នៃជំងឺទាំងនេះនៅក្នុងកសិដ្ឋាន និងតំបន់ក្បែរនោះឲ្យបានប្រាកដ។

## ៦.៣ វ៉ាក់សាំងសម្រាប់គោ ក្របី

❖**វ៉ាក់សាំងជំងឺអុតក្តាម:** គោ ក្របី ត្រូវចាក់ឲ្យបានទៀងទាត់ វ៉ាក់សាំងដែលមាន ៣វ៉ាឡង់ និងអាចចាក់បានម្តងក្នុងមួយឆ្នាំ។ ពេលមានផ្ទុះជំងឺនៅភូមិ ឃុំ ឬស្រុកជិតខាង ត្រូវចាក់វ៉ាក់សាំងនេះ ម្តងទៀតជាបន្ទាន់។

❖ **វ៉ាក់សាំងជំងឺសារទឹក**

វ៉ាក់សាំងប្រភេទវារត្រូវចាក់ចន្លោះ៦ខែម្តង ជាពិសេសត្រូវចាក់មុនរដូវភ្លៀង។ ជាការល្អត្រូវចាក់វ៉ាក់សាំងនេះ អំឡុងពេលផើមក្នុងខែចុងក្រោយ ដើម្បីឲ្យកូនគោទទួលបានអង់ទីគ័រពីមេ។




វ៉ាក់សាំងដែលមានវ៉ាឡង់បី
ជាមួយទឹកលាយអាលុយមីញ៉ូម






## ៧- ថ្នាំរម្ងាប់មេរោគ

ថ្នាំរម្ងាប់មេរោគ គឺជាសារធាតុគីមី ដែលសម្លាប់ ពពួក វីរុស បាក់តេរី និងផ្សិត។

### ៧.១ ថ្នាំរម្ងាប់មេរោគលើស្បែក

ថ្នាំរម្ងាប់មេរោគប្រើផ្ទាល់លើស្បែក បន្ទាប់ពីលាងសម្អាត រួមមាន:

- អាល់កុល
- អ៊ីយ៉ូឌីនមានពណ៌ត្នោត ដូចជាបេតាឌីន( Betadine )។
- មានថ្នាំជាច្រើនប្រើសម្រាប់លាបដំបៅជំងឺអុតក្តាម ភាគច្រើនមានទម្រង់ជាស្ព្រេយបាញ់ ជាទូទៅមានរួមផ្សំថ្នាំរម្ងាប់មេរោគដូចជា មេទីឡែនពណ៌ខៀវ (Methylen Blue ) ឬថ្នាំពណ៌ស្វាយ ( Gentiane Violet) និងថ្នាំអង់ទីប៊ីយ៉ូទិកផ្សេងៗទៀត (ភាគច្រើនជាគ្រួសារតេត្រាស៊ីគ្លីន)។







ថ្នាំពណ៌ស្វាយ+អុកស៊ីតេត្រាស៊ីគ្លីន







ណេអូមីស៊ីន+មេទីឡែនខៀវ




មេទីឡែនខៀវ+គ្លរតេត្រាស៊ីគ្លីន




ថ្នាំពណ៌ស្វាយ+អុកស៊ីតេត្រាស៊ីគ្លីន

### ៧.២ ថ្នាំរម្ងាប់មេរោគសម្រាប់ប្រើក្នុងកន្លែងចិញ្ចឹម

គ្រប់ថ្នាំរម្ងាប់មេរោគទាំងអស់ គួរប្រើបន្ទាប់ពីលាងសម្អាតរួច ពីព្រោះកាកសំណល់ផ្សេងៗ ធូលី។ល។ កាត់បន្ថយប្រសិទ្ធភាពថ្នាំរម្ងាប់មេរោគយ៉ាងខ្លាំង។

ថ្នាំរម្ងាប់មេរោគទាំងនេះត្រូវលាយជាមួយទឹកតាមការណែនាំពីអ្នកផលិត។

ថ្នាំរម្ងាប់មេរោគដែលមានកំហាប់ខ្ពស់-ត្រូវកាន់ និងទុកដាក់ដោយប្រុងប្រយ័ត្ន។












### ៧.៣ ថ្នាំរម្ងាប់មេរោគសម្រាប់ដាក់ក្នុងទឹកឲ្យសត្វផឹក

ទឹក គឺជាអាហារសំខាន់បំផុត ដែលត្រូវការក្នុង-បរិមាណច្រើនសម្រាប់ទ្រទ្រង់រាងកាយ។ ទឹកផឹកភាគច្រើនត្រូវបានបំពុលដោយមេរោគ ជាពិសេសមានប្រភពពីលាមកសត្វ។ ការរម្ងាប់មេរោគក្នុងទឹកមានសារៈសំខាន់ ណាស់ ដើម្បីការពារការឆ្លងមេរោគជំងឺ ផ្តាសាយបក្សី ។




ទឹកដែលបូមពីត្រពាំង ទន្លេ ឬ អាងស្តុកគ្មានគម្របសម្រាប់ការពារពី សត្វព្រៃ ឬសត្វពនេចរ។ត្រូវធ្វើការរម្ងាប់ មេរោគក្នុងទឹកផឹកជាមួយក្លរ៉ាមីន (Chloramine) ជាការអនុវត្តដ៏ល្អ។

## ៨-ថ្នាំបន្សាប

ជាសារធាតុសម្រាប់ទប់ស្កាត់ រារាំង និងបំបាត់សារធាតុពុលដែលបណ្តាលមកពីសារធាតុគីមីផ្សេងៗដូចជាថ្នាំសម្លាប់សត្វល្អិតប្រតិកម្មដោយសារការចាក់ថ្នាំការពារជាដើមដូចជា:




- ថ្នាំអាត្រូពីន(Atropine) សម្រាប់បន្សាបជាតិពុល នៅពេលសត្វស៊ីដោយជាតិពុលថ្នាំដីបតេរេច (Dipterex)ឬពីឡូកាពីន(Pilocarpine)។ អាត្រូពីន ផ្សំជាមួយថ្នាំអង់ទីប៊ីយោទិក ក្នុងការព្យាបាលជំងឺរាករូសធ្ងន់ធ្ងរ។

  អាត្រូពីនប្រឆាំងនឹងភាពកន្ត្រាក់នៃពោះវៀន កន្ត្រាក់បំពង់ខ្យល់ ទងសួត បន្ថយការឈឺចាប់។

- ថ្នាំអាដ្រេណាលីន(Adrenaline) ជាថ្នាំសង្គ្រោះបន្ទាន់ សម្រាប់ព្យាបាលនឹងប្រតិកម្មខ្លាំងក្លា ដែលបណ្តាលមកពីសត្វទិច ប្រតិកម្មដោយសារការចាក់វ៉ាក់សាំង ឬដោយសារថ្នាំប៉េនីស៊ីលីន(Penicillin)។

# ខ- ការណែនាំពីការប្រើប្រាស់បសុឱសថ

## ១- ថ្នាំសម្រាប់ចាក់

ថ្នាំត្រូវរក្សាទុកក្នុងដប ពណ៌ស្រអាប់ ដើម្បីការពារថ្នាំពីពន្លឺព្រះអាទិត្យ។ ដបបិទដោយច្នុកកៅស៊ូ។ ហើយច្នុកកៅស៊ូស្រោបដោយអាលុយមីញ៉ូម និងមានគម្របជ័រ ដើម្បីកុំឲ្យខ្យល់ចូល។ ច្នុកកៅស៊ូអាចចាក់ទំលុះបានច្រើនដង។



- ការរៀបចំប្រើ



បកគម្របជ័រចេញចាក់ម្ជុលចូលក្នុងថ្នុកកៅស៊ូរួចបូមថ្នាំ។

- ត្រូវប្រើម្ជុលស្អាត ព្រោះម្ជុលមិនស្អាតអាចចម្លងមេរោគនិងសារធាតុកខ្វក់ចូលក្នុងថ្នាំ និងកាត់បន្ថយគុណភាពរបស់ថ្នាំ។
- មិនត្រូវបាញ់ខ្យល់ចូលក្នុងដបពេលបូមថ្នាំ ព្រោះខ្យល់អាចមានមេរោគចម្លងទៅថ្នាំ។

ថ្នាំដបមានចំណុះ ២៥០ម.ល ១០០ម.ល ៥០ម.ល និង២០ម.ល។

ការបង្ហាញសម្រាប់វ៉ាក់សាំងរស់ និងសម្រាប់ថ្នាំមួយចំនួនតូចដូចជា ថ្នាំបេរីនីល (Berenil)។ អនុវត្តបច្ចេកទេសនេះ ដើម្បីធានាការរក្សាទុកបានល្អ។ វ៉ាក់សាំងរស់អាចរក្សាទុកបានតែ១ទៅ២ម៉ោង បន្ទាប់ពីលាយរួច។ថ្នាំបេរីនីលអាចរក្សាទុកបាន៧ថ្ងៃ។

## ២- ថ្នាំម្សៅដែលផ្តល់តាមមាត់



ថ្នាំម្សៅដែលលាយក្នុងចំណី ឬដាក់ក្នុងទឹកឲ្យផឹក ត្រូវច្របល់ កូរឲ្យសព្វ ប្រើជាពិសេសសត្វមានចំនួនច្រើន។

ជាទូទៅម្សៅ ដែលគេតែងតែប្រើសំរាប់លាយជាមួយចំណីគឺ ម្សៅប្រេមិច (ផ្តល់វីតាមីន និងសារធាតុរ៉ែ) និងព្យាបាលការពារ ប៉ុន្តែមិនមែនដើម្បីព្យាបាលជំងឺធ្ងន់ធ្ងរទេ ព្រោះសត្វឈឺធ្ងន់ធ្ងរវាឈប់ស៊ីចំណី។

ផលិតផលទាំងនេះត្រូវវេចខ្ចប់ជាកញ្ចប់តូចៗ ទម្ងន់១០០ក្រាម សម្រាប់កសិករចិញ្ចឹមសត្វជាលក្ខណ:គ្រួសារ។ កញ្ចប់ ទម្ងន់១គក្រ ឬបាវទម្ងន់២៥គក្រ សម្រាប់កសិដ្ឋានធំៗ។

## ៣- ថ្នាំទឹកសម្រាប់ផឹក



ថ្នាំនេះ ត្រូវអនុវត្តដោយចាប់សត្វឲ្យបានត្រឹមត្រូវដើម្បីបញ្ច្រកថ្នាំ ដូចជាថ្នាំទម្លាក់បរាសិត: អាល់បង់ដាសុលសម្រាប់គោ ក្របី។

បញ្ច្រក ថ្នាំរាគរបស់កូនជ្រូក ឬថ្នាំព្យាបាលជំងឺកុកស៊ីដ្យូស៊ីស។ ជារឿយៗ ត្រូវច្រកក្នុងដបដែលមានប្រព័ន្ធសប់បញ្ចេញនូវកម្រិតថ្នាំយ៉ាងត្រឹមត្រូវ។

## ៤- ថ្នាំគ្រាប់

- ថ្នាំគ្រាប់ សម្រាប់ព្យាបាលសត្វឆ្កែ និងឆ្មា ប៉ុន្តែគេកម្រប្រើសម្រាប់ជ្រូក និងគោ ក្របី។

គ្រាប់ថ្នាំ ( Boluses) គឺជាគ្រាប់ថ្នាំធំ ដែលប្រើដើម្បីបញ្ចូលថ្នាំអង់ទីប៊ីយ៉ូទិក ដោយផ្ទាល់ទៅក្នុងស្បូន បន្ទាប់ពីការកើតកូនរួច។



ប៉ារ៉ាសេតាម៉ុលគ្រាប់ក្នុងប្រអប់ធំ (១០០០គ្រាប់) ជារៀយៗលក់សម្រាប់សត្វ




ប៉ារ៉ាសេតាម៉ុលគ្រាប់ក្នុងប្រអប់ធំ (១០០០គ្រាប់) ជារៀយៗលក់សម្រាប់សត្វ

## ៥- ថ្នាំបន្តក់ភ្នែក

ភ្នែកងាយទទួលរងបញ្ហាខ្លាំង យើងអាចប្រើថ្នាំបន្តក់ភ្នែកទៅក្នុងភ្នែកសត្វ។ ថ្នាំដែលមានភាពមិនជាក់លាក់ធ្វើឲ្យរលាកភ្នែក និងធ្វើឲ្យភ្នែកឈឺចាប់។ ការបន្តក់ភ្នែកត្រូវបានប្រើផងដែរ សម្រាប់វ៉ាក់សាំងឲ្យកូនមាន់ ជាទូទៅ វាមានពណ៌ខៀវ ដើម្បីឲ្យមើលឃើញតំណក់ក្នុងភ្នែក ហើយប្រាកដថា កូនមាន់បានធ្វើវ៉ាក់សាំងត្រឹមត្រូវ។



## ៦-ថ្នាំដែលមានជាតិក្រែម និងស្ព្រេយ៍

ក្រែម និងស្ព្រេយ៍ ត្រូវប្រើតាមកន្លែង ជាពិសេសសម្រាប់របួសស្បែក។ ថ្នាំទាំងនោះ ត្រូវប្រើលើស្បែកដែលស្អាត បន្ទាប់ពីកាត់រោមនិងបេះក្រមរ ហើយលាងជាមួយទឹកនិងសាប៊ូ។

ស្ព្រេយ៍មានសារធាតុរំងាប់មេរោគ និងថ្នាំអង់ទីប៊ីយ៉ូទិក។ ថ្នាំនេះប្រើដើម្បីព្យាបាលរបួសលើជើង (អុតក្តាម មុត ដំបៅ...) ព្រោះកសិករអាចបាញ់ស្ព្រេយ៍បាន។




# គ- ការប្រើប្រាស់បសុឱសថ

ដើម្បីប្រើប្រាស់ថ្នាំឲ្យមានប្រសិទ្ធភាពភ្នាក់ងារសុខភាពសត្វភូមិ ត្រូវគោរពតាមការណែនាំរបស់អ្នកផលិត ដែលបានបញ្ជាក់យ៉ាងច្បាស់លើស្លាកថ្នាំ ដូចជា:

- កម្រិតថ្នាំដែលត្រូវប្រើ
- ផ្លូវបញ្ចូលឱសថ
- ពេលវេលាដែលប្រើឱសថ៖ ប្រើពេលណា និងរយ:ពេល។

## ១- ការអានស្លាកសញ្ញា

### ១.១ សមាសធាតុផ្សំ

រាល់ការណែនាំត្រូវបានសរសេរយ៉ាងច្បាស់លើស្លាក ដែលជាទូទៅជាភាសាខ្មែរ និងភាសារបរទេស។

ឈ្មោះពាណិជ្ជកម្មលើស្លាកដបថ្នាំអាចបញ្ជាក់បានខ្លះពីការផ្សំរបស់ថ្នាំ ប៉ុន្តែត្រូវពិនិត្យជាចាំបាច់ ព្រោះអ្នកផលិតខ្លះ មិនអនុវត្តឲ្យស្របតាមនិយាមរបស់រូបមន្តទេ។


















| អង់គ្លេស | បារាំង | វៀតណាម |
|---|---|---|
| សមាសធាតុផ្សំ (រូបមន្ត) | Composition | Thành Phàn |
|  |  |  |

## ១.២ ការណែនាំបសុឱសថកបនឹងជំងឺ (Indications)




តាមការណែនាំលើស្លាកសញ្ញា ដែលបានបរិយាយដោយអ្នកផលិត ពីការប្រើប្រាស់ថ្នាំកបនឹងជំងឺ ។ ឧទាហរណ៍: ថ្នាំខ្លះអាចព្យាបាលបានជំងឺច្រើនមុខ ដូចជាថ្នាំស៊ុលហ្វា៣៣ ជាថ្នាំអង់ទីប៊ីយ៉ូទិកអាចព្យាបាលស្ទើរតែគ្រប់ជំងឺឆ្លងទាំងអស់ លើមាន់ ជ្រូក និងគោក្របី។

## ១.៣ កម្រិតប្រើប្រាស់

កម្រិតថ្នាំសម្រាប់ប្រើប្រាស់ អាស្រ័យទៅនឹងទម្ងន់សត្វ ឬបរិមាណដែលត្រូវលាយក្នុងចំណី ឬទឹក ត្រូវបានបញ្ជាក់ជាក្រាម (នៃថ្នាំ)/គ.ក្រ (របស់ចំណី) ឬក្រាម (របស់ថ្នាំ)/លីត្រ(របស់ទឹក)

| ភាសាខ្មែរ | ភាសាអង់គ្លេស | ភាសាបារាំង | ភាសាវៀតណាម |
|---|---|---|---|
| កម្រិត | Dosage | Dosage | Cách Dùng |
| ការព្យាបាល | Treatment | Curatif | Tri Bênh |
| ការបង្ការ | Prevention | Preventif | Phòng Bênh |
| បក្សី | Poultry | Volailles | Gà |
| ជ្រូក | Swine | Porcs | Heo |
| គោ | Cattle | Bovins | Bò |
| ម្តងមួយថ្ងៃ | Once a day | 1 fois par jour | Ngày 1 lân |
| កំឡុងពេលបីថ្ងៃ | During 3 days | pendant 3 jours | Trong 3 ngày |

## ២- ការធ្វើឲ្យថ្នាំរលាយស្មើសាច់

មុនចាក់ថ្នាំ ចាំបាច់ត្រូវក្រឡុកដបថ្នាំ ដើម្បីឲ្យរលាយសព្វ។




## ៣-កម្រិតប្រើប្រាស់ត្រឹមត្រូវ

- សម្រាប់ថ្នាំចាក់ កម្រិតប្រើប្រាស់អាស្រ័យ ទៅនឹងទម្ងន់សត្វ។ ចាំបាច់ណាស់ក្នុងការប៉ាន់ស្មានទម្ងន់សត្វឲ្យបានត្រឹមត្រូវ។ ថ្នាំជាច្រើនបង្ហាញពីកម្រិតប្រើប្រាស់ គឺ១ម.ល/១០គ.ក្រ ឧទាហរណ៍ មេជ្រូកទម្ងន់២៥០គ.ក្រ ត្រូវចាក់២៥ម.ល ក្នុងករណីនេះ ការចាក់២៥ម.ល លើមេជ្រូក ត្រូវប្រើអន្ទាក់ចាប់ ហើយត្រូវរំលែកថ្នាំជាពីរដើម្បីចាក់ពីរកន្លែងផ្សេងគ្នា។
- ឧទាហរណ៍ដើម្បីលាយថ្នាំក្នុងចំណី ជាការចាំបាច់ត្រូវប្តូរកម្រិតប្រើប្រាស់ សម្រាប់កម្រិតការពារ ពេលដែលសត្វជ្រូក ឬមាន់ស៊ីចំណីធម្មតា និងកម្រិតសម្រាប់ការព្យាបាល ពេលសត្វឈឺ។ ឧទាហរណ៍: ជ្រូកមួយក្បាលទម្ងន់៥០គ.ក្រ ស៊ីចំណីផ្សំស្រេច២គក្រវៀងរាល់ថ្ងៃ ប៉ុន្តែពេលជ្រូកឈឺ វាស៊ីតែ១គក្រក្នុងមួយថ្ងៃ ឬស៊ីតិចជាងនេះទៀត។ ប្រសិនបើកម្រិតប្រើរបស់ថ្នាំ១០០ក្រាមលាយក្នុងចំណី៥០គក្រ នោះពេលជ្រូកស៊ីតែ១គក្រ កសិករត្រូវលាយ១០០ក្រាមថ្នាំក្នុងចំណី២៥គ.ក្រ ដើម្បីប្រាកដថាជ្រូកបានស៊ីថ្នាំអង់ទីប៊ីយ៉ូទិកបានគ្រប់ចំនួន។

## ៤- រយៈពេល (ចង្វាក់) នៃការប្រើប្រាស់ថ្នាំ

បន្ទាប់ពីចាក់ ថ្នាំខ្លះមានប្រសិទ្ធភាព រយៈពេលពីប៉ុន្មាននាទី ឬច្រើនថ្ងៃ។

- ក្នុងពេលប៉ុន្មាននាទី៖ អុកស៊ីតុកស៊ីន ( Ocytocine)...-ការចាក់ថ្នាំលើកទីពីរអាចធ្វើទៅបានប្រហែល៣០នាទី បន្ទាប់ពីចាក់លើកទីមួយ
- ១ម៉ោង៖ កាល់ម៉ាស៊ីន ( Calmagine) អាណាហ្សាំង ( Analgine)...
- ១២ម៉ោង៖ អំពីដិចសាឡូន ( Ampidexalone) ប៊ីយ៉ូកូលីស្ទីន ( Biocolistine)...
  ប្រសិនជាថ្នាំត្រូវចាក់នៅពេលព្រឹក ការចាក់លើកទីពីរត្រូវចាក់នៅពេលល្ងាច ដើម្បីរក្សាកម្រិតជាតិថ្នាំអង់ទីប៊ីយ៉ូទិកក្នុងខ្លួនសត្វ

- ១ថ្ងៃ៖ សិបត្ទូទ្រីល ( Septotryl) ហ្វ្រេកូទីល ( Frecortyl)...ក្នុងករណីនេះថ្នាំនឹងត្រូវចាក់នៅថ្ងៃបន្ទាប់។
- ២ថ្ងៃ៖ តុលហ្វេឌីន ( Tolfedine) ឡុងអាម៉ុក ( Longamox)...ក្នុងករណីនេះការចាក់លើកទី២ត្រូវធ្វើនៅពីរថ្ងៃ បន្ទាប់ពីចាក់លើកទី១។
- ៣ថ្ងៃ៖ រេម៉ាស៊ីគ្លីន ( Remacycline) ឡុងហ្ស៊ីស៊ីន ( Longicine)...
- លើសពី៧ថ្ងៃ៖ ជាតិដែកដិចត្រង់ ( Iron Dextran)...។

## ៥- បរិក្ខារដែលចាំបាច់

- ត្រូវមានម្ជុល និងសឺរ៉ាំងឲ្យបានគ្រប់គ្រាន់
  - **ទំហំរបស់សឺរ៉ាំង** ត្រូវសមស្របនឹងបរិមាណថ្នាំដែលត្រូវចាក់។ មិនអាចកំណត់១ម.លជាមួយសឺរ៉ាំង២០ម.ល ឬ ដើម្បីចាក់ថ្នាំ៣០ម.ល ចាក់បីដងជាមួយសឺរ៉ាំង១០ម.លនោះទេ។




  - **ប្រវែងរបស់ម្ជុល** ត្រូវឲ្យសមស្របសម្រាប់ចាក់សាច់ដុំ ចំពោះជ្រូក។ កម្រាស់ខ្លាញ់របស់មេជ្រូកទំងន់ ២៥០ គ.ក្រ គឺក្រាស់ជាង ៣០ម.ម ដូចនេះម្ជុលត្រូវមានប្រវែងយ៉ាងតិច៤០ម.ម។




  - **អង្កត់ផ្ចិត (ប្រហោង) របស់ម្ជុល** ត្រូវសមស្របជាមួយថ្នាំ ដែលត្រូវចាក់ដូចជាថ្នាំជាតិប្រេង (ថ្នាំដែលមានសកម្មភាពវែង) គឺខាប់ ត្រូវចាក់ថ្នាំជាមួយម្ជុលធំ។
- **ថ្នាំម្សៅប្រើតាមមាត់**

ដើម្បីលាយថ្នាំឲ្យបានស្មើសាច់ កសិករដែលគ្មានប្រដាប់លាយ ត្រូវលាយជាជំហានៗឲ្យសព្វ ដើម្បីឲ្យជ្រូកទាំងអស់ ស៊ីបរិមាណថ្នាំបានដូចៗគ្នា។ ឧទាហរណ៍: ដំបូងត្រូវលាយថ្នាំ១០០ក្រាម ជាមួយវត្ថុធាតុដើម១គ.ក្រ បន្ទាប់មកល្បាយនេះត្រូវយកទៅលាយក្នុងវត្ថុធាតុដើម៥គ.ក្រ និងចុងក្រោយយកល្បាយនេះទៅលាយជាមួយចំណី៥០គ.ក្រ។

# ឃ- កាកសំណល់ថ្នាំ

## ១- និយមន័យ

កាកសំណល់បសុឱសថ គឺជាចំនួនតិចតួចរបស់បសុឱសថ ដែលស្ថិតក្នុងផលិតផលសត្វរួមមាន៖ សាច់ ស៊ុត ឬទឹកដោះ បន្ទាប់ពីការចាក់ ឬប្រើប្រាស់ថ្នាំ។

ប្រសិនបើសាច់ ស៊ុត ឬទឹកដោះ ត្រូវបានបរិភោគបន្ទាប់ពីរយៈពេលខ្លីនៃការព្យាបាល ពួកគាត់នឹងត្រូវស្រូបយកនូវកម្រិតតិចតួចនៃថ្នាំដែលផ្តល់ឲ្យសត្វនោះ។



ប្រសិនបើមេមាន់ ឬមេទាត្រូវបានព្យាបាលដោយអង់ទីប៊ីយ៉ូទិក ប៉ុន្មានថ្ងៃមុនពង នោះពងវាមានផ្ទុកកាកសំណល់តូចៗរបស់អង់ទីប៊ីយ៉ូទិក

## ២- គ្រោះថ្នាក់ (ហានិភ័យ)

បរិមាណតិចតួចរបស់ថ្នាំអាចមានឥទ្ធិពលដូចជា៖

- ប្រតិកម្ម (អាលែស៊ី) មនុស្សមួយចំនួនមានប្រតិកម្មនឹងថ្នាំប៉េនីស៊ីលីន ហើយថ្នាំប៉េនីស៊ីលីនតិចតួច ក៏ធ្វើឲ្យមានប្រតិកម្មផងដែរ។



សញ្ញាលើស្បែកដោយប្រតិកម្មជាមួយថ្នាំប៉េនីស៊ីលីន

- ធន់នឹងការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក៖ ការបរិភោគញឹកញាប់ផលិតផលសត្វដែលមានកាកសំណល់របស់ថ្នាំតេត្រាស៊ីគ្លីន ធ្វើឲ្យធន់នឹងជំងឺអ៊ីកូលី មានន័យថាជំងឺអ៊ីកូលីអាចសម្របខ្លួននឹងថ្នាំតេត្រាស៊ីគ្លីន និងបច្ចុប្បន្ននេះថ្នាំតេត្រាស៊ីគ្លីនមិនមានប្រសិទ្ធភាពប្រឆាំងនឹងអ៊ីកូលីលើមនុស្សទេ។
- ការពុល៖ កាកសំណល់របស់ថ្នាំក្លរ៉ង់ហ្វេនីកុល អាចបង្កជាការខ្វះឈាមក្រហមរហូតដល់ស្លាប់ ចំពោះមនុស្ស។

## ៣- ការការពារកាកសំណល់

អ្នកផលិតថ្នាំបង្ហាញ**រយៈពេលអស់ជាតិ**ថ្នាំលើស្លាកថ្នាំ៖ គឺជាពេលវេលារង់ចាំរហូតដល់សាបជាតិថ្នាំ បន្ទាប់ពីការព្យាបាលរួច ដែលសាច់ ស៊ុត និងទឹកដោះត្រូវបានយកមកបរិភោគ។



ជាទូទៅការអនុវត្តន៍ដែលល្អ គឺត្រូវប្រើថ្នាំនៅពេលដែលចាំបាច់។ ជារឿយៗការគ្រប់គ្រងដែលល្អ អាចដោះស្រាយបញ្ហាសុខភាពចម្បងបាន។

# ង- ការថែរក្សាថ្នាំ

គុណភាពរបស់ថ្នាំត្រូវបានធានា ប្រសិនបើការរក្សាទុកក្នុងលក្ខខ័ណ្ឌបានល្អ មានកត្តាជាច្រើនដែលមានឥទ្ធិពលលើការរក្សាទុកថ្នាំ។

## ១- កំដៅ

- វ៉ាក់សាំង គឺជាថ្នាំដែលងាយទទួលការខូចខាតបំផុតដោយកំដៅ ជាពិសេសវ៉ាក់សាំងរស់។ ប្រព័ន្ធត្រជាក់មានសារៈសំខាន់ណាស់៖ សីតុណ្ហភាពរបស់វ៉ាក់សាំងតាំងពីកន្លែងផលិតរហូតដល់កសិដ្ឋាន ត្រូវរក្សាជានិច្ចក្នុងចន្លោះសីតុណ្ហភាពពី២ទៅ៨អង្សាសេ។




injection on the neck; subcutaneous injections are also effective.

The dose for all species of animals when infected with Babesiae, and T. congolense and T. vivax, is 0.8 gm to 1.6 gm

ការរក្សាទុក: ទុកនៅកន្លែងត្រជាក់ កុំឲ្យប៉ះពន្លឺថ្ងៃ

... trypanosoma strains a high dose is indicated and that is, 1.6 gm of BERENIL® granules (2 spoons) per 100 kg body weight. It is recommended, however, that a total dose of 9 gm of BERENIL® granules per animal is the highest limiting dose.

STORAGE : Store in a cool place. Protect from direct sunlight

PRESENTATION
Bottle of 5 gm and 22.5 gm - with a 0.8 gm measure spoon

® Registered Trademark

- គ្រប់ថ្នាំទាំងអស់ត្រូវខូចខាតដោយសីតុណ្ហភាពខ្ពស់ ត្រូវរក្សានៅសីតុណ្ហភាពពី២៥ទៅ២៧អង្សាសេ។

## ២ ពន្លឺ

ថ្នាំត្រូវរក្សាទុកក្នុងកន្លែងងងឹត ដែលវេចខ្ចប់ក្នុងប្រអប់ និងដាក់ក្នុងដបដែលមានពណ៌ស្រអាប់។ ពពួកវីតាមីន ងាយស្រួលទទួលរងការខូចខាតដោយពន្លឺ។

ប្រអប់ជារបស់ការពារល្អបំផុតពីពន្លឺថ្ងៃ






ថ្នាំអង់ទីប៊ីយ៉ូទិកនេះមិនអាចរក្សាទុកក្រៅទូងងឹតបានទេ



## ៣- អុកស៊ីតកម្ម

ដបថ្នាំមានចុកកៅស៊ូ ដែលអាចចាក់ទំលុះបានច្រើនលើក។ ទោះជាយ៉ាងណាក៏ដោយ ការចាក់ទម្លុះម្តងៗ អាចធ្វើឲ្យខ្យល់ចូលក្នុងដប និងមានអុកស៊ីសែន បង្កជាអុកស៊ីតកម្ម។ ឧទាហរណ៍ថ្នាំតេត្រាស៊ីគ្លីន ប្តូរពីពណ៌លឿងខ្ចី ទៅជាត្នោតចាស់ក្នុងកូនដបដែល-ចាក់ម្ជុលទំលុះរួចហើយ។ ពេលអ្នកចាប់ផ្តើមប្រើថ្នាំដប ត្រូវព្យាយាមប្រើឲ្យអស់ក្នុងពេលប៉ុន្មានថ្ងៃបន្ទាប់មក។




## ៤- សំណើម

ករណីខ្លះ ម្សៅក្លាយជារឹងដូចដុំថ្ម តែអាចប្រើបានបន្ទាប់ពីបុកកំទេច។

- បញ្ហានេះកើតមានច្រើនតែចំពោះម្សៅ ដែលបាវមិនបានបិទត្រឹមត្រូវ ឬបន្ទាប់ពីបើក ជាពិសេសរដូវភ្លៀង។ត្រូវជ្រើសរើសផលិតផលណាដែលច្រកក្នុងថង់ប្លាស្ទិក ប្រសិនបើរក្សាទុកច្រើនអាទិត្យ។




- ប៉ុន្តែបើម្សៅក្លាយជារឹងដូចថ្ម ហើយមានដុះផ្សិតនិងមានពណ៌ខៀវ ឬមានក្លិនអាក្រក់ ដូចនេះ មិនត្រូវប្រើជាដាច់ខាត។






## ៥- ការផុតកំណត់ប្រើប្រាស់

ធម្មតាថ្នាំត្រូវប្រើមុនពេលផុតកាលបរិច្ឆេទប្រើប្រាស់។ ថ្នាំដូចជាវីតាមីន វ៉ាក់សាំងមិនអាចទុកបានរយៈពេលវែងបានទេ ដូចនេះ ត្រូវគោរពតាមកាលបរិច្ឆេទផុតការប្រើប្រាស់។




3
4
5
6
1
2


in the jaw
in diaphragm
Cysts develop in the muscle of people
Trichinella inside the muscle of pig
People eat pork meat not enough cooked

# ជំពូកទី៩៖ បរាសិត


5
liver
1
grass and water
4
2
larva stage 2
larva stage 1
3
mud snail


b. LARVA
a. EGGS
in the grass
c. NYMPH
on animals
d. ADULT
female
suck a lot of blood
male
suck little blood

បរាសិតគឺជាសត្វល្អិតតូចៗ ដែលរស់នៅដោយសារសត្វ និងបំផ្លាញសត្វ។បរាសិតចែកចេញ ជាពីរគឺ បរាសិតខាងក្នុង វារស់ក្នុងខ្លួនសត្វ និងបរាសិតខាងក្រៅវានៅខាងក្រៅខ្លួនសត្វនៅលើស្បែកនិងក្នុងស្បែក។

ជាទូទៅបរាសិតមានគ្រោះថ្នាក់សម្រាប់សត្វ យើងចាំបាច់ត្រូវត្រួតពិនិត្យបរាសិតឲ្យបានទៀងទាត់ ពីព្រោះបរាសិតប៉ះពាល់លើសុខភាពសត្វ ដែលធ្វើឲ្យ:

- សត្វខ្សោយកម្លាំង និងលូតលាស់យឺត
- លទ្ធភាពបន្តពូជខ្សោយ
- បង្កជាជំងឺ
- ចម្លងជំងឺ
- រំខានចំពោះសត្វ។

# ក- វដ្តរបស់បរាសិត

គ្រប់បរាសិតទាំងអស់មានវដ្តជីវិតលូតលាស់ខុសៗគ្នាពីស៊ុតដល់ពេញវ័យ(លឿនសម្រាប់ការបន្តពូជ)។ ដំណាក់កាលខុសៗគ្នាដែលជាទូទៅរួមមាន៖

-ស៊ុត



- កូនដង្កូវ



- ព្រូនពេញវ័យ



## ១- វដ្តជីវិតលូតលាស់ដោយផ្ទាល់

ការលូតលាស់គ្រប់ដំណាក់កាលរបស់បរាសិត លើសត្វតែមួយ ឧទាហរណ៍: ព្រូនអាស្ការីសកើតលើជ្រូក វដ្តជីវិតនៃព្រូននេះមួយចប់សព្វគ្រប់ក្នុងខ្លួនជ្រូកប្រើរយៈពេលពីរអាទិត្យទៅពីរខែបន្ទាប់ពីជ្រូកស៊ីពងព្រូន។









ពេលកូនដង្កូវនៅក្នុងពោះវៀន វាផ្លាស់ទីទៅថ្លើមតាមរយៈឈាម

បន្ទាប់ពីនោះមក វាផ្លាស់ទីទៅសួត និងបន្ទាប់មកទៅបំពង់ខ្យល់ដើម្បីត្រឡប់ចូលក្នុងពោះវៀនវិញ។







ពេលដែលកូនដង្កូវមកដល់ពោះវៀនម្តងទៀតក្នុងដំណើរវែងឆ្ងាយ វានឹងក្លាយជាព្រូនពេញវ័យ និងចាប់ផ្តើមពង។

ពងត្រូវបានបញ្ចេញមកក្រៅ (ដើម្បីមើលពងព្រូន ក្នុងលាមកឃើញត្រូវការមីក្រូទស្សន៍) ។ ព្រូនពេញវ័យអាចបញ្ចេញមកក្រៅតាមលាមកពេលមានច្រើន។






## ២-វដ្តជីវិតលូតលាស់មិនផ្ទាល់

បរាសិតត្រូវការសត្វមួយផ្សេងទៀតសម្រាប់ការលូតលាស់ពីស៊ុតរហូតដល់ពេញវ័យ។ ឧទាហរណ៍ៈព្រូនហ្វាស្យូឡាគឺជាដង្កូវក្នុងថ្លើមគោ។ ដើម្បីបំពេញវដ្តជីវិតលូតលាស់មួយចប់សព្វគ្រប់ ព្រូនហ្វាស្យូឡាត្រូវការគោ និងខ្យង។ (សូមមើលរូបភាព)





គោមានហ្វាស្យូឡាបញ្ចេញពងព្រូននៅក្នុងលាមក (ជាញឹកញាប់លាមករាក)


ស៊ុតលូតលាស់ជាកូនដង្កូវក្នុងស្មៅដែលមានទឹក

និងកូនដង្កូវដែលត្រូវបានស៊ីដោយខ្យងតូចមួយនេះ



ខ្យងបញ្ចេញកូនដង្កូវថ្មីក្នុងស្មៅ (យើងហៅថាដំណាក់កាលទី២)

គោស៊ីស្មៅដោយកូនដង្កូវបន្ទាប់មកកូនដង្កូវចូលទៅក្នុងថ្លើម និងក្លាយជាដង្កូវថ្លើមពេញវ័យចាប់ផ្តើមពងហើយចូលទៅក្នុងពោះវៀននិងក្នុងលាមក។


គោនឹងស៊ីកូនដង្កូវពេលស៊ីស្មៅក្នុងតំបន់សើម


ហ្វាស្យូឡារស់នៅក្នុងបំពង់ថ្លើម និងបញ្ចេញស៊ុតទៅក្នុងពោះវៀន

# ខ- បរាសិតខាងក្រៅ

## ១-ឥទ្ធិពលរបស់បរាសិតខាងក្រៅ

### ១.១ ស្លាកស្នាមលើស្បែក

អង្គែជាជំងឺសើស្បែក លើសត្វ ជាពិសេសជ្រូក។វដ្តជីវិតពេញលេញរបស់អង្គែពី១០ទៅ១៥ថ្ងៃហើយអង្គែអាចរស់នៅក្នុងដីសើមជិត ៤អាទិត្យ។


បរាសិតបង្កជាអង្គែ

អង្គែញីបញ្ចេញស៊ុតនៅក្រោមស្បែកធ្វើឲ្យសត្វរមាស់យ៉ាងខ្លាំង ដោយដើរត្រដុសនិងគ្រវីក្បាលនៅលើស្បែកមានចេញពងតូចៗពិណក្រហម។


ស្លាកស្នាមជាចំណុចក្រហម និងក្រម៉ក្រៀម

### ១.២ ការបឺតឈាម

ប្រភពចំណីអាហាររបស់ដង្កែគឺបឺតឈាមពីសត្វ។មាត់របស់វាមានសភាពដូចស្នមានងៀងសម្រាប់ចាក់ទម្លុះស្បែកដើម្បីបឺតឈាមពីសត្វ។ ចំនួនដង្កែច្រើនអាចធ្វើឲ្យសត្វបាត់បង់ឈាម និងខ្សោយជាពិសេសកូនគោ។


គ្រប់ដង្កែញីបឺតឈាម បានពីរមីលីលីត្រ


មាត់វាអាចកាត់ស្បែកនិងចូលដល់សរសៃឈាម

ដង្កែឆ្លងកាត់ដំណាក់កាលលូតលាស់ខុសៗគ្នាដូចជា ស៊ុត កូនដង្កូវរស់ក្នុងស្មៅ ។ ដង្កែពេញវ័យរស់លើសត្វ និងពេលខ្លះលើមនុស្ស។ដង្កែឆ្លងទៅលើសត្វតាមស្មៅ ឬតាម គម្ពោតព្រៃ...។



ដង្កែញីបឺតឈាម
ដង្កែឈ្មោលបឺតឈាម

ដង្កែញីរស់លើសត្វ និងចិញ្ចឹមជីវិតដោយបឺតឈាម ដង្កែបោងធំប្រហែល ២០០ដងប្រៀបធៀបនឹងទំហំដើមរបស់វា បន្ទាប់មកវានឹងធ្លាក់មកដី និងបញ្ចេញពង ហើយងាប់។បន្ទាប់មកកូនដង្កូវលូតលាស់ និងផ្លាស់ទីលើស្មៅដើម្បីស្វែងរកចំណីដែលជាឈាមជាលើកដំបូងរបស់វា។

ប្រសិនបើសត្វឆ្លងកាត់ទីនោះពួកដង្កែតោងដើម្បីបឺតឈាម។

សត្វមេមានឈាមពេញ







បន្ទាប់មកវាពងក្នុងបរិយាកាសរួចវាងាប់

ដង្កែរងចាំក្នុងស្មៅ





លោត និងតោងជាប់ស្បែក

## ១.៣ បង្កការរំខាន និងធ្វើឲ្យសត្វកើតស្ត្រេស





ពពួកសត្វចង្រៃដែលបង្កការរំខាន និងធ្វើឲ្យសត្វកើតស្ត្រេស ជាពិសេសសត្វរុយដែលមានចំនួនច្រើន។ អាចសង្កេតឃើញបញ្ហានេះពិសេសលើជ្រូកក្នុងទ្រុងកើតកូន និងផ្តាច់ដោះ។ មានការលំបាកក្នុងការកម្ចាត់រុយណាស់ព្រោះវាកើតលឿន។

វដ្តជីវិតរបស់រុយពីស៊ុតដល់ពេញវ័យគឺមានរយៈពេលខ្លីពី៧ទៅ១៩ថ្ងៃ។រុយពេញវ័យមួយក្បាលពងរហូតដល់៩០០ស៊ុត។





## ១.៩ ការចម្លងជំងឺ

❖ រុយ

- ជ្រូក ដែលបង្កការរំខានពីសត្វរុយ ច្រើនឆ្លងជំងឺអ៊ីកូលី សាល់ម៉ូណេឡា ស្ត្រឹបតូកុក និងជំងឺដែលមានខ្លាញ់ (ស្តាភីឡូកុក) និងកុកស៊ីឌីយ៉ូស ។ -សេះ និងគោ រុយបង្កឲ្យឆ្លងជំងឺ ទ្រីប៉ាណូសូម៉ា (បរាសិតក្នុងឈាម)។



ជំងឺឡើងខ្លាញ់លើកូនជ្រូកកំពុងបៅដោះ



ជំងឺទ្រីប៉ាណូសូម៉ាលើសេះ

❖ មូស

មូសជាអ្នកចម្លងជំងឺអុតមាន់។ ជំងឺនេះបង្កឲ្យមានអគ្រោះថ្នាក់ចំពោះកូនមាន់ និងបង្កជាក្រម៉លើមាន់សាច់ និងមាន់ពង។


មូសចម្លងជំងឺអុតមាន់

❖ ដង្កែ

ដង្កែអាចចម្លងជំងឺបាបេស្យា និង អាណាផ្លាស្មា(បរាសិតក្នុងឈាម)។ មិនឃើញមានគោក្នុង ស្រុកឈឺនឹងជំងឺ នេះទេ ប៉ុន្តែគោកូនកាត់ និង គោទឹកដោះ នាំចូលពីបរទេសមានគ្រោះថ្នាក់ នឹងជំងឺបាបេស្យា និង អាណាផ្លាស្មា។

**ថែមដង្កែកើតលើមនុស្ស**


ទឹកនោមគោដែលឈឺដោយជំងឺបាបេស្យា

## ២-ការត្រួតពិនិត្យបរាសិតខាងក្រៅ

### ២.១ ចៃ

- ចំពោះមាន់



➢ ចៃកើតលើមាន់ មិនបឺតឈាមទេ។ ពពួកចៃរកស៊ីលើសំបកស្បែកដែលស្ងួត ស្លាប និង ក្រម៉។ ចៃកើតលើមាន់ មិនអាចចម្លងទៅមនុស្សទេ។

➢ ពងចៃតោងជាប់ស្លាប ជាពិសេសជុំវិញរន្ធគូថដែលបង្កឲ្យជ្រុះរោមនិងមាន ក្រម៉ជុំវិញរន្ធគូថ។

➢ ការព្យាបាលចៃត្រូវប្រើការបារីល (Carbaryl) ។ វដ្តជីវិតរបស់ចៃប្រហែលពីរអាទិត្យ ដូចនេះ ត្រូវព្យាបាលសារឡើងវិញរៀងរាល់ពីរអាទិត្យ។

## ២.២ អង្កែ

➢ អង្កែកើតលើជ្រូកដោយឆ្លងរាលដាលតាមការប៉ះពាល់។ អង្កែជ្រូកមិនអាចឆ្លងទៅ មនុស្សទេ។ ការលាងជ្រូករាល់ថ្ងៃធ្វើឲ្យមានសំណើមក្នុងទ្រុង គឺជាលក្ខណ្ឌល្អសម្រាប់ការរស់នៅរបស់អង្កែ។ ជ្រូកកើតអង្កែរំខានដល់ការរស់នៅ ធ្វើឲ្យជ្រូកត្រដុសខ្លួន ខ្វាច និងបក់ត្រចៀកឥតឈប់ឈរ។ មានស្នាមអុចតូចៗពណ៌ក្រហម និងមានក្រម៉ៅខ្មៅ ជុំវិញត្រចៀក។ជ្រូកដោយសារការរំខានខ្លាំងពេក ជាពិសេសកូនជ្រូក វាស៊ីចំណីមិនបានស្រួល បណ្តាលឲ្យជ្រូកលូតលាស់យឺត ហើយអាច ឆ្លងជំងឺលើស្បែក។





➢ **ការព្យាបាល:**

-ចាក់អ៊ីវែម៉ិចទីន (ក្រោមស្បែក) ២ដង ក្នុងអំឡុងពេលពី១២ទៅ១៤ថ្ងៃ។ ១មល សម្រាប់៣០គក្រទម្ងន់ជ្រូក-ឬលាយអ៊ីវែម៉ិចទីនក្នុងចំណីរយៈពេល៧ថ្ងៃ ឬបាញ់ថ្នាំសម្លាប់សត្វល្អិតដូចជា អាស៊ុនតុល (Asuntol) ប៉ុន្តែមានការលំបាកក្នុងការអនុវត្ត។

ទីកន្លែងដែលល្អសម្រាប់ចាក់អ៊ីវែម៉ិចទីនលើមេជ្រូកតាមក្រោមស្បែក



## ២.៣ រុយ

➢ រុយ ធ្វើឲ្យរំខានក្នុងទ្រុងមាន់ ជ្រូក ជាពិសេសក្នុងទ្រុងជ្រូកកើតកូន និងទ្រុងកូនជ្រូកផ្តាច់ដោះ និងលើគោ។ រុយអាចចម្លងជំងឺ ដូចនេះ ចាំបាច់ត្រូវត្រួតពិនិត្យចំនួនរុយឲ្យបានទៀងទាត់។

➢ **ការត្រួតពិនិត្យរុយ:**

- ត្រួតពិនិត្យកូនដង្កូវ: សីតុណ្ហាភាព៣៥អង្សាសេ និងសំណើមខ្ពស់ លាមក កន្លែងនិងសម្ភារៈកខ្វក់ កន្លែងចោលសម្រាម ជញ្ជាំងមានស្នាមប្រេះបែក។ល។ ជាកត្តាល្អបំផុតសម្រាប់ ពងរុយញាស់និងការបន្តពូជ។





ប្រសិនបើកន្លែងខាងលើ ទាំងនោះ ត្រូវបាន សម្អាត នោះវដ្តបន្តពូជរបស់រុយត្រូវ បានកាត់ បន្ថយយ៉ាងច្រើន មានន័យថា**កូនដង្កូវតិច រុយក៏តិចដែរ**។

- ថ្នាំប៊ុយតុក(Butox)ជាថ្នាំសម្លាប់សត្វល្អិតបាញ់លើខ្លួន សត្វ និងនៅក្នុងទ្រុងចិញ្ចឹមសត្វ ។ ថ្នាំនេះមាន ជាតិពុលតិចក្នុងបរិយាកាស និងលើសុខភាពសត្វ។
- ថ្នាំប៊ុយតុក (Butox) ២ម.ល លាយទឹកពី៣-៥លីត្រសម្រាប់ព្យាបាលគោទម្ងន់២៥០គក្រ



➢ ថ្នាំប៊ុយតុក (Butox) ២ម.ល លាយទឹក១លីត្រ សម្រាប់បាញ់លើជញ្ជាំង២០ម៉ែត្រការ៉េ។

➢ របោមជាសត្វល្អិតបឺតឈាម ហើយខាំមានការឈឺចាប់។ របោមមានសកម្មភាពនៅពេលថ្ងៃ របោម២០ទៅ៣០ក្បាល អាចបឺត ឈាមបាន ២០ស្លាបព្រាកាហ្វេរៀងរាល់ ៦ម៉ោង។

➢ ការត្រួតពិនិត្យរុយមិនងាយស្រួលទេ ពីព្រោះរុយទាំងនេះហើរ និងចុះបឺតនៅកន្លែងណាដែលថ្នាំសម្លាប់សត្វល្អិតមិនបានបាញ់សព្វ ដូចជាក្រោមពោះ ឬជើងហើយមានការលំបាកក្នុងការកំណត់ទីតាំង និងបំបាត់ជំរកបន្តពូជរបស់វាក្នុងដីសើម។



ជារឿយៗពោះ និងផ្នែកក្នុងជើងមិនត្រូវបានបាញ់សព្វទេ

## ២.៤ ដង្កែ

ដង្កែច្រើនឃើញលើគោ ក្របី និងជ្រូកដែលចិញ្ចឹមលែង

➢ គោនៅកម្ពុជា មានភាពធន់នឹងដង្កែ ដូចជា គោហ្សេប៊ុយ និងគោក្នុងស្រុក។ដង្កែមានចំនួនតិចតួច ការឆ្លងជំងឺដែលបង្កដោយដង្កែ មិនសូវស្រួចស្រាវទេ។ ប៉ុន្តែបើឃើញមាន ដង្កែ ញីលើសពី៤០-៥០ក្បាលត្រូវធ្វើការ ព្យាបាលជាបន្ទាន់។



ទីតាំងដែលដង្កែគោង ជាទូទៅមានដង្កែតិចតួចគោងលើសត្វមានសុខភាពល្អ

- ការព្យាបាលដង្កែៈ
  - អាចបាញ់ថ្នាំសម្លាប់សត្វល្អិតដូចជាអាស៊ុនតុល (៣ក្រាមលាយទឹក១លីត្រ ឬចាក់អ៊ីវែម៉ិចទីន (១មល/៥០គក្រ ចំពោះគោ និង១មល/៣០គក្រ ចំពោះជ្រូក)។
  - ត្រូវបាញ់ថ្នាំអាស៊ុនតុលក្រោមផ្ទះពេលគោ ក្របី មានដង្កែ ព្រោះកូនដង្កូវរស់ក្នុងស្មៅ និងក្នុង ដី អាចតោងមកមនុស្ស។
- ការត្រួតពិនិត្យតាមបែបជីវសាស្ត្រដែលអាចឃើញមាន់ ចិញ្ចឹមលែង ឬបក្សីផ្សេងទៀតដើរស៊ីដង្កែនៅលើខ្លួនគោក្របី។



## ២.៥ មូស

- មូសជាអ្នកចម្លងជំងឺអុតមាន់។
- ចំពោះជ្រូកប្រសិនបើស្បែកមានអុចៗ ជាច្រើននោះបណ្តាលកមពីមូសខាំប៉ុន្តែបើជ្រូកមានអង្កែស្បែកឡើង គ្រើមកន្ទួល។មូសខាំបង្កឲ្យមានការឆ្លងជំងឺធ្ងន់ធ្ងរលើស្បែកហើយជ្រូកលូតលាស់យឺតអាចលក់ក្នុងតម្លៃថោក។



អង្កែនិងមូសខាំធ្វើឲ្យមានលទ្ធផលជាស្លាកស្នាមដំបៅធ្ងន់ធ្ងលើស្បែក

- មូសមិនចម្លងជំងឺលើគោក្របីទេ។ប៉ុន្តែប្រសិនបើមានមូសច្រើនពេលយប់ធ្វើឲ្យប៉ះពាល់ដល់ការសម្រាកនិងមានភាពស្ពឹកស្រពន់ មិនសកម្មក្នុងពេលថ្ងៃមិនបានស៊ីស្មៅគ្រប់គ្រាន់បណ្តាលឲ្យមានសុខភាពមិនល្អ។



- ការត្រួតពិនិត្យមូសមិនងាយស្រួលទេប៉ុន្តែការកាត់ស្មៅ លុបបំបាត់កន្លែងទឹកដក់ និងទឹកកខ្វក់ចេញអាចកាត់បន្ថយចំនួនមូសបាន។





# គ-អំពីបរាសិតខាងក្នុង

## ១-ឥទ្ធិពលរបស់បរាសិតខាងក្នុង

### ១.១ ស្គមរ៉ាំរ៉ៃ

ឧទាហរណ៍: ជ្រូកមានព្រូនអាស្ការីសពេញវ័យច្រើនបណ្តាលឲ្យកូនជ្រូកស្គម និងមានភាពស៊ាំតិចតួចនៅពេលអាយុបានពីរខែ។ ចំពោះមាន់ចិញ្ចឹមលែងដើររកស៊ីចំណីតាមវាល មានកម្រិតគ្រោះថ្នាក់ខ្ពស់ដោយសារប្រភេទព្រូនមូលផ្សេងៗដែលរស់នៅក្នុងពោះវៀនតូច ឬក្នុងកោះដែលធ្វើឲ្យការលូតលាស់យឺត និងស្ថានភាពដងខ្លួនមិនល្អ។


ជ្រូកមានព្រូនច្រើនបណ្តាលឲ្យស្គម

### ១.២ សត្វមិនចង់ស៊ីចំណី

ព្រូនក្នុងក្រពះ និងពោះវៀនបង្កឲ្យមានការរំខានដល់សរីរាង្គខាងក្នុង ដែលធ្វើឲ្យសត្វមិនចង់ស៊ីចំណី។ឧទាហរណ៍:គោមានបរាសិតក្នុងពោះកន្សែង(ថតទីបួនរបស់ក្រពះគោ) ជាទូទៅបរាសិត មិនស្ថិតក្នុងពោះធំទេ។

ប្រសិបើសត្វគ្រុនក្តៅនិងមិនចង់ស៊ីចំណីត្រូវសង្ស័យលើជំងឺឆ្លង

ប្រសិនបើកំដៅធម្មតា និងមិនចង់ស៊ីចំណី ត្រូវសង្ស័យមានព្រូននៅខាងក្នុង។

### ១.៣ បញ្ហារាក

មានព្រូនក្នុងពោះវៀនបណ្តាលឲ្យរលាកពោះវៀន ធ្វើឲ្យសត្វរាក។

ដង្កូវថ្លើមដែលបង្កដោយ ព្រូនហ្វាស្យូឡា ធ្វើឲ្យថ្លើមខូចខាត ហើយមានឥទ្ធិពលដល់ការរំលាយអាហារ ដូចនេះបញ្ហារាកនឹងចាប់កើតមាន។


គោស្គមដែលមានជើង និងគ្រគាកប្រឡាក់ដោយលាមករាក

### ១.៤ បញ្ហាក្អក

- វដ្តកូនដង្កូវអាស្ការីស ធ្វើចលនាក្នុងខ្លួនសត្វ ហើយទៅដល់សួត បង្កឲ្យរលាកសួតបណ្តាលឲ្យសត្វក្អក
- ព្រូនសួតកើតលើគោបង្កជាជំងឺរលាកទងសួត ដែលមានរោគសញ្ញាដូចគ្នាទៅនឹងពពួកបង្កដោយវីរុសឬបាក់តេរីដែរ
- ព្រូនសួតពេញវ័យរស់ក្នុងទងសួតធ្វើឲ្យសត្វដកដង្ហើមលឿន ក្អក និងហូរសំបោរ។

## ១.៥ បញ្ហារោមបះស្រអាប់

សត្វដែលមានព្រូនក្នុងខ្លួនបង្កឲ្យមានបញ្ហាកង្វះសារធាតុចិញ្ចឹមជាច្រើនប្រភេទនិងមានរោគសញ្ញា កង្វះចំណីអាហារកង្វះវីតាមីន និងសារធាតុរ៉ែ។










## ១.៦ ស្លេកស្លាំង

ព្រូនបង្កជាដំបៅលើក្រពះឬថ្លើម និងបណ្តាលឲ្យចេញឈាម។ព្រូនក្រហមក្នុងក្រពះជ្រូកមានបណ្តោយ១សង់ទីម៉ែត្រ។ ព្រូនរស់ក្នុងក្រពះ និងជញ្ជក់ឈាមធ្វើឲ្យជ្រូកមិនចង់ស៊ីចំណី ចុះស្គមនិងស្លេកស្លាំង។ ចំពោះហ្វាស្យូឡាគោធ្វើឲ្យមានដំបៅថ្លើមនិងចេញឈាមបន្ទាប់មកធ្វើឲ្យសត្វស្លេកស្លាំង។ ពេលសត្វស្លេកស្លាំងបង្កឲ្យមានហើម ជាពិសេសក្រោមថ្គាម។



## ១.៧ ការបាត់បង់ភាពស៊ាំ

ចំពោះគោ ក្របី: ព្រូនក្រពះពណ៌ត្នោត រស់ក្នុងពោះកន្សែង ហៅថាអូស្ទែតាស៊ីយ៉ា គឺជាបរាសិតមួយក្នុងចំណោមបរាសិតជាច្រើនដែលធ្វើឲ្យភាពស៊ាំរបស់គោបាត់បង់(ធ្លាក់ចុះ)។



## ១.៨ ការងាប់

កូនគោ ក្របី អាចចុះខ្សោយ និងងាប់នៅអាយុពី៣ទៅ៤ខែ ដែលបង្កដោយព្រូនតុកសូការ៉ា ។ កូនដង្កូវព្រូនតុកសូការ៉ា ស្ថិតនៅក្នុងមេគោក្របី ហើយឆ្លងទៅកូនគោក្របីតាមរយៈទឹកដោះក្នុងអំឡុងពីរអាទិត្យដំបូងបន្ទាប់ពីកើត។ ព្រូនតុកសូការ៉ាពេញវ័យក្នុងខ្លួនកូនគោក្របី ធ្វើឲ្យកូនគោ ក្របីខ្សោយ ហើយពេលខ្លះធ្វើឲ្យកូនគោ ក្របីងាប់ផងដែរ។




## ១.៩ បង្កជាជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ

➤ ព្រូនសាច់ដុំ (ទ្រីគីនេឡា): ជាព្រូនមូលមានបណ្តោយប្រវែងពី២ទៅ៤មីលីម៉ែត្រ ដែលកើតជាគ្រាប់ចុងអង្កររក្នុងសាច់ដុំជ្រូក រួចឆ្លងទៅមនុស្សតាមរយៈការចម្អិនសាច់ជ្រូកមិនបានឆ្អិនល្អ។
ព្រូនញីរស់ក្នុងពោះវៀន ញាស់ជាកូនដង្កូវជាច្រើនដែលធ្វើចលនាក្នុងពោះវៀនទៅក្នុងឈាម។ កូនដង្កូវខ្លះបង្កើតជាចុងអង្ករក្នុងសាច់ដុំ អាចរស់បានច្រើនឆ្នាំ។ ប៉ុន្តែចុងអង្ករមានឥទ្ធិពលតិចតួចលើជ្រូក។ ដោយឡែកមនុស្សពេលហូមសាច់ជ្រូកមិនបានឆ្អិនល្អហើយមានកុនដង្កូវ។ កូនដង្កូវដែលមានក្នុងសាច់ជ្រូកធ្វើចលនាពីពោះវៀនទៅ សាច់ដុំពិសេសទៅកាន់សន្ទះទ្រូង និងថ្គាម។
រោគសញ្ញាបង្ហាញ០២ ដំណាក់កាល៖







- ដំណាក់កាលទី១ បន្ទាប់ពីលេបចូលកូន ដង្កូវពី ១ថ្ងៃ ទៅ២ថ្ងៃក្នុងពោះពោះវៀន ដំណើរការមិនស្រួលបណ្តាលឲ្យរាគ និងចង់ក្អួត

ដំណាក់កាលទី២ចាប់ផ្តើមប្រហែលពី២ ទៅ ៨អាទិត្យ បន្ទាប់ពីលេបចូល: ឈឺសាច់ដុំ ឈឺសន្លាក់រមាស់ គ្រុនក្តៅ និងរងាត្រជាក់ ។

- តេនញ៉ា ជាព្រូនសំប៉ែតពេញវ័យ រស់នៅក្នុងខ្លួនមនុស្ស និងឆ្កែ។ តេនញ៉ាមានប្រវែង ពី២ទៅ៧ម៉ែត្រ និងអាចរស់បាន២៥ឆ្នាំក្នុងខ្លួនមនុស្ស។ ជារឿយៗ មានតេញ៉ាតែមួយ គត់ក្នុងពោះវៀន។មនុស្សបញ្ចេញពងតេនញ៉ាក្នុងលាមក និងអាចឆ្លងទៅតាមស្មៅ និងតាមទឹក។ ពងតេនញ៉ាអាចរស់បានច្រើនខែក្នុងបរិយាកាស។ ភ្នាក់ងារកណ្តាល សម្រាប់តេនញ៉ាសូលីយ៉ូមគឺសត្វជ្រូក និងភ្នាក់ងារកណ្តាលសម្រាប់តេនញ៉ាសានីណាតាគឺសត្វគោ។នៅក្នុងខ្លួនគោ ជ្រូក ពងតេនញ៉ាញាស់ជាកូនដង្កូវ ហៅថាស៊ីស្ទីសែរកូស៊ីស។ស៊ីស្ទីសែរកូស៊ីសលូតលាស់ ក្នុងសាច់ដុំថ្លើម និងខួរក្បាល។










## តេនញ៉ាឆ្លងទៅមនុស្ស តាមផ្លូវពីរ៖




- ប្រសិនបើមនុស្សហូបសាច់ជ្រូកឬសាច់គោមិនបានចំអិនល្អ កូនដង្កូវចេញពីគ្រាប់ចុងអង្កុរទៅក្នុងពោះវៀន និងរពេញវ័យ។ ព្រូនពេញវ័យផ្ទុំជាបំណែកខ្លីៗមានបណ្តោយប្រវែង១សង់ទីម៉ែត្រ។ ពេលតេនញ៉ាកាន់តែវែងដោយសារវាផ្ទុំឡើងដោយបំណែកប្រហែល១០០០រួមគ្នា។បំណែកនីមួយផ្ទុកពងប្រហែល៥០០០០ ។ មនុស្សដែលឆ្លងតេនញ៉ាអាចបញ្ចេញពី៥ទៅ៦បំណែកក្នុងមួយថ្ងៃ ដែលស្មើនឹងពង៣លាន។មនុស្សកើតជំងឺតេនញ៉ាជារឿយៗវាមិនមានរោគសញ្ញាខ្លាំងក្លាទេ ប៉ុន្តែអាចអស់កម្លាំង និងមានបំណែកពណ៌សក្នុងលាមក។



- ប្រសិនបើពងតេនញ៉ាត្រូវបានលេបចូលដោយសារកង្វះអនាម័យ មិនបានលាងដៃមុនហូបអាហារ ពងតេនញ៉ាញាស់ជាកូនដង្កូវហៅថាស៊ីស្ទីសៃកូស៊ីស។កូនដង្កូវស៊ីស្ទីសៃកូស៊ីសចលនាក្នុងជញ្ជាំងពោះវៀន និងចូលទៅក្នុងចរន្តឈាម ទៅដល់សាច់ដុំ ឬ ជាលិការដ៏ទៃទៀត ដូចជាថ្លើម ឬខួរ ក្បាល រួចក្លាយជាចុងអង្គរដែលមានទំហំពី ០,៥ទៅ២០សង់ទីម៉ែត្រ។ ចុងអង្គអាចរស់ក្នុងជាលិកាបានច្រើនឆ្នាំដោយមិនធ្វើឲ្យមានរោគសញ្ញា ប៉ុន្តែនៅពេលចុងអង្គចាប់ផ្តើមចាស់សំបករបស់វា ចាប់ផ្តើមលេចធ្លាយបណ្តាលឲ្យមានការរលាក។ រោគសញ្ញាជារូមមានការរួញរឹងសាច់ដុំវិលមុខ ឈឺក្បាល និងអាចស្លាប់។




## ២-ការត្រួតពិនិត្យបរាសិតខាងក្នុង

### ២.១ ព្រូនមូល

- ចំពោះជ្រូក: ព្រូនអាស្ការីសពេញវ័យក្នុងពោះវៀន និង អាចរស់បាន១ឆ្នាំ។ ព្រូនអាស្ការីសបញ្ចេញពងលើស៥០០០០រៀងរាល់ថ្ងៃ ហើយធន់ក្នុងបរិយាកាស។ កូនជ្រូកអាចឆ្លងពងព្រូនពីមេជ្រូកដែលជាអ្នកផ្ទុកព្រូនអាស្ការីស តាមរយៈទឹកដោះ ឬតាមស្បែកកន្សោមដោះ ដូចនេះចាំបាច់ត្រូវទម្លាក់ព្រូនឲ្យមេជ្រូក មុនពេលកើតកូន និងលាងសម្អាតមេជ្រូក ពិសេសជុំវិញ រន្ធគូថនិងកន្សោមដោះ ជាមួយសាប៊ូមុនដាក់វាក្នុងទ្រុងកើតកូន។

**ដើម្បីព្យាបាលព្រូនអាស្ការីស និងព្រូនមូលផ្សេងទៀតចំពោះជ្រូក:** ត្រូវចាក់ អ៊ីវែម៉ិចទីន១% (១ម.ល/៣០គ.ក្រ) ឬឡឺវ៉ាមីសុល(levamisole) ៧,៥% (១ម.ល/១០គ.ក្រ) អាចប្រើសម្រាប់ការពារ ឬព្យាបាល។

- មេជ្រូកត្រូវព្យាបាល២អាទិត្យមុនកើតកូន
- កូនជ្រូកត្រូវព្យាបាល១អាទិត្យមុនផ្តាច់ដោះ។

**ចំពោះព្រូនទ្រីគីណេឡា គ្មានការព្យាបាលទេ។** ដូច្នេះត្រូវហូបសាច់ជ្រូកដែលចំអិនបានឆ្អិនល្អ។


កូនក្របីត្រូវទម្លាក់ព្រូនឲ្យវានៅពីរអាទិត្យបន្ទាប់កើត

- ចំពោះកូនគោឬកូនក្របី: ព្រូនតុកសូការ៉ាអាចបណ្តាលឲ្យងាប់ ជាពិសេសកូនក្របី។ ត្រូវធ្វើការការពារឬព្យាបាល ពេលកូនគោឬកូនក្របីមានអាយុ២អាទិត្យ ដោយប្រើពីរ៉ង់តែល (Pyrantel) ឬពីប៉េរ៉ាស៊ីន (Piperazine) ឬឡឺវ៉ាមីសុល។ ការប្រើអ៊ីវែម៉ិចទីនគ្មានប្រសិទ្ធភាពទេ។

ចំពោះព្រូនមូលដ៏ទៃទៀតក្នុងពោះវៀននិងក្នុងសួតគោ ត្រូវព្យាបាលដោយចាក់អ៊ីវែម៉ិចទីន១%(១មល សម្រាប់៥០គក្រទម្ងន់សត្វ ចាក់ក្រោមស្បែក) ឬអាចចាក់ឡឺវ៉ាមីសុល ៧,៥%(១ម.ល ក្នុងទម្ងន់ ១០គ.ក្រ)។

## ២.២ ព្រូនសំប៉ែត

គ្មានការព្យាបាលសម្រាប់ពួកស៊ីស្ទីសែរកូស៊ីស លើជ្រូកនិងលើគោទេ។ ប៉ុន្តែត្រូវធ្វើការការពារនិងព្យាបាល តេនញ៉ានៅលើមនុស្ស។

កូនជ្រូកបឺតពងរបស់អាស្ការីសដែលតោងជាប់នឹងស្បែករបស់កន្សោមដោះ



## ២.៣ ដង្កូវថ្លើម

មានថ្នាំពីរប្រភេទដែលគួរប្រើចំពោះពួកហ្វាស្យូឡា និងព្រូនមូលដ៏ទៃទៀតគឺ៖

- អ៊ីវែម៉ិចទីនដែលរួមជាមួយក្លរ័ស៊ុលឡុង (Clorsulon)។ ប៉ុន្តែ ក្លរ័ស៊ុលឡុងមិនសម្លាប់ ពង របស់ហ្វាស្យូឡាទេ និងត្រូវចាក់ជាប្រចាំ
- អាល់បង់ដាសុល(Albandazole)អាចសម្លាប់ព្រូនមូលនិងហ្វាស្យូឡា ពេញវ័យ និងពង។


ថ្នាំអាល់បែនដាសុលជាថ្នាំដែលមានប្រសិទ្ធភាពសម្រាប់ទម្លាក់ព្រូនគោស៊ីស្មៅតំបន់ទឹក

## ២.៤ ប្រូតូសូអា

ប្រូតូសូអាជាសរីរាង្គដែលមានកោសិកាតែមួយកុកស៊ីដ្យាគឺជា ប្រូតូសូអានិងជាជំងឺបរាសិតក្នុងពោះវៀនរបស់សត្វដែលគេហៅថាជំងឺកុកស៊ីដ្យូស។


កុកស៊ីឌីយ៉ាអាចឃើញតាមរយៈមីក្រូទស្សន៍ចំពោះតែលាមកមាន់ដែលឆ្លងតែប៉ុណ្ណោះ

ជំងឺកុកស៊ីដ្យូសឆ្លងរាលដាលពីសត្វមួយទៅសត្វផ្សេងទៀតតាមរយៈការប៉ះពាល់ជាមួយលាមកដែលមានជំងឺ និងធ្វើឲ្យសត្វរាគមានឈាម។ កុកស៊ីដ្យាជាបរាសិតរស់នៅនិងធំធាត់ក្នុងជញ្ជាំងរបស់កោសិកាពោះវៀននិងបញ្ចេញពង ក្នុងលាមក។ ពងទាំងនេះហៅថា អូអូគីស ដែលមានភាពធន់នឹង បរិយាកាស និងថ្នាំរម្ងាប់មេរោគ។កន្លែងសើមនិងគ្មានពន្លឺព្រះអាទិត្យអាចជាទីកន្លែងស្នាក់របស់អូអូគីសបាន មួយឆ្នាំ ឬលើសជាងនេះ។

➢ ជំងឺកុកស៊ីដ្យូសលើមាន់

**ជំងឺកុកស៊ីដ្យូស** ធ្វើឲ្យមានការប៉ះពាល់ខ្លាំងលើក្រុមបក្សីក្មេង អាយុប្រហែល៣ អាទិត្យ។ពេលកូនមាន់ មានជំងឺកុកស៊ីដ្យូស យើងអាចសង្កេតឃើញ មាន់ខ្លះមិនក្លៀវក្លា រោមបះ ស្រេកទឹក រាគមានឈាម។ បើគ្មានការព្យាបាលជាបន្ទាន់មាន់នឹងងាប់។

ការការពារ:

- ត្រូវធ្វើអនាម័យឲ្យបានល្អ កម្រាលទ្រុងត្រូវស្ងួត ស្នូកទឹកនិងស្នូកចំណីស្អាតជាប្រចាំ និងផ្តល់ចំណី ទឹកឲ្យមានអនាម័យមិនប្រឡាក់ប្រឡូសលាមក។


អស់កម្លាំង ក្បាលគងលើទ្រូង ធ្លាក់ស្លាប


លាមកមានឈាម


ខ្នែងពោះវៀនមានឈាមពេញ


ទិដ្ឋភាពធម្មតារបស់ខ្នែងពោះវៀន

- លាយថ្នាំស៊ុលហ្វា៣៣ (Sulfa33)ក្នុងទឹកឲ្យសត្វផឹក ពេលពេលមាន់មានអាយុពីរអាទិត្យឬប្រើអំប្រូលីយ៉ូម (Amprolium) តុលត្រាស៊ុលរីល (Toltrazuril) រយៈពេល៣ថ្ងៃ។ចំណីផ្សំស្រេចសម្រាប់មាន់រហូតដល់អាយុ៣អាទិត្យជារឿយៗមានថ្នាំដើម្បីការពារជំងឺកុកស៊ីដ្យូស នៅលើសំបកបាវបញ្ជាក់លើស្លាកសញ្ញា "មានផ្ទុកសារធាតុសាលីណូមីស៊ីន (Salinomycin)ឬម៉ូនេស៊ីន(Monensin) ឬឡាសាឡូស៊ីត (Lasalocid)" សារធាតុគីមីទាំងបីនេះ ត្រូវបានប្រើដើម្បីការពារជំងឺកុកស៊ីដ្យូស។ ការព្យាបាល ត្រូវប្រើថ្នាំដូចគ្នាខាងលើ ប្រើរយៈពេល៥ថ្ងៃ។

➢ ជំងឺកុកស៊ីដ្យូសលើជ្រូក

ជំងឺកុកស៊ីដ្យូសឆ្លងរាលដាលលើកូនជ្រូកអាយុពី១ទៅ៣អាទិត្យ។ បណ្តាលឲ្យរាគប្រែពណ៌ ពីលឿងទៅជាប្រផេះ គ្មានលាយឈាម ។ ជាទូទៅកូនជ្រូកមិនងាប់ទេ ប៉ុន្តែវាចុះស្គម និងរោមបះ។


រាគពណ៌ប្រផេះខាប់តាមប្រភេទ

ការព្យាបាល: អាចប្រើថ្នាំស៊ុលហ្វាឌីមីឌីន (Sulfadimidine)ឬស៊ុលហ្វា៣៣ (Sulfa33)ឬ សិបតូទ្រីល (Septotryl))ដើម្បីជួយឲ្យ បានធូរស្រាល។

ការការពារ:ដើម្បីការពារការខាតបង់ក្នុងពេលកូនជ្រូកផ្តាច់ដោះ ដូចនេះត្រូវប្រើថ្នាំតុលត្រាស៊ុលរីល (បេកុក (Baycoc)អង់ទីកុក (Anticoc) )មួយដងពេលកូនជ្រូកមានអាយុ៣ថ្ងៃ។


ជំងឺកុកស៊ីដ្យូសត្រូវបង្ការនៅអាយុ៣ថ្ងៃជាមួយតុលត្រាស៊ីរីល (Toltrazuril)

- ធ្វើអនាម័យក្នុងទ្រុង លាងសម្អាតទ្រុង ប្រមូលលាមក កម្ទេចកម្ទីចំណីលើកម្រាល...) ផ្ទៃទ្រុងស្ងួត កម្ចាត់រុយ ប្រើសម្ភារៈដែលប្រើហើយត្រូវមានអនាម័យ លាងសម្អាត និងសម្ងួត ដោយពន្លឺព្រះអាទិត្យ។ត្រូវចងចាំថា ពងអូអូគីទមាន ភាពធន់នឹងថ្នាំរម្ងាប់មេរោគ។

➢ ជំងឺកុកស៊ីដ្យូសលើគោ



ជំងឺកុកស៊ីដ្យូសបង្កជាជំងឺពោះវៀនលើកូនគោក្របី អាយុ ពី៣អាទិត្យទៅ៦ខែ ប៉ុន្តែជំងឺនេះអាចកើត លើគោ អាយុលើសពី២ឆ្នាំ។

- រោគសញ្ញា
  រាគធ្វើឲ្យសត្វស្គមរាំរ៉ៃ។ ក្នុងករណីធ្ងន់ធ្ងរ លាមកមាន ឈាម និងសំបោរ ហើយកន្ទុយ និងជុំវិញគូថប្រឡាក់ ជាប់លាមកពណ៌ខ្មៅ។
- ការព្យាបាល
  អាចប្រើថ្នាំស៊ុលហ្វាឌីមីឌីន (ស៊ុលហ្វា៣៣) ចាក់ ឬច្រកតាមមាត់ ឬប្រើថ្នាំអំប្រូលីយ៉ូម១០មក្រ/គក្រ/ថ្ងៃ) រយៈពេល៥ថ្ងៃ។
  ការការពារៈអាចប្រើថ្នាំអំប្រូលីយ៉ូម(៥មក្រ/គក្រ/ថ្ងៃ) រយៈពេល២១ថ្ងៃ។

## ២.៥ បរាសិតក្នុងឈាមលើគោ

បរាសិតក្នុងឈាម បង្កជាជំងឺសំខាន់បីគឺៈ ទ្រីប៉ាណូសូម៉ា បាបេស្យា និងអាណាប្លាស្មា។










ការធ្វើរោគវិនិច្ឆ័យមានភាពងាយស្រួលបន្ទាប់ពីការដាក់ពណ៌លើដំណក់ឈាមនិងពិនិត្យដោយមីក្រូទស្សន៍។

➢ ជំងឺទ្រីប៉ាណូសូម

- គោ ក្របីក្នុងស្រុក មានការវិវត្តជំងឺជាទម្រង់ពាក់កណ្តាលស្រួចស្រាវ ឬរាំរ៉ៃ ដោយសារការ ប្រើប្រាស់ជាកម្លាំងអូសទាញហួសកម្លាំងដោយសារការខ្វះខាតចំណីអាហារ។

- ចំពោះពូជកូនកាត់ ជំងឺទ្រីប៉ាណូសូមអាចកើតឡើងក្នុងទម្រង់ស្រួចស្រាវ និង បង្ករឲ្យងាប់។ ចំពោះសេះងាយទទួលរងជំងឺនេះជាងគោ ក្របី។

ជំងឺទ្រីប៉ាណូសូម ឆ្លងតាមរុយដែលបឺតឈាមដូចជារុយសេះ (អាបោម) ។

រោគសញ្ញា គឺ៖




- គ្រុនក្តៅឡើងចុះក្នុងចន្លោះ (៤០ អង្សាសេ)
- ចុះខ្សោយនិងស្គមខ្លាំង
- ស្លេកស្លាំង និងហើមផ្នែកខាងក្រោមដងខ្លួន
- រាគមិនឈប់មិនអាចព្យាបាលបាន
- ហើមភ្នែកនិងមានហូរទឹកភ្នែក
- រលូតកូន
- មានរោគសញ្ញាប្រសាទ ញ័រញាក់។

ជំងឺទ្រីបាណូសូម៉ាជារឿយៗសម្លាប់សេះក្នុងប្រទេសកម្ពុជានិងមានរោគសញ្ញាជាក់លាក់ដូចជា៖




ការព្យាបាល

- ទ្រីប៉ាមីឌីយ៉ូម (Trypamidium):ប្រើក្នុងកម្រិត១មក្រ/គក្រទម្ងន់សត្វ ចាក់តែម្តង ចាក់សាច់ដុំ ឬតាមសរសៃវ៉ែន
- បេរីនីល (Berenil): ប្រើក្នុងកម្រិត៣,៥មក្រ/គក្រទម្ងន់សត្វ ចាក់ពីរដង ពី៧ទៅ ៨ថ្ងៃ

➢ ជំងឺបាបេស្យា

ជំងឺបាបេស្យាកើតលើគោ ក្របី ។ ជំងឺនេះបង្កដោយចៃលើគោ និងក្របី បង្កដោយបរាសិតប្រូតូសូអាមួយប្រភេទហៅថាបាបេស្យា។រោគសញ្ញាខាងក្រៅប្រែប្រួល

តាមអាយុប្រភេទសត្វ និងប្រភេទរបស់បរាសិត (ក្នុងប្រទេសកម្ពុជា យើងឃើញមានបាបេស្យាពីរប្រភេទ មួយហៅថាប៊ីសេមីណា (Bigemina) និងមួយទៀតហៅថាបូវីស (Bovis) ករណីភាគច្រើនរបស់ជំងឺបាបេស្យា ច្រើនឃើញចំពោះគោពេញវ័យ ចំពោះសត្វអាយុក្មេងជាង៩ខែមិនសូវមានចេញរោគសញ្ញា។

រោគសញ្ញាដែលសង្កេតឃើញគឺ៖

- គ្រុនក្តៅខ្លាំងដែលមានសីតុណ្ហភាពរហូតដល់៤១,៥អង្សាសេក្នុងពេលច្រើនថ្ងៃ
- មិនស៊ីចំណី
- ពោះធំឈប់កន្ត្រាក់
- សត្វមិនចង់ធ្វើចលនា។







- ពេលចាប់ផ្តើមឈឺ ជាលិកាភ្នែកឡើងក្រហម រួចក្លាយជាស្លេក នៅប៉ុន្មានថ្ងៃបន្ទាប់មកទៀតឡើងពណ៌លឿង ។
- ទឹកនោមឡើងក្រហមចាស់ទៅជាត្នោត និងមានពពុះរហូត
- សញ្ញាប្រសាទ ដូចជានៅមិននឹងពេលធ្វើចលនា និងសង្កៀតធ្មេញ។

ការព្យាបាល

ចាក់បេរីនីល (Berenil®) កម្រិត៣,៥មក្រ/គក្រទម្ងន់សត្វ ចាក់ជ្រៅក្នុងសាច់ដុំ

➢ ជំងឺអាណាប្លាស្មា

ចំពោះសត្វទំពារអៀងជំងឺអាណាប្លាស្មារាតត្បាតក្នុងឈាមនិងបំបែកខ្លួនក្នុងកោសិកាឈាមក្រហម។ ដង្កែជាភ្នាក់ងារអាចម្លងជំងឺអាណាប្លាស្មាបាន។

រោគសញ្ញា:

មិនសូវស្រួចស្រាវ ឃើញកើតចំពោះគោចាស់អាយុលើសពី៩ខែដូចជា:

- គ្រុនក្តៅ
- ការស្លេកស្លាំងកើនជាលំដាប់
- កើតលឿង (ឡើងលឿង)
- ត្រចៀកធ្លាក់។

ចំពោះគោទឹកដោះនាំចូលអាចបង្ហាញទម្រង់ស្រួចស្រាវតែក្នុងពេលប៉ុន្មានម៉ោងប៉ុណ្ណោះ។ គោហេប្រ៊ុយមានភាពធន់នឹងជំងឺអាណាប្លាស្មានេះ។

កាព្យាបាល៖

- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិក គ្រួសារតេត្រាស៊ីគ្លីន។

ការចាក់ថ្នាំអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ដែលមានសកម្មភាពវែង ក្នុងកម្រិត២០ម.ក្រ/គក្រ។ ចាក់តាមសរសៃវ៉ែន ចាក់តែម្តងគត់។






# ជំពូកទី១០៖ ជំងឺបក្សី






# ក. ជំងឺមានរោគសញ្ញាផ្លូវដង្ហើម

ជំងឺផ្លូវដង្ហើមមានរោគសញ្ញា រួមមានៈ ហូរទឹកភ្នែក ទឹកសំបោរ ហើមឆ្អឹងរុន្ធច្រមុះ កណ្តាស់ បែកពពុះ ឬឮសូរសម្លេងក្រឹតក្រក និងពិបាកដកដង្ហើម។

## ១. ជំងឺដង្កោ(ញូវកាស)

ជំងឺដង្កោបង្កដោយវីរុស។ វីរុសដែលបង្កជំងឺនេះមានប្រភេទវីរុសផ្សេងៗគ្នា អាស្រ័យតាមប្រភេទវីរុសនិមួយៗ។

### ១.១ រោគសញ្ញា

នៅកម្ពុជាជំងឺដង្កោមានសណ្ឋានស្រួចស្រាវ កើត មាននៅគ្រប់ទីកន្លែង។ រោគសញ្ញាជំងឺដង្កោ អាចផ្លាស់ប្តូរពីអត្រាងាប់ខ្ពស់ទៅ ងាប់មធ្យម គឺចាប់ងាប់ពី ១ថ្ងៃទៅ៣ថ្ងៃបន្ទាប់ពីឈឺ។



មានបក្សីងាប់លឿនជារៀយៗ គឺរោគសញ្ញាតែមួយរបស់ជំងឺញូវកាសនៅពេលដែលជំងឺចាប់ផ្តើម។




ភគមានទឹកពណ៌ខៀវចាស់



- **កម្រិតវីរុសឆ្លងរាលដាលខ្លាំងៈ** អត្រាងាប់ខ្ពស់ រាលដាលលឿនក្នុងហ្វូង ពេលខ្លះមាន រោមបះ មិនស៊ីចំណី ខ្សោយ និង រាគពណ៌បៃតងចាស់។
- **កម្រិតវីរុសឆ្លងរាលដាលខ្សោយៈ** មាន់ងាប់តិចតួច ឆ្លងរាលដាលយឺត មានសញ្ញាផ្លូវដង្ហើម ដូចជា ដកដង្ហើមញាប់ ក្អក និង កណ្តាស់។
- រោគសញ្ញាប្រព័ន្ធប្រសាទដូចជា រមួលក ប៉ុន្តែ ជាទូទៅបញ្ហារមួលក ច្រើនកើតក្រោយរោគសញ្ញាផ្លូវដង្ហើម។
- ការផលិតស៊ុតថយចុះខ្លាំង។

## ១.២ ការឆ្លងជំងឺ

- វីរុសអាចរស់បានក្នុងបរិយាកាស ជាពិសេសក្នុងលាមក។
- រយៈពេលសម្ងំជំងឺជាមធ្យមពី ៥ទៅ៦ថ្ងៃ
- **ការឆ្លងដោយផ្ទាល់:** ឆ្លងពីសត្វមួយ ទៅសត្វមួយទៀត តាមលាមក និងទឹកសំបោររបស់សត្វមានជំងឺ។
- **ការឆ្លងមិនផ្ទាល់:** ឆ្លងតាមរយៈម្ចាស់សត្វ មនុស្សមកពីក្រៅ តាមស្បែកជើង សម្លៀកបំពាក់ ឬឧបករណ៍សម្ភារៈប្រើប្រាស់ យកមកពីផ្សារ ពីកន្លែង ឬកសិដ្ឋានផ្សេង ដែលមានជំងឺ។


គ្រោះថ្នាក់ទី១៖ ទិញមាន់ដែលមានការសម្ងំជំងឺញូវកាស
គ្រោះថ្នាក់ទី២៖ នាំវីរុសរបស់ជំងឺញូវកាសតាមស្បែកជើង ដែលជាប់ប្រឡាក់នៅតាមផ្សារ។

## ១.៣ ស្លាកស្នាមពេលវះកាត់

- មានស្លាកស្នាមដូចគ្នានឹងជំងឺផ្តាសាយបក្សី
- ស្លាកស្នាមសំខាន់ៗ ក្នុងករណីមាន**កម្រិតវីរុសឆ្លងរាលដាលខ្លាំង:** ដូចជា មានចេញឈាមនៅលើទងកោះ ក្នុងពោះវៀន និងបំពង់ខ្យល់ ហើមក្បាល និងហើមក។




## ១.៤ ការព្យាបាល

- មិនមានការព្យាបាលនោះទេ។
- ក្នុងករណីកម្រិតវីរុសឆ្លងរាលដាលខ្សោយ តែលេចចេញរោគសញ្ញាស្រួចស្រាវ អាចបណ្តាលមកពីការជ្រៀតចូលជំងឺបង្កដោយបាក់តេរី ដូចជាមីកូប្លាស្មា (Mycoplasma) អ៊ីកូលី (E.Coli) ហើយការព្យាបាលត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាថ្នាំដុកស៊ីស៊ីគ្លីន (Doxycycline) ។



## ១.៥ ការការពារ




➤ ចំពោះហ្វូងសត្វមានចំនួនតិចតួច ការប្រើប្រាស់វ៉ាក់សាំងអាយធូ (I2) មានភាពសមស្រប ព្រោះវ៉ាក់សាំងនេះមិនត្រូវការប្រព័ន្ធត្រជាក់ខ្លាំងក្លានោះទេ អាចដឹកជញ្ជូននិងរក្សាទុកនៅសីតុណ្ហភាពធម្មតា។

➤ ការធ្វើវ៉ាក់សាំងអាចកាត់បន្ថយសញ្ញាគ្លីនិក ប៉ុន្តែមិនអាចទប់ស្កាត់ការបំបែកខ្លួនរបស់វីរុស និងបញ្ចេញមកក្រៅបានទេ។

➤ ការចាក់វ៉ាក់សាំងមាន់នៅអាយុ៧ថ្ងៃ និង ២៨ថ្ងៃ អាចការពារជំងឺរហូតដល់ពេលលក់។

## ២. ជំងឺរលាកទងសួត

ជំងឺរលាកទងសួត បង្កឡើងដោយវីរុស

➤ ជំងឺនេះឆ្លងរាលដាលខ្លាំងបំផុត និងឆ្លងតែចំពោះមាន់

➤ ជំងឺនេះឆ្លងតាមខ្យល់ ឆ្លងតាមរយៈមនុស្ស តាមចំណី ទឹក បក្សីមានជំងឺ បក្សីងាប់ដោយជំងឺ និងសត្វកកេរ....។

➤ មានអត្រាងាប់ខ្ពស់រហូតដល់១០០% ប៉ុន្តែអាចមានអត្រាងាប់ទាបកម្រិតតិចជាង១០%។

➤ ជារឿយៗជំងឺនេះមានភាពស្មុគស្មាញ ដោយមានការឆ្លងជំងឺឱកាសនិយម ដូចជាមីកូប្លាស្មា និងអ៊ីកូលី។

## ២.១ រោគសញ្ញា




➤ ដកដង្ហើមខុសប្រក្រតី

➤ ដង្ហក់ ក្អក និងដកដង្ហើមឮសូរគ្រឹតគ្រត

➤ ចំពោះកូនមាន់មានសភាពធ្ងន់ធ្ងរជាង មាន់ធំគឺៈ មានហើមភ្នែក ហៀរសំបោរ និងមាន ស្លេះក្នុងបំពង់ខ្យល់ និងអាចស្ទះខ្យល់។

- ការផលិតស៊ុតធ្លាក់ចុះរហូតដល់៥០%
- ស៊ុតខូចរូបរាង ឬមានសំបកទន់ស៊ុតមានផ្ទុកទឹកខាងក្នុង។







## ២.២ ការព្យាបាល

មិនមានការព្យាបាលជាក់លាក់ទេ ប៉ុន្តែអាចប្រើថ្នាំអង់ទីប៊ីយ៉ូទិកពី ៥ទៅ៧ថ្ងៃដើម្បីជួយទប់ ស្កាត់ការឆ្លងជំងឺឱកាសនិយម ដែលបង្កដោយបាក់តេរី។

## ២.៣ ការការពារ

ជារឿយៗវ៉ាក់សាំងជំងឺរលាកទងសួតត្រូវបានដាក់បញ្ចូលក្នុងវាក់សាំងជំងឺដង្កោ។ ការការពារដែលល្អប្រសើរ ត្រូវមានកម្មវិធីចាក់វាក់សាំងជាក់លាក់ ជាទូទៅបានអនុវត្តតែក្នុងកសិដ្ឋានប៉ុណ្ណោះ។

## ៣. ជំងឺផ្តាសាយបក្សី

ជំងឺផ្តាសាយបក្សី បង្កដោយវីរុស។ជាទូទៅជំងឺផ្តាសាយបក្សីដែលផ្ទុះឡើងនាពេលបច្ចុប្បន្ន មានកម្រិតគ្រោះថ្នាក់ខ្ពស់ ជាប្រភេទ ហាស៥អិន១ (H5N1)។

ការសង្ស័យជា ជំងឺផ្តាសាយបក្សី នៅពេលមានអត្រាបក្សីងាប់ខ្ពស់ និងងាប់ស្រួចស្រាវ (ងាប់លឿន)។ ពេលបក្សីងាប់លឿន រោគសញ្ញាឬស្លាកស្នាមមិនអាចកើតមាន។ មិនត្រូវធ្វើការវះកាត់ដាច់ខាត តែត្រូវហៅបសុពេទ្យស្រុក ឬទូរស័ព្ទទាន់ហេតុការណ៍ ដែលមានលេខ (**០១២៨៣៣៧៩៥ ឬ ០១២២១៤៩៧០**) ដើម្បីយកសាកសពបក្សីធ្វើការវិភាគ។


ក្នុងករណីអត្រាងាប់ស្រួចស្រាវនិងច្រើន ត្រូវសង្ស័យជំងឺផ្តាសាយបក្សី


បក្សីដែលងាប់ធ្លាក់ចុះពីដើមឈើ កើតមាន ចំពោះជំងឺផ្តាសាយបក្សី

## ៣.១ រោគសញ្ញា

រោគសញ្ញាអាចផ្លាស់ប្តូរពីកម្រិតឆ្លងរាលដាលស្រាល មានអត្រាងាប់តិច ឬគ្មានងាប់ទៅជាអត្រាងាប់ខ្ពស់ និងឆ្លងរាលដាលលឿន។

បក្សីទឹកដូចជា ទាព្រៃ ជាទូទៅមានភាពធន់នឹង ជំងឺផ្តាសាយបក្សីជាងបក្សីស្រុក។ វីរុសជំងឺ ផ្តាសាយបក្សីមិនធ្វើឲ្យមានជំងឺធ្ងន់ធ្ងរលើបក្សីទឹកទេ តែវាអាចជាភ្នាក់ងារចម្លងជំងឺខ្លាំង លើបក្សី ស្រុក។ បក្សីទឹកដើរតួជាអ្នកផ្ទុកវីរុស ក្នុងពោះវៀននិងបញ្ចេញវីរុសតាមលាមកមកក្រៅ។

**រោគសញ្ញាក្នុងទម្រង់ជំងឺស្រួចស្រាវ៖** បក្សីឈប់ស៊ីចំណី ស្ថិតនៅម្ខាងដាក់ក្បាលលើខ្នង និងរោមបះ ហើយងាប់នៅប៉ុន្មានម៉ោងក្រោយមក។
















**រោគសញ្ញាក្នុងទម្រង់ជំងឺមិនសូវស្រួចស្រាវ ៖**

- ពិបាកដកដង្ហើម
- ខ្វិនជើង និងញ័រក្បាល
- សិរ និងឈាង់ឡើងហើម មានពណ៌ស្វាយ
- ចេញឈាមក្រោមស្បែកនិងជើង ។










### រោគសញ្ញាលើទា ៖

- មានសភាពងងុយដេក ក្បាលសំយុងចុះប៉ះដី
- ភ្នែកឡើងស
- ត្របកភ្នែកហើម
- រាគពិណាស










ជំងឺផ្ដាសាយបក្សីមិនមានការព្យាបាលនោះទេ។

## ៣.២ វិធានការការពារ

ត្រូវអនុវត្តវិធានជីវសុវត្ថិភាព:

- ក្រុងបក្សីដែលទិញពីផ្សារ ឬនាំមកថ្មីឲ្យនៅដាច់ដោយឡែកមុនពេលដាក់ចូលក្នុងហ្វូង។


ទ្រុងបង្ខាំងត្រូវបំបែកចេញពីមាន់ជំទៃក្នុង ទីកន្លែងស្អាតនិងស្ងួត

- បក្សីទឹក ដូចជាទា អាចជាអ្នកផ្ទុក ជំងឺយ៉ាងស្ងៀមស្ងាត់ វាមិនឈឺ ប៉ុន្តែវាបញ្ចេញ វីរុសមកក្រៅ ឆ្លងទៅបក្សីក្នុងភូមិ និងបណ្ដាលឲ្យផ្ទុះជំងឺ។
- ចិញ្ចឹមបក្សីដាក់ទ្រុង ប្រើសំណាញ់ព័ន្ធជុំវិញដើម្បីចៀសវាង ការប៉ះពាល់ជាមួយបក្សីព្រៃ។


បក្សីត្រូវដាក់ក្នុងទ្រុងការពារដោយសំណាញ់ចេញពីបក្សីព្រៃ

➢ វីរុសឆ្លងតាមរយៈស្បែកជើង សម្លៀកបំពាក់ និងដៃ...។ ដូចនេះត្រូវលាងដៃ និងសម្អាតស្បែកជើងជាមួយសាប៊ូ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ ក្នុងការចម្លងមេរោគ។

ហានិភ័យទី១៖ តើទាទាំងនេះអត់មានជំងឺផ្តាសាយបក្សីមែនទេ? ទាអាចបញ្ចេញវីរុសហើយមើលទៅមានសុខភាពល្អ



ហានិភ័យទី២៖ អតិថិជនអាចយកនិងនាំវីរុសតាមដៃនិងស្បែកជើង

## ៤. ជំងឺអាសន្នរោគបក្សី

ជំងឺអាសន្នរោគបក្សី ជាជំងឺបង្កដោយបាក់តេរីប៉ាស្ទឺរ៉ែឡា។ ជំងឺនេះ អាចចាត់ចូលក្នុងប្រភេទជំងឺផ្លូវដង្ហើមផងដែរ ព្រោះរោគសញ្ញារបស់វា មានទាំងផ្លូវដង្ហើម និងផ្លូវរំលាយអាហារ។ ជំងឺអាសន្នរោគបក្សី ជាជំងឺឆ្លងស្រួចស្រាវ មានអត្រាឈឺ និងងាប់ខ្ពស់ជាពិសេសលើទា។ ប៉ុន្តែ សណ្ឋានរ៉ាំរ៉ៃច្រើនកើតមានជារឿយៗ ។

សិរ និងណាង់ក្លាយជាពណ៌ខៀវ ស្វាយ





### ៤.១ រោគសញ្ញា

- បក្សីងាប់លឿន និងស្រួចស្រាវ អាចជាសញ្ញាដំបូងនៃជំងឺនេះ។
- សិរ និងណាង់ឡើងពណ៌ស្វាយ មុនពេលងាប់។
- ដំបូងរាគមានទឹក និងពណ៌ស ហើយក្លាយជាពណ៌បៃតងលាយជាមួយសំបោរ។
- ជំងឺអាសន្នរោគមាន់ក្លាយជាជំងឺរ៉ាំរ៉ៃ មាន់មានដំបៅលើសិរ ហើមសន្លាក់ និងហើមបាតជើង។
- ជាតិខ្ទុះជ្រាបចេញ អាចមាននៅក្នុងឆ្អឹងច្រមុះជុំវិញភ្នែក។




### ៤.២ ស្លាកស្នាម

- មានជាំឈាមអុចៗលើបេះដូង លើផាលលើពោះវៀន និងខ្លាញ់ពោះ
- រលាកពោះវៀន និងសួត
- ថ្លើមមានចំណុចដំបៅរលួយពណ៌លឿង។







## ៤.៣ ការព្យាបាល

ប្រើថ្នាំអង់ទីប៊ីយ៉ូទិកដែលមានប្រសិទ្ធភាពដូចជាថ្នាំ ទ្រីមេតូព្រីមស៊ុលហ្វា (TMP+ Sulfa) និងត្រូសារតេត្រាស៊ីគ្លីន (Tetracycline)។ ត្រូវការព្យាបាលលើសពីពអាទិត្យ ព្រោះ មេរោគ ប៉ាស្ទីរ៉ែឡា (Pasteurella)អាចរស់នៅ បានយូរក្នុងកន្លែងសើម គ្មានពន្លឺព្រះអាទិត្យ និងកន្លែងមានកាកសំណល់កខ្វក់។

## ៥. ជំងឺរលាកបំពង់សម្លេង និងបំពង់ខ្យល់ (ILT)

ជំងឺរលាកបំពង់សម្លេង និងបំពង់ខ្យល់បង្កដោយវីរុស និងឆាយផ្លាស់ទីតាមខ្យល់។

### ៥.១ រោគសញ្ញា

- ហៀរទឹកភ្នែក
- នៅស្ងៀមស្ងាត់
- ពិបាកដកដង្ហើម ដកក និងក្បាល ដើម្បីសម្រួលដល់ការដកដង្ហើម។
- ក្អក កណ្តាស
- គ្រវីក្បាល ដើម្បីបញ្ចេញសំណល់ក្នុងបំពង់ខ្យល់ ។
- មានឈាមជ្រាបចេញពីបំពង់ខ្យល់។
- បក្សីងាប់ច្រើនដោយការស្ទះខ្យល់ ។







### ៥.២ ការព្យាបាល

- ប្រើថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីការពារការឆ្លងជំងឺឱកាសនិយមដែលបង្កដោយបាក់តេរី។
- ត្រូវចាក់វ៉ាក់សាំងលើហ្វូងសត្វពេលមានផ្ទុះជំងឺ។ជាធម្មតាត្រូវចាក់វ៉ាក់សាំងដើម្បីការពារជំងឺ ប៉ុន្តែក្នុងករណីជំងឺរលាកបំពង់សម្លេង និងបំពង់ខ្យល់ អាចប្រើដើម្បីព្យាបាលផងដែរ។

## ៦. ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ / មីកូប្លាស្មា(Mycoplasma)

ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ បង្កដោយបាក់តេរី ។ មេរោគអាចឆ្លងរាលដាលយ៉ាងលឿន ពីមាន់មួយទៅមាន់មួយទៀត។

មធ្យោបាយឆ្លងរាលដាល ជាទូទៅគឺតាមអូវ៉ែ។ មេរោគឆ្លងចូលក្នុងស៊ុតក្នុងបំពង់បន្តពូជរបស់មេមាន់ (អូវ៉ែ) ដូចនេះ កូនមាន់ទើបញាស់អាចមានមេរោគឆ្លងចូល។




### ៦.១ រោគសញ្ញា

- រោគសញ្ញាជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ បង្កដោយបាក់តេរី មីកូប្លាស្មា ប្រែប្រួលពីការសើម ជុំវិញភ្នែកទៅហើមជុំវិញភ្នែក។
- ដកដង្ហើមតាមមាត់ និងមានសម្លេងចេញពីបំពង់ក។
- មីកូប្លាស្មាជាមូលហេតុចម្បងបង្កជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃលើមាន់។ ពីព្រោះមេរោគមីកូប្លាស្មា បំផ្លាញបំពង់ដកដង្ហើម និងបង្កឲ្យមានការឆ្លងមេរោគផ្សេងទៀត ដូចជាអ៊ីកូលី កូរីសា ឬរលាកសួត។







### ៦.២ ស្លាកស្នាម

- ថង់ខ្យល់តូចៗស្រអាប់
- ក្នុងដំណាក់កាលស្រាល ឃើញសំបោរទៅជាសភាពដូចខ្លាញ់។ ក្នុងករណីធ្ងន់ធ្ងរ មានសភាពដូចខ្ទុះ។




### ៦.៣ ការព្យាបាល

- ប្រើថ្នាំអង់ទីប៊ីយ៉ូទិក មានប្រសិទ្ធភាពប្រឆាំងនឹងមីកូប្លាស្មាដូចជា ដុកស៊ីស៊ីគ្លីន (Doxycycline) ឬ ទីឡូស៊ីន (Tylosin) ។

ជារឿយៗថ្នាំដុកស៊ីស៊ីគ្លីន (Doxycycline) រួមជាមួយថ្នាំកូលីស្ទីន (Colistin) ប្រើសម្រាប់ព្យាបាលជំងឺឱកាសនិយមបង្កដោយអ៊ីកូលី។

- ថ្នាំទីឡូស៊ីនប្រើសម្រាប់កូនមាន់អាយុមួយថ្ងៃ។ ថ្ងៃយកកូនមាន់មកដល់ត្រូវលាយទីឡូស៊ីនក្នុងទឹកឲ្យវាផឹក ដើម្បីកំចាត់ពួកមីកូប្លាស្មាដែលអាចឆ្លងពីមេមាន់ និងដើម្បីការពារការឆ្លង រាលដាលពពួកមីកូប្លាស្មាក្នុងកសិដ្ឋាន។ ប្រើរយៈពេល៥ថ្ងៃ ។

## ៧. ជំងឺអុតបក្សី

ជំងឺអុតបក្សីជាជំងឺបង្កដោយវីរុស ដែលមានការឆ្លងរាលដាលយឺត តែបន្តឆ្លងមានរយៈពេលពី ៣ ទៅ ៥អាទិត្យ ឬច្រើនខែ។ ជំងឺអុតបក្សីឆ្លងតាមរយៈការប៉ះពាល់បក្សីឈឺ ឬមូសខាំ។








### ៧.១ រោគសញ្ញា

- ជំងឺអុតទម្រង់ស្ងួត ចាប់ផ្តើមពីចំណុចតូចៗពណ៌ស ហើយវិវត្តជាដុំពក ដូចឫស។ ស្លាកស្នាមជាទូទៅ ឃើញលើកន្លែងមិនសូវមានរោម ដូចជា លើសិរ ណាង ត្រចៀក ភ្នែកនិងពេលខ្លះ លើជើង។
- ជំងឺអុតទម្រង់សើម មានក្នុងមាត់ និងប្រដាប់ដកដង្ហើមផ្នែកខាងលើ ជាពិសេសបំពង់ខ្យល់ និងដើមក។
- សត្វអស់កម្លាំង ស៊ីចំណីតិច
- ធំលូតលាស់យឺត
- ការផលិតស៊ុតធ្លាក់ចុះ
- កូនមាន់មានអត្រាងាប់ខ្ពស់។

### ៧.២ ការព្យាបាល ជំងឺអុតមាន់មិនមានការព្យាបាលទេ។

### ៧.៣ ការការពារ

ការចាក់វ៉ាក់សាំងតាមវិធីជួសស្លាប កូនមាន់ត្រូវចាក់តាំងពីនៅតូច អាយុមួយថ្ងៃ។ បក្សីដែល បានចាក់វ៉ាក់សាំងរួច គួរធ្វើការពិនិត្យនៅប្រមាណជា ៧ទៅ១០ថ្ងៃ បន្ទាប់ពីការចាក់។ ប្រសិនបើមានស្នាមហើមលើស្បែក ឬក្រមរនៅទីកន្លែងដែលបានចាក់ នោះជាសញ្ញាជោគជ័យ នៃការចាក់វ៉ាក់សាំង។

## ៨. ជំងឺផ្តាសាយ (ជំងឺកូរីសា)

ជំងឺផ្តាសាយ (ជំងឺកូរីសា) បង្កដោយបាក់តេរី។ ជំងឺផ្តាសាយ (ជំងឺកូរីសា) កើតតែលើមាន់ប៉ុណ្ណោះ និងឆ្លងពីបក្សី ទៅបក្សី និងអាចឆ្លងលើហ្វូងទាំងមូល ក្នុងរយៈពេល១០ថ្ងៃ។

### ៨.១ រោគសញ្ញា

- ហើមជុំវិញរន្ធច្រមុះ
- ហូរសំបោរ កណ្តាស
- ភ្នែកមមី
- ការផលិតស៊ុតធ្លាក់ចុះដល់៤០%។
- ជាទូទៅមិនមានសញ្ញាផ្លូវដង្ហើម និងប្រសាទ។





ហើមក្រោមភ្នែក

### ៨.២ ការព្យាបាល

ប្រើថ្នាំតេត្រាស៊ីគ្លីន(Tetracyclines) និងអេរីត្រូមីស៊ីន (Erythromycine) មានប្រសិទ្ធភាពខ្ពស់ ត្រូវព្យាបាលយ៉ាងហោច២អាទិត្យ។

## ខ. ជំងឺមានរោគសញ្ញាផ្លូវរំលាយអាហារ

រោគសញ្ញាប្រព័ន្ធរំលាយអាហារ រួមមាន៖ មិនស៊ីចំណី ហើមគែ រាគ ឬប្រឡាក់សើមនៅគូទ។

### ១. ជំងឺកុកស៊ីដ្យូស

ជំងឺកុកស៊ីដ្យូស បង្កដោយមេរោគកុកស៊ីដ្យា។ កុកស៊ីដ្យាមានច្រើនប្រភេទ និងជាប្រតូសូអា មានកោសិកាតែមួយ។

ជំងឺកុកស៊ីដ្យូសកើតចំពោះបក្សីនៅតូច ដំណាក់កាលដែលគ្រោះថ្នាក់បំផុតគឺពេលបក្សីមានអាយុ៣អាទិត្យ។

### ១.១ រោគសញ្ញា

- បក្សីចំកោងខ្នង
- រោមគ្រសុសនិងអាចធ្លាក់ស្លាប
- រាគមានសំបោរ
- លាមកមានជាប់ឈាម
- កូនមាន់ស្រេកទឹក ។


កូនមាន់ចំកោងខ្នងលើស្មាម្ខាង





ចេញឈាមលើខ្នែងពោះវៀន

## ១.២ ការការពារ

- ត្រូវធ្វើអនាម័យជាប្រចាំ: កម្រាលស្មូត (ជាពិសេសជុំវិញស្នូកទឹក) និងកម្ចាត់រុយ។

ប្រើថ្នាំរួមមាន៖

- ថ្នាំសាលីណូមីស៊ីន (Salinomycine) មានលាយក្នុងចំណីផ្សំស្រេច (មានបញ្ជាក់លើបាវ)។
- លាយថ្នាំតុលត្រាស៊ីរីល (Toltrazuril) ស៊ុលហ្វា៣៣ (Sulfa33) អំប្រូលីយ៉ូម (Amprolium) ក្នុងទឹកឲ្យផឹក។ សម្រាប់កូនមាន់អាយុ២អាទិត្យ លាយថ្នាំនេះចំនួនពីរដង ដាក់ដោយឡែកពីគ្នាក្នុងរយៈពេល១០ថ្ងៃ ។

## ១.៣ ការព្យាបាល

លាយស៊ុលហ្វា៣៣ (ស៊ុលហ្វាឌីមេរ៉ាស៊ីន Sulfadimerazine) ឬ តុលត្រាស៊ីរីល (បេកុក Baycox) ឬអំប្រូលីយ៉ូម ១០មីលីលីត្រក្នុងទឹក១លីត្រ អំឡុងពេល៣ទៅ៥ថ្ងៃ។

## ២. ជំងឺសាល់ម៉ូ

ជំងឺសាល់ម៉ូ បង្កដោយបាក់តេរី ឈ្មោះសាល់ម៉ូណែឡា។ សាល់ម៉ូណែឡាមានច្រើនប្រភេទ ប្រភេទខ្លះ អាចបង្កបញ្ហាដល់សុខភាពមនុស្ស។

សាល់ម៉ូណែឡាដែលអាចបង្ក ជំងឺលើហ្វូងបក្សីមាន ពីរប្រភេទគឺ៖

## ២.១ សាល់ម៉ូណែឡាពូឡូរុមបង្កជាជំងឺលើកូនមាន់

ក្នុងអំឡុងអាយុ បីអាទិត្យដំបូង ដែលកូនមាន់ ងាប់មានរយៈ ពេលពី ៥ទៅ៧ថ្ងៃ។ ដំណាក់កាលដំបូង ក្រោយពេលញាស់បានបន្តិចចំនួន កូនមាន់ ងាប់លើសលប់។

សាល់ម៉ូណែឡាឆ្លងរាលដាលតាមរយៈ ស៊ុត ទូភ្ញាស់ កេសដាក់កូនមាន់ ទ្រុង ស្នូកទឹក ស្នូកចំណី ដែលមានមេរោគ ។ល។



**រោគសញ្ញាលើកូនមាន់**

- កូនមាន់ចុះខ្សោយ ដេកប្រមូលផ្តុំគ្នា ហាក់ដូចជារងាររាគជាប់គូទ ពណ៌ស ឬប្រផេះ ។

## ២.២ សាល់ម៉ូណែឡាបង្កជំងឺលើមាន់ពេញវ័យ

ជំងឺសាល់ម៉ូ ជាជំងឺដែលមេរោគឆ្លងចូលក្នុងឈាម។

**រោគសញ្ញាលើមាន់ពេញវ័យ**



- អត្រាងាប់ខ្ពស់
- ការផលិតស៊ុត ការបង្កកំណើត និងញាស់ធ្លាក់ចុះ
- រាគមានសំបោរពណ៌លឿង ទៅជាខៀវ ឬត្នោត
- មាន់ស្រេកទឹកខ្លាំង។

បញ្ជាក់: ជំងឺសាល់ម៉ូណែឡាគួរធ្វើរោគវិនិច្ឆ័យផ្សេង ពីករណីរបស់ជំងឺរលាកពោះវៀន។

## ២.៣ ស្លាកស្នាម



- កូនមាន់ងាប់ក្នុងអាយុមួយអាទិត្យ បង្ហាញពីការ មិនស្រូបអង្គធាតុលឿងក្នុងពោះ។
- កូនមាន់ងាប់ក្នុងអាយុពីរអាទិត្យ បង្ហាញពីការមិន ស្រូបជាតិលឿង (សារធាតុខ្លាញ់ក្នុងពោះ) វត្ថុរាវជុំវិញបេះដូង (រលាកស្រោមបេះដូង) ហើមផាល និងមានចំណុចដំបៅរលួយពណ៌ប្រផេះលើថ្លើម។
- ចំពោះមេមាន់ បំពង់បន្តពូជអាចស្វិតផាលខូច ទ្រង់ទ្រាយ ថ្លើមប្រែពណ៌ ជាពណ៌ទង់ដែង។



## ២.៤ ការព្យាបាល

ប្រើថ្នាំអង់ទីប៊ីយ៉ូទិកដូចជា ទ្រីមេតូព្រីម ស៊ុលហ្វា អាចកាត់បន្ថយអត្រាងាប់ ប៉ុន្តែមិនអាចលប់បំបាត់ជំងឺពីហ្វូងបានទេ។

## ៣. ព្រូន

**បរាសិតខាងក្នុង** (ព្រូន) ជាទូទៅច្រើនកើតលើមាន់ចិញ្ចឹមជាលក្ខណៈគ្រួសារ។ ជាធម្មតាសត្វមានព្រូនតិចតួចក្នុងខ្លួនសត្វវាមិនបង្កជាបញ្ហាទេ ប៉ុន្តែប្រសិនបើមានព្រូនច្រើន វាមានផលប៉ះពាល់ ខ្លាំងដល់ការលូតលាស់ ការផលិតស៊ុត និងលើសុខភាពទាំងមូល។

រាល់ព្រូនខាងក្នុងខ្លួនសត្វទាំងអស់ ដូចជាព្រូនអាស្ការីស រស់ក្នុងពោះវៀនតូច ធ្វើឲ្យមានការ ខូចខាតខ្លាំង។ ម្យ៉ាងទៀតមានព្រូនមូលប្រភេទផ្សេងៗគ្នានៅក្នុងបំពង់អាហារ ក្នុងតែ ក្នុងកោះ ឬក្នុង ខ្នែងពោះវៀន។

ព្រូនមូលឆ្លងពីមាន់មួយទៅមាន់មួយទៀត តាមរយៈការលេបចូលពងព្រូនដែលមានក្នុងទឹក ក្នុងចំណី ឬតាមរយៈការស៊ីជន្លេនដែលផ្ទុកបរាសិត។

### ៣.១ រោគសញ្ញា



- លូតលាស់យឺត
- ស្គម
- ពេលខ្លះយើងឃើញព្រូនក្នុងលាមក
- រាគ
- ផលិតកម្មស៊ុតថយចុះ
- ភាពធន់នឹងជំងឺដ៏ទៃទៀតចុះខ្សោយ
- បក្សីនៅតូចឈឺធ្ងន់ធ្ងរជាងបក្សីធំ។ក្នុងករណី

មានការឆ្លងធ្ងន់ធ្ងរ(ព្រូនច្រើន) អាចស្ទះក្នុង ពោះវៀនបណ្តាលឲ្យបក្សីងាប់។

### ៣.២ ការព្យាបាល

ប្រើថ្នាំតេត្រាមីសុល (Tetramizole) ឬឡេវ៉ាមីសុល (Levamisole) ។

## ៤. ជំងឺកូលីបាក់ស៊ី

ជំងឺកូលីបាក់ស៊ី ជាជំងឺឆ្លងបង្កដោយអឺកូលី ដែលកើតជាទូទៅចំពោះការចិញ្ចឹមបក្សី ក្នុងកសិដ្ឋាន។

## ៥.១ ការឆ្លងជំងឺ

- ធូលីក្នុងទ្រុងមាន់មានអឺកូលីយ៉ាងច្រើន
- ជាធម្មតាមេរោគអឺកូលី មាននៅក្នុងពោះវៀនតូច ពេលមាន់ស្ថិតក្នុងស្ថានភាពស្ត្រេស ឬមានឆ្លងមេរោគដទៃទៀតជ្រៀតចូល ដូចជា មីកូប្លាស្មា។ មេរោគទាំងនោះវាលដាលចូលក្នុងឈាម បង្កជាជំងឺ។
- ចំពោះកូនមាន់ ឆ្លងតាមស៊ុតដែលប្រឡាក់លាមកមានអឺកូលី ហើយវា ជ្រៀតចូលតាមសំបកស៊ុត។


ស៊ុតប្រឡាក់លាមក ដូច្នេះពួកអឺកូលីលេចឡើងតាមរយៈសំបកស៊ុត

## ៥.២ រោគសញ្ញា

- អំប្រីយ៉ុង និងកូនមាន់មាន អត្រាងាប់ខ្ពស់។
- ផ្លូវដង្ហើមមានលក្ខណៈឈឺចាប់
- រាគពណ៌ស ប្រែក្លាយជាពណ៌លឿង ខៀវ កោសិកាស្បែកងាប់ ដោយសារមាន ឆ្លងមេរោគក្រោមស្បែក។


អឺកូលិ: ស្លាកស្នាមនៅលើស្បែក

## ៥.៣ ស្លាកស្នាម

- មានសារធាតុសរសៃលើបេះដូង ថ្លើម និងថង់ខ្យល់
- ថង់ស៊ុតលឿងមិនប្រក្រតី កូនមាន់មានពោះប៉ោង
- ស៊ុតលឿងមានពណ៌ល្អក់ និងមានក្លិនស្អុយ

សារធាតុខាប់លើសរីរាង្គ



ស៊ុតលឿង"ប៉ិតុង"


ពោះប៉ោងចំពោះកូនមាន់

ចំណាំ: ជំងឺសាល់ម៉ូបង្កដោយមីកូប្លាស្មា ថ្លើមគ្មានចំណុចដំបៅរលួយពណ៌ប្រផេះទេ។

## ៤.៤ ការព្យាបាល

ជំងឺនេះធន់នឹងថ្នាំអង់ទីប៊ីយ៉ូទិកច្រើនប្រភេទ។

ដូចនេះត្រូវប្រើ:

- ថ្នាំក្ល័រតេត្រាស៊ីគ្លីន (Chlortetracycline) រួមជាមួយថ្នាំកូលីស្ទីន (Colistine) ឬ ថ្នាំភ្លុយមេគីន(Flumequine) រួមជាមួយនឹងអាម៉ុកស៊ីស៊ីលីន(Amoxicilline)។

## ៥. ជំងឺហ្គុមបូរ៉ូ

ជំងឺហ្គុមបូរ៉ូ បង្កដោយវីរុស។ ជំងឺនេះធ្វើឲ្យប្រព័ន្ធភាពស៊ាំចុះខ្សោយ មាន់ងាយទទួលរងជំងឺ ដ៏ទៃទៀត ដូចជាជំងឺប្រព័ន្ធដង្ហើម និងរំលាយអាហារ ជំងឺទាំងនេះ វិវត្តលឿន និងពិបាកព្យាបាល។ម្យ៉ាងទៀត បន្ទាប់ពីធ្វើវ៉ាក់សាំងមាន់មិនមានភាពស៊ាំល្អ វ៉ាក់សាំងមានប្រសិទ្ធភាពទាប។

### ៥.១ រោគសញ្ញា



- បក្សីខ្សោយ ធ្វើចលនាតិចតួច
- មិនចង់ស៊ីចំណី
- ក្នុងខ្លួនខ្សោះទឹក
- រាគពណ៌សស្អិតជាប់នឹងរោមគូថ។

### ៥.២ ស្លាកស្នាម

- មានជាំឈាមក្នុងភ្លៅ និងសាច់ដុំទ្រូង
- កញ្ចូញគូទហើមរីកធំ មានឈាមឬខ្ទុះខាងក្នុង
- ចំពោះសណ្ឋានរ៉ាំរ៉ៃ កញ្ចូញគូទក្លាយជារឹងនិងក្រៀមស្វិត។



ចេញឈាមក្នុងសាច់ដុំ



កញ្ចូញគូថហើម



ចេញឈាមក្នុងកញ្ចូញគូថ

### ៥.៣ ការព្យាបាល

មិនមានការព្យាបាលទេ។ ប៉ុន្តែអាចប្រើថ្នាំអង់ទីប៊ីយ៉ូទិកលាយក្នុងទឹកឲ្យវាផឹក រយៈពេល ១០ថ្ងៃ ព្រោះជំងឺហ្គុមបូរ៉ូធ្វើឲ្យភាពស៊ាំថយចុះហើយមាន់ងាយឆ្លងជំងឺឱកាសនិយម បង្កដោយបាក់តេរី។

### ៥.៤ ការការពារ

ការធ្វើវ៉ាក់សាំងគឺជាវិធីសំខាន់ដើម្បីត្រួតពិនិត្យជំងឺហ្គុមបូរ៉ូ។ ការធ្វើវ៉ាក់សាំងមេបា គឺមានសារៈសំខាន់ណាស់ ដើម្បីឲ្យវាផ្តល់អង្គបដិបក្ខពីកំណើត ដើម្បីការពារកូនមាន់ពីការចម្លងជំងឺ។

## ៦. ជំងឺបេស្តទា

ជំងឺបេស្តទា បង្កដោយវីរុស កើតលើទា និងបក្សីទឹកផ្សេងទៀត។ ជំងឺនេះមានសភាពស្រួចស្រាវ រាលដាលយ៉ាងរហ័ស និងបង្កឲ្យសត្វងាប់ភ្លាមៗ។





### ៦.១ រោគសញ្ញា

- ចាញ់ពន្លឺ បិទភ្នែក ជ្រកកន្លែងងងឹត
- ដើរទ្រេតទ្រោត រញ៉េរញ៉ៃ
- ស្រេកទឹកខ្លាំង
- រាគធ្ងន់ធ្ងរ
- ជួនកាលលៀនលិង្គចេញមកក្រៅខ្ទិន។

### ៦.២ ស្លាកស្នាម

- រលាកពោះវៀនធ្ងន់ធ្ងរក្រម៉ក្រៀមពណ៌លឿងក្នុងបំពង់អាហារ ចេញឈាមក្នុងពោះវៀន ក្នុងខ្លួន និងបេះដូង ។ល។




### ៦.៣ ការព្យាបាល

មិនមានការព្យាបាលទេ ។វ៉ាក់សាំងអាចចាក់ដើម្បីបញ្ឈប់ការឆ្លងរាលដាល និងព្យាបាលសត្វដែលឆ្លងជំងឺ។ ប៉ុន្តែ ជាទូទៅវ៉ាក់សាំងចាក់ដើម្បីការពារជំងឺតែប៉ុណ្ណោះ។

## គ. ជំងឺ និងបញ្ហាធ្វើឲ្យផលិតកម្មស៊ុតថយចុះ

សញ្ញាបញ្ជាក់ពីការធ្លាក់ចុះផលិតកម្មស៊ុត សំដៅដល់ សំបកស៊ុតស្តើង ឬស៊ុតគ្មានសំបក ស៊ុតជ្រួញ ឬខូចរូបរាង ផ្ទៃកសមានទឹកច្រើន ឬមានចំណុចឈាមក្នុងស៊ុត។

## ១. ជំងឺរលាកទងសួត



- **ជំងឺរលាកទងសួត** មាន
  ឥទ្ធិពលលើផលិតកម្មស៊ុត:
  - ការធ្លាក់ចុះផលិតកម្មស៊ុតកើតមានពេល
    - ប្រហាក់ប្រហែលគ្នា
      នឹងសញ្ញាផ្លូវដង្ហើម
  - <u>ផលិតកម្មស៊ុតធ្លាក់ចុះលើសពី៥០%</u>
  - ផលិតកម្មស៊ុតត្រឡប់មកសភាពដើមវិញ បន្ទាប់ពី ៥ទៅ៦អាទិត្យ ប៉ុន្តែអត្រាទាបជាងមុន
  - សំបកស៊ុតទន់ និងទ្រង់ទ្រាយមិនល្អ ផ្នែកពិណាសមានទឹកច្រើន។
- **ស្លាកស្នាម**
  - អូវែ មានចេញឈាម
  - មានទឹកពណ៌លឿងក្នុងពោះ ដោយសារស៊ុតលឿងធ្លាក់ក្នុងស្រោមពោះ។ មាន់ដែលមានជំងឺរលាកទងសួត ជាពិសេសមាន់អាយុ០១អាទិត្យមិនអាចក្លាយជាមេមាន់ពងបានល្អទេ ព្រោះបំពង់នាំអូវូលវាស្វិត។

## ២. បញ្ហាកង្វះជាតិកាល់ស្យូម

សំបកស៊ុតផ្សំឡើងដោយជាតិកាល់ស្យូមកាបូណាត។ តម្រូវការជាតិកាល់ស្យូមសម្រាប់មេមាន់ក្រមុំមានកម្រិតទាប។ ប៉ុន្តែពេលដែលមេមាន់ក្រមុំ ចាប់ផ្តើមពងដំបូង តម្រូវការកាល់ស្យូមនឹងកើនឡើង យ៉ាងហោច ៤ដង (៤ក្រាម/ថ្ងៃ)។ជាតិកាល់ស្យូមមិនបានគ្រប់គ្រាន់ធ្វើឲ្យផលិតកម្មស៊ុតថយចុះ និងគុណភាពសំបក ស៊ុតស្តើង និងទន់។មេមាន់ផ្ទុកជាតិកាល់ស្យូមបម្រុងមួយចំនួនក្នុងឆ្អឹងក្នុងករណីមេមាន់ ប្រើប្រាស់ជាតិកាល់ស្យូម បំរុងនេះ បណ្តាលឲ្យ ឆ្អឹងផុយស្រួយ និងមិនអាចក្រោកឈរបាន។ ជាតិកាល់ស្យូមត្រូវផ្តល់ក្នុងរបបចំណី បានមកពីដេសេប៉េ DCP ឬសំបកងាវ។






## ៣. មីកូតុកស៊ីន

ផ្សិតលូតលាស់ក្នុងចំណីមានសំណើមលើសពី១២% ជាពិសេសគ្រាប់ពោត ផ្សិតផលិតមីកូតុកស៊ីន។ យើងអាចមើលឃើញផ្សិតក្នុងចំណី ប៉ុន្តែយើងមិនអាចមើលឃើញមីកូតុកស៊ីន បានទេ មានតែធ្វើការវិភាគនៅមន្ទីរពិសោធន៍ប៉ុណ្ណោះ។

ទាងាយរងគ្រោះពីការពុលជាងមាន់។ ក្នុងករណីជំងឺស្រួចស្រាវ អត្រាងាប់ខ្ពស់រហូតដល់ ៥០%។ ភាពធន់នឹងជំងឺមានកម្រិតទាប(ភាពស៊ាំទាប) និងការផលិតស៊ុតធ្លាក់ចុះយ៉ាងខ្លាំង។

ពោតហាលមិនស្ងួតល្អ បណ្តាលឲ្យកើតមានមីកូតុកស៊ីន។ ដើម្បីបន្សាបមីកូតុកស៊ីន មានផលិតផលខ្លះរាងដូចជាដីឥដ្ឋ លាយ ដេតុក (Detox) ១០០ក្រាមទៅ ២០០ក្រាម ក្នុងចំណី ១០០គីឡូក្រាម ដើម្បីស្រូបមីកូតុកស៊ីន។


ពោតត្រូវសម្ងួតឲ្យបានល្អដើម្បីការពារការលូតលាស់របស់មីកូប្លាស្មា

## ៤. ចៃ

ចៃមាន់ចិញ្ចឹមជីវិតលើស្រកាស្ងួត រោម ស្លាប ឬក្រមរលើស្បែក។

ចៃខាំបង្កឲ្យក្រហល់ក្រហាយស្បែក បង្ហាញអាការៈ មិនធម្មតា ការផលិតស៊ុតធ្លាក់ចុះរហូតដល់២០%។

ការកម្ចាត់បរាសិតខាងក្រៅ(ចៃ) ដោយប្រើថ្នាំកាបារីល(Carbaryl) ពីរដងក្នុងរយៈពេល ៤អាទិត្យ។


ចៃច្រើនបឺតយកឈាមអាចបណ្តាលឲ្យគ្រោះថ្នាក់

ហាមដាច់ខាតមិនត្រូវប្រើកាបារីល ពេលមាន់ផ្តល់ស៊ុតសម្រាប់មនុស្សបរិភោគ។

## ៥. ព្រូន

ព្រូនអាស្ការី (ព្រូនមូល) រស់ក្នុងពោះវៀនបក្សី ហើយស្រូបសារធាតុចិញ្ចឹម ធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់និងផលិតស៊ុត។


ពេលខ្លះការចម្លងរបស់ព្រូនអាចច្រើនចំពោះមាន់ចិញ្ចឹមលែង

## ៦. ជំងឺដង្កោ(ញ្ញវកាស)

- ក្នុងករណីជំងឺពុំរ៉ែមានសញ្ញាតែវៃកាច់
- កន្ទ្បោមពងមានចេញឈាម
- ការផលិតស៊ុតធ្លាក់ចុះ។

## ៧. ជំងឺឡឺកូស៊ីស

ជំងឺឡឺកូស៊ីសបង្កដោយវីរុស កើតលើមាន់កំពុងផ្តល់ស៊ុត ដែលមានអាយុ លើស ពី៦ខែ។

### ៧.១ រោគសញ្ញា




- មិនសូវស៊ីចំណី
- ឈប់ផលិតស៊ុត។

### ៧.២ ស្លាកស្នាម

- មានដុំពក លើថ្លើម លើផាល កញ្ចាញគូទ និងអូវែ។

# ឃ. ជំងឺដែលមានរោគសញ្ញាសរសៃប្រសាទ

រោគសញ្ញាសរសៃប្រសាទ រួមមាន: រមួលក ធ្លាក់ស្លាប ខ្វិន និងខ្វាក់។

## ១. ជំងឺម៉ារិក / ខ្វិន

ជំងឺម៉ារិកបង្កដោយវីរុស ជាប្រភេទជំងឺមហារីកបក្សី

### ១.១ រោគសញ្ញា

- ដុំសាច់ពកអាចដុះលើសរីរាង្គផ្សេងៗ បង្កជារោគសញ្ញាផ្សេងៗគ្នា
- ប្រភេទវីរុសជំងឺម៉ារិក ភាគច្រើនរាតត្បាតជុំវិញសរសៃប្រសាទ បង្កឲ្យខ្វិនស្លាប និងជើង
- ដុំសាច់ពកអាចដុះលើភ្នែក លើប្រស្រីភ្នែក ធ្វើឲ្យខ្វាក់
- ក្នុងទម្រង់ស្រួចស្រាវមានដុំសាច់ពកជាច្រើនដុះលើថ្លើម ផាល និងសាច់ដុំ ធ្វើឲ្យសត្វងាប់លឿន
- វីរុសអាចលូតលាស់ក្នុងរន្ធរោម ធ្វើឲ្យមានស្លាកស្នាមលើស្បែក។ ជំងឺនេះមានលក្ខណ: ឆ្លងរាលដាលខ្លាំង ព្រោះមានវីរុសជាច្រើនបញ្ចេញតាមស្បែក។



### ១.២ ស្លាកស្នាម

- ដុំសាច់ពកមួយឬច្រើនដែលដុំលើសរីរាង្គខាងក្នុង និងជាលិកាអាចរាតត្បាតពេញផ្ទៃរបស់សរីរាង្គ។
  ទម្រង់ជាទូទៅរបស់ជំងឺម៉ារិក ធ្វើឲ្យសរសៃប្រសាទឡើងក្រាស់ពី ៣ទៅ៤ដង ប្រៀបនឹងសរសៃប្រសាទធម្មតា។




### ១.៣ ការការពារ

- កូនមាន់អាចធ្វើវ៉ាក់សាំងនៅកន្លែងភ្ញាស់
- ការធ្វើវ៉ាក់សាំងដើម្បីការពារការដុះដុំសាច់ វាមិនអាចការពារការឆ្លងដោយវីរុសទេ។

## ២. ជំងឺដង្កោ(ញូវកាស)

- ប្រភេទវីរុសជំងឺដង្កោអាចបំផ្លាញប្រព័ន្ធ សរសៃប្រសាទ។ ជាទូទៅរោគសញ្ញា ប្រព័ន្ធសរសៃប្រសាទ លេចឡើងក្រោយ សញ្ញាផ្លូវដង្ហើម។
- មាន់អាចរមួលក្បាល និងក ពិបាកដើរ និងដើររាងជារង្វង់។



## ៣. ជំងឺរលាកខួរក្បាលបក្សី

ជំងឺរលាកខួរក្បាលបក្សី បង្កដោយវីរុស និងកើតមានលើកូនមាន់ឆ្លងតាមរយៈស៊ុត។

### រោគសញ្ញា

- ជំងឺចាប់ផ្តើមលេចឡើងបន្ទាប់ពីញាស់ភ្លាម
- កូនមាន់ព្រិលភ្នែក ឈរមិននឹង អង្គុយលើគន្លាក់ជើង
- ដើរញ័រក្បាល បន្ទាប់ពីធ្វើឲ្យកូនមាន់ផ្អើល។
- ក្នុងករណីស្រួចស្រាវមានកូនមាន់ជាច្រើនទ្រោបជើងទាំងពីរញែកចេញក្រៅហើយងាប់។
- អត្រាងាប់ប្រែប្រួលពីការផ្ទុះមួយលើកទៅមួយលើកទៀត។



## ៤. ជំងឺខ្វិនទន់ជើង (ជំងឺបូទុយលីស)

ជំងឺបូទុយលីស បង្កដោយជាតិពុលរបស់បាក់តេរីក្លូស្ទ្រីដ្យូម ។

មេរោគជំងឺបូទុយលីស អាចរស់ក្នុងសាកសពបក្សីរលួយ កម្រាលសើម ដង្កូវ រុយ ឬសារធាតុខនិជដំទៃទៀត ។




### ៤.១ រោគសញ្ញា

- សត្វខ្វិន ទន់ជើង ទន់ក ធ្លាក់ស្លាប និងធ្លាក់ត្របកភ្នែក លក្ខណៈពិសេស បក្សីមានសភាពភ្លឹកៗ ក និងក្បាល ដកទៅមុខ។

### ៤.២ ការការពារ

- បក្សីងាប់ ត្រូវដុត ឬកប់ជាបន្ទាន់
- ត្រួតពិនិត្យ និងកម្ចាត់ហ្វូងរុយ។

# ង. ជំងឺ និងបញ្ហាធ្វើឲ្យពិបាកធ្វើចលនា

ការខ្វកជើង ការហើមសន្លាក់ របួស និងបញ្ហាការផ្តល់ចំណី គឺជាមូលហេតុរួម ដែលបណ្តាលឲ្យសត្វពិបាកធ្វើចលនា។

ដើម្បីការពារបញ្ហាខាងលើនេះ ត្រូវផ្តល់របបចំណីឲ្យមានតុល្យភាព ជាពិសេសការផ្តល់វីតាមីន និងសារធាតុរ៉ែ ក្នុងអំឡុងអាទិត្យទីមួយនៃអាយុរបស់សត្វ។

## ១. បញ្ហាខ្វកជើង

### ១.១ ការបង្កដោយពពួកស្តាភីឡូកុកគុសៈ



ដោយសារមានដំបៅ ហើមនៅបាតជើង បណ្តាលឲ្យបក្សីខ្វកជើង ។ មេរោគស្តាភីឡូកុកគុសអាចរស់នៅក្នុងដី និងក្នុងថ្លុកទឹក។

**ការព្យាបាលៈ** លាយថ្នាំអេរីត្រូមីស៊ីនក្នុងចំណីរយៈពេល ៥ថ្ងៃ។



## ១.២ ការបង្កដោយសារព្រូន:

ដំណើរមិនមាំមួន ចំពោះទា។ បើទាជំទង់ដើរ មានសភាពឈឺជើង ដំបូងត្រូវពិនិត្យថា តើទាទាំងនោះបានទម្លាក់ព្រូនក្នុងពេលថ្មីៗដែរឬទេ។

## ១.៣ បណ្តាលមកពីរបួស



ប្រើខ្សែដើម្បីចងមាន់ជារឿយៗ ធ្វើឲ្យមានដំបៅលើជើងវា

ក្នុងករណីខ្វក ចាំបាច់ត្រូវធ្វើការពិនិត្យជើង និងបាតជើង បក្សីឲ្យបានដិតដល់។

**ការពារព្យាបាល:**

- របួសស្រាល ត្រូវលាងសម្អាតនិងប្រើថ្នាំរម្ងាប់មេរោគ។
- របួសធ្ងន់ធ្ងរត្រូវលាងសម្អាតនិងប្រើថ្នាំរម្ងាប់មេរោគ និងលាយថ្នាំអង់ទីប៊ីយ៉ូទិក ក្នុងចំណី ដូចជាថ្នាំ អេរីត្រូមីស៊ីន (Erythromycine)ឬ ដុកស៊ីស៊ីគ្លិន (Doxycycline) ឬ អាម៉ុកស៊ីស៊ីលីន (Amoxicilline)។

**ការការពារ:** បក្សីខ្វកជើងត្រូវយកចេញពីហ្វូង និង ដាក់ក្នុងទ្រុងតូច ងាយស្រួលផ្តល់ទឹកចំណី និងកុំឲ្យ សត្វធ្វើ ចលនាច្រើន។

## ១.៤ បណ្តាលមកពីកង្វះវីតាមីនដេ:

- បក្សីវារែកមិនចង់ដើរ ឬធ្វើចលនា។
- បក្សីត្រូវការវីតាមីនដេ ដើម្បីស្រូបជាតិ កាល់ស្យូម និងជាតិផូស្វរ័ និងបង្កើតជាគ្រោងឆ្អឹង។
- កង្វះវីតាមីនដេ៣ (Vitamin D3) ក្នុងចំណី បង្កឲ្យឆ្អឹងទន់និងធ្វើឲ្យកូនមាន់ខ្វកជើង។

# ២. ហើមសន្លាក់

- **បង្កដោយមេរោគសាល់ម៉ូណែឡា**

  មេរោគសាល់ម៉ូណែឡា (ពុលឡូរ៉ុមPullorum)បង្កឲ្យកូនមាន់ងាប់នៅអាទិត្យទីមួយនៃអាយុរបស់វា។ ចំពោះបក្សីធំ ជំងឺនេះអាចមានសភាពស្រួចស្រាវ មធ្យម បណ្តាលឲ្យខ្វកជើង និងហើមសន្លាក់។





- **បង្កដោយមេរោគមីកូប្លាស្មា**
  បក្សីដែលឆ្លងជំងឺ បង្កដោយមេរោគមីកូប្លាស្មា ពិបាកក្នុងការដកដង្ហើម និងពិបាក ធ្វើចលនា ខ្ទក់ជើងយ៉ាងខ្លាំង និងស្គមស្រពន់ ហើមសន្លាក់ ស្រកទម្ងន់ និងកើត ពងដោរលើទ្រូង។

ការព្យាបាលៈ ត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាទីឡូស៊ីន(Tylosine)ឬដុកស៊ីស៊ីគ្លីន(Doxycycline)។

## ៣. ម្រាមជើងក្រញង់



កង្វះជាតិវីតាមីនបេ២ បណ្ដាលឲ្យម្រាមជើងបក្សីរួញក្រញង់ កន្ទេកជើង និងកូនមាន់ក្រាប អង្គុយចុះលើគន្លាក់ជើងរបស់វា។ សង្កេតឃើញចំពោះបក្សីអាយុ៣អាទិត្យឡើងទៅ។

ការព្យាបាលៈ ត្រូវលាយចំណីជាមួយប្រេមិច ឬប្រើ ចំណីដែលមានវីតាមីនច្រើនមុខ ក្នុងអំឡុងអាទិត្យទីមួយនៃអាយុរបស់វា ។

# ច. ជំងឺ និងបញ្ហាប៉ះពាល់លើលក្ខណៈខាងក្រៅ

រោម ស្បែក សិរ និងស្ថានភាពស្គមកំព្រឹង អាចឆ្លុះបញ្ចាំងពីបញ្ហាខាងក្រៅ ឬមានសញ្ញាបន្ថែមរបស់ជំងឺទូទៅ។

## ១. សិរ និងណង់



- សញ្ញាហើមសិរ និងណង់ ចំពោះជំងឺអាសន្នរោគ ហើយជំងឺនេះក្នុងសភាពរ៉ាំរ៉ៃ មាន បូស(ដំបៅអាប់សែ) លើណង់។
- សញ្ញាដុំពក ចំពោះជំងឺអុតបក្សី
- ដុំពកដុះលើកន្លែងគ្មានរោម ដូចជាសិរ និងណង់ជាដើម។

## ២. ភ្នែក



ភ្នែកមានទឹក និងរលាកឡើងក្រហមជំងឺផ្លូវដង្ហើម មួយចំនួន ដូចជាជំងឺដង្កោ ជំងឺរលាក បំពង់ខ្យល់ ជំងឺរលាកស្វួត ជំងឺផ្តាសាយបក្សី និងជំងឺបង្ក ដោយមីកូប្លាស្មា អាចបណ្តាលឲ្យ មានភ្នែកក្រហម ធ្វើឲ្យ បក្សីនៅមិនសុខ ត្រដុះ និងខ្វាចភ្នែកវា។

- **ចំពោះជំងឺផ្តាសាយ (កូរីសា) និងមីកូប្លាស្មា** ក្នុងដំណាក់កាលទី២ ភ្នែកហើមឃើញដូចខ្ទុះ ហូរចេញពីត្របកភ្នែក និងអាចបិទជាប់គ្នា។
- **ចំពោះជំងឺម៉ារិក**
  - ជំងឺនេះធ្វើឲ្យកើតជាដុំសាច់ អាចដុះលើ ប្រស្រីភ្នែក ក្នុងភ្នែកបណ្តាលឲ្យខ្វាក់ភ្នែក។





## ៣. ការហូរទឹករំអិលតាមរន្ធច្រមុះ



- **ជំងឺរលាកស្វួត**

  មានហូរទឹករាវថ្លាគ្មានពណ៌ចេញពីច្រមុះប្រែទៅជាសំបោរ ។



- **ជំងឺផ្តាសាយ (កូរីសា)**
  - ហើមជុំវិញផ្ទៃមុខ
  - ហូរទឹកមានសភាពស្អិតដូចខ្ទុះពីរន្ធច្រមុះ
  - និងភ្នែក
  - ពិបាកដកដង្ហើម។



- **ជំងឺរលាកបំពង់ខ្យល់**

  មានឈាមលាយសំបោរ ជ្រាបចេញពី បំពង់ខ្យល់របស់បក្សីឈឺ ហើយដាមជាប់ ជុំវិញរន្ធច្រមុះ។

## ៤. ស្លាកស្នាមលើស្បែក

- **ជំងឺអុត / ឬសដូចដុំពក**

ជំងឺនេះបង្កជាឬសដូចដុំពក ដុះលើផ្នែកខ្លះ នៃក្បាល ជើង និងកន្លែងដែលគ្មានរោម។



- **ជំងឺម៉ារិក / មានដុំពកលើស្បែកជើង**

មានដុំពកកើតនៅគល់ស្លាប ប៉ុន្តែភាគច្រើនដុំពក កើតលើជើង។



- **រលាករន្ធគូថ/ជំងឺហ្គុមបូរ៉ូ**

ចំពោះជំងឺហ្គុមបូរ៉ូ លាមករាវ ធ្វើឲ្យ ប្រឡាក់រោមជុំវិញ រន្ធគូថ និង មានចឹក រន្ធគូថគ្នា។





- **គ្រមរ / ចៃ**

ចៃចោះរន្ធក្រោមស្រកាជើង ស្រកានេះរីកធំឡើងក្លាយជារដិបរដុបនិងឆ្លងជំងឺ។ ប្រសិនបើមិនធ្វើការព្យាបាលទាន់ពេលទេ បក្សីអាចដើរខ្វកជើង។

**ការព្យាបាល:**

ត្រូវត្រាំជើងបក្សីក្នុងប្រេង ឬក្រែម ដើម្បីធ្វើឲ្យ ចៃងាប់។ ព្យាបាលរៀងរាល់៣ទៅ៤ថ្ងៃម្តងសម្រាប់រយៈពេលពីរអាទិត្យ។



- **របួស / ការចឹកគ្នា**

បក្សីចឹកគ្នាទៅវិញទៅមកបង្កជារបួស ពេល ខ្លះចិកគ្នារហូតដល់ងាប់។ បក្សីដល់គ្នាដែល មានអាយុ ពូជ ពណ៌ ទំហំខុសគ្នា មិនធ្លាប់ចិញ្ចឹមជាមួយគ្នា បង្កការជ្រួលច្របល់ក្នុងហ្វូង ដែលរិតតែបង្កើនឱកាសឲ្យ មានការចិកគ្នាខ្លាំង។




វិធីតែមួយគត់ដែលមានប្រសិទ្ធភាពដើម្បីកុំឲ្យចិកគ្នាត្រូវកាត់ចំពុះផ្នែកខាងលើ។

## ៥. សភាពរបស់រោម

- **ពងចៃស្អិតលើរោម /ចៃ**

ពងចៃជាចម្កោមជាប់លើរោមសត្វចៃពេញវ័យមិនបឺតឈាមទេ តែវាចិញ្ចឹមជីវិតដោយសារក្រមរស្បែកស្ងួត និងរោម។



ការព្យាបាល: ត្រូវប្រើថ្នាំកាបារីល (Carbaryl)។

ថ្នាំកាបារីលមិនអាចប្រើលើមាន់ពង ហើយ លក់ទៅទីផ្សារបានទេ។

- **រោមលូតលាស់មិនល្អ ឬចិករោម / កង្វះជាតិមេទីយ៉ូនីន**

កង្វះជាតិមេទីយ៉ូនីនជះឥទ្ធិពលមិនល្អដល់ការលូតលាស់របស់រោម។



ការចិករោមគ្នាដោយសារកង្វះជាតិប្រូតេអ៊ីន និងអាស៊ីតអាមីណោក្នុងរបបចំណី ជាពិសេសជាតិមេទីយ៉ូនីន។ រោមសំបូរជាតិមេទីយ៉ូនីន តែបក្សីមិនអាចទទួលនូវសារធាតុដែលវាត្រូវការ ពួកវានឹងចឹកទាញរោមបក្សីផ្សេងទៀត ព្រមទាំងចឹកទាញរោមខ្លួនវាដើម្បីស៊ី។

- **រោមបះ /បក្សីឈឺ**

ស្ទើរតែគ្រប់ជំងឺឆ្លងទាំងអស់ និងជំងឺបរាសិត ដូចជាកុកស៊ីដ្យូស បង្កឲ្យអស់កម្លាំង និងរោមបះ។ ដូចនេះវាជាសញ្ញាធ្ងន់ធ្ងររបស់បញ្ហាសុខភាព។



- **ការជ្រុះរោម /ជម្រុះស្លាប**



ជាធម្មតារៀងរាល់ឆ្នាំមាន់តែងជម្រុះរោម ឬជ្រុះរោមចាស់ ដំបូងជ្រុះរោមលើក្បាលបន្ទាប់មកលើកដងខ្លួន និងចុងក្រោយលើស្លាប និងកន្ទុយ។ ក្នុងអំឡុងពេលនេះប្រហែល៦ ទៅ ៧អាទិត្យ ជាទូទៅមេមាន់ឈប់ផលិតស៊ុត(ឈប់ពង)។

➢ **រោមជាប់រន្ធគូថ /ជំងឺសាល់ម៉ូណែឡូស**

ដុំពណ៌ជាប់នឹងលាមកបង្កជាស្អិតជាប់រន្ធគូថ។



## ៦. ការស្គមកំព្រឹង

➢ **ដោយសារព្រូន**

មានព្រូនក្នុងពោះវៀន ព្រូនស្រូបសារធាតុចិញ្ចឹមសំខាន់ៗមានក្នុងពោះវៀន ដូចនេះបង្កឲ្យបក្សីខ្វះសារធាតុចិញ្ចឹម។

សភាពជងខ្លួនអាចត្រួតពិនិត្យលើសាច់ដុំទ្រូង



➢ **ដោយសារជំងឺឡឺកូស៊ីស**

ជំងឺឡឺកូស៊ីស អាចសម្គាល់បានដោយមានដុះដុំពកលើឡាំផូអ៊ីត ជាពិសេសក្នុងថ្លើម និងផាល។ ដុំពកអាចធ្វើឲ្យប៉ះពាល់ដល់សរីរាង្គ ផ្សេងទៀតដូចជា អូវែ និងសួត។ បក្សីដែលមានជំងឺនេះបង្ហាញអាការៈមិនឃ្លានចំណី និងចុះស្គមជាលំដាប់។



➢ **ឈប់ស៊ីចំណី/ កង្វះសារធាតុចិញ្ចឹម**

ការផ្តល់ចំណីមិនគ្រប់គ្រាន់ជាមូលហេតុ ធ្វើឲ្យ សភាពរាងកាយមិនល្អ ជាទូទៅលើមេមាន់ដែលត្រូវការសារធាតុបម្រុងពេលក្រាបពង។

ពេលក្រាបពង មេមាន់ចាកចេញពីសំបុកតែ
នាទីប៉ុណ្ណោះនិងវាមិនអាចស៊ីចំណីបានគ្រ








# ជំពូកទី១១៖ ជំងឺជ្រូក





# ក-ជំងឺប៉េស្តជ្រូក (Classical Swine Fever)

## ១- មូលហេតុ

- ជំងឺប៉េស្តជ្រូកបង្កដោយវីរុស កើតលើជ្រូកគ្រប់វ័យ
- មិនអាចព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិកបានទេ វីរុសនេះមានច្រើនក្នុងអាមីដាល់នៃសត្វជ្រូក ។ វីរុសបានបញ្ចេញតាមមាត់ ច្រមុះ និងភ្នែក។ នាពេលបច្ចុប្បន្ននេះការធ្វើអង្កេតនិងធ្វើរោគវិនិច្ឆ័យលើជំងឺប៉េស្តជ្រូកឃើញមានលាយឡូកឡំជាមួយជំងឺត្រចៀកខៀវ( PRRS) ។




## ២- ការបង្កជំងឺ (វីរុឡង់) Virulence

ល្បឿនរបស់វីរុសឆ្លងចូលក្នុងខ្លួនជ្រូកហើយវីរុសបំបែកខ្លួនអាចផ្លាស់ប្តូរពីលឿនខ្លាំងទៅជាយឺត។ក្នុងកសិដ្ឋានជំងឺនឹងផ្លាស់ប្តូរពី**ស្រួចស្រាវ**(ជ្រូកងាប់យ៉ាងលឿន)ទៅជា**មិនសូវស្រួចស្រាវ** ជារឿយៗជ្រូកមិនងាប់ ប៉ុន្តែវាចុះខ្សោយ និងធំលូតលាស់យឺត។

## ៣- ការចម្លងជំងឺ

- ជ្រូកអាចឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយជ្រូកឈឺ
- តាមរយៈទឹកកាម ពេលបង្កាត់ជាមួយជ្រូកឈឺ
- ចម្លងក្នុងស្បូកទៅគភ៌ (Fetuses) ចម្លងក្នុងពេលដើម
- ពេលផ្តល់ចំណីឲ្យជ្រូក ដោយប្រើកាកសំណល់ដែលមានសាច់ចំអិនមិនបានត្រឹមត្រូវល្អ ឬសរីរាង្គរបស់ជ្រូកឈឺ។
- តាមរយៈមនុស្ស និងសម្ភារៈដូចជាកសិករ ភ្នាក់ងារសុខភាពសត្វភូមិ និងបសុពេទ្យ ដែលទស្សនៈកិច្ចកសិដ្ឋាន បន្ទាប់ពីបានប៉ះពាល់ជ្រូកឈឺ ដែលវីរុសតោងជាប់លើស្បែកជើង និងសម្លៀកបំពាក់។ល។



មេរោគចេញពីអាមីដាល់(សាច់បំពង់ក) ហើយបញ្ចេញតាមរន្ធច្រមុះ មាត់ និងលំហូរទឹកភ្នែក

ការជួលជ្រូកបាតីជាការអនុវត្តដែលមានហានិភ័យខ្ពស់ក្នុងការសាយភាយជំងឺប៉េស្តជ្រូក



១.រ៉ឺម៉កអាចនាំវីរុសជំងឺប៉េស្តជ្រូកនៅលើកង់ពីកសិដ្ឋានមួយទៅកសិដ្ឋានមួយទៀត
២. ជ្រូកបាមើលទៅមានសុខភាពល្អ ប៉ុន្តែអាចបញ្ចេញវីរុសតាមច្រមុះនិងមាត់
៣.ទឹកកាមរបស់ជ្រូកបាអាចសាយភាយវីរុស

បសុពេទ្យនិងអ្នកទស្សនាដ៏ទៃទៀតអាចសាយភាយវីរុសពីកសិដ្ឋានមួយទៅកសិដ្ឋានមួយទៀតតាមរយៈស្បែកជើង សម្លៀកបំពាក់ និងដៃ



## ៤- រោគសញ្ញា

- ជាទូទៅរោគសញ្ញាលេចឡើងរយៈ ពេលពី៥ ទៅ ១០ថ្ងៃ បន្ទាប់ពីការចម្លងជំងឺ
- សីតុណ្ហភាពលើសពី ៤១អង្សាសេ ពេលប្រើថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពបញ្ចុះកំដៅទេ ដូច្នេះត្រូវគិតដល់ជំងឺប៉េស្តជ្រូក
- ជ្រូកអាចបញ្ចេញវីរុស មុនពេលបង្ហាញរោគសញ្ញា មានន័យថា វាអាចសាយភាយជំងឺពេលដែលវាមើលទៅមានសុខភាពល្អ។

ក្តៅខ្លាំងនិងគ្រុនយូរ ត្រូវតែគិតដល់ជំងឺប៉េស្ត



➢ **សណ្ឋានស្រួចស្រាវ**

ច្រើនកើតលើជ្រូកសាច់ទម្ងន់ពី៣០ទៅ៦០គីឡូក្រាម

- គ្រុនក្តៅខ្លាំង
- អស់កម្លាំង និងចុះខ្សោយ
- ភ្នែកឈឺឡើងក្រហម
- ដើរទ្រេតទ្រោត
- ស្បែកចេញពណ៌ស្វាយ
- រោគសញ្ញាផ្សេងទៀតអាចកើតមាន ដូចជារាគពណ៌បៃតង (សាល់ ម៉ូណែឡា) រោគសញ្ញាផ្លូវដង្ហើម
- អត្រាងាប់ខ្ពស់ក្នុងរយៈពេល ១ទៅ២អាទិត្យបន្ទាប់ពីចេញរោគសញ្ញាដំបូង។

ភ្នែកក្រហម



ចេញពណ៌ស្វាយលើកន្លែងដែលគ្មានរោមលើជើង



### ➢ សណ្ឋានមិនស្រួចស្រាវ

កើតឡើងពេលដែលមេរោគមានអនុភាពខ្សោយឬពេលដែលជ្រូកបានចាក់វ៉ាក់សាំងហើយវ៉ាក់សាំងគ្មានគុណភាពឬអាចបណ្តាលមកពីមិនមានកម្មវិធីចាក់វ៉ាក់សាំងត្រឹមត្រូវឬចាក់ខុស បច្ចេកទេស។ ឧទាហរណ៍វ៉ាក់សាំងត្រូវចាក់ក្នុងសាច់ដុំបែរជាចាក់ក្នុងខ្លាញ់ទៅវិញ។

ចេញពណ៌ស្វាយលើស្បែក



- គ្រុនក្តៅខ្លាំង
- មានចំណុចតូចៗដែលបែកគ្រាប់ឈាមក្រោមស្បែក
- ជ្រូកប្រមូលផ្តុំគ្នានិងមិនស្វាហាប់ ហើយស៊ីតិច

ជារឿយៗមានការរាគត្បាតពីជំងឺឱកាសនិយមដែលបង្កដោយបាក់តេរីបណ្តាលទៅជាជំងឺធ្ងន់ធ្ងរដូចជាជំងឺសាល់ម៉ូណែឡូស ជំងឺសារទឹកដែលបង្កជារាគបៃតង និងឬមានក្អកធ្ងន់ធ្ងរហើយស្ទះដង្ហើម។



ជំងឺប៉េស្តជ្រូកសណ្ឋានមិនស្រួចស្រាវ ជ្រូកនៅតែស៊ីចំណី

កូនជ្រូកតិចតួចមានទំហំមិនប៉ុនគ្នានិងខ្សោយ កង្វះទឹកដោះកើតជាទូទៅពេលមានជំងឺប៉េស្តជ្រូក



ការចម្លងបន្ថែមរបស់បាក់តេរី



ជ្រូកមានគ្រុនក្តៅនិងប្រមូលផ្តុំគ្នា



បាក់តេរីរាគត្បាតបណ្តាលឲ្យហូរសំបោរ

### ➢ រោគសញ្ញាចំពោះមេជ្រូក

- រលូតកូន
- កូនកើតមកងាប់
- កូនងាប់ក្នុងពោះឡើងក្រៀម
- កូនជ្រូកកើតមកតូចៗនិងខ្សោយ

រោគសញ្ញាទាំងនេះដូចគ្នានឹងករណី ដែលគេសង្កេតឃើញលើជំងឺគ្រុនចៀកខៀវ ប៉ុន្តែរោគសញ្ញាពិសេស គឺកូនជ្រូកដែលទើបនឹងកើតញាក់ញ័រ ជាសញ្ញាយ៉ាងច្បាស់ពីអនុភាពខ្សោយរបស់វីរុសដែលមានក្នុងកសិដ្ឋានឬការធ្វើវ៉ាក់សាំងមិនបានត្រឹមត្រូវ។

## 4. ស្លាកស្នាម

រោគសញ្ញាពេលខ្លះមិនសូវច្បាស់លើកលែងតែសីតុណ្ហភាពឡើងខ្ពស់ដែលមិនអាចបញ្ចុះកំដៅដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិកប៉ុន្តែស្លាកស្នាមជាក់លាក់អាចមើលឃើញលើសាកសព។

ជាទូទៅសញ្ញាដែលសង្កេតឃើញគឺ:

- មានពណ៌ក្រហមចាស់នៅលើគែមផាល
- ស្នាមក្រហមអុចៗលើសួត
- ហូរឈាម(បែកគ្រាប់ឈាម)ក្នុងក្រពេញទឹករងៃ








## ៥- ការព្យាបាល

ជំងឺបង្កដោយវីរុស មិនមានថ្នាំព្យាបាលទេ។ពេលដែលការធ្វើរោគវិនិច្ឆ័យជំងឺប៉េស្តជ្រូកបានបញ្ជាក់ច្បាស់លាស់ហើយ មិនត្រូវធ្វើការព្យាបាលទេពីព្រោះក្រោយ១០ថ្ងៃនៃការចាក់ថ្នាំអង់ទីប៊ីយ៉ូទិក ជ្រូកអាចនៅរស់ ប៉ុន្តែវាធំលូតលាស់យឺតខ្លាំង ដែលទីបំផុតគឺជាការខាតបង់ប្រាក់។

**ព្យាបាលតាមរោគសញ្ញាគឺ៖**

- ចាក់ថ្នាំបញ្ចុះកំដៅ (ឧទាហរណ៍: ថ្នាំប៉ារ៉ាសេតាម៉ុល (Paracetamol)
- ការពារជំងឺឱកាសនិយម ដោយចាក់ថ្នាំផ្លរ័ហ្វេនីកុល (Florfenicol) ឬ ថ្នាំដុកស៊ីស៊ីគ្លីន(Doxycycline)
- ក្នុងករណីមានរាគដូចទឹកពណ៌បៃតង ឬចាក់ថ្នាំទីឡូស៊ីន(Tylosine) ជាមួយថ្នាំហ្សង់តាមីស៊ីន(Gentamycine) ឬថ្នាំអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin)។
- ចាក់វីតាមីន ឬថ្នាំជំនួយកម្លាំង ។

## ៥-ការការពារ

- ត្រូវចាក់វ៉ាក់សាំងតាមកម្មវិធី ឲ្យបានត្រឹមត្រូវ
- ត្រូវជ្រើសរើសវ៉ាក់សាំងដែលមានគុណភាព ។

**កម្មវិធីចាក់វ៉ាក់សាំងមានដូចខាងក្រោម:**

- កូនជ្រូកចាក់នៅពេលមានអាយុ ៣ទៅ៧អាទិត្យ និងចាក់នៅអាយុ ១១អាទិត្យ។ ចំពោះការចាក់វ៉ាក់សាំងនៅអាយុ៣អាទិត្យមានសារៈសំខាន់ ប្រសិនបើមេជ្រូកមិនបានចាក់ទៀងទាត់។ តែបើមេជ្រូកបានចាក់ទៀងទាត់ ជាពិសេសមួយខែមុនពេលកើតកូននោះ ទឹកដោះដំបូង(Colostrum) និងទឹកដោះនឹងមានអង្គបដិបក្ខ (អង់ទីគ័រ)ជំងឺប៉េស្តជ្រូក ហើយជួយការពារ កូនជ្រូករហូតដល់អាយុ៧អាទិត្យ។
- មេជ្រូកត្រូវចាក់វ៉ាក់សាំងមួយខែមុនពេលកើតកូនដើម្បីបង្កើនអង្គបដិបក្ខ (អង់ទីគ័រ)នៅក្នុងទឹកដោះ។
- មេជ្រូកពេញវ័យ ត្រូវចាក់វ៉ាក់សាំងឡើងវិញនៅអាយុ៦ខែ (ប្រសិនបើទិញមកពីខាងក្រៅដែលមិនប្រាកដថាមានកម្មវិធីចាក់វ៉ាក់សាំងត្រឹមត្រូវ ពេលនៅតូចដូចនេះចាំបាច់ត្រូវចាក់វ៉ាក់សាំងប៉េស្តជ្រូកលើកទីពីរនៅអាយុ៧ខែ)។
- ជ្រូកបាត្រូវចាក់វ៉ាក់សាំងរៀងរាល់៦ខែ។

## ខ-ជំងឺអុតក្តាម (Foot and Mouth Disease)

### ១- មូលហេតុ

- ជំងឺអុតក្តាមបង្កដោយវីរុស
- មិនអាចព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិកបានទេ
- វីរុសអុតក្តាម មាន៧ ប្រភេទលើសកលលោក។ ដោយឡែក ក្នុងប្រទេសកម្ពុជាមាន៣ប្រភេទគឺអូ អា និងអេស៊ីយ៉ា១ (O, A, Asia1)។

### ២- ការចម្លងជំងឺ

- វីរុសមានភាពធន់នឹងបរិយាកាស និងអាចឆ្លងតាមខ្យល់
- តាមខ្យល់ដកដង្ហើម ដោយដំណក់តូចៗចេញតាមរន្ធច្រមុះ ដែលផ្ទុកវីរុស ។ ផ្លូវដកដង្ហើមជាចំណុចសំខាន់ក្នុងការរាតត្បាតជំងឺពីជ្រូកឈឺទៅជ្រូកជា។

- តាមរយៈស្បែកជើង សំលៀកបំពាក់ ដៃ សក់របស់មនុស្សវីរុសជំងឺអុតក្តាម អាចរស់បាន១ទៅ២ថ្ងៃក្នុងបំពង់ដកដង្ហើមរបស់មនុស្ស អាចឆ្លងទៅសត្វ។

ជំងឺអុតក្តាមលើជ្រូកឆ្លងរាលដាលយ៉ាងខ្លាំងនិងមានការពិបាកក្នុងការការពារ។ ការផ្ទុះជំងឺអុតក្តាមរាលដាលយ៉ាងលឿន ក្នុងរយៈពេលពីរ ទៅបី អាទិត្យ។



### ៣- រោគសញ្ញា

- ជាទូទៅជ្រូកលេចចេញរោគសញ្ញាក្នុងរយៈពេល ៣ទៅ៥ថ្ងៃ។
- គ្រុនក្តៅ
- ពងដោរលើជើង មាត់ និងដោះ
- ជ្រូកមានដំបៅធ្ងន់ធ្ងរលើក្រចកជើង និងពងដោរលើចង្វែកជើង វាមិនអាចដើរ មិនអាចស៊ីបាន និងស្រែកថ្ងូរ ព្រោះមានការឈឺចាប់ខ្លាំង
- ពងដោរលេចចេញនៅលើច្រមុះ។






### ៤-ការព្យាបាល

ដើម្បីការពារការឆ្លងចូលជំងឺឪកាសនិយម និង បំបាត់ការឈឺចាប់តែប៉ុណ្ណោះ។

- ចាក់ថ្នាំប៉ារ៉ាសេតាម៉ុល (Paracetamol)
- ចាក់ថ្នាំទ្រីមេតូព្រីម (TMP+Sulfa) ជាមួយស៊ុលហ្វា ឬថ្នាំតេត្រាស៊ីគ្លីន (Tetracycline)
- ការព្យាបាលដោយកន្លែង បន្ទាប់ពីលាងដំបៅជើងជាមួយសាប៊ូ ថ្នាំរម្ងាប់មេរោគ ខាងក្រៅ ដែលផ្សំដោយថ្នាំពណ៌ស្វាយ (Methylen blue) ឬ សង់ទីយ៉ានវីយ៉ូលេ(Gentiane violet)ជាមួយថ្នាំ តេត្រាស៊ី



គ្លីន (Tetracycline) ដោយបាញ់ពីលើ ដំបៅពីរដងក្នុងមួយថ្ងៃ។ ជ្រូកឈឺមិនអាចដើរ និងមិនអាច ស៊ីបាន ដូចនេះចាំបាច់ត្រូវផ្តល់ទឹក និងចំណីឲ្យបានគ្រប់គ្រាន់។

**៥-ការការពារ**

- មានវ៉ាក់សាំងពីរប្រភេទគឺ៖ **វ៉ាក់សាំងវ៉ាឡង់មួយ** (Monovalent) គឺជាវ៉ាក់សាំងដែលអាចប្រឆាំងប្រភេទអូ (ដែលកើតមានជាទូទៅលើជ្រូកក្នុងប្រទេសកម្ពុជា ) និង**វ៉ាក់សាំងបីវ៉ាឡង់** (Trivalent)ប្រឆាំងនឹងប្រភេទអូ អា និងអាស៊ីយ៉ា១។
- ដើម្បីការពារជំងឺអុតក្តាមលើជ្រូកឲ្យមានប្រសិទ្ធភាព ត្រូវចាក់**វ៉ាក់សាំងបីវ៉ាឡង់**ឲ្យបានទៀងទាត់។
- ត្រូវចាក់វ៉ាក់សាំងអុតក្តាមប្រភេទបីវ៉ាឡង់(Trivalent)ឲ្យមេជ្រូកពីរដងក្នុងមួយឆ្នាំ និងចាក់រំលឹក ក្នុងករណីមានផ្ទុះជំងឺនៅក្នុងតំបន់។

## គ-ជំងឺត្រចៀកខៀវ PRRS

**១- មូលហេតុ**

វីរុសរាតត្បាត និងបំផ្លាញម៉ាក្រូហ្វា (Macrophages) ដែលទទួលខុសត្រូវ ក្នុងការចាប់ និងបំផ្លាញមេរោគ ដែលចូលក្នុងរាងកាយ ជាពិសេសតាមសួត។ ការវិវត្តរបស់ជំងឺមានការពាក់ព័ន្ធយ៉ាងជិតស្និតនឹងការចម្លងជំងឺឱកាសនិយម បង្កដោយបាក់តេរី និងមុខងាររបស់វីរុសដ៏ទៃទៀតដូចជាជំងឺប៉េស្តជ្រូក។

**២-ការចម្លងជំងឺ**

- ទឹកមាត់ លាមក ទឹកនោម ទឹកដោះដំបូងរបស់សត្វឈឺ សាយភាយវីរុស
- មនុស្សជាមួយស្បែកជើង សម្លៀកបំពាក់ និងដៃអាចពាំនាំវីរុស
- ម្ជុលប្រើសម្រាប់ចាក់ថ្នាំ អាចចម្លងទៅជ្រូក
- ទឹកកាមរបស់ជ្រូកបាអាចចម្លងវីរុស
- ទាត្រូវបានគេសង្ស័យជាភ្នាក់ងារចម្លងជំងឺនេះដែរ។

**៣-រោគសញ្ញា**

រោគសញ្ញាប្រែប្រួលអាស្រ័យនឹងអនាម័យ និងស្ថានភាពសុខភាពរបស់ជ្រូក។ ប្រភេទខ្លះត្រូវគេហៅថា"ចម្លងជំងឺកម្រិតខ្ពស់"បណ្តាលឲ្យមានជំងឺធ្ងន់ធ្ងរ មានអត្រាងាប់ខ្ពស់។

➢ មេជ្រូក

នៅប្រទេសកម្ពុជារោគសញ្ញាលើមេជ្រូកគឺជាសញ្ញាជំងឺដែលមានសភាពជាក់លាក់ និងច្បាស់លាស់។

- មេជ្រូកមួយចំនួនឈប់ស៊ីចំណីការមិនឃ្លានចំណីនេះនឹងមានរយៈពេលពី៧ទៅ១០ថ្ងៃ
- សីតុណ្ហភាពខ្ពស់ ៤០អង្សាសេ(ចំពោះប៉េស្តជ្រូកសីតុណ្ហភាពលើសពី៤១អង្សាសេ)
- មេជ្រូកជាច្រើនរលូតកូន
- ការកើតកូនមុនពេលកំណត់(មានរយៈពេល១០៨ទៅ១១១ថ្ងៃ)
- ពេលកើត កូនជ្រូកខ្សោយ
- អាចឃើញកូនជ្រូកងាប់ក្រៀមជាច្រើន
- អត្រាកូនងាប់ខ្ពស់ ពេលកើត
- អាចឃើញមេជ្រូកជាច្រើនមានកូនតែ២ -៣ ឬ៤តែប៉ុណ្ណោះ
- កូនជ្រូកបៅដោះ ភាគច្រើនរាគ ដែលមានការលំបាកក្នុងការផ្តាច់ដោះ
- មេជ្រូកខ្លះងាប់


កើតកូនមុនពេលកំណត់មាន កូនជ្រូកងាប់ច្រើនពេលកើត


ការរលូតកូន


សញ្ញាដំបូងឃើញនៅលើជ្រូកដើមគឺវាមិនព្រមស៊ីចំណី៧ទៅ១០ថ្ងៃ

- មេជ្រូកខ្លះបង្ហាញពណ៌ខៀវលើត្រចៀក ដូចនេះហើយបានជាគេហៅ វាថា"ជំងឺត្រចៀកខៀវ" តាមពិតករណីនេះមានដោយកម្រ និងមិនអាចធ្វើរោគវិនិច្ឆ័យនឹងសញ្ញានេះបានទេ។

➢ **កូនជ្រូកក្រោយពេលផ្តាច់ដោះ**

វីរុសជំងឺត្រចៀកខៀវបំផ្លាញ ម៉ាក្រូហ្វាសួត(ប្រព័ន្ធការពាររបស់សួត) និងកូនជ្រូកផ្តាច់ដោះមិនត្រូវបានការពារដោយអង្គបដិបក្ខ(អង់ទីគ័រ) របស់មេទៀតទេ។

- ក្អកខ្លាំង និងពិបាកដកដង្ហើម

- ចុះស្គម រោមស្រអាប់ ស្បែករលាកចេញទឹក
- អត្រាងាប់មានកម្រិត ពេលដែលកូនជ្រូកបានព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក សម្រាប់ការឆ្លងចូលជំងឺឱកាសនិយមហើយកូនជ្រូកធំលូតលាស់យឺតក្នុងដំណាក់កាលបំប៉ន។

➢ **ជ្រូកសាច់ក្នុងដំណាក់កាលបំប៉ន**


ហើមភ្នែក និងហូរទឹកភ្នែក

- គ្រុនក្តៅ និងក្អក ជាពិសេសក្នុងកសិដ្ឋានដែលមានបញ្ហាជំងឺមីកូប្លាស្មា
- ហើមភ្នែក និងមានហូរទឹកភ្នែក
- ស្បែកឡើងក្រហមដូចជាដេកក្រោមពន្លឺព្រះអាទិត្យ
- ស៊ីចំណីថយចុះ និងស្រកទម្ងន់


ស្បែកពណ៌ក្រហមលើមេជ្រូកក្រមុំ


ជំងឺផ្លូវបន្តពូជ និងផ្លូវដង្ហើមត្រូវបានគេហៅថាជំងឺត្រចៀកខៀវ ប៉ុន្តែសញ្ញាពិសេសនេះតិកម្របង្ហាញ

**៤- ការវិវត្តរបស់ជំងឺ**

- មេជ្រូកនិងជ្រូកបាបញ្ចេញវីរុសជំងឺត្រចៀកខៀវ ក្នុងកំឡុងពេលពីរអាទិត្យប៉ុណ្ណោះ ប៉ុន្តែជ្រូកសាច់បញ្ចេញវីរុសជាមធ្យម២ខែ។
- កូនក្នុងពោះឆ្លងជំងឺអំឡុងពេលផើម(ជាពិសេសមេជ្រូកចាប់ឈីបន្ទាប់ពីផើមបាន៧៥ថ្ងៃ)ប្រសិនបើពួកវានៅរស់ កូនជ្រូកនឹងបញ្ចេញវីរុស ក្នុងអំឡុង ពេល៥ខែ។ កូនជ្រូកទាំងនេះខ្សោយពេលកើត ដូចនេះត្រូវយកវាចេញ ។ (ត្រូវប្រុងប្រយ័ត្នពេលទិញកូនជ្រូក ដែលមិនដឹងប្រភពច្បាស់លាស់!)។
- កូនជ្រូកក្រោយពេលផ្តាច់ដោះងាយទទួលជំងឺ ពីព្រោះភាពស៊ាំរបស់វាទាប
- ជ្រូកសាច់ដែលបញ្ចេញវីរុសរយៈពេលពីរខែ ដោយគ្មានរោគសញ្ញាបាន ចម្លង វីរុសទៅលើកូនជ្រូកដែលខ្សោយ វីរុសបានបំបែកខ្លួនយ៉ាងច្រើនក្នុង ខ្លួនកូនជ្រូក។

### ៥- ការធ្វើរោគវិនិច្ឆ័យ

ការវិភាគរកមេរោគបង្កជំងឺ មិនអាចឆាប់ដឹងលទ្ធផលទេ។ការយកវត្ថុវិភាគដើម្បីវិភាគនៅមន្ទីរពិសោធន៍ត្រូវយកឈាមពីជ្រូកយ៉ាងតិច១២ក្បាល ។ការវិភាគ មិនអាចញែកឲ្យខុសគ្នារវាងជ្រូក ដែលកើតជំងឺគ្រុនចៀកខៀវ និងជ្រូកដែលបានចាក់ វ៉ាក់សាំងជំងឺគ្រុនចៀកខៀវនេះទេ។

### ៦- ការព្យាបាល

ជំងឺបង្កដោយវីរុស គ្មានថ្នាំព្យាបាលឲ្យបានជាក់លាក់ទេប៉ុន្តែអាចប្រើប្រាស់ថ្នាំជួយកាត់បន្ថយឥទ្ធិពលរបស់ជំងឺ។

- មេជ្រូកដើម ត្រូវលាយថ្នាំដុកស៊ីស៊ីគ្លីន (Doxycycline) ក្នុងចំណីរយៈពេល ៦អាទិត្យ ប្រសិនបើជ្រូកខ្លះមិនស៊ី ត្រូវចាក់ថ្នាំតេត្រាស៊ីគ្លីន ដែលមានសកម្ម ភាពវែង ។
- ត្រូវចាក់ថ្នាំតេត្រាស៊ីគ្លីន(Tetracycline)ដែលមានសកម្មភាពវែងនៅ២ថ្ងៃ មុនពេលកើតកូន។
- មេជ្រូកបំបៅដោះ ត្រូវចាក់ថ្នាំតេត្រាស៊ីគ្លីន(Tetracycline)ដែលមានសកម្មភាពវែងនៅថ្ងៃកើតកូន និងក្រោយមកទៀត
- ត្រូវលាយថ្នាំដុកស៊ីស៊ីគ្លីន(Doxycycline)ក្នុងចំណីរយៈពេលមួយខែ។
- កូនជ្រូកនៅពេលផ្តាច់ដោះ ត្រូវលាយថ្នាំផ្លរ៉ហ្វេនីកុល(Florfenicol)ក្នុងចំណី គ្រាប់នៅមួយអាទិត្យ មុនពេលផ្តាច់ដោះ និងបន្តពីរអាទិត្យទៀតបន្ទាប់ពី ផ្តាច់ ដោះ។
- កូនជ្រូកក្រោយពេលផ្តាច់ដោះ និងជ្រូកសាច់ ត្រូវព្យាបាលអាស្រ័យលើរោគ សញ្ញា។ ប្រើថ្នាំអង់ទីប៊ីយ៉ូទិកប្រឆាំងនឹងជំងឺផ្លូវដង្ហើម និងប្រឆាំងគ្រុនក្តៅ។

### ៧- ការការពារ

ត្រូវអនុវត្តវិធានជីវសុវត្ថិភាពរួមមាន៖

- ត្រូវប្រុងប្រយ័ត្នចលនាចេញ ចូលក្នុងកសិដ្ឋាន ជាពិសេស ចំពោះបសុពេទ្យ ភ្នាក់ងារសុខភាពសត្វភូមិ ឬកសិករដទៃទៀត
- មុនចូលកសិដ្ឋាន ត្រូវផ្លាស់ប្តូរសម្លៀកបំពាក់ ស្បែកជើង និងលាងដៃនឹងសាប៊ូ
- មិនត្រូវទិញកូនជ្រូកក្រោយពេលផ្តាច់ដោះ ពីកន្លែងដែលមិនស្គាល់ប្រភពច្បាស់លាស់ទេ
- ប្រើប្រាស់ម្ជុលផ្សេង និងស្អាត សម្រាប់ចាក់ឲ្យជ្រូកក្រុមផ្សេងគ្នាក្នុងកសិដ្ឋាន។

- **ការធ្វើវ៉ាក់សាំង**
  - វីរុសជំងឺត្រចៀកខៀវមានប្រភេទវីរុសផ្សេងៗគ្នាហើយអាចផ្លាស់ប្តូរទម្រង់បានយ៉ាងងាយ
  - ក្នុងពេលផ្ទុះជំងឺត្រចៀកខៀវ បណ្តាលឲ្យមានសត្វងាប់ ហើយវ៉ាក់សាំងមិនអាចប្រើ ដើម្បីទប់ស្កាត់ការផ្ទុះជំងឺបានទេ
  - វ៉ាក់សាំងជាប្រភេទវ៉ាក់សាំងរស់ ពេលចាក់វ៉ាក់សាំងគឺបញ្ចូលវីរុស នៅ ក្នុងកសិដ្ឋាន ហើយវីរុសអាចឆ្លងពីជ្រូកទៅជ្រូក និងផ្លាស់ប្តូររូបរាង
  - វ៉ាក់សាំងជំងឺត្រចៀកខៀវអាចប្រើបានតែនៅក្នុងកសិដ្ឋានដែលបានឆ្លងមេរោគរួចហើយ ដើម្បីជម្រុញការជួយសង្គ្រោះកូនជ្រូកទើបកើត និងជម្រុញទិន្នផលបន្តពូជ។

## ឃ-ជំងឺផ្លូវដង្ហើម

១- ក្អករ៉ាំរ៉ៃ

- **បង្កដោយមេរោគមីកូប្លាស្មា**
  - មេរោគមីកូប្លាស្មាបំផ្លាញផ្លូវដង្ហើមនិងមានការឆ្លងចូលជំងឺឱកាសនិយមដូចជាពពួកប៉ាស្ទឺរ៉ែឡា ដែលបង្កឲ្យមានជំងឺសួតធ្ងន់ធ្ងរ
  - សីតុណ្ហភាពខុសគ្នា រវាងពេលថ្ងៃនិងពេលយប់(ប្រហែល១០អង្សាសេ) សម្រួលដល់ការលូតលាស់របស់ពពួកមីកូប្លាស្មា។

<u>រោគសញ្ញា</u>



មីកូប្លាស្មា: បណ្តាលឲ្យជ្រូកក្អក

- ក្អករន្ថើនពី៧ទៅ៨ដងក្នុង ពេល ក្អកម្តងៗ
- ក្អកខ្លាំងនៅពេលព្រឹក
- គ្រុនក្តៅ សីតុណ្ហភាព ៣៩.៥ អង្សាសេ
- មិនសូវស៊ីចំណី
- មេរោគមីកូប្លាស្មាបានរាតត្បាតក្នុងកសិដ្ឋាន និងធ្វើឲ្យជ្រូកចាប់ ផ្តើម ក្អក ពេលមានអាយុ២ខែ ។
- បន្ទាប់ពីព្យាបាល ក្អកបានធូរស្រាល ប៉ុន្តែជារឿយៗក្អកនឹងរើឡើងវិញ បន្តរហូតដល់ពេលលក់។

- ជ្រូកចាប់ផ្ដើមក្អកនៅអាយុ២ខែ ដែលពួកវាបានឆ្លងមេរោគតាំងពីថ្ងៃ ដំបូងក្រោយពេលផ្ដាច់ដោះ។

ការព្យាបាល

ត្រូវប្រើថ្នាំអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ឬដុកស៊ីស៊ីគ្លីន (Doxycycline) ឬទីឡូស៊ីន (Tylosin) ឬផ្លរហ្វេនីកុល (Florfenicol)។

**អាម៉ុកស៊ីស៊ីលីន(Amoxicilline)មិនមានប្រសិទ្ធភាពប្រឆាំងនឹងមីកូប្លាស្មាទេ។** ពេលដែលប្រើអាម៉ុកស៊ីស៊ីលីន ជារឿយៗជ្រូកមានសភាពគ្រាន់ បើក្នុងពេលព្យាបាលព្រោះថ្នាំអង់ទីប៊ីយ៉ូទិកនេះសម្លាប់បាក់តេរីផ្សេង ៗទៀតដូចជាប៉ាស្ទឺរ៉ែឡា ប៉ុន្តែក្រោយមកពីរបីថ្ងៃ បន្ទាប់ពីការព្យាបាល បានបញ្ចប់ ក្អកចាប់ផ្ដើមឡើងវិញ និងក្អកខ្លាំងជាងមុន។

ការការពារ

- បន្ទាប់ពីផ្ដាច់ដោះ ត្រូវលាយថ្នាំដុកស៊ីស៊ីគ្លីន ឬផ្លរហ្វេនីកុល ក្នុង ចំណី ឲ្យកូនជ្រូកស៊ីភ្លាមៗប្រើរយៈពេល១០ទៅ១៥ថ្ងៃព្រោះកូន ជ្រូក គ្មាន អង្គបដិបក្ខ(អង់ទីគ័រ)ដែលទទួលបានពីទឹកដោះមេនិងបានឆ្លងមេរោគ។
- ពេលផ្លាស់ប្ដូរទ្រុង (ទីកន្លែង) ទៅទ្រុងបំប៉ន ក្រោយពេលផ្ដាច់ដោះ កូនជ្រូកងាយស្ត្រេស មេរោគមីកូប្លាស្មាអាចឆ្លងចូល ដូច្នេះត្រូវលាយថ្នាំ តេត្រាស៊ីគ្លីន ឬដុកស៊ីស៊ីគ្លីន ឬទីឡូស៊ីនឬ ផ្លរហ្វេនីកុលក្នុងចំណី ប្រើរយៈពេលពី៥ ទៅ៧ថ្ងៃ ។

## ➢ បង្កដោយវីរុសផ្ដាសាយជ្រូក

ជំងឺផ្ដាសាយជ្រូកបង្កដោយវីរុស ហាស១អិន១(H1N1) ដែលអាចបណ្ដាលឲ្យមានការ ប៉ះពាល់ដល់សុខភាពមនុស្ស ។ មកទល់ពេលនេះវីរុសនេះមិនត្រូវបានរកឃើញលើជ្រូកក្នុងប្រទេសកម្ពុជាទេ។

រោគសញ្ញា

**ជំងឺស្រួចស្រាវបំផុត:** ជ្រូកឃើញមានសុខភាពល្អ ហើយចាប់ឈឺ មានអត្រា ៩០% ៖

- ក្អកធ្ងន់ធ្ងរនិងដកដង្ហើមខ្លាំងសីតុណ្ហភាពលើសពី៤០អង្សាសេ។



ក្នុងករណីផ្ដាសាយជ្រូក៩០%ឈឺ ពួកវាមិនសកម្មនិងក្រោកឈរពេលក្អកតែប៉ុណ្ណោះ

<u>ការព្យាបាល</u>

- គ្មានថ្នាំព្យាបាលទេ
- ត្រូវចាក់ថ្នាំអុកស៊ីតេត្រាស៊ីគ្លីនរយៈពេល៣ទៅ៥ថ្ងៃ ដើម្បីការពារជំងឺឱកាសនិយម បង្កដោយបាក់តេរី ដូចជាពពួកប៉ាស្ទឺរ៉ែឡា មីកូប្លាស្មា... ។



២-ពិបាកដកដង្ហើម

❖ ជំងឺសារទឹក

ជារឿយៗជំងឺសារទឹក មានលាយឡុកឡំជាមួយ មេរោគមីកូប្លាស្មា។

<u>រោគសញ្ញា</u>

- ខ្ទុះហូរចេញពីច្រមុះ
- ក្អករយៈពេលខ្លី និងមានការឈឺចាប់
- ដកដង្ហើមញាប់
- គ្រុនក្តៅលើសពី៤០អង្សាសេ
- ស្បែកពណ៌ខៀវ ជាពិសេសនៅផ្នែកចុងត្រចៀក (ប៉ុន្តែមិនមែនជំងឺ ត្រចៀកខៀវទេ)។

<u>ការព្យាបាល</u>

- ថ្នាំតេត្រាស៊ីគ្លីន( Tetracycline) ឬផ្លរ័ហ្វេនីកុល( Florfenicol) ឬអង់រ៉ូផ្លុក សាក់ស៊ីន(Enrofloxacine)ក្នុងករណីធ្ងន់ធ្ងរ ចាក់កម្រិតទ្វេរដង ក្នុងថ្ងៃទី១
- ចំពោះថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន អាចបណ្តាលឲ្យមានភាពស៊ាំ ក្រោយមកការប្រើថ្នាំនេះនឹងមិនមានប្រសិទ្ធភាពទៀតទេ... ។

<u>ការការពារ</u>

- ត្រូវធ្វើការត្រួតពិនិត្យ ពួកមីកូប្លាស្មាឲ្យបានត្រឹមត្រូវ
- **ការចាក់វ៉ាក់សាំងជំងឺសារទឹកជ្រូក មិនសូវមានប្រសិទ្ធភាពទេ នៅពេលមានវត្តមានប៉ាស្ទឺរ៉ែឡារស់នៅក្នុងបំពង់ដកដង្ហើម ពួកវានឹងបំបែកខ្លួន ហើយរាតត្បាតទៅសួតនៅពេលជ្រូកចុះខ្សោយ។**
- ថ្នាំតេត្រាស៊ីគ្លីន( Tetracycline) ឬផ្លរ័ហ្វេនីកុល( Florfenicol) ឬអង់រ៉ូផ្លុកសាក់ស៊ីន(Enrofloxacine) ក្នុងករណីធ្ងន់ធ្ងរ ចាក់កម្រិតទ្វេរដង ក្នុងថ្ងៃទី១។
- ចំពោះថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន អាចបណ្តាលឲ្យមានភាពស៊ាំក្រោយមកការប្រើថ្នាំនេះនឹងមិនមានប្រសិទ្ធភាពទៀតទេ... ។

<u>ការការពារ</u>

- ត្រូវធ្វើការត្រួតពិនិត្យ ពួកមីកូប្លាស្មាឲ្យបានត្រឹមត្រូវ
- **ការចាក់វ៉ាក់សាំងជំងឺសារទឹកជ្រូក មិនសូវមានប្រសិទ្ធភាពទេ នៅពេលមានវត្តមានប៉ាស្ទឺរ៉ែឡារស់នៅក្នុងបំពង់ដកដង្ហើម ពួកវានឹងបំបែកខ្លួន ហើយរាតត្បាតទៅសួត នៅពេលជ្រូកចុះខ្សោយ។**



❖ **ជំងឺអាក់ទីណូបាក់ស៊ីលុស** បង្កដោយបាក់តេរី

<u>រោគសញ្ញា</u>

- ស្រួចស្រាវបំផុត ការសម្ងំជំងឺមានរយៈ ពេល ១២ម៉ោង
- បែកពពុះនិងមានឈាមហូរតាមច្រមុះ
- ក្អកខ្លីគឺ១ទៅ៣ដងក្នុងមួយពេល
- ពិបាកដកដង្ហើមខ្លាំង
- គ្រុនក្តៅលើសពី៤០អង្សាសេ
- សត្វអស់កម្លាំងខ្លាំង ហើយងាប់។

<u>ការព្យាបាល</u>

- ប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាអាម៉ុកស៊ីស៊ីលីន ឬទ្រីមេតូព្រីមជាមួយស៊ុលហ្វា ឬអង់រ៉ូផ្លុកសាក់ស៊ីន។

**៣-ពិនិត្យស្លាកស្នាមលើសួត**

ស្លាកស្នាមមានលើសួតគឺខុសគ្នាសម្រាប់គ្រប់ប្រភេទជំងឺទាំងអស់។ ជាការចាំបាច់ត្រូវត្រួតពិនិត្យសួតពេលជ្រូកងាប់ ករណីជំងឺសារទឹក និងករណីជំងឺអាក់ទីណូបាក់ស៊ីលុស។ ស្លាកស្នាមរបស់ជំងឺមីកូប្លាស្មាអាចឃើញក្នុងពេលពិឃាត ព្រោះទូទៅជ្រូកមិនងាប់ដោយសារជំងឺមីកូប្លាស្មាទេ។








## ង-ជំងឺរលាកពោះវៀន

### ១- ជំងឺពាគ

➢ **ជំងឺអ៊ីកូលីលើកូនជ្រូកទើបកើត**






រោគសញ្ញា

- កើតលើកូនជ្រូកអាយុក្រោម៥ថ្ងៃ
- លាមករាគពណ៌លឿងខាប់លាយសំបោរប្រឡាក់ជុំវិញគូថនិងកន្ទុយ
- ខ្វះជាតិទឹក

ការព្យាបាល

- ត្រូវព្យាបាលកូនជ្រូកទាំងអស់ក្នុងសំបុក ជាមួយថ្នាំកូលីស្ទីន ជាមួយអំពីស៊ីលីន (Colistin+Ampicillin) ចាក់១ថ្ងៃ ២ដង (ពេលព្រឹក និងល្ងាច)
- ចំពោះមេជ្រូកត្រូវព្យាបាលដោយប្រើថ្នាំទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (TMP+Sulfa) ដើម្បីកាត់បន្ថយការឆ្លងលើទឹកដោះដោយមេរោគអ៊ីកូលី។

ការការពារ

- ត្រូវជួយឲ្យកូនជ្រូកបានបៅទឹកដោះដំបូង បន្ទាប់ពីកើតភ្លាម ព្រោះទឹកដោះមានអង្គបដិបក្ខ(អង់ទីគ័រ)ដែលប្រឆាំងនឹងមេរោគអ៊ីកូលី
- ការពារមិនឲ្យកូនជ្រូកត្រជាក់ និងប៉ះត្រូវខ្យល់ខ្លាំង ពីព្រោះពេលត្រជាក់ មេរោគអ៊ីកូលីនឹងបំបែកខ្លួន
- ត្រូវរៀបចំធ្វើសំបុកឲ្យបានសមស្របហើយពេលយប់ត្រូវរៀបចំប្រដាប់កំដៅកូនជ្រូក។

➢ **ជំងឺកុកស៊ីដ្យូស**



រោគសញ្ញា

- កើតលើកូនជ្រូកអាយុពី៧ទៅ ២១ថ្ងៃ បន្ទាប់ពី កើត
- រាគពណ៌លឿងប្រែទៅជាពណ៌ខៀវប្រផេះ
- រាគខាប់ដូចមានលាយជាតិក្រែម
- កូនជ្រូកស្គមប៉ុន្តែងាប់មិនកើតជាទូទៅទេ។

<u>ការព្យាបាល</u>

មានការលំបាកក្នុងការព្យាបាល។ ត្រូវចាក់ថ្នាំដូចជាស៊ុលហ្វាឌីមីឌីន ឬស៊ុលហ្វាឌីមេតូស៊ីន (Sulfadimidine orsulfadimethoxine)។

<u>ការការពារ</u>

ប្រើថ្នាំដែលមានប្រសិទ្ធភាពបំផុត ដូចជា តុលត្រាស៊ុយរីល Toltrazuril (អង់ទីកុកឬបេកុក anticoc, baycox) ច្រកតាមមាត់ នៅអាយុបីថ្ងៃ បន្ទាប់ពីកើត ។

- **ជំងឺរាគឈាមកូនជ្រូក បង្កដោយមេរោគក្លូស្រ្ទីដ្យូម**

<u>រោគសញ្ញា</u>

- កើតលើកូនជ្រូកអាយុ១ទៅ៧ថ្ងៃ បន្ទាប់ពីកើត
- រាគមានឈាម ក្លិនស្អុយខ្លាំង
- អត្រាងាប់ខ្ពស់
- ជាទូទៅកើតលើជ្រូកដែលចិញ្ចឹមលែង


គ្រោះថ្នាក់ខ្ពស់សម្រាប់ជ្រូកទាំងនេះ ក្នុងការជួបពពួកក្លូស្ទ្រីឌីយ៉ូមក្នុងភក់

<u>ការព្យាបាល</u>

ត្រូវចាក់ ឬច្រកថ្នាំអង់ទីប៊ីយ៉ូទិក ដូចជា អាម៉ុកស៊ីស៊ីលីន ។

- **អ៊ីកូលីចំពោះកូនជ្រូកផ្តាច់ដោះ**

<u>រោគសញ្ញា</u>

- ជាទូទៅកើតលើកូនជ្រូកក្នុងអំឡុងពេល ៥ទៅ៧ថ្ងៃក្រោយពេលផ្តាច់ដោះ
- រាគមានសភាពស្អិតដោយផ្លាស់ប្តូរពីរាវទៅខាប់
- លាមកប្រែពណ៌ពីប្រផេះលឿងទៅបៃតង។
- ខ្វះជាតិទឹក ធ្វើឲ្យស្រកទម្ងន់លឿន។




<u>ការព្យាបាល</u>

ប្រើថ្នាំអង់ទីប៊ីយ៉ូទិកដូចជា កូលីស្ទីន(Colistin ) ឬទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa )ឬហ្សង់តាមីស៊ី( Gentamycin) ឬអង់រ៉ូផ្លុកសាក់ស៊ីន( Enrofloxacin) ។

<u>ការការពារ</u>

- សម្រាប់កូនជ្រូកផ្តាច់ដោះ ត្រូវរៀបចំទ្រុងមិនឲ្យខ្យល់បក់ចំខ្លាំង និងត្រូវផ្តល់កំដៅ ជាពិសេសនៅពេលយប់។

- ផ្តល់ចំណីពិសេសសម្រាប់កូនជ្រូកផ្តាច់ដោះ ពីព្រោះប្រដាប់រំលាយអាហាររបស់កូនជ្រូកនៅខ្សោយ មិនធ្លាប់រំលាយវត្ថុរឹងនោះទេ ដូច្នេះការផ្តល់ចំណី ផ្សំស្រេចជួយសម្រួលការរំលាយអាហាររបស់កូនជ្រូក។
- ត្រូវលាយថ្នាំកូលីស្ទីនក្នុងចំណីនៅអាទិត្យទី១ បន្ទាប់ពីផ្តាច់ដោះ ។

➢ **រាគប្រផេះ ឬជំងឺរលាកពោះវៀន(អីលីទីស)**



រោគសញ្ញា

- ជ្រូកសាច់ ឬមេជ្រូករាគពុំរ៉ៃ ពណ៌ប្រផេះ
- ជួនកាលរាគស្រួចស្រាវមានឈាម ធ្វើឲ្យជ្រូកស្លេក ស្លាំងសត្វចុះស្គម ។

ការព្យាបាល

ប្រើថ្នាំដូចជា ទីឡូស៊ីន (Tylosin ) ឬ ទីឡូស៊ីន ជាមួយហ្សង់ តាមីស៊ីន (Tylosin + Gentamycin) ឬទីយ៉ាមុយលីន ( Tiamulin)។

➢ **ជំងឺសាល់ម៉ូណែឡូស**

ជារឿយៗជំងឺសាល់ម៉ូណែឡូសជាជំងឺឱកាសនិយមលើជ្រូក ដែលកើតជំងឺប៉េស្ត។



រោគសញ្ញា

- រាគរាវដូចទឹកលាយឈាមក្លិនស្អុយខ្លាំង
- ក្អក មានការឈឺចាប់
- ស្បែកពណ៌ក្រហម
- កន្ទុយ និងត្រចៀក មានពណ៌ខៀវ
- សត្វមានសភាពលឿង ព្រោះខូចថ្លើម។

ការព្យាបាល

មានការលំបាកក្នុងការព្យាបាល

ប្រើថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា ឬ អង់រ៉ូផ្លុកសាក់ស៊ីន។

ការការពារ

- មិនត្រូវចាក់វ៉ាក់សាំងទេ
- ត្រូវមានអនាម័យឲ្យបានល្អ បាញ់ថ្នាំ រម្ងាប់មេរោគ និងកម្ចាត់កណ្តុរ។

## ២- ជំងឺទល់លាមក

- ការទល់លាមក បណ្តាលមកពីលាមកស្ងួត
- មេជ្រូកផើមអាចប្រឈមនឹងការទល់លាមក
- ជំងឺទាំងអស់ ដូចជា ជំងឺប៉េស្ត ជំងឺត្រចៀកខៀវបណ្តាលឲ្យកំដៅឡើងខ្លាំងដែលធ្វើឲ្យសត្វមិនចង់ស៊ីចំណី បន្ទាប់មកនឹងទល់លាមក។



➢ **មុនពេលកើតកូន**

- ជាទូទៅពេលមេជ្រូកប្តូរទៅទ្រុងសម្រាប់កើតកូន ពី៧ទៅ១០ថ្ងៃមុនពេលកើតបណ្តាលឲ្យមេជ្រូកស្ត្រេសយ៉ាងខ្លាំង មេជ្រូកមិនចង់ស៊ីចំណីពី២ទៅ៣ថ្ងៃ ដែលបណ្តាលឲ្យមានការទល់លាមក អាចបង្កឲ្យមានការលំបាកក្នុងការកើតកូន។
- ចាំបាច់ត្រូវផ្លាស់មេជ្រូកយ៉ាងហោចឲ្យបាន១០ថ្ងៃ មុនពេលកើតកូន។ក្នុងអំឡុងពេលនេះមេជ្រូកមិនចង់ចំណី បន្ទាប់ពី៣ទៅ៤ថ្ងៃ មេជ្រូកនឹងស៊ីចំណីធម្មតាឡើងវិញ ហើយការទល់លាមកនឹងបាត់ទៅវិញ។
- មិនត្រូវបន្ថយចំណីមុនពេលកើតកូនទេត្រូវបន្ថែមចំណីរហូតដល់៤គីឡូក្រាមជាការប្រសើរវាជួយការពារការទល់លាមក និងផ្តល់ថាមពលបន្ថែមក្នុងពេលកើតកូន។
- មេជ្រូកធាត់មុនពេលកើតកូន មិនជាការប្រសើរទេ ដូចនេះត្រូវត្រួតពិនិត្យជាប្រចាំក្នុងអំឡុងពេលផើម
- ការកាត់បន្ថយចំណីក្នុងអាទិត្យចុងក្រោយនៃការផើមនឹងមិនមានប្រសិទ្ធភាពលើរាងកាយទេ ប៉ុន្តែវាជះឥទ្ធិពលដល់កូនជ្រូកទើបកើត និងធ្វើឲ្យការកើតកូនមានការលំបាក។

<u>ការព្យាបាល</u>

- ត្រូវដេញឲ្យមេជ្រូកដើរ
- ត្រូវផ្តល់បន្លែស្រស់
- ផ្តល់ប្រេងប៉ារ៉ាហ្វីន (៣០០មីល្លីលីត្រក្នុងមួយថ្ងៃ) ។

➢ **បញ្ហាលើរូបមន្ត ផ្សំចំណី**


កន្ទក់ស្រូវសំឡីមានជាតិសរសៃច្រើន មានគុណប្រយោជន៍សម្រាប់មេជ្រូក

បរិមាណជាតិសសៃក្នុងចំណីមានសារៈសំខាន់ ដើម្បីការពារការទល់លាមកចំពោះមេជ្រូក។ មេជ្រូកស៊ីចំណីធម្មតាតែវាទល់លាមកក្នុងពេលផើមជាការចាំបាច់ត្រូវពិនិត្យរូបមន្តចំណីថាតើចំណីមានផ្ទុកជាតិសសៃគ្រប់គ្រាន់ដែរទេ។ ប្រភពសំខាន់របស់ជាតិសសៃគឺកន្ទក់ជាពិសេសកន្ទក់ស្រូវសាឡីគុណភាពលេខពីរ។

**៣-បញ្ហាមិនស៊ីចំណី:**

**៣.១ សីតុណ្ហាភាព ឡើងខ្ពស់**

<u>មូលហេតុ</u>

- មានមេរោគឆ្លងចូលក្នុងឈាម ដែលបង្កជាជំងឺក្នុងឈាម ឧទាហរណ៍ដូចជាកញ្ច្រិល
- កូនជ្រូកងាប់ក្នុងពោះហើយ មិនធ្លាក់
- សុក ឬចំណែកសុកមិនធ្លាក់
- រលាកប្លោកនោម ឬរលាកតម្រងនោម ដោយសារមេរោគឆ្លងចូលក្នុងប្លោកនោម និងបន្តទៅដល់តម្រងនោម។


កូនជ្រូកចុងក្រោយ រឺសុកមិនអាចបញ្ចេញមកក្រៅ បណ្តាលឲ្យមេជ្រូកហូរឈាម


ការឆ្លងមេរោគក្នុងប្លោកនោម បណ្តាលឲ្យហូរឈាម ចំណុចសំខាន់ត្រូវត្រួតពិនិត្យដែលឈឺអោយបានល្អ

<u>រោគសញ្ញា</u>

- គ្រុនក្តៅលើសពី៤០អង្សាសេ នៅពេលព្រឹកព្រលឹម
- មេជ្រូកមិនអាចស៊ី
- ការឆ្លងស្រួចស្រាវ ជារឿយៗសត្វចុះខ្សោយខ្លាំង

- ការហូរខ្ទុះ នឹងសង្កេតឃើញពីរបីថ្ងៃ ក្នុងករណីមានការឆ្លងចូលមេរោគក្នុងឈាម
- អាចមានសញ្ញាផ្សេងទៀតរបស់ជំងឺ ហើយរោគសញ្ញាទាំងនោះនឹង លេចឡើង បន្ទាប់ពី២ទៅ៣ថ្ងៃ ពេលដែលជំងឺវិវត្តក្នុងកសិដ្ឋាន។

**ចំណាំ: ជំងឺប៉េស្ត** ដែលកើតមានច្រើនថ្ងៃលើជ្រូក ដោយសីតុណ្ហភាពឡើងខ្ពស់ ហើយការចាក់ថ្នាំអង់ទីប៊ីយ៉ូទិក គ្មានប្រសិទ្ធភាព ត្រូវសង្ស័យថាជាជំងឺប៉េស្តជ្រូក។ ដូចនេះត្រូវពិនិត្យកសិដ្ឋានម្តងទៀត ហើយនៅពីរបីថ្ងៃបន្ទាប់ នឹងធ្វើការវះកាត់ ដើម្បីកំណត់ពីសញ្ញាទូទៅរបស់ជំងឺប៉េស្តជ្រូក។

<u>ការព្យាបាល</u>

- ត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពទូលាយឲ្យបានឆាប់ ដូចជាថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន ឬតេត្រាស៊ីគ្លីនត្រូវចាក់កម្រិតទ្វេដងនៅថ្ងៃទី១
- ថ្នាំប៉ារ៉ាសេតាម៉ុល។

**៣.២ ដោយសារដំបៅក្រពះ**

<u>មូលហេតុ</u>

- ជាតិសសៃក្នុងចំណីមិនគ្រប់គ្រាន់
- គុណភាពវត្ថុធាតុដើមក្នុងចំណីមិនល្អ ។



ដំបៅក្រពះមាននយ័ថាដាច់រលាត់ក្រពះ វាមានការឈឺចាប់និងចេញឈាម

<u>រោគសញ្ញា</u>

- សីតុណ្ហភាពធម្មតា
- ដំបៅក្រពះ កើតមានជាទូទៅលើ មេជ្រូក និងជ្រូកសាច់
- មិនស៊ីចំណី
- ស្បែកស្លេកស្លាំង ដោយមានចេញឈាមក្នុងក្រពះ
- ទល់លាមក លាមកពណ៌ខ្មៅ ដោយសារការរំលាយអាហារមានលាយឈាម
- ក្អួត

<u>ការព្យាបាល</u>

- ផ្តល់ចំណីស្រស់
- ផ្តល់ចំណី៤ទៅ៥ដងក្នុងមួយថ្ងៃ ដោយលាយជាមួយទឹក ដើម្បីឲ្យចំណីទន់
- ចាក់ថ្នាំកម្លាំងដូចជាវីតាមីនចម្រុះ ដើម្បីបង្កើនការស៊ីចំណី និងវីតាមីនបេ១២ (Vitamin B12) ដើម្បីកុំឲ្យស្លេកស្លាំង។

### ៤- បញ្ហាមកពីព្រូន

<u>រោគសញ្ញា</u>

- ពេលមានព្រូនឆ្លងចូលច្រើនអាចឃើញព្រូន ក្នុងលាមព្រូនមានប្រវែងពី២៥០ម.មទៅ ៤០០ម.ម
- ព្រូនក្នុងពោះវៀនស្រូបយកចំណី ដែលធ្វើឲ្យ រាងកាយសត្វចុះខ្សោយ។
- ការបម្លាស់ទីរបស់កូនព្រូន ចូលក្នុងសួត បណ្តាលឲ្យសត្វក្អក។




<u>ការព្យាបាល</u>

ត្រូវចាក់ថ្នាំឡេវាមីសូល ឬអ៊ីវែម៉ិចទីន ១% : ១មីល្លីលីត្រសម្រាប់៣០គីឡូក្រាមទម្ងន់សត្វរស់។

<u>ការការពារ</u>

- ត្រូវចាក់ថ្នាំអ៊ីវែម៉ិចទីន ១% : ១មីល្លីលីត្រ សម្រាប់ ៣០គីឡូក្រាមឲ្យមេជ្រូកនៅពីរអាទិត្យ មុនពេលកើតកូន
- ត្រូវចាក់ថ្នាំអ៊ីវែម៉ិចទីន ១% : ឲ្យកូនជ្រូក មុនពេលផ្តាច់ដោះ។

### ច-ខ្វកជើង (LAMENESS)

ដើម្បីសង្កេតមើលជ្រូកខ្វកជើង ត្រូវឲ្យជ្រូក ឬមេជ្រូកទាំងអស់ក្រោកឈរ ដើម្បីធ្វើរោគវិនិច្ឆ័យ និងការព្យាបាល។

**បញ្ហាខ្វកជើង៖**

- ធ្វើឲ្យមេជ្រូកផឹកទឹកមិនគ្រប់គ្រាន់ បណ្តាលឲ្យកើតជំងឺរលាកផ្លោកនោម
- ធ្វើឲ្យជ្រូកស៊ីចំណីមិនគ្រប់គ្រាន់ បណ្តាលឲ្យក្តៀន និងការលូតលាស់មិនល្អ
- ធ្វើឲ្យសត្វទទួលរងបញ្ហាមួយចំនួនដូចជាស្ត្រេស បណ្តាលឲ្យសត្វចុះខ្សោយ និងភាពស៊ាំធ្លាក់ទាប ក្នុងការទប់ទល់នឹងជំងឺ។

**១-ការរលាកសន្លាក់ឆ្អឹង**

រលាកសន្លាក់ឆ្អឹង បង្កដោយបាក់តេរី។ បាក់តេរីពពួកស្ត្រិបតូកុកគុសច្រើនកើតលើកូនជ្រូកបៅដោះ។ មេរោគដ៏ទៃទៀត អាចបណ្តាលឲ្យរលាកសន្លាក់ឆ្អឹងដែរ ដូចជាមេរោគជំងឺកញ្ច្រិល។





**រោគសញ្ញា**

- ខ្វក់ជើង
- ហើមសន្លាក់
- កូនជ្រូកឈឺចាប់
- មិនចង់ក្រោកឈរ។

**ការព្យាបាល**

ប្រើថ្នាំឡាំងកូមីស៊ីន(Lincomycin) ឬអាម៉ុកស៊ីស៊ីលីន(Amoxicillin) ឲ្យបានឆាប់ ដើម្បីការពាររលាកសន្លាក់ឆ្អឹងរ៉ាំរ៉ៃ។

**ការការពារ**

ចំពោះកូនជ្រូកទើបកើតបាន១ថ្ងៃ ត្រូវចាក់ថ្នាំអាម៉ុកស៊ីស៊ីលីន(Amoxicillin LA) ដែលមានសកម្មភាពវែង ០,៥មីលីលីត្រ ។

## ២-ការពុកស្អុយក្រចកជើង

ការពុកស្អុយក្រចកជើង កើតលើចង្វែក និងកជើង។ ជាទូទៅកើតលើមេជ្រូក ដែលចិញ្ចឹមលើកម្រាលមិនល្អ។

**មូលហេតុ**


មិនត្រូវចិញ្ចឹមជ្រូកលើ កម្រាលបែបនេះទេ

ជាទូទៅដោយសារកម្រាលទ្រុងធ្វើអំពីស៊ីម៉ង់ត៍មិនល្អទ្រុងមិនត្រូវតាមស្តង់ដា ដូចនេះចាំបាច់ត្រូវជួសជុលកម្រាលនោះចេញ។

**រោគសញ្ញា**



- មេជ្រូកខ្វក់ជើងយ៉ាងខ្លាំង
- ហើមនឹងឈឺចាប់លើចង្វែកជើង
- ហើមអាចមានជុំវិញកជើង ហើយបង្កជាដំបៅ។

**ការព្យាបាល**



- ចាក់ថ្នាំឡាំងកូមីស៊ីន(Lincomycin) / ឬ ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា(TMP+Sulfa)
- ដាក់អង្កាមលើកម្រាលទ្រុងកម្រាស់២០សង់ទីម៉ែត្រ ដើម្បីការពារកុំឲ្យវាប៉ះជាមួយកម្រាលស៊ីម៉ង់ត៍
- បាញ់ថ្នាំអុកស៊ីតេត្រាស៊ីគ្លីន (OTC) លើដំបៅ ដើម្បីឲ្យឆាប់ជាសះស្បើយ។

### ៣- បញ្ហាពីជំងឺអុតក្ដាម FMD

រោគសញ្ញាសំខាន់របស់ជំងឺអុតក្ដាមលើជ្រូកគឺខ្វកជើងយ៉ាងធ្ងន់ធ្ងរ និងឆ្លងរាលដាលលើសត្វជាច្រើនក្នុងទ្រុង។ ស្លាកស្នាមលេចឡើងលើជើង និងច្រមុះយ៉ាងច្បាស់។

<u>រោគសញ្ញា</u>



- ខ្វកជើងភ្លាមៗ
- សត្វចង់ដេក
- ពេលដើរវាស្រែកខ្លាំង ដោយការឈឺចាប់
- មានពងដោរលើគល់ក្រចក
- មានពងដោរលើច្រមុះ។

<u>ការព្យាបាល</u>

សូមមើលក្នុងផ្នែកស្ដីពីជំងឺអុតក្ដាម ។

### ៤- បញ្ហាមកពីជំងឺប៉េស្ដជ្រូក CSF

មានជំងឺជាច្រើនបណ្ដាលឲ្យសត្វគ្រុនក្ដៅ សីតុណ្ហភាពឡើងខ្ពស់ សត្វមិនចង់ដើរ។ ដោយឡែកជំងឺប៉េស្ដជ្រូកបណ្ដាលឲ្យសត្វមានការខ្វិលច្រអូស និងទន់ជើង។

<u>រោគសញ្ញា</u>

- ស៊ីតិចតួច ឬមិនស៊ីសោះ
- ក្រាបចុះ
- ដើរទ្រេតទ្រោត ដូចជាស្រវឹង និងចង់អង្គុយ ឬដេក។



អាកប្បកិរិយាពិសេស ពេលដែលយើងដេញជ្រូកដែលកើតជំងឺប៉េស្ដឲ្យក្រោកឈរ



ខ្វិនជើងក្រោយ ជ្រូកស្ថិតក្នុងសភាពអង្គុយ



ប្រសិនបើជ្រូកអាចក្រោកឈរ ជើងក្រោយស្ថិតនៅឃ្លាត ហើយជ្រូកនឹងដេកជាថ្មីយ៉ាងលឿន

## ៥- បញ្ហាអង្គុយដូចឆ្កែ Dog sitting position

<u>មូលហេតុ</u>



- មេជ្រូកមានទម្ងន់ធ្ងន់ពេក
- ផលិតទឹកដោះច្រើន
- ស៊ីចំណីមិនគ្រប់គ្រាន់ក្នុងពេលបំបៅដោះ
- កង្វះវីតាមីនដេ៣
- ចំណីមានជាតិកាល់ស្យូមទាប ។

<u>រោគសញ្ញា</u>

- មេជ្រូកអង្គុយដូចឆ្កែ ជើងញែកចេញ
- ជើងពិបាកបត់ចុះឡើង ហើយរឹង
- ខូចជើងស្រួចស្រាវក្នុងពេលបំបៅដោះ ឬបន្ទាប់ពីផ្តាច់ដោះភ្លាមៗ។

<u>ការព្យាបាល</u>

ត្រូវចាក់វីតាមីនដេ៣ជាមួយកាល់ស្យូម (កូហ្វាកាល់ស្យូម Cofacalcium)។

<u>ការការពារ</u>

ផ្តល់ជាតិដេសេប៉េ (DCP) ៣០ក្រាមក្នុងមួយថ្ងៃ បន្ទាប់ពីកើតកូន។

## ៦-ជើងញែក

<u>រោគសញ្ញា</u>



- កូនជ្រូកមិនអាចក្រោកឈរ
- កូនជ្រូកមិនអាចដើរបានឬចលនាបានធ្វើឲ្យមេងាយកិនពីលើ
- ជើងក្រោយកន្ទែកចេញពីគ្នាកូនជ្រូកកើតជំងឺនេះកម្រនៅរស់។

<u>ការព្យាបាល</u>

- ត្រូវប្រើកៅស៊ូយឺតសំប៉ែតរុំចងជើងក្រោយ
- ត្រូវឈ្លីសាច់ដុំ(ម៉ាស្សា)
- ត្រូវជួយកូនជ្រូកឲ្យបៅទឹកដោះពី២ទៅ៣ដងក្នុងមួយថ្ងៃ។



កូនជ្រូកទន់ជើងមិនអាចគេចនៅពេលមេវាអង្គុយលើ

<u>ការការពារ</u>

ត្រូវចាក់វីតាមីនអី ជាមួយសេលីនីយ៉ូម (Vitamin E+Selenium) អាចចាក់ឲ្យមេជ្រូកផើមអំឡុងពេល ៣អាទិត្យ មុនពេលកើត ដោយ ចាក់មួយអាទិត្យចាក់ម្តង។

## ឆ-ជំងឺស្បែក (SKIN DISEASES)

### ១-ស្បែកឡើងជាតិប្រេងពណ៌ប្រផេះ

<u>មូលហេតុ:</u> បង្កដោយបាក់តេរីពពួកស្តាភីឡូកុកគុស ដែលឆ្លងចូលតាមស្បែកដាច់រលាត់។

<u>រោគសញ្ញា</u>

- កន្លែងដែលឆ្លងចូលនៅរង្វង់មុខ ឬលើជើង
- ចាប់ផ្តើមពីចំណុចតូចៗ ពណ៌ត្នោតចាស់
- កន្លែងទាំងនោះមានសភាពជាខ្លាញ់រងើម ហើយកខ្វក់
- ចំណុចពណ៌ត្នោតរីករាលដាលពេញដងខ្លួន
- កូនជ្រូកកើតជំងឺនេះធ្ងន់ធ្ងរ អាចងាប់បាន។






<u>ការការពារ</u>

- ចៀសវាងកម្រាលសើម
- កម្រាលដែលសឹកគ្រើម អាចធ្វើឲ្យមានស្លាកស្នាមដំបៅលើជង្គង់
- កាត់ធ្មេញដោយប្រុងប្រយត្ន័កុំឲ្យមានរបួស
- រម្ងាប់មេរោគលើកន្សោមដោះរបស់មេជ្រូកពីរដង ក្នុងមួយថ្ងៃជាមួយអ៊ីយ៉ូឌីន ព្រោះកន្សោមដោះជាកន្លែង ងាយឆ្លងមេរោគ។

<u>ការព្យាបាល</u>

- ការព្យាបាលគ្មានប្រសិទ្ធភាពទេ
- ចាក់ថ្នាំអាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពវែង(Amoxicillin LA) ឬ ថ្នាំឡាំងកូមីស៊ីន(lincomycin)
- បាញ់ថ្នាំរម្ងាប់មេរោគលើស្បែក (តេបាស់៤(TH4) លាយ២មីលី្លលីត្រក្នុងទឹកមួយលីត្រ)។

### ២-ការលេចឡើងចំណុចពណ៌ក្រហមលើស្បែក(ជំងឺកញ្រ្ជិល)



ជំងឺកញ្រ្ជិល បង្កដោយបាក់តេរី និងកើត មាន ស្ទើរគ្រប់កសិដ្ឋានទាំងអស់ ជាទូទៅ ជំងឺនេះ កើតលើជ្រូកមាន អាយុលើសពីបីខែ។

**រោគសញ្ញា**

- ផ្ទាំងរាងដូចត្បូងពេជ្រ ប្រែពីពណ៌ក្រហម ទៅជាខ្មៅ
- ជារឿយៗអាចស្ទាបដោយដៃក្នុងដំណាក់កាលដំបូង
- ពេលខ្លះជ្រូកងាប់ភ្លាម ដោយសារមេរោគឆ្លងចូលក្នុងឈាម និងធ្វើឲ្យខូច បេះដូង
- សត្វក្តៅខ្លាំង សីតុណ្ហភាពលើសពី(៤១អង្សាសេ)សត្វឈប់ស៊ីចំណី។

**ការការពារ**

អាចចាក់វ៉ាក់សាំងឲ្យមេជ្រូក បា ដោយចាក់លើកទី១នៅអាយុ៤ខែ និងចាក់រំលើក នៅ៤អាទិត្យក្រោយ។

**ការព្យាបាល**

ចាក់ថ្នាំប៉េនីស៊ីលីន(Penicillin) ឬអាម៉ុកស៊ីស៊ីលីន(Amoxicillin) រយៈពេលពី៣ ទៅ៥ថ្ងៃ។

### ៣- កន្ទួលពណ៌ក្រហម (ជំងឺអង្គែ)

ជំងឺអង្គែបង្កឡើងដោយបរាសិត និងធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់របស់ជ្រូក។

**រោគសញ្ញា**



- ស្បែកពេលពណ៌ក្រហម ភាគច្រើនលើខ្នង និងចង្កេះ
- រមាស់នៅមិនស្ងៀម ដើរត្រដុស
- បក់ត្រចៀក និងមានវត្ថុពណ៌ត្នោត
- ចាស់នៅខាងក្នុងត្រចៀក។



**ការការពារ**

ត្រូវចាក់ថ្នាំអ៊ីវែម៉ិចទីន( Ivermectin) រៀងរាល់៣ខែម្តង។

<u>ការព្យាបាល</u>

ចាក់ថ្នាំអ៊ីវែម៉ិចទីន(Ivermectin) ១មីលីលីត្រក្នុងទម្ងន់៣០ គីឡូក្រាម ចំនួនពីរដងក្នុងពេល២អាទិត្យ ព្រោះវដ្តរបស់បរាសិតគឺ១០ទៅ១៤ថ្ងៃ។ ថ្នាំអ៊ីវែម៉ិចទីនត្រូវចាក់ក្រោមស្បែក។ថ្នាំអ៊ីវែម៉ិចទីនអាចប្រើលាយក្នុងចំណីរៀងរាល់ថ្ងៃ សម្រាប់រយៈពេល៧ថ្ងៃ។

៤-ចំណុចពណ៌ក្រហម ដោយសារសត្វល្អិតខាំ



<u>រោគសញ្ញា</u>

- ចំណុចក្រហម
- ស្បែករលាត់
- បាត់បង់ឈាម និងលូតលាស់យឺត ។

<u>ការការពារ</u>

- កម្ចាត់ជម្រករបស់រុយ
- សម្អាតកាកសំណល់ចំណី
- សម្អាតទ្រុងនិងជុំវិញបរិវេណទ្រុង
- សម្អាតទីធ្លាបន្តពូជរបស់រុយ ដោយជួសជុលបេតុងស៊ីម៉ង់ត៍ ដែលបាក់បែក ព្រោះការបាក់បែក និងប្រហោងក្នុងជញ្ជាំងជាកន្លែងរុយអាចពងដាក់។

<u>ការព្យាបាល</u>

- បាញ់ថ្នាំសម្លាប់សត្វល្អិត (ទ្រីក្លរ័ហ្វុង Trichlorfon) កន្លែងស្នាក់នៅរបស់រុយ
- បាញ់ថ្នាំប៊ុយតុក (Butox) រៀងរាល់ពីរខែម្តងលើខ្លួនសត្វ
- ចាក់ថ្នាំដិចសាមេតាសូន (Dexamethasone) ប្រសិនបើរលាត់ធ្ងន់ធ្ងរ និង អាម៉ុកស៊ីស៊ីលីន (Amoxicillin) ប្រសិនបើចំណុចទាំងនោះមានការឆ្លងមេរោគ (ឡើងហើមពណ៌ស្វាយ ក្រមរ)។

៥-ស្បែករលាកពណ៌ក្រហម ដោយពន្លឺព្រះអាទិត្យ

ត្រូវការពិនិត្យកន្លែងសត្វរស់នៅ និងសួរព័ត៌មានពីម្ចាស់សត្វ ដើម្បីរកមូលហេតុសម្រាប់ធ្វើរោគវិនិច្ឆ័យ ។



ស្រោចទឹកលើដងខ្លួនជួយកាត់បន្ថយកំដៅរាងកាយ

<u>រោគសញ្ញា</u>

- ស្បែកឡើងក្រហម រលាកមានទឹករងៃ
- មានការឈឺចាប់នៅមិនសុខ
- គ្រុនក្តៅ។ រលាកដោយពន្លឺព្រះអាទិត្យធ្ងន់ធ្ងរអាចធ្វើឲ្យសត្វងាប់ដោយការខ្សោះជាតិទឹកខ្លាំង និងនៅពេលដែលសីតុណ្ហភាពដងខ្លួនលើសពី៤២ អង្សាសេ។

<u>ការការពារ</u>

ត្រូវដាក់ជ្រូកក្នុងទ្រុងមានដំបូល និងមានម្លប់។

<u>ការព្យាបាល</u>

- ស្រោចទឹកលើដងខ្លួនជ្រូក ដើម្បីបញ្ចុះកំដៅ
- ត្រូវឲ្យទឹកផឹកគ្រប់គ្រាន់ ព្រោះជ្រូកអាចខ្សោះជាតិទឹក
- ចាក់ថ្នាំប៉ារ៉ាសេតាម៉ុល(Paracetamol) ដើម្បីបញ្ចុះកំដៅដងខ្លួន និងការរលាក ។

**ចំណាំ:** សញ្ញារបស់ជំងឺត្រចៀកខៀវចំពោះជ្រូកសាច់ អាចដូចគ្នាខ្លាំងនឹងការរលាកដោយពន្លឺព្រះអាទិត្យ ប៉ុន្តែភ្នែកវាឡើងហើម ជ្រូកក្អក និងខូចផ្លូវបន្តពូជ ត្រូវបានគេសង្កេតឃើញក្នុងកសិដ្ឋាន។

**៦-ការប្រែជាពណ៌ស្វាយ/ជំងឺប៉េស្ត**



<u>រោគសញ្ញា</u>

- ស្បែកឡើងពណ៌ស្វាយ លេចចេញដំបូងនៅត្រចៀក និងកន្ទុយរួចរាលដាលដល់ចុងច្រមុះ ផ្នែកខាងក្រោមជើង ពោះ និងខ្នង
- សីតុណ្ហភាពឡើងខ្ពស់លើសពី៤០អង្សាសេក្នុងពេលច្រើនថ្ងៃ
- ដើរទ្រេតទ្រោតចង់ដួល រួចអង្គុយ ឬក្រាបចុះ។





<u>ការព្យាបាល និងការការពារ</u>

មើលក្នុងជំពូកស្តីពីជំងឺប៉េស្តជ្រូក។

**៧-ជំងឺឡើងខៀវ ស្វាយ ( ស៊ីយ៉ាណូស៊ីស Cyanosis )**

**៧.១ ជំងឺសាល់ម៉ូណែឡូស**

បង្កដោយបាក់តេរីសាល់ម៉ូណែឡា ឆ្លងរាលដាលលើមនុស្ស និងហ្វូងសត្វ ។ ប្រភេទសាល់ម៉ូណែឡាខ្លះអាចបង្កជាជំងឺលើជ្រូក។

ការចម្លងជំងឺធ្ងន់ធ្ងរនៃមេរោគសាល់ម៉ូណែឡា កូឡេរ៉ាស៊ីស (Salmonella Choleraesuis) កើតមានលើជ្រូក ដែលមានអាយុពី១២ទៅ១៤អាទិត្យ។




<u>រោគសញ្ញា</u>

- ស្បែកចុងកន្ទុយ ចុងត្រចៀក ចុងច្រមុះ និងជើង ប្រែជាពណ៌ខៀវ
- គ្រុនក្តៅលើសពី៤០អង្សាសេ
- ហើមសួត ដកដង្ហើមមានការឈឺចាប់
- រាកមានក្លិនស្អុយ
- កើតលើជ្រូកអាយុតិចជាង៦ខែ ។

<u>ការការពារ</u>

- ធ្វើអនាម័យជាប្រចាំ និងបាញ់ថ្នាំរម្ងាប់មេរោគឲ្យបានទៀងទាត់
- ត្រូវប្រុងប្រយ័ត្នទឹកសម្រាប់ជ្រូកដេកត្រាំលេង
- ការចាក់វ៉ាក់សាំងមិនមានប្រសិទ្ធភាពទេ។

<u>ការព្យាបាល</u>

ត្រូវចាក់ថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា(TMP+Sulfa)ឬអង់រ៉ូផ្លុកសាក់ស៊ីន(Enroflox acine) (ប៉ុន្តែថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន អាចបង្កើតភាពធន់បានយ៉ាងលឿន)។

## ៧.២ ជំងឺត្រចៀកខៀវ PRRS

កូនតិចក្នុងសំបុក មានតែកូនជ្រូក៥ក្បាល រួមទាំងកូនជ្រូកដែលខ្សោយ




ជំងឺត្រចៀកខៀវ បង្កឡើងដោយវីរុស។ ជំងឺនេះ ត្រចៀក មានប្រែពណ៌ទៅជាខៀវ (Cyanosis) ដែលអាចមើលឃើញលើមេជ្រូកនិងជ្រូកមួយចំនួន ប៉ុន្តែកើតឡើងដោយកម្រ។ ជំងឺត្រចៀកខៀវ ដែលត្រចៀកមានប្រែពណ៌ទៅជាខៀវ មិនមែនជារោគសញ្ញាចម្បងរបស់ជំងឺទេ។ រោគសញ្ញាចម្បងរបស់ជំងឺត្រចៀកខៀវ គឺៈ មិនស៊ីចំណី គ្រុនក្តៅ រលូតកូននិងខ្សោយ ឬកូនជ្រូកកើតមកងាប់ក្រៀម។ សូមមើលផ្នែកការបរិយាយលំអិតអំពីជំងឺត្រចៀកខៀវ។

## ជ- ជំងឺផ្លូវបន្តពូជ

### ១- ប៉ាវ៉ូវីរុស Parvovirus

ជំងឺប៉ាវ៉ូបង្កឡើងដោយវីរុស ដែលមានការឆ្លងរាលដាលស្ទើរគ្រប់កសិដ្ឋាន។ ជាទូទៅជំងឺនេះ បណ្ដាលឲ្យគ្មានការបង្កកំណើត។

<u>រោគសញ្ញា</u>

**ចំពោះមេជ្រូកជើម**

- ប្រសិនបើមេជ្រូកឆ្លងជំងឺក្នុងអំឡុងពេល៣៥ថ្ងៃនៃការជើម បណ្ដាលឲ្យកូននៅក្នុងពោះខ្លះងាប់ និងមានកូនតិច ក្នុងមួយសំបុក (៤ទៅ៥ក្បាល) ។ ប្រសិនបើកូនទាំងអស់(អំប្រីយុង) ងាប់វារកឈ្មោលឡើងវិញ។
- ប្រសិនបើមេជ្រូកឆ្លងជំងឺបន្ទាប់ពី៣៥ថ្ងៃ ពេលដែលកូនជ្រូកចាប់ផ្ដើមលូត លាស់ វីរុសឆ្លង រាលដាលយឺតៗពី កូនជ្រូកមួយទៅកូនជ្រូកមួយ ទៀត ដូចនេះកូនជ្រូកកើតមកងាប់មានសភាពក្រៀមដែលមានទំហំខុសគ្នា(ពី៣០ទៅ១៦០ មីល្លីម៉ែត្រ)។



កូនងាប់ក្រៀម ដែលមានទំហំផ្សេងៗគ្នា

**ចំណាំ:** ការរលូតកូនមិនមែនជាលក្ខណៈរបស់ជំងឺប៉ាវ៉ូទេ។

<u>ការព្យាបាល</u>

ជំងឺប៉ាវ៉ូគ្មានការព្យាបាលទេ។

<u>ការការពារ</u>

ការចាក់វ៉ាក់សាំង ចំពោះមេជ្រូកក្រមុំ និងមេជ្រូក ត្រូវចាក់នៅ១០ទៅ១៥ថ្ងៃ មុនពេលដាក់ឈ្មោល ឬបង្កាត់ដោយសិប្បនិម្មិត។

- មេជ្រូកក្រមុំ ត្រូវចាក់ពីរដង បើការដាក់ឈ្មោលលើកទីមួយគ្រោងធ្វើនៅពេលមានអាយុ៨ខែដូច្នេះការចាក់វ៉ាក់សាំងត្រូវចាក់នៅអាយុ៦ខែកន្លះ និងចាក់រំលឹកនៅអាយុ៧ខែកន្លះ
- មេជ្រូកត្រូវចាក់ថ្នាំការពារមួយអាទិត្យមុនពេលផ្ដាច់ដោះ។

### ២- ការហូរខ្ទុះតាមយោនី

មូលហេតុនៃការហូរខ្ទុះតាមយោនីអាច:

រលោកផ្លោកនោម រលោកស្បូន។



<u>រោគសញ្ញា</u>

- ជំងឺនេះអាចរ៉ាំរ៉ៃ តែមិនធ្វើឲ្យងាប់ទេ
- មានខ្ទុះក្នុងទឹកនោម ឬមានខ្ទុះស្អិតជាប់នឹងយោនីមានខ្ទុះលើកម្រាលទ្រុង ។

<u>ការព្យាបាល</u>

ដើម្បីព្យាបាលការហូរខ្ទុះតាមយោនីទោះបីជាមើលទៅមេជ្រូកមានសុខភាពល្អក្ដីព្រោះការឆ្លងពីផ្លោកនោម ឬពីស្បូននឹងមិនបាត់ទៅវិញទេ ដូចនេះត្រូវធ្វើការព្យាបាលឲ្យបានត្រឹមត្រូវ។ ប្រសិនបើការឆ្លងលើតម្រងនោម ហើយមិនបានធ្វើការព្យាបាលទេ ជំងឺអាចធ្វើឲ្យខូចតម្រងនោម។ ប្រសិនបើការឆ្លងលើស្បូន ហើយមិនត្រូវបានធ្វើការព្យាបាលទេ ជំងឺអាចធ្វើឲ្យសត្វមិនបង្កកំណើត មានន័យថាកូនមិនអាចលូតលាស់ក្នុងស្បូនដោយសារមានខ្ទុះ។ ប្រើថ្នាំអង់ទីប៊ីយ៉ូទិកដូចជា តេត្រាស៊ី គ្លីន (Tetracycline) ឬ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa) លាយក្នុងចំណីរយៈពេល០១ ទៅ ៣ អាទិត្យ។

៣-រលាកស្បូន



<u>រោគសញ្ញា</u>

- ហូរខ្ទុះតាមយោនី មានក្លិនស្អុយ ពណ៌ស ឬពណ៌ត្នោត
- កើតមានពី៤ទៅ៥ថ្ងៃ បន្ទាប់ពីកើតកូន
- មេជ្រូកមានកំដៅលើសពី៤០អង្សាសេ
- មេជ្រូកមិនអាចស៊ី ឬស៊ីតិចតួចជារឿយៗ មានរួមផ្សំជាមួយសញ្ញារបស់ជំងឺលាសដោះ កន្សោមដោះឡើងរឹង និងគ្មានទឹកដោះ ។

<u>ការព្យាបាល</u>



- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិក៖ ដូចជាថ្នាំទ្រីមេតូព្រីមមួយស៊ុលហ្វា(TMP+Sulfa) ឬអង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacin) ឬ អាម៉ុកស៊ីស៊ីលីន (Amoxicillin) ឬអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline)រយៈពេលបីថ្ងៃ។
- ចាក់ថ្នាំប្រូស្តាក្លង់ឌីន(Prostaglandine) តែមួយដង ដើម្បីទម្លាក់រាល់វត្ថុដែល អាចឆ្លងជំងឺពីក្នុងស្បូន។

<u>ការការពារ</u>

ចាក់អុកស៊ីតុកស៊ីន(Ocytocin)ពីរមីល្លីលីត្រឲ្យមេជ្រូកទាំងអស់នៅពេលកើតកូនរួច ដើម្បីប្រាកដថាសុក ឬចំណែកសុកត្រូវធ្លាក់អស់។

**៤-ការរលូតកូន**



ការរលូតកូនគឺធ្វើឲ្យកូនងាប់ក្នុងដំណាក់កាលផើមពី ៣៥ទៅ១១០ថ្ងៃ ។ រាល់ការឆ្លងជំងឺធ្វើឲ្យសត្វគ្រុនក្តៅលើសពី៤១អង្សាសេ ដូចជាជំងឺប៉េស្តជ្រូក ជំងឺកញ្ជ្រិលអាចបង្កឲ្យរលូតកូន ប៉ុន្តែមិនមែនជាលក្ខណៈរបស់ជំងឺប៉េស្តជ្រូក ឬជំងឺកញ្ជ្រិលទេ។

**ការរលូតកូនដែលមានអត្រាខ្ពស់ ត្រូវគិតដល់:**

- **ជំងឺត្រចៀកខៀវ**
  - មេជ្រូកផើមមិនស៊ីចំណីពី៧ទៅ១០ថ្ងៃ
  - មេជ្រូកអាចឡើងកំដៅខ្ពស់រហូតដល់៤១អង្សាសេ
  - ក្នុងរយៈពេល៤ទៅ៦អាទិត្យ អត្រារលូតកូនអាចឡើងដល់ទៅ៥០%
  - ការរលូតកូនកើតមានគ្រប់ដំណាក់កាលផើមប៉ុន្តែភាគច្រើនក្នុងដំណាក់កាលផើមចុងក្រោយ
  - ក្នុងអំឡុងពេលនេះ អត្រាងាប់របស់មេជ្រូកអាចលើសពី១០%។

- **ជំងឺឡិបតូស្ពៀរ៉ូស**

<u>មូលហេតុ</u>



កណ្តុរនាំមេរោគចូលក្នុងចំណី និងទឹក តាមរយៈទឹកនោមរបស់វា

ជំងឺឡិបតូស្ពៀរ៉ូស បង្កដោយបាក់តេរី ឆ្លងតាមរយៈទឹកនោមរបស់ជ្រូកដែលផ្ទុកជំងឺ ឬជូនកាលឆ្លងតាមរយៈសត្វកកេរ។បាក់ តេរីអាចឆ្លងពីជ្រូក ទៅជ្រូក ឬតាមការស៊ី ចំណី ឬផឹកទឹកដែលប្រឡាក់ប្រឡូក ដោយ ទឹកនោមសត្វកណ្តុរដែលមានមេរោគ។ ជំងឺឡិបតូស្ពៀរ៉ូសកើតមានក្នុងកសិដ្ឋាន វាមានការលំបាកក្នុងការកំចាត់ណាស់ ។

<u>សញ្ញាគ្លីនិក</u>

ចំពោះមេជ្រូកដើម:

- មិនស៊ីចំណី
- គ្រុនក្តៅ កើតមានពី២ទៅ៦ថ្ងៃ មុនការរលូត។
- មេជ្រូករលូតកូនក្នុងពេល១ទៅ៣អាទិត្យមុនពេលកើត ឬពេលកើត កូនគ្រប់ខែកើតមកងាប់។

<u>ស្លាកស្លាម៖</u>

ការរះកាត់កូនជ្រូកទើបកើត មានវត្ថុរាវជាច្រើន និងសារធាតុសសៃក្នុងប្រហោងពោះ ពេលខ្លះឡើងពណ៌លឿង។

<u>ការព្យាបាល</u>

- ចាក់ថ្នាំស្ត្រិបតូមីស៊ីន(Streptomycin) ២៥មីល្លីក្រាម ក្នុង០១គីឡូក្រាម នៃទម្ងន់ជ្រូករស់ចាក់តែមួយដង និងត្រូវធ្វើការព្យាបាលឲ្យជ្រូក ដែលទើបដាក់ក្នុងកសិដ្ឋាន។
- ប្រើថ្នាំតេត្រាស៊ីគ្លីនជាមួយទីឡូស៊ីន(Tetracycline+Tylosin) ឬថ្នាំតេត្រាស៊ីគ្លីន (Tetracycline) លាយក្នុងចំណីរយៈពេល២អាទិត្យ ។

➢ **មីកូតុកស៊ីន**

មីកូតុកស៊ីនឆ្លងទៅពោតសើមឬពោតមិនបានសម្ងួតដោយពន្លឺព្រះអាទិត្យឲ្យបានគ្រប់គ្រាន់មិនអាចមើលឃើញមីកូតុកស៊ីនក្នុងវត្ថុធាតុដើមដោយផ្ទាល់បានលុះត្រាតែវិភាគក្នុងមន្ទីរពិសោធន៍។

<u>រោគសញ្ញា</u>

មេជ្រូកក្អួត និងរលូតកូន២ថ្ងៃ បន្ទាប់ពីមានរោគសញ្ញាក្អួត។

**ចំណាំ: ការប្រើថ្នាំដិចសាមេតាសូន** (Dexamethasone) ក្នុងអំឡុងពេលបីអាទិត្យចុងក្រោយនៃដំណាក់កាលដើមបណ្តាលឲ្យរលូតកូន។

**៥- ការមិនបង្កកំណើត**

គឺជាការអសមត្ថភាពរបស់មេជ្រូក ក្នុងការផលិតកូន។

➢ **ការមិនរកឈ្មោល**

ជាធម្មតា វដ្តរកឈ្មោលរបស់មេជ្រូកពី១៨ទៅ២៤ថ្ងៃ ជាមធ្យម២១ថ្ងៃ ។មេជ្រូកក្រមុំការរកឈ្មោលដំបូង ជាធម្មតានៅអាយុ៦ខែ។ ចំណែកមេជ្រូករកឈ្មោលពី៥ទៅ៧ថ្ងៃ បន្ទាប់ពីផ្តាច់ដោះ ។

## មូលហេតុ



- មេជ្រូកស្គមពេលផ្តាច់ដោះ
- ផ្តល់ចំណីមិនបានគ្រប់គ្រាន់អំឡុងពេលបំបៅដោះ
- ដោយសារឈឺជើងមិនអាចក្រោកឈរស៊ីចំណីបានស្រួល
- កំណត់ការរកឈ្មោលមិនត្រឹមត្រូវ។ ជ្រូកកូនកាត់បង្ហាញសញ្ញារកឈ្មោលតិចតួច ជា ពិសេសមេជ្រូកក្រមុំហើយមិនសូវមើលឃើញយោនីហើមឡើងក្រហម និងជ្រូក ដែលកាច អាចមិនបង្ហាញការផ្លាស់ប្តូរអត្តចរិក។ ដូចនេះចាំបាច់ ត្រូវសង្កេតតាមដានរាល់ថ្ងៃ។ ជាទូទៅមេជ្រូកក្រមុំ ត្រូវធ្វើ ការបង្កាត់ នៅ ពេលដែលវារកឈ្មោល លើក ទី៣ដែលមានអាយុប្រហែល៨ខែ។
- ដោយសារបច្ចេកទេសមិនត្រឹមត្រូវ ស្រ្តេស ពន្លឺ
- ការភ្លេចអារម្មណ៍ពីបាជ្រូក
- ផ្តល់ចំណីលើសការកំណត់ ត្រូវកម្រិតការផ្តល់ចំណី ឲ្យបានសមស្រប
- មេជ្រូកឬមេក្រមុំស្ថិតនៅកន្លែងស្ងាត់ស្ងៀមកន្លែងងងឹតគ្មានជ្រូកបានៅក្បែរ ។
- មានគីសនៅលើអូវែ
- មានគីសច្រើននៅក្នុងអូវែ បង្កឲ្យមានការពន្យាការមិនរកឈ្មោលដែលបញ្ហានេះមានឥទ្ធិពលតិចជាង១០% នៃការមិនរកឈ្មោល។

ការនៅស្ងៀមគឺជាសញ្ញាជាក់ច្បាស់ដើម្បីកំណត់ការរកឈ្មោល



ដាក់លាយមេក្រមុំដើម្បីឲ្យវាខាំគ្នាក្នុងបំណងបង្កើតស្រ្តេស វាមានប្រយោជន៍ជម្រុញការរកឈ្មោល



ឲ្យបាជ្រូកដើរជិតគឺមានប្រយោជន៍ជម្រុញការរកឈ្មោល



ត្រូវធានាឲ្យមានភ្លើងបំភ្លឺ១៦ម៉ោងដើម្បីជម្រុញការរកឈ្មោល





មេជ្រូកត្រូវផ្តល់ចំណីឲ្យបានត្រឹមត្រូវបន្ទាប់ពីផ្តាច់ដោះ

### ➢ ការរកឈ្មោលឡើងវិញ

មេជ្រូក ឬមេជ្រូកក្រមុំ ដែលបានបង្កាត់ដោយសិប្បនិម្មិត ឬដាក់ឈ្មោលផ្ទាល់ ប៉ុន្តែនៅប៉ុន្មានអាទិត្យក្រោយមកមេជ្រូកទាំងនោះមានសញ្ញារកឈ្មោលសារជាថ្មីទៀត។ ប្រសិនបើការរកឈ្មោលកើតមាន២១ថ្ងៃ(តាមការពិតគឺ១៨ទៅ២២ថ្ងៃ) បន្ទាប់ពីការរកឈ្មោលលើកមុន ដែលមិនបានដាក់បា មានន័យថាជាការរកឈ្មោលឡើងវិញធម្មតា។

<u>មូលហេតុ</u>

- ជាទូទៅដោយសារជំងឺនាបច្ចុប្បន្ននេះ ជំងឺត្រចៀកខៀវគឺជាមូលហេតុនៃការរកឈ្មោលឡើងវិញ ។ ការរកឈ្មោលឡើងវិញគឺមិនទៀងទាត់ អាចកើតមានពី២១ទៅ៣៥ថ្ងៃ បន្ទាប់ពីការបង្កាត់។
- ដោយសារការរលាកស្បូន ការរលាក និងការឆ្លងមេរោគលើស្បូន គឺមិនអាចសម្រួលដល់ការលូតលាស់របស់សុក និងកំណកូន (Embryos) បានទេដូចនេះ ជ្រូកមិនអាចដើម។ ជ្រូកដែលរលាក ស្បូនហាក់ដូច មានសុខភាពធម្មតា ប៉ុន្តែ អាចសង្កេត ឃើញមានវត្ថុ រាវតិចតួចហូរតាមយោនី។មេរោគ(បាក់តេរី) ដែលឆ្លងចូលក្នុងស្បូន បន្ទាប់ពីកើតកូន ឬអំឡុងពេលរកឈ្មោល។

នៅពេលដែលមេរោគជ្រាតចូលក្នុងស្បូនសុក ហើយបណ្ដាលអោយអំប្រ៊ីយ៉ុងមិនអាចរីកលូតលាស់បាន និងបណ្ដាលអោយរលូត។ សញ្ញានេះនឹងធ្វើអោយមេជ្រូករកឈ្មោលម្ដងទៀត




<u>ការព្យាបាល</u>

បាក់តេរីដែលបង្កឲ្យមានជំងឺរលាកស្បូន ភាគច្រើនពពួកអីកូលី ស្តាភីឡូកុកគុស និងស្ត្រិបតូកុកគុស។ ដូចនេះត្រូវប្រើប្រើថ្នាំដូចជា:

- តេត្រាស៊ីគ្លីន(Tetracycline) ឬអាម៉ុកស៊ីស៊ីលីន(Amoxicillin) ឬទ្រីមេតូព្រីមជាមួយស៊ុលហ្វា(TMP+Sulfa) លាយក្នុងចំណីរយៈពេល១អាទិត្យ ចាប់ពីថ្ងៃទី១នៃការរកឈ្មោល។

### ➢ បញ្ហាជ្រូកបាមិនអាចបង្កកំណើតបាន

ជាធម្មតាទឹកកាមរបស់ជ្រូកបា ត្រូវមានគុណភាពល្អ ដើម្បីធានាការបង្កកំណើត។ ជ្រូកបាដែលមិនអាចបង្កកំណើតបានមើលទៅមានសុខភាពល្អ លក្ខខណ្ឌសមស្របល្អសម្រាប់ពងស្វាស ប៉ុន្តែទឹកកាមមិនមានគុណភាពគ្រប់គ្រាន់។

បុព្វហេតុៈ



បង្កាត់លើសពី១ដងក្នុងមួយថ្ងៃ=មេជ្រូករកឈ្មោលឡើងវិញ

- ជ្រូកបាបានប្រើលើសកំណត់។ ជាធម្មតាជ្រូកបាមិនអាចពាក់មេ ឬយកទឹកកាមលើសពី៣ដងក្នុងមួយអាទិត្យទេ ពីព្រោះកំហាប់របស់មេជីវិតថយចុះយ៉ាងខ្លាំង។
- គ្រុនក្តៅ ពងស្វាសត្រូវការសីតុណ្ហភាពទាប ដើម្បីផលិតមេជីវិត ពីព្រោះពងស្វាសស្ថិតនៅខាងក្រៅដងខ្លួន។
- ជ្រូកឈឺមានសីតុណ្ហភាពលើសពី៤០អង្សាសេ ទឹកកាមមិនអាចបង្កកំណើត រយៈពេល៣ អាទិត្យ។ទោះបីជ្រូកបា បានជាសះស្បើយឡើងវិញក្តី ពីព្រោះ ទឹកកាមគ្មានផ្ទុកមេជីវិត។



កូនតិចក្នុងសំបុក(កូនតិចជាង៦ក្បាល) មិនអាចសង្គ្រោះឲ្យរស់បាន ព្រោះកន្សោមដោះគ្មានគ្រប់គ្រាន់ដើម្បីបៅនិងឈប់ផលិតទឹកដោះ

## ៦-បញ្ហាកូនតិចក្នុងមួយសំបុក

ជាធម្មតាគ្រោងឆ្អឹងរបស់កូនជ្រូកមិនទាន់លូតលាស់ទេ មុនថ្ងៃទី៣៥ បន្ទាប់ពីបង្កាត់ ។ ប្រសិនបើមានការឆ្លងចូលមេរោគមុនថ្ងៃទី៣៥ ដែល បណ្តាលឲ្យ កំណារ កូនជ្រូក(Fetus)ងាប់ គឺជាមូលហេតុ ធ្វើឲ្យមានកូនតិចក្នុងសំបុកគឺតិចជាង៦ក្បាល។

➢ **ដោយសារជំងឺប៉ារ៉ូ** (មុន៣៥ថ្ងៃ)

វីរុសជំងឺប៉ារ៉ូ រាតត្បាតក្នុងស្បូនមុនថ្ងៃទី៣៥ បានសម្លាប់កូនជ្រូកក្នុងពោះដោយជ្រើសរើស ។ កំណារកូនជ្រូកងាប់គ្មានឆ្អឹងទេ ហើយត្រូវបានស្រូបអស់។ ជាលទ្ធផលគឺកូនតិចពី៣ទៅ៦ក្បាលក្នុងមួយសំបុក។

➢ **ដោយសារការរលាកស្បូន**

ស្បូនរលាកដោយសារការឆ្លងមេរោគ បន្ទាប់ពីកើតកូនរួច ហើយសុកមិនអាចវិវត្តបានធម្មតា បណ្តាលឲ្យសុកតូច ឬសុកខូច ព្រោះមិនអាចតោងជាប់ លើផ្ទៃទាំងមូលរបស់ស្បូនបាន គ្មានកន្លែងគ្រប់គ្រាន់សម្រាប់ ការចាប់លូតលាស់របស់កូន ជាលទ្ធផលគឺកូនមានចំនួនតិច។ដូចនេះចាំបាច់ត្រូវ សម្អាតស្បូនបន្ទាប់ពីកើតកូនរួច និងត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន(Ocytocin)២មីល្លីលីត្រ ពេលកើតកូនរួចអស់ ដើម្បីធ្វើឲ្យប្រាកដថាសុកបាន ធ្លាក់ចេញអស់ និង ត្រូវចាក់ ប្រូស្តាក្លង់ឌីន១មីល្លីលីត្រ (លុយតាលីសLutalyse) ក្នុងពេល៤៨ម៉ោង បន្ទាប់ ពីកើតកូន ដើម្បីធ្វើឲ្យសារធាតុរាវកខ្វក់ ហូរចេញអស់ពីក្នុងស្បូន។

➢ **ដោយសារគុណភាពទឹកកាម**

- ដំណើរការបង្កាត់ត្រូវប្រើរយៈពេលលើសពី១៥នាទី ដើម្បីឲ្យទឹកកាមចំណុះ ៤០០មីល្លីលីត្របានបង្កាត់អស់។ ប្រសិនបើដំណើរការ បង្កាត់ត្រូវបានកាត់ផ្តាច់នោះ វាបណ្តាលឲ្យមានកូន តិចក្នុងមួយសំបុក។
- ប្រសិនបើប្រើបាពាក់ពីរដងក្នុងមួយថ្ងៃ បណ្តាលឲ្យមេជីវិតមានចំនួនតិច ធ្វើឲ្យមានកូនតិចក្នុងមួយសំបុក។
- ជ្រូកបាមានអាយុក្មេងជាង៩ខែ ផលិតកូនបានតិចក្នុងមួយសំបុក។

➢ **ដោយសារការធ្វើចលនា/ស្ត្រេស**

បន្ទាប់ពីបង្កាត់ មេជ្រូកត្រូវធ្វើចលនាក្នុងពេល៣ថ្ងៃ ។ជាធម្មតាការបង្កកំណើត(មានគភ៌)ក្នុងថ្ងៃទី១៣។ ស្ត្រេសបណ្តាលពីការធ្វើចលនា មុនពេលបង្កកំណើត(មានគភ៌)បណ្តាលឲ្យមានកូនតិចក្នុងមួយសំបុក។

**៧-បញ្ហាកូនជ្រូកទើបកើតខ្សោយ និងងាប់ក្រៀម**



ពេលកូនជ្រូកងាប់ក្នុងស្បូនក្រោយថ្ងៃទី៣៥ បន្ទាប់ពីបង្កាត់កូនជ្រូកទាំងនោះ មិនអាចរលាយបានទេ ព្រោះមានឆ្អឹង ហើយក្លាយជាងាប់ក្រៀម។

**សញ្ញាកូនជ្រូកដែលងាប់នោះមាន:**

ភ្នែកលិប កូនក្រៀមមានពណ៌ត្នោតចាស់ គ្រោងឆ្អឹងនៅធម្មតាមិនខូចខាត។ កូនជ្រូក ដែលមិនងាប់ បាននៅសេសសល់ហើយកើតមកខ្សោយក្នុងសំបុក។

**បញ្ហាកូនជ្រូកទើបកើតខ្សោយ និងងាប់ក្រៀម ដោយសារមានជំងឺផ្សេងទៀតដូចជា៖**

- **ជំងឺប៉ាវ៉ូ:** មានកូនងាប់ក្រៀមជាច្រើន ទំហំខ្លួនតូចពី៣០ទៅ១៦០មីល្លីម៉ែត្រ និងមានទំហំដងខ្លួនផ្សេងៗគ្នា។
- **ជំងឺអូជេស្គី:** កើតកូនមកកូនងាប់ក្រៀម កូនជ្រូកដ៏ទៃទៀតខ្សោយ និងខ្លះទៀតបង្ហាញសញ្ញាប្រកាច់ ។
- **ជំងឺត្រចៀកខៀវ:** មានកូនជ្រូកងាប់ក្រៀម២ឬ៣ក្បាលក្នុងមួយសំបុក ហើយជារឿយៗមេជ្រូកកើតកូនពី ៣ទៅ៤ថ្ងៃ មុនពេលកំណត់ ។

- ជំងឺប៉េស្តជ្រូក: ជំងឺនេះបណ្តាលឲ្យកូនជ្រូកងាប់ក្នុងពេលផើម ។ ជាទូទៅកូនជ្រូកងាប់ កើតមកមានសភាពក្រៀម។ ចំណែកកូនជ្រូកមិនងាប់ពេលកើតមក កូនជ្រូកនោះខ្សោយ និងមានសភាពញាក់ញ័រ។

## ៨-បញ្ហាអត់ទឹកដោះ

### មូលហេតុ



ទឹកដោះមិនចេញ បន្ទាប់ពីកើតកូនរួច

ដោយសារមានជំងឺរលាកស្បូន លាសដោះ អត់ទឹកដោះ (MMA) ដែលកើតមាន ជាទូទៅលើមេជ្រូក។បញ្ហាអត់ទឹកដោះ ជាទូទៅបង្កដោយបាក់តេរី ដែលរាតត្បាត លើកន្សោមដោះ និងបង្កជាជាតិពុល។ ចំពោះការហូរវត្ថុរាវតាមយោនីនិងទល់លាមក ជារឿយៗជាប់ពាក់ពន្ធ័នឹងបញ្ហាខាងលើនេះ។

### រោគសញ្ញា

បញ្ហាអត់ទឹកដោះ ច្រើនកើតឡើងក្នុងរយៈពេល១២ម៉ោងនៃការកើតកូន។

- ពេលច្របាច់ក្បាលដោះ ទឹកដោះមិនហូរចេញ -មេជ្រូកឈប់ស៊ីចំណី
- អស់កម្លាំង និងអន្ទះអន្ទែងពេលកូនបៅ។
- មេជ្រូកដែលឆ្លងជំងឺ អាចមានសញ្ញាគ្រុនក្តៅតិចតួច ពី៤០ទៅ៤១អង្សាសេ។

បញ្ហានេះត្រូវធ្វើការព្យាបាលជាបន្ទាន់ព្រោះប្រសិនបើកូនជ្រូកមិនបានបៅទឹកដោះដំបូងទេ កូនជ្រូកខ្សោយ។ ម្យ៉ាងទៀតពេលដែលកូនជ្រូកមិនអាចបៅដោះបន្ទាប់ពីកើតបណ្តាលឲ្យកូនជ្រូកបាត់បង់ថាមពលរងារមិនស្វាហាប់ ហើយជាឪកាសសម្រាប់ជំងឺរាកកើតឡើង។

### ការព្យាបាល

ចាក់ថ្នាំអុកស៊ីតុកស៊ីន០,៥សេសេ តាមសរសៃឈាម



- ការងារដ៏សំខាន់ណាស់ គឺរៀបចំឲ្យកូន ជ្រូកបានបៅដោះមេ មុនធ្វើការចាក់ថ្នាំឲ្យមេ និងរៀបចំសំបុក ដើម្បីការពារភាពត្រជាក់។
- ចាក់ថ្នាំអុកស៊ីតុកស៊ីន(Ocytocin)០,៥មីល្លីលីត្រ ធ្វើឲ្យចេញទឹកដោះភ្លាម បន្ទាប់ ពី ពីរ បី វិនាទី។
- ចាក់ថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa) ឲ្យមេជ្រូកដើម្បីទប់ទល់

ការលូតលាស់របស់មេរោគអ៊ីកូលីក្នុងកន្សោមដោះ

- ចាក់ថ្នាំដិចសាមេតាសូន Dexamethazoneប្រសិនបើកន្សោមដោះរឹងនិងក្តៅ។




៩-បញ្ហាលាសដោះ

ដោយសារមានមេរោគអ៊ីកូលី ស្តាភីឡូកុកគុស និងស្ត្រិបតូកុកគុស ចូលក្នុងកន្សោមដោះនិងបង្កជាជំងឺលាសដោះក្នុងក្រពេញដោះ។




<u>រោគសញ្ញា</u>

បញ្ហាលាសដោះមានការផ្លាស់ប្តូរសណ្ឋានពីស្រួចស្រាវ ទៅជារ៉ាំរ៉ៃ។ ប៉ុន្តែជំងឺលាសដោះដែលបង្កឡើងដោយមេរោគអ៊ីកូលីមានសភាពស្រួចស្រាវ និងខ្លាំងក្លា ដូចជា:

- គ្រុនក្តៅ
- ភ្នាសស្តើងភ្នែកឡើងក្រហម
- ក្រពេញដែលឆ្លងជំងឺ ឡើងហើម ពណ៌ក្រហម និងឈឺចាប់។




- កូនជ្រូកស្រេកដោយសារគ្មានទឹកដោះបៅពីព្រោះមេជ្រូកគ្មានទឹកដោះ ។

<u>ការព្យាបាល</u>

ត្រូវប្រើថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីមជាមួយស៊ុលហ្វា(TMP+Sulfa) ឬអាម៉ុកស៊ីស៊ីលីនបូកជាមួយកូលីស្ទីន (Amoxicillin+Colistin)។ សម្រាប់ករណីស្រួចស្រាវ មើលផ្នែកជំងឺរលាកស្បូន លាសដោះ និងអត់ទឹកដោះ(MMA)។



**ការការពារ**

- សម្អាតកន្សោមដោះ
- សម្អាតទ្រុងជ្រូកឲ្យបានត្រឹមត្រូវ
- កាត់ធ្មេញកូនជ្រូក ដើម្បីកុំឲ្យកូនជ្រូកខាំដោះ ការពារមិនឲ្យរបួស ឬធ្វើឲ្យដាច់ក្បាលដោះ។





ស្លាកស្នាមដែលបង្កឡើង ដោយធ្មេញកូនជ្រូក



មីក្រុបអាចចូលក្នុងកន្សោមដោះមុនពេលកើតកូន។ អនាម័យល្អមានសារៈសំខាន់ក្នុងអំឡុងពេលដើម

## ឈ-ជំងឺលើប្រព័ន្ធប្រសាទ

### ១- ជំងឺហើម

ជំងឺហើមអាចបណ្តាលមកពីការផ្តាច់ដោះ និងផ្លាស់ប្តូររបបចំណី។ ជំងឺហើមដែលបង្កដោយបាក់តេរីអឺកូលីហើយបង្កើតជាជាតិពុល។ ជាតិពុលបំផ្លាញសរសៃឈាមតូចៗ ជាពិសេសក្នុងខួរក្បាល និងបង្កជាជំងឺហើមដែលមានសញ្ញាសរសៃប្រសាទលេចឡើង

**រោគសញ្ញា**

- បន្ទាប់ពីផ្តាច់ដោះប្រហែល២អាទិត្យ អាចឃើញកូនជ្រូកងាប់លឿន
- កូនជ្រូកដើរដូចស្រវឹង មិនអាចទប់ខ្លួនឲ្យនឹង
- ប្រកាច់
- ហើមត្របកភ្នែក
- ឈប់ស៊ីចំណី ប៉ុន្តែសីតុណ្ហភាពធម្មតា។



ត្របកភ្នែកប៉ោងមើលទៅហាក់ដូចជ្រូកងងុយដេក



កូនជ្រូកមិនអាចដើរបាន



ហើមត្របកភ្នែក

រោគសញ្ញាសរសៃប្រសាទ

ការព្យាបាល

- បំបែកកូនជ្រូកដាក់កន្លែងស្ងាត់
- ចាក់ថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា(TMP+Sulfa) ឬ អង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine)

ការការពារ

- ផ្តល់ចំណី ជាពិសេសក្នុងពេលផ្តាច់ដោះ ដែលមានប្រូតេអ៊ីនលើស២០% ។ លាយចំណីនេះជាមួយចំណីមេជ្រូកផើម២០% ដើម្បីកាត់បន្ថយជាតិប្រូតេអ៊ីន។
- បន្ថយបរិមាណចំណីសម្រាប់កូនជ្រូកដំទៃទៀត មិនឲ្យវាស៊ីដោយសេរី ត្រូវកំណត់ចំណី៥០ក្រាមសម្រាប់១គីឡូក្រាមទម្ងន់ដងខ្លួន។
- រម្ងាប់មេរោគជាមួយសារធាតុក្លរ ដើម្បីសម្លាប់ពពួកអឺកូលី ។

២-ជំងឺស្ត្រិបតូកុកគុស

ជំងឺស្ត្រិបតូកុកគុស កើតជាទូទៅលើកូនជ្រូកផ្តាច់ដោះ ។ ពេលខ្លះឃើញកូនជ្រូកងាប់១ឬ២ក្បាល ដោយគ្មានរោគសញ្ញា។

រោគសញ្ញា

- ភ្នែកឡើងក្រហម
- ដំណើរវិលវល់
- បន្ទាប់មកជ្រូកដេកផ្អៀងទៅម្ខាងប្រកាច់ហើយ២ទៅ៣ម៉ោងក្រោយមកជ្រូកងាប់
- សីតុណ្ហភាពលើសពី៤១អង្សាសេ។










ការព្យាបាល

ការព្យាបាលអាចមានប្រសិទ្ធភាពប្រសិនបើការព្យាបាលចាប់ផ្តើមភ្លាមៗនៅដំណាក់កាលដំបូងបំផុត ពេលដែលជ្រូកមិនចង់ដើរឬពេលដែលវានៅដាច់ពីគេ។

- យកកូនជ្រូកទៅដាក់នៅកន្លែងស្ងាត់ស្ងៀម
- ដំបូងត្រូវចាក់ថ្នាំដិចសាមេតាសូន (Dexamethasone) និងចាក់ថ្នាំអាម៉ុកស៊ីស៊ីលីន(Amoxicillin)។

<u>ការការពារ</u>

- រម្ងាប់មេរោគតាមទ្រុង មុននឹងដាក់កូនជ្រូកចូល
- ក្នុងករណីមានកូនជ្រូក១ក្បាលឆ្លងជំងឺនៅក្នុងទ្រុងត្រូវលាយថ្នាំអាម៉ុកស៊ីស៊ីលីន(Amoxicillin)ក្នុងចំណីឲ្យកូនជ្រូកផ្សេងទៀតស៊ីដែរ សម្រាប់រយៈពេល៥ថ្ងៃ។

**៣-ជំងឺអូជេស្គី**

ជំងឺអូជេស្គីកើតលើកូនជ្រូកអាយុតិចក្រោមមួយអាទិត្យ។កូនជ្រូកខ្លះមានសភាពខ្វិន ជើងក្រោយ អាចអង្គុយដូចឆ្កែ។ ជ្រូកខ្លះទៀតអាចខ្វិលច្រអូស ដើរយើរយោក ឬដើរជារង្វង់និងប្រកាច់។ កូនជ្រូកខ្លះអាចងាប់ក្នុងពេលតែប៉ុន្មានម៉ោង ដោយគ្មានចេញរោគសញ្ញា។ កូនជ្រូកមានអត្រាងាប់ខ្ពស់ ពេលដែលមានសញ្ញា សរសៃប្រសាទលេចឡើង។ ជាទូទៅកូនជ្រូកងាប់ក្នុងរយៈពេលពី២៤ ទៅ៣៦ម៉ោង។

**ចំណាំ:** កូនជ្រូកអាយុក្រោយផ្តាច់ដោះ ហើយប្រកាច់មិនមែនជាសញ្ញារបស់ជំងឺអូជេស្គីទេ ដូចនេះត្រូវសង្ស័យលើជំងឺស្រ្តិបតូកុកប្រសិនបើសីតុណ្ហភាពលើសពី៤១អង្សាសេ ឬជំងឺហើម(Edema) ប្រសិនបើសីតុណ្ហភាពធម្មតា។អាចធ្វើរោគវិនិច្ឆ័យ លើឆ្កែ ឬឆ្មាដែលឈឺដោយសារស៊ីសាច់ជ្រូកឆៅ ដែលកើតជំងឺអូជេស្គី: ចំពោះឆ្កែ រោគសញ្ញារួមមាន: រមាស់អន្ទះអន្ទែងខ្លាំង ថ្គាម និងដើមកខ្វិន ស្រែកលូ និងងាប់។

- ចំពោះឆ្មាងាប់លឿន ជាទូទៅមិនមានរោគសញ្ញា។

**៤-ជំងឺតេតាណូស**

<u>មូលហេតុ</u>

ជាញឹកញាប់ជំងឺតេតាណូសកើតឡើង ដោយសារការខ្វះអនាម័យក្នុងពេលវះកាត់ ឧទាហរណ៍ គ្រៀវ កាត់ធ្មេញ ឬមានរបួសផ្សេងៗ...។

<u>រោគសញ្ញា</u>

- កូនជ្រូកងាយទទួលរងជំងឺនេះខ្លាំង
- ជើងនិងសាច់ដុំរឹង
- បះកន្ទុយ
- សាច់ដុំត្រចៀក និងមុខកន្ត្រាក់ញាក់ញ័រ។



<u>ការព្យាបាល</u>

ក្នុងដំណាក់ដំបូងត្រូវចាក់ថ្នាំប៉េនីស៊ីលីន(Penicillin) កម្រិតខ្ពស់។





# ជំពូកទី១២៖ ជំងឺសំខាន់ៗគោ ក្របី





- គេឃើញសត្វងាប់រហ័សសត្វងាប់ក្នុងកំឡុងពេលប្រហែលពីរបី ទៅ២៤ម៉ោងដោយគ្មានរោគសញ្ញាជាក់លាក់ ការព្យាបាលមិនអាចធ្វើបាន ប៉ុន្តែការធ្វើរោគវិនិច្ឆ័យឲ្យបានល្អវាមានសារៈសំខាន់ណាស់ដើម្បីការពារគោផ្សេងទៀតកុំប៉ះពាល់ជាមួយសត្វដែលងាប់។



## ក. ជំងឺឈាមខ្មៅ (អង់ត្រាក់)

បង្កដោយបាក់តេរីឈ្មោះថាបាក់ស៊ីលុស អង់ត្រាក់ស៊ីសគោឆ្លងមេរោគតាមរយៈដី ជំងឺនេះអាចចម្លងមកមនុស្សតាមការប៉ះពាល់ ដកដង្ហើម ឬតាមមាត់។

<u>រោគសញ្ញា</u>

ពីការមើលឃើញសត្វមានសភាពធម្មតាទៅជាងាប់ក្នុងពេលពីរបីម៉ោង គេឃើញសត្វងាប់ទៅហើយមានហូរឈាមពណ៌ខ្មៅ-ពីមាត់និងទ្វារធំបន្ទាប់ពីងាប់ភ្លាមដងខ្លួនគោមានសភាព ទន់យូរជាងគក្នុងករណីមិនស្វិតស្រួចស្រាវ

- ចុះខ្សោយយ៉ាងខ្លាំង និងគ្រុនក្តៅរហូតដល់ ៤១,៥អង្សាសេ
- ពិបាកដង្ហើម
- មានឈាមក្នុងទឹកនោម ទឹកដោះ លាមក
- មានចលនាមិននឹង និងប្រកាច់។

ហូរឈាមតាមទ្វារធំ



<u>ស្លាកស្នាម</u>

មិនត្រូវវះកាត់សាកសពគោដែលងាប់ទេ ព្រោះឈាមរបស់សត្វដែលងាប់នឹងសាយភាយមេរោគយ៉ាងច្រើនក្នុងដី។ មេរោគ នឹងបំលែងជាស្ពរ៍ ហើយរស់ក្នុងដីបានច្រើនឆ្នាំ។ ការផ្ទុះជំងឺភាគច្រើនកើតក្នុងកន្លែងដែលសត្វធ្លាប់ងាប់ដោយជំងឺឈាមខ្មៅពីពេលមុន។

<u>ការព្យាបាល</u>

ត្រូវព្យាបាលឲ្យលឿនជាមួយប៉េនីស៊ីលីន ប៉ុន្តែជាទូទៅពេលដែលរោគសញ្ញាត្រូវបានកំណត់វាយឺតពេលរួចទៅហើយ។

ការការពារ

- ការចាក់ថ្នាំការពារមានប្រសិទ្ធភាពណាស់ ប៉ុន្តែដើម្បីឲ្យមានភាពស៊ាំពេញលេញត្រូវការពេលពី១០ទៅ១៤ថ្ងៃ
- គោដែលប្រឈមគ្រោះថ្នាក់ (ដូចជាគោដែលស៊ីស្មៅនៅវាលដែលមានសត្វមួយបានងាប់ដោយជំងឺឈាមខ្មៅ) ត្រូវធ្វើការព្យាបាលជាបន្ទាន់ជាមួយនឹងអង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពវែងដើម្បីបញ្ឈប់ការជ្រៀតចូលរបស់មេរោគ
- ការចាក់ថ្នាំការពារពី ៧ទៅ១០ថ្ងៃ បន្ទាប់ពីការព្យាបាលដោយអង់ទីប៊ីយ៉ូទិក (ថ្នាំអង់ទីប៊ីយ៉ូទិកមិនត្រូវប្រើក្នុងពេលដំណាលគ្នានឹងធ្វើវ៉ាក់សាំងទេ។

## ខ- ជំងឺបូសខ្យល់

មូលហេតុបង្កឡើងដោយបាក់តេរី ក្លូស្ទ្រីយ៉ូមសូវី (Clostridium Chauvei)

- ជំងឺនេះមិនអាចចម្លងពីសត្វមួយទៅមួយទៀតទេ គោស៊ីស្មៅខ្លីប៉ះចំស្ពរ័ (ទម្រង់របស់បាក់តេរីដែលរស់បានច្រើនឆ្នាំ) ដែលអាចលេចឡើង ឬគោស៊ីប៉ះចំដីជាមួយស្មៅ។



ស្មៅខ្លីៗពេលចាប់ផ្តើមខែភ្លៀងនៅកន្លែងដែលមានគោក្របីងាប់ភ្លាមៗពីពេលមុនជាសញ្ញាគ្រោះថ្នាក់ខ្ពស់



រោគសញ្ញា

- ជំងឺនេះច្រើនកើតលើសត្វក្មេងអាយុពី៦ទៅ២៤ខែ ក្នុងលក្ខខណ្ឌល្អ
- សត្វងាប់យ៉ាងលឿន ពី១២ទៅ៤៨ម៉ោង ដែលជារឿយៗគ្មានរោគសញ្ញា
- ក្នុងករណីជាច្រើន សត្វត្រូវបានគេឃើញងាប់ដោយគ្មានសង្កេតឃើញមានឈឺពីមុន ករណីមិនសូវស្រួចស្រាវ។
- ខ្វកជើងធ្ងន់ធ្ងរ
- ការហើមដែលមានឮសម្លេងប្រែសៗវិវត្តក្នុងសាច់ដុំត្រគៀក ក និងស្មា
- ដំបូងការហើមមានទំហំតូច ក្តៅ និងមានការឈឺចាប់
- ដោយជំងឺនេះវិវត្តលឿន ការហើមរីកធំមានសម្លេងប្រែសៗពេលយើងស្ទាបវា
- ស្បែកចាប់ផ្តើមត្រជាក់ និងស្ពឹក


ជំងឺនេះគេហៅថាបូសខ្យល់ព្រោះសាច់ដុំក្លាយជាខ្មៅដោយមានការវាយលុករបស់មីក្រុប

**ស្លាកស្នាម**

សាច់ដុំដែលទទួលផលប៉ះពាល់ផ្លាស់ប្តូរពណ៌ពីក្រហមចាស់ទៅជាខ្មៅ និងឡើងដូចអេប៉ុងដែលផ្តល់នូវអារម្មណ៍ដែលមានសម្លេងប្រែសៗពេលដែលសង្កត់លើសាច់ដុំ។

**ការព្យាបាល** ត្រូវធ្វើឲ្យបានលឿនក្នុងដំណាក់កាលខ្វកជើងដែលមានការហើមក្តៅ និងឈឺចាប់ដោយចាក់ថ្នាំអំពីនីស៊ីលីន (Penicillin) ឬអាម៉ុកស៊ីស៊ីលីន (Amoxicillin) កម្រិតខ្ពស់

**ការការពារ**

- ការចាក់ថ្នាំការពារមានប្រសិទ្ធភាពដែលជាទូទៅកសិករប្រើវ៉ាក់សាំង "៧មុខ" ប្រឆាំងជំងឺបង្កដោយក្លូស្ទ្រីឌីយ៉ូម ដូចជាជំងឺបូសខ្យល់ តេតាណូស បូទុយលីស...
- គោដែលប្រឈមមុខនឹងគ្រោះថ្នាក់ (គោដែលស៊ីស្មៅនៅកន្លែងដែលធ្លាប់មានសត្វងាប់ដោយជំងឺបូសខ្យល់ពីមុន)។
- ត្រូវធ្វើការព្យាបាលឲបានលឿនជាមួយនឹងថ្នាំអាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពវែង (Long – acting amoxicillin) ដើម្បីបញ្ឈប់ការចម្លងសម្ងំជំងឺដែលមានសក្តានុពល។ ការចាក់ថ្នាំការពារអាចធ្វើទៅបានត្រឹមតែ៧ទៅ១០ថ្ងៃបន្ទាប់ពីការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក (ថ្នាំអង់ទីប៊ីយ៉ូទិក មិនត្រូវប្រើពេលដំណាលគ្នានឹងការធ្វើវ៉ាក់សាំងទេ)។

## គ-ជំងឺសារទឹក (HS)

- បង្កដោយបាក់តេរីប៉ាស្ទឺរ៉ែឡាមុលតូស៊ីដាប្រភេទបេ
- ក្របីងាយទទួលរងជំងឺនេះជាងគោរយៈពេលសម្ងំមេរោគខ្លីគឺសត្វចាប់ ផ្តើមឈឺនៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចម្លងតាមរយៈការប៉ះជាមួយសត្វដែលឈឺ។


ក្របីមានភាពងាយទទួលជំងឺជាគោ

**រោគសញ្ញា**

ការងាប់ចាប់ផ្តើមក្នុងពេល ៦ ទៅ ២៤ម៉ោង ចំពោះជំងឺសារទឹកវាអាចសង្កេតឃើញរោគសញ្ញាពិសេសមុនពេលងាប់៖

- វាវែកមិនចង់ដើរ
- គ្រុនក្តៅ
- ចេញទឹកមាត់ និងហៀរសំបោរ

- ពិបាកដកដង្ហើម ហូរឈាមចេញ
- ហើម ក តំបន់សាច់ទ្រូងនិងពោះ










<u>ស្លាកស្នាម</u>

ថ្គាមនិងកហើម ដែលមានជាតិ អន្ទិលពណ៌លឿងខ្ចីយ៉ាងច្រើន។

<u>ការព្យាបាល</u>

ជំងឺវិវត្តយ៉ាងលឿន និងវាមានការលំបាកក្នុងការព្យាបាលទាន់ពេលវេលា។




- ប្រើថ្នាំពួកស៊ុលហ្វូណាមិត Sulfonamide (ចាក់សសៃរវ៉ែន) ថ្នាំតេត្រាស៊ីគ្លីន (Tetracycline) ចាក់សសៃរវ៉ែន) និងថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine) ត្រូវបានណែនាំឲ្យព្យាបាល ជំងឺនេះ
- ចាក់លើកទី១ដោយប្រើកម្រិតទ្វេដង (២០មីលីក្រាម/១គីឡូក្រាម)
- វាចាំបាច់ត្រូវព្យាបាលគោដែលប៉ះពាល់ជិតដិតនឹងសត្វដែលឈឺដើម្បីបញ្ឈប់ជំងឺនេះក្នុងដំណាក់កាលសម្ងំមេរោគ

<u>ការការពារ</u>

ដោយការចាក់វ៉ាក់សាំង



- វ៉ាក់សាំងត្រូវធ្វើក្នុងចន្លោះរយៈពេល៦ខែជាពិសេសត្រូវចាក់មុនរដូវភ្លៀង
- មានការការពារបានល្អលើកូនគោដែលទទួលអង្គការពារពីមេរបស់វា។ មេគោត្រូវចាក់ថ្នាំការពារក្នុងកំឡុងខែចុងក្រោយនៃការជើម។

ការពុលអ៊ុយរ៉េ

គោត្រូវបានទាក់ទាញដោយក្លិនរបស់ជីអ៊ុយរ៉េ និងវាធ្លាប់ស៊ីបាវដែលមានសល់ថ្នាំគីមី

**រោគសញ្ញា**

- រយៈពេលពីពេលដែលស៊ីជីអ៊ុយរ៉េចូលទៅដល់ពេលចេញសញ្ញាគ្លីនិក គឺពី២០ទៅ៦០នាទី
- ការងាប់នឹងកើតមានក្នុងកំឡុងពេល២ម៉ោង

**សញ្ញាដំបូង**

- កន្ត្រាក់ត្រចៀកនិងសាច់ដុំមុខសង្កៀរធ្មេញមានហៀរទឹកមាត់បែកពពុះ
- មិនអាចរក្សាលំនឹងនិងកន្ត្រាក់សាច់ដុំនិងមានអាកប្បកិរិយាឆេវឆាវ
- ហើមពោះ
- ដកដង្ហើមលឿននឹងខ្លាំង

សញ្ញាដំបូងគឺកន្ត្រាក់សាច់ដុំមុខ និងសង្កៀរធ្មេញ



**ការព្យាបាលបន្ទាន់**

ឲ្យគោផឹកទឹកខ្មេះពី២ទៅ៥លីត្រ (ឬអាសុីតអាសេទិកកម្រិត ៥%)

## ឃ-ជំងឺអុតក្តាម FMD

បង្កដោយវីរុស ដែលថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពទេ។វីរុសជំងឺនេ មាន ៧ ប្រភេទ ហើយប្រភេទវីរុសអូ អា និងអាស៊ី១ ត្រូវបានរកឃើញលើគោក្នុងប្រទេសកម្ពុជា។

វីរុសអាចសាយភាពពីជ្រូកទៅគោ ព្រោះជ្រូកបញ្ចេញបរិមាណវីរុសយ៉ាងច្រើន ហើយគោងាយ

ទទួលជំងឺនេះតាមរយៈការចម្លងតាមខ្យល់។

**រោគសញ្ញា**

- គ្រុនក្តៅ និងមិនឃ្លានចំណី។ មិនឃ្លានចំណីដោយសារគ្រុនក្តៅ និងពងដោរបែកក្នុងមាត់
- ដែលធ្វើឲ្យវាមានការឈឺចាប់ហើយធ្វើឲ្យសត្វមិនអាចស៊ីចំណីបាន

- ពងដោរលេចលើអណ្តាត អញ្ចាញធ្មេញ ជើងធ្មេញ បបូរមាត់ (កម្រឃើញលើជ្រូក) បណ្តាលឲ្យចេញទឹកមាត់យ៉ាងច្រើន
- ស្លាកស្នាមដំបៅត្រូវបានឃើញនៅជុំវិញគល់ក្រចកជើងសត្វដែលឆ្លងជំងឺ ផ្អៀងពីជើងមួយទៅមួយទៀតដោយសារការទន់ជើង
- ពងដោរអាចលេចចេញលើក្បាលដោះ និងកន្សោមដោះ
- ការងាប់ទូទៅកើតលើកូនគោព្រោះការខូចសាច់ដុំបេះដូង




<u>ការព្យាបាល</u>


ការជាត្រលប់មកសភាពដើមវិញបន្ទាប់ពីការព្យាបាល៣អាទិត្យ

បង្កដោយវីរុស ដូចនេះវាគ្មានការព្យាបាលទេមិនត្រូវចាក់វ៉ាក់សាំងលើសត្វឈឺទេ

គោលបំណងនៃការព្យាបាលគឺបង្ការការចម្លង របស់បាក់តេរីដោយត្រូវចាក់៖

- ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa) ឬអុកស៊ីតេត្រាស៊ីគ្លីន ពី៥ទៅ៧ថ្ងៃ
- លាងដំបៅជើងជាមួយសាប៊ូ ឬសាច់ជូរ ម្ទេស ជើងបាញ់ថ្នាំសំលាប់មេរោគ ដែលមាន
- ជាតិវីយ៉ូលេហ្សង់ត្យាននិងអុកស៊ីតេត្រាស៊ីគ្លីនលើជើង បន្ទាប់ពីសម្អាតរួចសត្វមិនអាចដើរ

ស៊ីនិងផឹកបានដូច្នេះត្រូវ៖

- ឲ្យស្មៅ និងកន្ទក់ និងទឹក
- ដាក់សត្វក្នុងម្លប់ដើម្បីកាត់បន្ថយការខ្សោះជាតិទឹក

<u>ការការពារ</u>

វ៉ាក់សាំងមានប្រសិទ្ធភាព ហើយវាមានប្រយោជន៍ក្នុងការធ្វើវ៉ាក់សាំងគោពីរដងក្នុងមួយឆ្នាំ។ ចាំបាច់ត្រូវប្រើវ៉ាក់សាំងដែលមានវីរុសបីប្រភេទគឺអូ អា អាស៊ី១។

## ង. ជំងឺផ្លូវដង្ហើម



គោក្មេងៗហើយស្គមអាចងាយទទួលជំងឺ

### ១ ជំងឺរលាកសួត (Pneumonia)

សត្វពាហនៈទាំងអស់ងាយទទួលរងជំងឺផ្លូវដង្ហើម ប៉ុន្តែជាទូទៅវាចាប់ ផ្តើម ពេលដែលសត្វមានបញ្ហាស្រ្តេស។

<u>បុព្វហេតុ</u>

ស្រ្តេសជាទូទៅរួមមាន ការផ្លាស់ប្តូរសីតុណ្ហភាព ការអស់កម្លាំង ផ្តល់ចំណីនិងទឹកមិនគ្រប់គ្រាន់។ លក្ខខ័ណ្ឌស្ងួតនិងមានធូលីក៏អាចបង្កើនបញ្ហានេះផងដែរ។ មេរោគដែលជាប់ទាក់ទងនឹងជំងឺ រលាកសួតគឺប៉ាស្ទឺរ៉ែឡា។ មេរោគនេះជាធម្មតារស់នៅក្នុងផ្លូវដង្ហើមផ្នែកខាងលើ (រន្ធច្រមុះ បំពង់អាហារ និងដើមក) ប៉ុន្តែមិននៅក្នុងបំពង់ខ្យល់និងសួតទេ។

ចំពោះគោដែលមានសុខភាពល្អ ពួកប៉ាស្ទឺរ៉ែឡាបំបែកខ្លួនយឺតហើយកោសិកាមាក្រូហ្វា(Macrophage) និងអង់ទីគ័របំផ្លាញពួកវា។ ក្នុងករណី សត្វមានបញ្ហាស្រ្តេស ភាពស៊ាំនឹងចុះខ្សោយហើយ ប៉ាស្ទឺរ៉ែឡារាតត្បាតលើសួត។ លើសពីនេះប្រសិនបើផ្លូវដង្ហើមត្រូវរលាកដោយធូលីនេះមេរោគអាចវិវត្តបានយ៉ាងស្រួល។ គឺបណ្តាលឲ្យកើតជំងឺរលាកសួត។

<u>រោគសញ្ញា</u>




ពេលដែលពួកប៉ាស្ទឺរ៉ែឡាត្រូវបានគេហៅវាថាប្រភេទបេ (Type B) វាបង្ករជាជំងឺសារទឹកដែលធ្វើសត្វងាប់លឿន (មើលក្នុងផ្នែកជំងឺសារទឹក)។ ប្រភេទផ្សេងទៀតរបស់ប៉ាស្ទឺរ៉ែឡាបង្កជារលាកសួតមិនសូវស្រួចស្រាវ ប៉ុន្តែជំងឺរលាកសួតគឺគ្រប់ពេលបង្ករជាការឈឺធ្ងន់ធ្ងរដែលត្រូវធ្វើការព្យាបាលភ្លាមៗ។ ជំងឺរលាកសួតអាចទន្ទ្រានកូនគោ និងគោធំ

- សត្វបង្ហាញពីចង្វាក់ដកដង្ហើមកើនឡើង
- គ្រុនក្តៅលើសពី៤០អង្សាសេនិងបាត់បង់ការស៊ីចំណី
- ក្អក
- ហៀរសំបោរ

<u>ស្លាកស្នាម</u>

ការកើតដំបៅរលួយធ្ងន់ធ្ងរ (សួតលែងមានសភាពយឺតតទៅទៀត) សសៃឆ្មារ Fibrinous (សារធាតុខាប់ស្អិត) នៃការរលាកសួតចាប់ផ្ដើមវិវត្ត។



សួតធម្មតា



ហើមសួតធ្ងន់ធ្ងរ

<u>ការព្យាបាល</u>

ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជា តេត្រាស៊ីគ្លីន ឬ ផ្លរហ្វេនីកុល (Tetracycline, Florfenicol) ជាមួយថ្នាំប្រឆាំងនឹងការរលាកដូចជាប៉ារ៉ាសេតាម៉ុល តុលហ្វេឌីន គេតូផេន (Paracetamol, Tolfedine, Ketophen)

## ២. ព្រូនក្នុងសួត



ព្រូននេះត្រូវបានគេហៅថា ឌីទ្យោកូលុស (Dictyocaulus) ព្រូនសួតបង្ករជាជំងឺសួតលើគោដែលមានសញ្ញាគ្លីនិកដូចគ្នានឹងជំងឺបង្កដោយមីក្រុប។ ព្រូនសួតធំពេញវ័យរស់ក្នុងទងសួត ហើយ ផលិតស៊ុតជាច្រើន។

<u>រោគសញ្ញា</u>



- ក្អក
- សីតុណ្ហភាពអាចឡើងដល់៤០អង្សាសេក្នុងករណីការរំខានធ្ងន់ធ្ងរ
- ហៀរសំបោរ
- សត្វពិបាកក្នុងខ្លួន(ស្រែកថ្ងូរ)
- ជាទូទៅខ្លួនសត្វស្គមស្គាំង និងរោមបះ

ការការព្យាបាល

- ថ្នាំអាល់បង់ដាសុល (Albendazole) ១០មីលីលីត្រក្នុង១០០គីឡូក្រាម
- ថ្នាំអ៊ីវែម៉ិចទីន (Ivermectine) ១មីលីលីត្រក្នុង៥០គីឡូក្រាមក្នុងករណីធ្ងន់ធ្ងរ (សីតុណ្ហភាពខ្ពស់ និងអស់កម្លាំង) ត្រូវប្រើថ្នាំប្រឆាំងនឹងបរាសិតរួមជាមួយថ្នាំអង់ទីប៊ីយ៉ូទិក

ដូចការព្យាបាលជំងឺរលាកសួតដែរ។

## ច. ជំងឺរលាកពោះវៀន

### ១ ដង្កូវថ្លើម

វាបង្កឡើងដោយបរាសិតមួយប្រភេទគឺហ្វាស្យូឡា អេប៉ាទីកា (fasciola hepatica) ។ កូនដង្កូវត្រូវបានសត្វលេបចូលពេលស៊ីស្មៅ។ វដ្តរបស់ហ្វាស្យូឡាត្រូវការមានខ្យងមួយប្រភេទដែលហេតុដូច្នេះហើយតំបន់ដែលសើមហាក់ការចម្លងពួកហ្វាស្យូឡាច្រើន។

រោគសញ្ញា

ជំងឺដង្កូវថ្លើមអាចស្រួចស្រាវ មិនសូវស្រួចស្រាវ ឬរ៉ាំរ៉ៃដែលសញ្ញាលើមេគោគឺការខូចខាតថ្លើម ដែលមានរោគសញ្ញាប្រែប្រួលអាស្រ័យនឹងចំនួនដង្កូវមានក្នុងថ្លើម។


ពួកហ្វាស្យូឡារាំងខ្ទប់បំពង់និងបង្កឲ្យចេញឈាម

ជំងឺនេះធ្វើឲ្យចេញឈាមហើយជាលិកាខូចខាតដោយសារការបម្លាស់ទីរបស់កូនដង្កូវមិនទាន់ពេញវ័យទៅក្នុងថ្លើម និងការខូចខាតបំពង់ទឹកប្រមាត់ (ស្វះ)និងបាត់បង់ឈាមដោយសារដង្កូវពេញវ័យ។

សញ្ញារួមមាន៖

- បាត់បង់ការស៊ីចំណី
- ស្រកទម្ងន់ និងស្គមសត្វស្លេកស្លាំង (ពណ៌ភ្នាសសើម ក្លាយជាពណ៌សដែលជាធម្មតាវាមាន ពណ៌ផ្កាឈូក)
- រាគរ៉ាំរ៉ៃ
- ហើមថ្គាម
- បាត់បង់ការស៊ីចំណី



ស្គមនិងរោមស្រអាប់

## ការព្យាបាល

ត្រូវចាក់ថ្នាំដូចជា៖ ដូវេនិច(Dovenix) អាល់បង់ដាសុល (Albendazole) ពីរដងក្នុងមួយឆ្នាំ



មានសំបោរលើរាគពណ៌ខ្មៅ (មានឈាម)



ស្គមនិងរោមស្រអាប់



ស្លេកស្លាំងខ្លាំង

1. ព្រូនខាងក្នុង

ព្រូនក្នុងពោះវៀនគោឆ្លងដោយសារការលេបកូនដង្កូវ(larva) ពេលស៊ីស្មៅ។ ព្រូនពេញវ័យក្នុងរាងកាយគោផលិតស៊ុតដែលឆ្លងកាត់ទៅក្នុងលាមក។ ស៊ុតញាស់ក្នុងស្មៅដែលវិវត្តជាកូនដង្កូវហើយបម្លាស់ទីក្នុងវាលស្មៅដែលគោស៊ីចំពូកវា។



### រោគសញ្ញា

- ស្រកទម្ងន់
- ការស៊ីចំណីថយចុះ ប៉ុន្តែគ្មានគ្រុនក្តៅ
- រាគមានពណ៌បៃតង
- រោមបះ

### ការព្យាបាល

- ប្រើថ្នាំឡេវ៉ាមីសុល (Levamisole) អាល់បង់ដាសុល Albendazole...
- អ៊ីវែម៉ិចទីន ១% គឺ១មីលីលីត្រ/៥០ គីឡូក្រាមដោយចាក់ក្រោមស្បែក



រាគពណ៌ខៀវនិងមានយ៉ាងច្រើន

## ២ ជំងឺកុកស៊ីដ្យូស៊ីស Coccidiosis

វាបង្កឡើងដោយបរាសិតដែលតូចមានកោសិកាតែមួយ។ កុកស៊ីដ្យូស៊ីសកើតមានជារឿយៗលើកូនគោអាយុពី១ទៅ៦ខែ។



<u>រោគសញ្ញា</u>

- បាត់បង់ការស៊ីចំណីនិងស្រកទម្ងន់ដែលជាទូទៅធ្វើឲ្យសត្វស្គម
- រាកខ្លាំងដែលអាចមានឈាមនិងសំបោរ
- ឈឺចាប់ពេលជុះលាមក (ឈឺពោះ)ក្នុងស្ថានភាពជំងឺមិនសូវស្រួចស្រាវ (កើតជាទូទៅ)
- ខូចរោម និងលក្ខណ៍ទូទៅមិនល្អរាគប្រែជាពណ៌ខ្មៅនិងមានដូចសំបោរហើយអាចបង្កើតជាការប្រឡាក់ជុំវិញកន្ទុយ។

<u>ការព្យាបាល</u>

គឺត្រូវចាក់ថ្នាំស៊ុលហ្វា៣៣ (Sulfa33) រយៈពេល៥ថ្ងៃ។

### ៣ ជំងឺអ៊ីកូលី E.Coli



កូនគោលេបចូលបាក់តេរីពេលដែលបៅដោះឬវាអាចចូលតាមរយៈទងផ្ចិត។ រាគបង្កដោយអ៊ីកូលីកើតមានក្នុងកំឡុងថ្ងៃដំបូងបន្ទាប់ពីកើត។

<u>រោគសញ្ញា</u>

- រាគមានពណ៌លឿង ស
- កូនគោចុះខ្សោយយ៉ាងខ្លាំង ឈប់បៅ

ការចម្លងលើផ្ចិត សន្លាក់ និងការចម្លងមេរោគក្នុងឈាមទូទៅអាចកើតមានផងដែរ។

<u>ការព្យាបាល</u>

កូនគោដែលទើបកើតមកមានរាគត្រូវផ្តាច់ទឹកដោះជាបន្ទាន់ពេលដែលកូនគោបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (ភ្នែកឡើងរូង) វាចាំបាច់ត្រូវព្យួរសេរ៉ូមតាមសសៃរវ៉ែន ឬត្រូវបញ្ច្រុកតាមមាត់នូវទឹកដែលលាយជាមួយអេឡិចត្រូលីត (electrolytes) (ទឹកតែមួយមុខមិនមានប្រសិទ្ធភាពទេ)។ នៅជនបទគ្មានអេឡិចត្រូលីត ដូចនេះអាចលាយស្ករបីស្លាបព្រាធំនិងអំបិលកន្លះស្លាបព្រាធំក្នុងទឹកពីរលីត្រ។ កូនគោត្រូវផឹកទឹក១លីត្ររៀងរាល់៦ម៉ោងម្តង។ កូនគោដែលខ្សោះជាតិទឹកភាគច្រើនទទួលរងដោយសីតុណ្ហភាពដងខ្លួនចុះទាប និងត្រូវដាក់វានៅកន្លែងកក់ក្តៅជាពិសេសពេលយប់។ គួរចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជា កូលីស្ទីន ទ្រីមេតូព្រីមជាមួយស៊ុលហ្វា។

### ការការពារ

កូនគោកើតមកភ្លាមគ្មានអង់ទីគ័រប្រឆាំងនឹងជំងឺអីកូលីទេ។ ពួកវានឹងទទួលអង់ទី គ័រនេះពីទឹកដោះមេវា។ ប៉ុន្តែមានតែទឹកដោះដំបូងទេ (Colostrum) ដែលមានអង្គការពារច្រើន និងវាផលិតតែប៉ុន្មានម៉ោងបន្ទាប់ពីកើតតែប៉ុណ្ណោះ។ដូចនេះវាចាំបាច់បំផុតត្រូវឲ្យកូនគោបៅទឹកដោះដំបូងនៅកំឡុងពេល១២ម៉ោងបន្ទាប់ពី កើត។



ត្រូវឲ្យទឹកដោះដំបូង (Colostrum) បន្ទាប់ពីកើតភ្លាម

## ៤ ជំងឺសាល់ម៉ូណែឡា **Salmonellosis**

ក្នុងបរិដ្ឋានពួកសាល់ម៉ូណែឡារស់បានពី៤ទៅ៥ឆ្នាំក្នុងទឹក ដី ធូលី កន្លែងសើមដែលមិនប៉ះជាមួយពន្លឺព្រះអាទិត្យផ្ទាល់។ការធ្វើអនាមយ័ជុំវិញផ្ទះនិងក្នុងភូមិជាមធ្យោបាយសំខាន់ក្នុងការគ្រប់គ្រងពួកសាល់ម៉ូណែឡា។



កន្លែងល្អបំផុតសម្រាប់ការលូតលាស់របស់ពពួកសាល់ម៉ូណែឡា

### រោគសញ្ញា

ការចម្លងអាចមានចាប់ពីការមើលទៅសត្វដែលផ្ទុក"មានសុខភាពល្អ"រហូតបង្ហាញសញ្ញាចម្លងស្រួចស្រាវ

### គ្រុនក្តៅខ្លាំង



- ចំពោះគោធំយើងអាចឃើញរាគធូន់ធូរនិងមានក្លិនស្អុយខ្លាំងព្រមទាំងបរិមាណឈាមនិងសំបោរប្រែប្រួលក្នុងលាមក និងបំណែកទ្រនាប់ខាងក្នុងពោះវៀន។ ការរលូតអាចកើតមានចំពោះគោដែលឆ្លងជំងឺ។ ក្នុងករណីរ៉ាំរ៉ៃដែលកើតមានតាមពីក្រោយដំណាក់កាលស្រួចស្រាវធ្វើឲ្យគ្រុនក្តៅកើតឈប់ៗ រាគរាវដូចទឹកដែលធ្វើឲ្យខ្សោះទឹក និងស្រកទម្ងន់។
- ចំពោះកូនគោអាយុ២ទៅ១២អាទិត្យ ដែលជំងឺនេះច្រើនរាតត្បាលលើកូនគោដែលមិនបានបៅទឹកដោះដំបុង។ វាបង្កឲកើតជាគ្រុនក្តៅខ្លាំង រាគពណ៌លឿងច្រើនជាមួយឬគ្មានឈាម និងសំបោរហើយធ្វើឲ្យខ្សោះជាតិ ទឹកលឿន និងការងាប់អាចកើតមានក្នុងកំឡុងពេល២៤ទៅ៤៨ម៉ោង។

<u>ការព្យាបាល</u>

- ដូចការព្យាបាលជំងឺអ៊ីកូលី ការធ្វើឲ្យមានជាតិទឹកឡើងវិញត្រូវអនុវត្តជាបន្ទាន់
- ការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកមិនសូវប្រាកដប្រជាព្រោះពួកសាល់ម៉ូណែឡាវិវត្តច្រើនធន់នឹងថ្នាំអង់ទីប៊ីយ៉ូទិក
- ការព្យាបាលត្រូវធ្វើយ៉ាងតិច៦ថ្ងៃ
- ថ្នាំដូចជាទ្រីមេតូព្រីម ជាមួយស៊ុលហ្វា កូលីស្ទីនជាមួយអំពីស៊ីលីន អង់រ៉ូផ្លុកសាក់ស៊ីន អាចប្រើបានប៉ុន្តែការធន់នឹងថ្នាំងទាំងនេះកើតមានយ៉ាងលឿន។ ជាទូទៅពួកសាល់ម៉ូណែឡាធន់នឹងថ្នាំតេត្រាស៊ីគ្លីន។

## ជំងឺរាគដោយឱកាស



ពេលខ្លះរាគគឺជា<u>រោគសញ្ញា</u>តែប៉ុណ្ណោះ គោមិនបានបង្ហាញរោគសញ្ញាទូទៅ ប៉ុន្តែយើងអាចសង្កេតឃើញលាកមរាវដូចទឹក។

ជាទូទៅវាបង្កដោយកំហុសក្នុងការផ្តល់ចំណីដូចជា៖

- ការផ្លាស់ប្តូរចំណីសត្វលឿន
- នៅដើមរដូវភ្លៀងគោស៊ីស្មៅខ្ចីច្រើនបណ្តាលឲ្យរាគ
- ចំណីចាស់ រលួយ ឡើងមេ (ពោត កន្ទក់)

<u>ការព្យាបាល</u>

- ស្មៅឬចំណីថ្មីត្រូវផ្តល់ឲ្យវាបន្តិចម្តងៗ
- ដាក់គោក្រោមផ្ទះនិងផ្តល់ចំបើងដែលមានគុណភាពល្អ

## យកចំណីដែលខូចចេញ

## ជំងឺហើមពោះ

<u>រោគសញ្ញា</u>

- ជំងឺហើមពោះគឺជាប៉ោងផ្នែកខាងឆ្វេងរបស់មេគោ
- គោះពោះគោបង្ហាញថាមានឧស្ម័ន ឬពពុះពេញគោមិនអាចភើរឧស្ម័នក្នុងពោះបានទេ
- ការទំពារអៀងឈប់





ហើមប៉ោងផ្នែកខាងស្តាំ និងដោយសារការដើម

- ពោះឡើងធំដូចស្គរដែលសង្កត់លើសន្ទះទ្រូងធ្វើឲការដកដង្ហើមមានការលំបាកខ្លាំង
- សីតុណ្ហភាពធម្មតា





ការស្ទាបដើមកនិងបំពង់អាហារ

<u>បុព្វហេតុ</u>

- **ការស្ទះវត្ថុផ្សេងៗ**

ជារឿយៗវាបង្ករដោយការស្ទះក្នុងបំពង់អាហារ (ស្នូលពោត ផ្លែឈើ...) បសុពេទ្យត្រូវស្ទាប

បំពង់អាហារដោយស្បែកដើម្បីកំណត់កន្លែងស្ទះ។

<u>ការព្យាបាល</u>

បសុពេទ្យត្រូវយកចំណីដែលស្ទះចេញដោយដៃ។

ចោះពោះគោដោយប្រើត្រូការ (Trocar) ពេលដែលការហើមពោះធ្ងន់ធ្ងរដើម្បីបញ្ចេញខ្យល់។

គ្រប់ពេលត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីបង្ការជំងឺអាប់សែស្រោមពោះ។

**ស្មៅខ្ចីសើម**

- វាអាចកើតមានយ៉ាងលឿន ជាពិសេសពេលដែលសត្វស៊ីស្មៅលើវាលស្មៅដែលសើមនៅពេលព្រឹក។ គោស៊ីស្មៅខ្ចីច្រើនពេកពេលដែលរដូវភ្លៀងចាប់ផ្ដើម។ វាអាចបណ្ដាលឲ្យសត្វងាប់ភ្លាមៗ។



បន្ទាប់ពីភ្លៀងដំបូង ស្មៅខ្ចីៗចាប់ផ្ដើមជំនួសឲ្យចំបើងចាស់ៗ

<u>ការការពារ</u>

- មិនត្រូវឲ្យគោដែលឃ្លានខ្លាំងស៊ីស្មៅដែលមានគ្រោះថ្នាក់។

<u>ការព្យាបាល</u>

- ច្រកប្រេង៣០០ទៅ៥០០មីលីលីត្រតាមមាត់

**ការពុលជីអ៊ុយរ៉េ**

វាអាចកើតមានពេលដែលគោលិចជីអ៊ុយរ៉េដែលនៅសល់ក្នុងបាវ។ បុព្វហេតុទូទៅទីពីរគឺពេលដែលកសិករប្រើប្រាស់បច្ចេកទេសស្រោចជីអ៊ុយរ៉េដោយផ្ទាល់លើចំបើងដើម្បីបង្កើនគុណភាពចំណីបច្ចេកទេសនេះត្រូវការឲ្យមានកម្រិតសមរម្យ


ពេលដែលចំបើងលាយជាមួយអ៊ុយរ៉េដាក់ក្នុងអាងដើម្បីដំណើរការផ្អាប់រយៈពេល២អាទិត្យ វាគ្មានគ្រោះថ្នាក់ទេ ព្រោះអ៊ុយរ៉េត្រូវបំលែងជាអាម៉ូនីញ៉ាក់

<u>រោគសញ្ញា</u>
- ហើមពោះធ្ងន់ធ្ងរ
- ញាក់ញ័រសាច់ដុំដែលធ្វើឲសត្វមិនអាចទប់លំនឹងបាន
- ការងាប់កើតមានក្នុងពេល២ម៉ោង

<u>ការព្យាបាល</u>
ត្រូវច្រកទឹកខ្មេះ២ទៅ៥លីត្រតាមមាត់។

## ឆ. បញ្ហាស្បែក

1. បរាសិតខាងក្រៅ

1.1 រុយ

មានរុយច្រើនប្រភេទអាចរំខានគោ។ ប្រភេទខ្លះគឺ**បឺតឈាម**ដែលបង្កជាអស់ឈាមជាពិសេសលើសត្វក្មេង មានស្លាកស្លាមរបស់ស្បែក និងការរំខានជាអចិន្ត្រៃពោះការខាំមានការឈឺចាប់។ ប្រភេទខ្លះ**មិនមែនបឺតឈាម** បង្ករជាការរំខានពេលដែលពួកវាមានចំនួនច្រើន (មានរុយច្រើនជាង១០០/សត្វមួយក្បាល) ពួកវាអាចសាយភាយបាក់តេរីឬវីរុស និងពួកវាជាប្រភពធ្វើឲ្យមានភាពក្រហល់ក្រហាយពេលដែលពួកវាស៊ីចំណីលើភ្នាសសើមរបស់ភ្នែក។




ស្លាកស្នាមបង្ករដោយរុយបឺតឈាម



<u>ការគ្រប់គ្រង</u>

មានផលិតផលពីរដែលមានសម្រាប់គ្រប់គ្រងរុយលើគោគឺ៖
- ពែរមេទ្រីន Permethrin (ប៊ុយតុកButox)
- គូម៉ាផូស Coumaphos (អាស៊ុនតុល Asuntol)

1.2 មូស

មូសបឺតឈាមពីគោ។ ពួកវាសម្រក់ឈាមក្នុងទឹកហើយជាទូទៅវាមានចំនួនច្រើននៅកន្លែងងងឹត ដែលគោតែងដេកជាធម្មតា។ ពួកវាបឺតឈាមពេលថ្ងៃរសៀល និងយប់បង្ករជាការរំខានដែលសត្វមិនអាចដេកនិងពេលថ្ងៃពួកវាអស់កម្លាំងដើម្បីស៊ីស្មៅពួកវាបាត់បង់លក្ខណ្ឌដងខ្លួនល្អ។



**ការគ្រប់គ្រង**

ដុតស្លឹកឈើ និងមែកឈើតូចៗដើម្បីបង្កើតជាផ្សែងធ្វើឲ្យមូសចេញឆ្ងាយពីសត្វ។ ដាក់មុងដើម្បីការពារឲ្យកន្លែងមានសុវត្ថិភាពក្នុងពេលយប់។

### 1.3 ដង្កៃ

ពេលដែលគោត្រូវរំខានខ្លាំងក្លា ដង្កៃត្រូវបានឃើញគ្រប់កន្លែងលើដងខ្លួន។ ចំពោះសត្វដែលមានការរំខានតិចតួចពីដង្កៃគឺយើងអាចមើលឃើញវាភាគច្រើននៅកន្ទុយ ពោះ ស្មានិងត្រចៀក។

- ដង្កៃបឺតឈាមពីសត្វ និងចំនួនដង្កៃច្រើនអាចធ្វើឲបាត់បង់ឈាមនិងចុះខ្សោយពិសេសចំពោះកូនគោ
- ដង្កៃមានមាត់វែងហើយអាចបង្ករជាខូចខាតធ្ងន់ធ្ងរដល់ស្បែក
- ដង្កៃអាចចម្លងភ្នាក់ងារជំងឺដូចជាបាបេស្យា អាណាផ្លាស្មា



លាងទឹកឲ្យគោគឺជាការល្អ និងជាមធ្យោបាយមានសុវត្ថិភាពដើម្បីត្រួតពិនិត្យដង្កៃ





**ការគ្រប់គ្រង**

- ពែរមេទ្រីន Permethrin (ប៊ុយតុកButox)មានសកម្មភាពភ្លាមៗ
- គូម៉ាផូស Coumaphos (អាស៊ុនតុល Asuntol) មានសកម្មភាពភ្លាមៗ
- អ៊ីវែម៉ិចទីន Ivermectin (អ៊ីវែម៉ិច) ទទួលបានប្រសិទ្ធភាពខ្ពស់បំផុត នៅពេលពី៤ទៅ៥ថ្ងៃបន្ទាប់ពីការចាក់

### 1.4 ចៃ

អង្កែបង្ករជាការត្រដុសយ៉ាងខ្លាំងអេះខ្វាចស្បែកដែលកើតមានតាមក្រោយការបាត់បង់រោមនិងស្បែកក្រម៉ក្រាស់។ស្លាកស្នាមអាចគ្របដណ្តប់ដងខ្លួនទាំងមូល



<u>ការគ្រប់គ្រង</u>

វាមានការលំបាកព្រោះចៃចូលរូងលាក់ខ្លួន។ការចាក់ថ្នាំអ៊ីវែម៉ិចទីនគឺជាបច្ចេកទេសគ្រប់គ្រងចៃល្អបំផុត។ថ្នាំអាស៊ុនគុលអាចប្រើបានការចាក់លើកទី២ចាំបាច់ត្រូវធ្វើនៅ២ឬ៣ អាទិត្យក្រោយមកអាស្រយ័វដ្តរបស់បរាសិត។

2. ចាញ់ពន្លឺថ្ងៃ

<u>សញ្ញា</u>

- ស្បែកអាចឡើងក្រហម និងហើម
- វិវត្តជាពងស្បែកហើយដែលបែក
- បំណែករបស់ស្បែកអាចជ្រុះចេញ





<u>បុព្វហេតុ</u>

- ប្រតិកម្មថ្នាំដូចជាពពួកស៊ុលហ្វា
- ផ្សិតក្នុងស្មៅប្រាស្សារីយ៉ា(Brachiaria)
- ថ្លើមខូច(ដោយហ្វាស្សូឡា...)ដែលមិនអាចបំបាត់ជាតិពុលបាន
- ការព្យាបាល
- ដាក់សត្វនៅក្នុងម្លប់
- ដំណាក់ដំបូងត្រូវចាក់ថ្នាំដិចសាមេតាសូន
- ប្រសិនបើមានក្រម៉ច្រើនត្រូវចាក់ថ្នាំដូចជាអាម៉ុកស៊ីលីនដែលមានសកម្មភាពវែង

3. ការប្រែពណ៌

រោម និងស្បែកប្រែពណ៌ជារឿយៗជាប់ទាក់ទងនឹងសភាពរាងកាយមិនល្អ រោមប៉ះ។ មូលហេតុទូទៅគឺកង្វះវីតាមីនអា សង្ក័សី និងទង់ដែង។ មូលហេតុមួយទៀតគឺស្លាកស្នាមដែលបង្ករដោយសត្វល្អិតទិច(ខាំ)ឬការជាសះស្បែកណាមួយ។ រោមនឹងដុះឡើងវិញដែលមានពណ៌ផ្សេង។





<u>ការព្យាបាល</u>

ចាក់មួយឬពីរម្ជុលថ្នាំវីតាមីនកម្រទទួលបានជោគជ័យ

- រាល់ពពួករ៉ែ និងវីតាមីនធ្វើការរួមគ្នា ការកែរខៃការខ្វះខាតនេះមានភាពស្មុគស្មាញ
- វាត្រូវការស្រូបយកពពួករ៉ែនិងវីតាមីនដែលមានគុល្យភាពល្អ
- ជាការល្អបំផុតត្រូវឲចំណីផ្សំរយៈពេល៣ទៅ៤អាទិត្យ។



4. ដំបៅ

ដំបៅគឺជាការដាច់ស្បែក ដំបៅ ប្រសិនបើដង្កូវទន្រ្ទានលើដំបៅ ជ្រៅអាចពាក់ពន្ធ័នឹងសាច់ជុំមានតែបាញ់ថ្នាំសម្លាប់សត្វល្អិតសន្លាក់។



រាល់ដំបៅទាំងអស់ចេញឈាមនិងពីរបីនាទីក្រោយមត្រូវយកមានការឈឺចាប់ និងអាចក្លាយ ដង្កូវចេញ (វាចេញឈាម)ដោយជាចម្លងដោយមីក្រុបឬដង្កូវ ប្រើដង្កៀបហើយព្យាបាលដូចដំបៅធម្មតា



<u>ការព្យាបាល</u>

សម្អាតដំបៅជាមួយទឹកឲច្រើននិងដុសច្រាស់ថ្នមៗ ដែលនេះវា គឺជាការព្យាបាលដំបៅ៩០%។ កាត់រោមលាបអ៊ីយ៉ូឌីន (ប្រសិន បើដំបៅស្អាត) ឬ បាញ់ថ្នាំដែល មានថ្នាំ តេត្រាស៊ីគ្លីននិងថ្នាំស្វាយ (Gentiane violet)។ ប្រសិនបើដំបៅជ្រៅត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាអាម៉ុកស៊ីលីន ដែលមានសកម្មភាពវែង ឬ អុកស៊ីតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង។



5. ឬស្ស



ឬស្សបង្ករដោយវីរុសដែលហៅថាប៉ាពីឡូម៉ាវីរុស (papillomavirus)។ វីរុសនេះអាចសាយភាយទៅគោផ្សេងទៀតពេលដែលស៊ីស្មៅនៅតាមគម្លោត (វីរុសស្ថិតលើផ្ទៃកច្រើននិងលេចចេញស្លាកស្នាមលើស្បែក)។ជាធម្មតាគោមិនឈឺទេហើយគ្មានការព្យាបាលជំងឺនេះទេ។ឬស្សលើគោតែងរួញនិងជ្រុះបន្ទាប់ពី៣ទៅ៦ខែ។



## ជ. ខ្វកជើង

នៅប្រទេសកម្ពុជាគោត្រូវបានប្រើភាគច្រើនជាកម្លាំងអូសទាញដូចនេះជើងរឹងមាំគឺមានសារៈសំខាន់ដើម្បីធ្វើការក្នុងវាលស្រែ។

1. **ជំងឺស្បែកក្រចកជើង**

ជំងឺស្បែកក្រចកជើងគឺជាជំងឺស្បែករបស់គោដែលមានឥទ្ធិពលលើស្បែកផ្នែកខ្ពស់របស់កែងជើង។ ជំងឺស្បែកក្រចកជើងអាចឃើញមាននៅចន្លោះក្រចកជើងផងដែរ។



<u>រោគសញ្ញា</u>

គោដែលមានជំងឺស្បែកក្រចកជើងអាចបង្ហាញសញ្ញាខ្វកជើងពេលដែលក្រោកឈ ឬពេលដែលផ្លាស់ទី។

ការបង្ហាញជាទូទៅភាគច្រើនគឺការឈររបស់សត្វមានភ្លាត់ជើងច្រើនដងដោយគ្មានមូលហេតុ។ គោមិនសូវមានកម្លាំងពេលធ្វើការក្នុងវាលស្រែដោយពួកវាឈឺជើង។ ជំងឺនេះភាគច្រើនត្រូវបានឃើញពេលដែលគោធ្វើការក្នុងដីភក់ វាកើតមានជាទូទៅចំពោះគោដែលភ្ជួរស្រែ។

ប្រសិនបើជំងឺស្បែកក្រចកជើងត្រូវបានព្យាបាលវាអាចស្ថិតនៅជាច្រើនខែ។ ដោយការត្រាំជើង កសិករត្រូវរកជើងលដើម្បីត្រាំ និងកាន់សត្វឲ្យត្រឹមត្រូវដើម្បីត្រាំជើងឲ្យបានពីរបីនាទីក្នុងទឹកដែលមាន៖

- ហ្វរ័ម៉ាលីន(formalin) ៣%ពីរដងក្នុងមួយថ្ងៃរយៈពេលបីថ្ងៃឬ
- ទង់ដែងស៊ុលហ្វាត (Copper sulfate 5%)

ក្នុងករណីធ្ងន់ធ្ងរត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីមជាមួយស៊ុលហ្វា ឬអុកស៊ី តេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង។

<u>ការការពារ</u>

ត្រូវប្រាកដថាកម្រាលមានសភាពទន់និងស្ងួតនៅជម្រកដែលដាក់គោ

<u>រលួយស្អុយជើង</u>

រលួយស្អុយជើងគឺជាការចម្លងដំបៅរលួយ (ជាលិកាត្រូវបានចម្លងហើយបន្ទាប់មកត្រូវបានបំផ្លាញដែលមានក្លិនស្អុយ) នៃស្បែក(ចន្លោះក្រចកជើង)



<u>បុព្វហេតុ</u>

លាមកសើម និងភក់អាចធ្វើឲ្យស្បែកចន្លោះម្រាមទន់ដែលធ្វើឲ្យវាងាយមុត។ ភ្នាក់ងារចម្លងចូលតាមរយៈស្បែកដែលមានរបួសបង្ករដោយការមុតថ្ម ដែក ឈើ... ការធ្វើការរបស់គោក្នុងភក់គឺបញ្ជាក់យ៉ាងច្បាស់ពីមូលហេតុរបស់ដំបៅរលួយជើង

<u>រោគសញ្ញា</u>

- ខ្វកជើងលេចឡើងយ៉ាងលឿន ដែលជាទូទៅមានជើងម្ខាងដែលទទួលរងគ្រោះ
- គ្រុនក្តៅ
- ហើមជើង
- ដាច់ដោចក្នុងស្បែកចន្លោះក្រចក អាចមានខ្ទុះតិចៗ

<u>ការព្យាបាល</u>

- ចាក់ថ្នាំស៊ុលហ្វា៣៣តាមសសៃរវ៉ែនមានប្រសិទ្ធភាព
- ចាក់ថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វារយៈពេលបីថ្ងៃ
- ចាក់ថ្នាំតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង

2. ជំងឺស្លាក់

វាគឺជាការរលាកនៅសន្លាក់ដែលជាទូទៅរួមនឹងការចម្លងជំងឺ។

<u>បុព្វហេតុ</u>

- ដំបៅសន្លាក់ដែលជាទូទៅមានសន្លាក់តែម្ខាងទទួលរងគ្រោះការចម្លងទូទៅដ៏ទៃទៀតដែលវិវត្តក្នុងសន្លាក់ជាពិសេសលើកូនគោ ការចម្លងមកពីផ្ចិត សួតឬបំពង់រំលាយអាហារមានដូចជាពួកមីកូប្លាស្មា អ៊ីកូលី ឬសាល់ម៉ូណែឡា
- មេគោបំបៅកូនដែលកង្វះជាតិកាល់ស្យូមផូស្វរ័ សមាសធាតុមីក្រូដ៏ទៃទៀត។
- ចំពោះកូនគោវាបង្ករឲ្យក្រិនជើងមុនខូចទ្រុងទ្រាយនិងសន្លាក់កជើងធំ។



<u>រោគសញ្ញា</u>

- ខ្វកជើងស្តែងចេញ
- ឈឺចាប់ពេលស្ទាបកន្លែងសន្លាក់ដែលហើម
- ចំណង់ស៊ីចំណីតិចតួច
- គ្រុនក្តៅ

ការព្យាបាល

- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទីឡូស៊ីនTylosin ឡាំងកូមីស៊ីនLincomycin តេត្រាស៊ីគ្លីនTetracyclin រយៈពេល៥ទៅ៧ថ្ងៃ
- ថ្នាំដែលកាត់បន្ថយការឈឺចាប់ និងការរលាកដូចជាប៉ារ៉ាសេតាម៉ុលParacetamol ឌីពីរ៉ូនDypirone (អាណាល់សាំង Analgine កាល់ម៉ាស៊ីនCalmalgine)



យកចំបើងធ្វើកន្លែងដេកពេលដែលគោរាស្គម

3. ខ្ទិន

ដេកខ្ទិលច្រអូសរយៈពេលយូរ

- ខ្ទិន(ជើងមុខ)ពេលដែលគោស្គម និងខ្សោយ គោមិនក្រោកឈរច្រើនថ្ងៃ
- សសៃរមិនត្រូវបានការពារដោយសាច់ដុំនិងត្រូវបានខូចខាតពេលដែលគោដេកទៅម្ខាងលើផ្ទៃដែលរឹង

ការព្យាបាល

- ជួយគោដែលខ្សោយឲ្យក្រោកពីរដងក្នុងមួយថ្ងៃ
- ត្រូវចាក់ថ្នាំលើកកម្លាំងដូចជាការ៉ាស៊ីល (Carasil) អេម៉ាតូប៉ែន ប៉េ១២ (Hematopen B12) ត្រដុសស្នា និងភ្លៅជាមួយចំបើង

## ឈ.សភាពដងខ្លួនមិនល្អ ( DISASTROUS BODY CONDITION )

វាជាទូទៅឃើញក្នុងប្រទេសកម្ពុជានូវគោស្គមរោមប៉ះ និងរោមស្រអាប់ហើយមានសភាពអស់កម្លាំង។



វាមិនងាយស្រួលក្នុងការធ្វើឲ្យសត្វត្រឡប់មកមានសភាពដងខ្លួនស្តង់ដារវិញ មូលហេតុចម្បងគួរតែៈ

1. កង្វះ(ការចុះអន់ថយ)

កង្វះការផ្តល់ចំណី(គុណភាពនិងបរិមាណ)គឺជាមូលហេតុចម្បង។

ការចាក់ថ្នាំវីតាមីនច្រើនប្រភេទ ឬថ្នាំលើកម្លាំងមិនគ្រប់គ្រាន់ទេ។

ដាច់ខាតត្រូវផ្តល់ស្មៅដែលមានគុណភាពល្អ (ផ្តល់ប្រូតេអ៊ីន) និងឬចំណីផ្សំនៅផ្ទះ (មើលក្នុងផ្នែកការផ្តល់ចំណីគោ)
វាត្រូវការពេលវេលាប្រហែល៦អាទិត្យដើម្បីធ្វើឲ្យដងខ្លួនវិលមកសភាពល្អត្រឹមត្រូវដោយប្រើរបបចំណីដែលមានថាមពល និងប្រូតេអ៊ីនគ្រប់គ្រាន់។ មានបច្ចេកទេសបីអាចគ្រប់គ្រាន់គឺ៖



១. ផ្តល់ស្លេចស្មៅ និងស្មៅគីណៀ

២. ផ្តល់ចំណីបន្ថែមផ្សំនៅផ្ទះ





៣.រៀបចំផ្អាប់ចំបើង

2. ការបំបៅដោះ Milking

វាមិនជាកម្រទេដែលឃើញកូនគោអាយុច្រើនជាង៦ខែហើយនៅបៅដោះមេ។ មេគោមិនអាចស៊ីគ្រប់គ្រាន់ប្រសិនបើវាមិនបានទទួលចំណីបន្ថែមដើម្បីរក្សាការផលិតទឹកដោះ។ មេគោត្រូវការទាញយកចំណីបម្រុងទុកហើយវានឹងបាត់បង់សភាពរាងកាយល្អរបស់វា។ វាចាំបាច់ត្រូវផ្តាច់ដោះកូនគោមុន៦ខែ (បំបែកមេគោនឹងកូនគោ) ដើម្បីបង្ការរាងកាយដងខ្លួនធ្លាក់ចុះអន់ថយ។ មេគោដែលស្គមមិនបង្ហាញសញ្ញារកឈ្មោលទេ។



កូនគោមានអាយុច្រើនខ្លាំងនៅជាមួយមេគោដែលស្គម



គោស្គម ស៊ីស្មៅជាក្រុម និងមានជំងឺរាគ ប្រើថ្នាំអាល់បង់ដាសុល នឹងមានប្រយោជន៍

3. បរាសិតភាព Parasitism

ការរំខានខ្លាំងក្លាដោយព្រូនជះឥទ្ធិពលដល់លក្ខណ៍ដងខ្លួនប៉ុន្តែដង្កូវថ្លើមអាចបណ្តាលឲលក្ខណ្ឌ៍ដងខ្លួនមហន្តរាយខណ:ពេលដែលការស្លេកស្លាំងវិវត្ត។ វាមានសារ:សំខាន់ដើម្បីទម្លាក់ព្រូនគោពីរដងក្នុងមួយឆ្នាំ នៅដើមនិងចុងរដូវភ្លៀង ជាពិសេសចំពោះគោដែលស៊ីចំណីជាក្រុម និងស៊ីស្មៅនៅតំបន់សើម។

4. បរាសិតក្នុងឈាម



បាបេស្យា (Babesia) ទ្រីប៉ាណូសូម៉ា (Trypanosoma) និងពួកអាណាប្លាស្មា (Anaplasma) គឺមាននៅប្រទេសកម្ពុជា។ ទ្រីប៉ាណូសូម៉ាជារឿយរកឃើញលើគោប៉ុន្តែវាមិនច្បាស់ថាមានឥទ្ធិពលលើសុខភាព និងលក្ខណ្ឌដងខ្លួនមិនល្អនោះទេ។

ក្នុងករណីលក្ខណ្ឌរាងកាយទទួលមហន្តរាយរួមមានគ្រុនក្តៅនិងហូរទឹកភ្នែកកើតឈប់ៗ ត្រូវចាក់ថ្នាំបេរីនីល (Berenil) ដើម្បីគ្រប់គ្រងទ្រីប៉ាណូសូម៉ា។

## ញ.ជំងឺលើប្រដាប់បន្តពូជ

1. រលាកស្បូន / ហូរទឹកតាមយោនី



មានហូរទឹកថ្លាតាមយោនីគឺជាការ ធម្មតាក្នុងកឡុងពេលរកឈ្មោលឬពីរបីថ្ងៃបន្ទាប់ពីកើតកូន ប៉ុន្តែពេលខ្លះយើងឃើញខ្ទុះក្នុងទឹកដែលហូរដែលជាធម្មតាវាបណ្តាលមកពីការចម្លងលើស្បូន នោះគេហៅថារលាកស្បូន

<u>បុព្វហេតុ</u>

- ស្បូនធម្មតាគឺជាកន្លែងដែលល្អស្អាត
- បន្ទាប់ពីកើតកូន ស្បូនត្រូវបានឆ្លងដោយមេរោគច្រើនមកពីរន្ធយោនី ប៉ុន្តែជាធម្មតាពីរ

  បីថ្ងៃបន្ទាប់ស្បូននឹងអាចកំចាត់មេរោគទាំងនេះនិងការពារការចម្លង។
- ពេលខ្លះការចម្លងនឹងស្ថិតនៅហើយបាក់តេរីនឹងវិវត្តព្រោះស្បូនមិនអាចកំចាត់បាក់តេរី (សុកធ្លាក់មិនអស់ បញ្ហាលើផលិតកម្មអរម៉ូន...) វាផលិតជាខ្ទុះនិងបង្ករឲ្យមានការហូរខ្ទុះ។




<u>រោគសញ្ញា</u>

- ឬវត្ថុដែលមិនល្អអាចត្រូវបានឃើញក្នុងយោនី
- ក្លិនស្អុយកើតមានជាទូទៅ
- ឃ្លានចំណីតិចតួច
- ខ្ទុះ

## ការព្យាបាល

- ចាក់ថ្នាំប្រូស្តាក្លង់ឌីន ២ដងក្នុងពេលពី១១ទៅ១៤ថ្ងៃដើម្បីឲ្យហូរកំទិចកំទីចេញពីស្បូន វាបើកស្បូននិងជម្រុញការកន្ត្រាក់ វត្ថុដែលកខ្វក់នឹងរុញចេញ(ថ្នាំអុកស៊ីតុកស៊ីនមិនអាចប្រើបានទេព្រោះថ្នាំនេះមិន"បើក"ស្បូននិងអាចធ្វើឲមានការកន្ត្រាក់តែកំឡុងពេលកើតកូនទេ)
- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាតេត្រាស៊ីគ្លីន ឬទីឡូស៊ីនរយៈពេល៥ថ្ងៃ
- មិនត្រូវឲអនុសាសន៍"លាង"ស្បូនជាមួយល្បាយអ៊ីយ៉ូឌីន ឬពែម៉ងកាណាតទេ។ វាធ្វើឲក្រហាល់ក្រហាយនិងបរិមាណច្រើនរបស់វត្ថុរាវនឹងធ្វើឲប៉ះពាល់ដល់ការមូលចូលក្នុង។

## ការការពារ

មេគោដែលប្រឈមនឹងគ្រោះថ្នាក់គឺជាមេគោដែលធ្លាប់មានបញ្ហាក្នុងកំឡុងពេលកើតកូន ដែលត្រូវការលូកដើម្បីជួយវា ពេលដែលសុកមិនធ្លាក់ ពេលដែលលាសដោះកើតបន្ទាប់ពីកើតកូន។ ត្រូវចាក់ប្រូស្តាក្លងឌីននៅ២៤ម៉ោងបន្ទាប់ពីកើតកូនហើយចាក់ម្តងទៀតនៅ២អាទិត្យក្រោយមក។

## 2. មិនរកឈ្មោល

ការមិនរកឈ្មោលមានន័យថាមេគោដែលមិនផើមមិនត្រូវការគោបា វាគឺជាការធម្មតាក្នុងកំឡុងពេលដំបូងនៃដំណាក់កាលបំបៅដោះកូនគោ។

## បុព្វហេតុ

បញ្ហាទូទៅខ្លះអាចធ្វើឲមានការមិនរកឈ្មោលរយៈវែងដែលយើងអាចនិយាយថាសត្វអាះ

- លក្ខណ្ឌ័ដងខ្លួនមិនល្អ ដែលរាំងសកម្មភាពវដ្តរបស់មេគោ
- ការបៅដោះដោយកូនគោ
- មានគិសលើអូវែ


ដងខ្លួនមិនល្អគ្រប់


រយៈពេលបំបៅដោះយូរពេកធ្វើអោយវាក្ររកឈ្មោល


ដងខ្លួនមិនល្អគ្រប់

<u>ការព្យាបាល</u>

ផ្តល់ចំណីឲ្យគ្រប់គ្រាន់ និងផ្តាច់ដោះទាន់ពេលនឹងជួយសម្រួលការរកឈ្មោល ប្រសិនបើគោស្ថិតក្នុងសភាពល្អ ត្រូវព្យាបាលបាល Luteal cysts ដោយប្រើប្រូស្តាក្លង់ឌីន ៥មីលីលីត្រ នៃលុយតាលីស (Lutalyse) ដើម្បីជម្រុញការរកឈ្មោក្នុងពេលពី៣ទៅ៥ថ្ងៃ។

3. ការរកឈ្មោលឡើងវិញ

មេគោបង្ហាញវដ្តរកឈ្មោលរៀងរាល់៣អាទិត្យ ប៉ុន្តែមិនអាចផើមបន្ទាប់ពីបង្កាត់។ ការរកឈ្មោលឡើងវិញត្រូវបានកំណត់ ថាមេគោ មិនមានគតិបន្ទាប់ពីដាក់បាន ៣ដងឬលើសពីនេះ ពេលដែលវារកឈ្មោលពិតប្រាកដ។



មេគោរកឈ្មោល វានឹងត្រូវពាក់ ដោយគោបា ប៉ុន្តែ ពេលខ្លះវាត្រឡប់ រកឈ្មោលជាថ្មី នៅ៣អាទិត្យ ក្រោយមកវាជា សញ្ញានៃការរក ឈ្មោលឡើងវិញ

<u>បុព្វហេតុ</u>

- រលាកស្បូន វាគឺជាការចម្លងមិនជាក់លាក់របស់ស្បូនបង្ករដោយបាក់តេរីរាតត្បាលលើស្បូនបន្ទាប់ពីកើតកូន។ តាមពិតកូនមិនអាចវិវត្តបានត្រឹមត្រូវក្នុងស្បូនដែលឆ្លងជំងឺ។ការរលាកស្បូនពេលខ្លះមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យព្រោះគោបានបញ្ចេញខ្ទុះមកក្រៅ។
- គោបាអាចអា ដូចនេះត្រូវផ្លាស់ប្តូរបាផ្សេងពេលដាក់លើកក្រោយ។

<u>ការព្យាបាល</u>

- ចាក់ថ្នាំប្រស្តាក្លង់ឌីន(Prostaglandins) ២ដងក្នុងពេលពី១១ទៅ១៤ថ្ងៃ
- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាតេត្រាស៊ីគ្លីន ឬទីឡូស៊ីនរយៈពេល៥ថ្ងៃ

4. លាសដោះ Mastitis

លាសដោះគឺជាការរលាកក្រពេញដោះ។ ការចម្លងជំងឺនិងលទ្ធផលរបស់វាធ្វើឲថយចុះផលិតកម្មទឹកដោះយ៉ាងច្រើន

មីក្រុបអាចចូលក្នុងក្បាលដោះ



<u>បុព្វហេតុ</u>

វាបង្ករដោយបាក់តេរី។មេរោគអាចចូលតាមរយៈមុខរបួសឬតាមរយៈបំពង់របស់ក្បាលដោះ។

<u>រោគសញ្ញា</u>

- ករណីលាសដោះភាគច្រើនជាប់ពាក់ពាក់ពន្ធ័ផ្នែក១ភាគ៤(លើក្បាលដោះ១)របស់កន្សោមដោះ ដែលមានផលិតកម្មទឹកដោះជាធម្មតាលើផ្នែក៣ភាគ៤ដ៏ទៃទៀត

- ក្នុងករណីស្រួចស្រាវភាគទាំងបួនហើម ក្តៅ និងឡើងក្រហមហើយមានផលិតកម្មទឹកដោះតិចតួច។ គ្រុនក្តៅ អស់កម្លាំង និងការញាប់ញ័រកើតជាទូទៅ។ មេគោអាចញែងខ្លួនចេញឬធាក់ពេលដែលប៉ះកន្សោមដោះព្រោះផ្នែកទាំងបួនភាគមានភាពងាយទទួល។
- ក្នុងករណីមិនសូវស្រួចស្រាវនិងទម្រង់រ៉ាំរ៉ៃ គ្មានគ្រុនក្តៅ ឬសញ្ញាទូទៅ ប៉ុន្តែផលិតកម្មទឹកដោះទាប ហើយផ្នែកទាំងបួនភាគអាចល្អ។
- មេគោការពារពេលដែលកូនគោព្យាយាមបៅ កូនគោឃ្លាន និងមានស្ថានភាពមិនល្អ។



កូនគោបាត់បង់សភាពរាងកាយល្អដោយគ្មានសញ្ញាជំទែបង្ហាញ វាអាចជាសញ្ញាគ្មានទឹកដោះគ្រប់គ្រាន់



ទឹកដោះត្រូវច្របាច់ចេញឲ្យអស់ដោយដៃ

## ការព្យាបាល

ព្យាបាលត្រូវអនុវត្តតាំងពីដំបូងដើម្បីទទួលជោគជ័យ

- ត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន(Ocytocin) ៥មីលីលីត្រដើម្បីធ្វើឲកន្សោមដោះហូរ
- ទឹកដោះក្នុងផ្នែកមួយភាគបួនដែលឈឺត្រូវច្របាច់ចេញដោយដៃ (វាមានសារៈសំខាន់ក្នុងការដាក់គោក្នុងសាឡុងព្រោះវាមានការឈឺចាប់) ពីរដងក្នុងមួយថ្ងៃ។
- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីមជាមួយស៊ុលហ្វា ឬអាម៉ុកស៊ីលីនរយៈពេលបីថ្ងៃ
- ប្រសិនបើកន្សោមដោះរឹងត្រូវចាក់ថ្នាំដិចសាមេតាសូន ឬតុលហ្វេឌីនដើម្បីកាត់បន្ថយការរលាក។

ត្រួតពិនិត្យឲ្យទៀងទាត់កន្សោមដោះគឺជាការអនុវត្តដ៏ល្អ។ជំងឺដែលមានសណ្ឋានមិនសូវស្រួចស្រាវមួយភាគបួនគឺកាចសាហាវនិងមានចេញទឹកដោះតិចតួច

